## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

### ករណីសិក្សា៖ ប្រាសាទសំបូរព្រៃគុក

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២២


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឈុំ សុវណ្ណារ័ត្ន**

**សេង លីដា**

សាស្ត្រាចារ្យណែនាំ

លោក **ស៊ូ គឹមព្រឹទ្ធា**


ថ្នាក់បរិញ្ញាបត្រ ទេសចរណ៍ និងបដិសណ្ឋារកិច្ច

ជំនាន់ទី ៨

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះឈុំ សុវណ្ណរ័ត្ន និងសេង លីដា ជានិស្សិតឆ្នាំទី៤ ជំនាន់ទី៨ ផ្នែកគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំអោនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

• អ្នកមានគុណរបស់ពួកយើង ពោលគឺលោកឪពុក និងអ្នកម្តាយដែលលោកបានផ្តល់កំណើត និងលះបង់គ្រប់បែបយ៉ាង ដើម្បីចិញ្ចឹមបីបាច់ និងផ្តល់ក្តីស្រលាញ់ដ៏កក់ក្តៅបំផុតប្រកបដោយមេត្តា ករុណា និងក្តីសណ្តោសឱ្យកូនៗទាំងពីររូប ព្រមទាំងខ្នះខ្នែងតាមជួយផ្គត់ផ្គង់ ផ្តល់កម្លាំងកាយ និងចិត្ត និងដំបូន្មានល្អៗឱ្យកូនៗនៅគ្រប់កាលៈទេសៈទាំងអស់ តាំងពីតូចក្រូចឆ្មារហូតដល់ធំពេញវ័យ និងមានចំណេះដឹងដូចសព្វថ្ងៃ។

• សាស្ត្រាចារ្យ **ស៊ូ គឹមព្រឹទ្ធា** ជាសាស្ត្រាចារ្យណែនាំសារណា ដែលលោកបានចំណាយពេលវេលាយ៉ាងមានតម្លៃរបស់លោកក្នុងការណែនាំ ផ្តល់ដំបូន្មាន និងជួយកែសម្រួលនូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានក្នុងអំឡុងពេលកំពុងចងក្រងសារណានេះ។

• លោក **គៀន សុភាព** ជាប្រធានការិយាល័យផ្នែកផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ខេត្តកំពង់ធំ ដែលលោកបានទទួលរាក់ទាក់ និងចំណាយពេលវេលាដ៏មមាញឹករបស់លោកមកសំណេះសំណាលជាមួយក្រុមនិស្សិតយើង ដើម្បីឆ្លើយសំណួរ ព្រមទាំងផ្តល់ឯកសារចាំបាច់មួយចំនួនទាក់ទងនឹងស្ថានភាពខេត្តកំពង់ធំ។

• អ្នកស្រី **ជា សុភារី** ជាប្រធាននាយកដ្ឋានផែនការអភិវឌ្ឍទេសចរណ៍ជាតិសំបូរព្រៃគុក ដែលបានអនុញ្ញាតឱ្យក្រុមនិស្សិតយើងខ្ញុំចុះអង្កេត និងសម្ភាសនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

• លោកប្រធានសហគមន៍សំបូរព្រៃគុក ដែលបានស្វាគមន៍យើងយ៉ាងកក់ក្តៅបំផុត និងបានចំណាយដ៏មានតម្លៃរបស់លោកក្នុងការឆ្លើយតបនូវរាល់សំណួរដែលពួកយើងបានសួរ។

• សមាជិកនៃសហគមន៍សំបូរព្រៃគុក ដែលរួមមានឆ្មាំយាមប្រាសាទ សន្តិសុខ លោកពូ អ្នកមីង បងៗ និងទេសចរ ដែលបានចំណាយពេលមកចូលរួមក្នុងការឆ្លើយនឹងសំណួររបស់ក្រុមនិស្សិតយើងខ្ញុំ។

• លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យគ្រប់រូប ដែលបានបង្ហាត់បង្រៀន និងផ្តល់ចំណេះដឹងដល់ពួកខ្ញុំតាំងពីតូចដល់ធំ ព្រមទាំងមិត្តភក្តិទាំងឡាយ ដែលតែងតែជួយលើកទឹកចិត្តតាំងពីដើមរហូតដល់ទីបញ្ចប់។

ដូចនេះ ពួកយើងមានតែប្រាមដៃដប់ដើម្បីលើកប្រណមសូមអរគុណដល់ការលើកទឹកចិត្តល្អៗ និងការជួយជ្រោមជ្រែងរបស់អ្នកទាំងអស់គ្នា ព្រោះបើពុំដូច្នេះទេ ពួកយើងប្រាកដជាគ្មានកម្លាំងចិត្ត និងចំណេះដឹងគ្រប់គ្រាន់ដើម្បីចងក្រងកិច្ចការមួយនេះដោយជោគជ័យឡើយ។

# អារម្ភកថា

វិស័យទេសចរណ៍ត្រូវបានគេកត់សម្គាល់ថាមានវឌ្ឍនភាពយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារមានការអភិវឌ្ឍន៍នៃផ្នែកមួយចំនួន ជាពិសេសផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលធ្វើឱ្យការធ្វើដំណើរ កាន់តែមានភាពងាយស្រួល និងមានសុវត្ថិភាពជាងមុន។ ការអភិវឌ្ឍន៍ទាំងនេះបានធ្វើឱ្យមានដំណើរកម្សាន្ត ហើយជាលទ្ធផលវាបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ពលរដ្ឋក្នុងសហគមន៍និងប្រទេសជាតិទាំងមូល។ កំណើននៃទេសចរអាចជួយដល់ការរីកចម្រើននៃសេដ្ឋកិច្ច ព្រោះវាជួយបង្កើនឱកាសការងារ កាត់បន្ថយអត្រានិកម្មភាព និងភាពក្រីក្រ។ លើសពីនេះទៀត ទេសចរណ៍ក៏អាចជួយដល់សង្គមផងដែរ ដោយកំណើនភ្ញៀវទេសចរអាចជំរុញឱ្យរាជរដ្ឋាភិបាលចាប់ផ្តើមយកចិត្តទុកដាក់កាន់តែខ្លាំងលើបញ្ហាសុវត្ថិភាព បរិស្ថានអនាម័យ ព្រមទាំងសេវាសាធារណៈសម្រាប់បម្រើជូនទេសចរពេលមកដល់។

យើងពិតជាមានសេចក្តីសប្បាយរីករាយជាពន់ពេកនៅក្នុងការលើកយកប្រធានបទ "ការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ករណីសិក្សាប្រាសាទសំបូរព្រៃគុក" មកធ្វើការសិក្សាស្រាវជ្រាវដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ គោលបំណងចម្បងនៃការតាក់តែងកិច្ចការសារណានេះ គឺដើម្បីឱ្យអ្នកអានទាំងអស់បានយល់ដឹងអំពីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដែលជារមណីយដ្ឋានដ៏ចាស់ចំណាស់មួយដែលបានបន្សល់តាំងពីបុព្វបុរសជំនាន់មុននិងត្រើនរំលឹកឱ្យកូនខ្មែរទាំងអស់ចូលរួមថែរក្សា និងការពារសម្បត្តិបេតិកភណ្ឌមួយនេះឱ្យបានគង់វង្សយូរអង្វែងតកូនចៅ។ ជាងនេះទៀត ការស្រាវជ្រាវនេះបានផ្តល់មតិយោបល់មួយចំនួនដើម្បីចូលរួមជាដំណោះស្រាយក្នុងការកែលំអនូវចំណុចខ្វះខាតមួយចំនួនដែលរមណីយដ្ឋានកំពុងតែជួបប្រទះ។ លើសពីនេះទៀត យើងខ្ញុំសង្ឃឹមថាអត្ថបទសារណាមួយនេះអាចក្លាយជាឯកសារសម្រាប់និស្សិត ឬប្អូនៗជំនាន់ក្រោយដែលចាប់អារម្មណ៍នឹងប្រធានបទមួយនេះយកទៅប្រើប្រាស់ធ្វើជាឯកសារនាំផ្លូវក្នុងការពង្រីកចំណេះដឹងមូលដ្ឋាន និងបទពិសោធន៍ខ្លះៗ ដើម្បីសម្រួលដល់ការស្វែងយល់ និងសម្រាប់ជាស្ពានចំលងអ្នកអានគ្រប់រូបទៅកាន់ព័ត៌មានលម្អិត។

ទោះជាយ៉ាងណាមិញ សារណានេះមិនទាន់មានភាពល្អឥតខ្ចោះនៅឡើយទេ ព្រោះវានៅមានព័ត៌មានខ្វះខាតជាច្រើនដែលមិនអាចគ្របដណ្តប់អស់។ ទន្ទឹមនឹងនេះ វាក៏មានកំហុសអចេតនាមួយចំនួនទាក់ទងនឹងពាក្យពេជ វេយ្យាករណ៍ ឃ្លាឃ្លោង និងអក្ខរក្រមផងដែរ។ ដូចនេះហើយ យើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសឆ្គងទាំងឡាយណាដែលកើតមាននៅក្នុងការចងក្រងសៀវភៅនេះ ហើយយើងខ្ញុំរីករាយនឹងរងចាំការរិះគន់ទាំងឡាយពីសំណាក់អ្នកអាន លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ដើម្បីកែលំអរ និងស្ថាបនាកិច្ចការរបស់យើងខ្ញុំ។

ជាចុងក្រោយ ក្រុមយើងខ្ញុំសូមថ្លែងអំណរគុណរដល់ អ្នកអាន លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្ត និស្សិតទាំងអស់ដែលបានយកចិត្តទុកដាក់អានសៀវភៅដល់ចប់ហើយសូមជូនពរឱ្យជួបតែពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងចៀសផុតពីគ្រោះចង្រៃទាំងអស់ជាពិសេសគឺជម្ងឺកូវីដ១៩នេះផ្ទាល់តែម្តង។

# មាតិកា

បញ្ជីអក្សរកាត់ ....................................................................................................iv
បញ្ជីក្រាហ្វិច....................................................................................................v

## សេចក្តីផ្តើម

១. លំនាំបញ្ហា ....................................................................................................១
២. ចំណោទបញ្ហា ....................................................................................................៣
៣. គោលបំណងនៃការស្រាវជ្រាវ ....................................................................................................៣
៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ....................................................................................................៤
៥. អត្ថប្រយោជន៍នៃការស្រាវជ្រាវ ....................................................................................................៤
៦. វិធីសាស្ត្រស្រាវជ្រាវ ....................................................................................................៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....................................................................................................៦

## ជំពូកទី១

## រំលឹកទ្រឹស្តីដែលទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍

១.១. និយមន័យទេសចរណ៍.................................................................................................... ៧
១.២. ប្រភេទនៃទេសចរណ៍ ....................................................................................................៨
១.២.១. ទេសចរណ៍ជាតិ (National Tourism)....................................................................................................៨
១.២.២. ទេសចរណ៍អន្តរជាតិ (International Tourism) ....................................................................................................៩
១.២.៣. ទេសចរណ៍សង្គម (Social Tourism) ....................................................................................................៩
១.២.៤. ទេសចរណ៍ផ្ទៃក្នុង (Internal Tourism) ....................................................................................................៩
១.៣. គោលបំណងទេសចរណ៍.................................................................................................... ១០
១.៤. ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ....................................................................................................១២
១.៥. ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ....................................................................................................១៣
១.៦. ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ .................................................................................................... ១៥
១.៧. បទពិសោធន៍បរទេសទាក់ទងនឹងការអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ....................................................................................................២០

## ជំពូកទី២

## ស្ថានភាពទូទៅនៃទេសចរណ៍ខេត្តកំពង់ធំ

២.១. ស្ថានភាពទូទៅនៃខេត្តតកំពង់ធំ ........ ២៥

២.១.១. ទីតាំងភូមិសាស្ត្រ ........ ២៥

២.១.២. វិស័យអទិភាពរបស់ខេត្ត ........ ២៦

២.២. ស្ថានភាពទេសចរណ៍ខេត្តកំពង់ធំ ........ ២៨

២.២.១. សក្តានុពលទេសចរណ៍ខេត្តកំពង់ធំ ........ ២៨

២.៣. ស្ថានភាពនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ........ ៣៤

២.៣.១. ទីតាំងភូមិសាស្ត្រ ........ ៣៤

២.៣.២. ប្រវត្តិរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ........ ៣៥

២.៣.៣. ស្ថានភាពសហគមន៍ ........ ៣៦

២.៤. សក្តានុពលរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ........ ៣៧

២.៥. បញ្ហាប្រឈម ........ ៤១

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវស្តីពីការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

៣.១. លទ្ធផលនៃការសម្ភាសអំពីប្រជាសាស្ត្រ ........ ៤៣

៣.១.១. ការសម្ភាសន៍ទៅលើភេទ ........ ៤៣

៣.១.២. ការសម្ភាសន៍ទៅលើអាយុ ........ ៤៣

៣.១.៣. ការសម្ភាសន៍ទៅលើមុខរបរ ........ ៤៤

៣.១.៤. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាបរិយាកាស ........ ៤៥

៣.១.៥. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាអនាម័យ ........ ៤៥

៣.១.៦. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាផ្លូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ........ ៤៦

៣.១.៧. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព ........ ៤៦

៣.១.៨. ការសម្ភាសន៍លើស្ថានភាពប្រជាពលរដ្ឋ ........ ៤៧

៣.២. លទ្ធផលនៃការសម្ភាសន៍ជាមួយទេសចរ ........ ៤៧

៣.២.១. ការសម្ភាសន៍ទៅលើភេទ ........ ៤៧

៣.២.២. ការសម្ភាសន៍លើអាយុ ........................................................................ ៤៨
៣.២.៣. ការសម្ភាសន៍ទៅលើចំនួនដងដែលធ្លាប់មកទស្សនានៅរមណីយដ្ឋាន............................ ៤៩
៣.២.៤. ការសម្ភាសន៍នៃការស្គាល់រមណីយដ្ឋានរបស់ទេសចរ................................................ ៥០
៣.២.៥. ការសម្ភាសន៍លើគោលបំណងដែលមកទស្សនា ....................................................... ៥០
៣.២.៦. ការសម្ភាសន៍លើការយល់ឃើញលើចំនួនផុងសម្រាម ................................................ ៥១
៣.២.៧. ការសម្ភាសន៍លើការយល់ឃើញលើចំនួនបង្គន់អនាម័យ ............................................. ៥២
៣.២.៨. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់.................. ៥២
៣.២.៩. ការសម្ភាសន៍ទៅលើការយល់ឃើញលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធ.................................... ៥៣
៣.២.១០. ការសម្ភាសន៍លើការយល់ឃើញលើបញ្ហាបរិស្ថាន................................................... ៥៤
៣.៣. សំណូមពររបស់ទេសចរ....................................................................................... ៥៤
៣.៣.១. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ.................................................................................. ៥៥
៣.៣.២. ផ្នែកសេវាសាធារណៈ ..................................................................................... ៥៦
៣.៣.៣. ផ្នែកបរិស្ថានអនាម័យ .................................................................................... ៥៨
៣.៣.៤. ផ្នែកសន្តិសុខ និងសុវត្ថិភាព ........................................................................... ៦១
៣.៤. យន្តការគ្រប់គ្រងនៃខេត្តកំពង់ធំ............................................................................. ៦២
៣.៤.១. មន្ទីរទេសចរណ៍ខេត្តកំពង់ធំ............................................................................. ៦២
៣.៤.២. សហគមន៍សំបូរព្រៃគុក ................................................................................ ៦៦

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..................................................................................................... ៦៨
២. ការផ្តល់អនុសាសន៍ ................................................................................................. ៦៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

PDTRA : Petra Development & Tourism Region Authority

UNEP : United Nations Environment Programme

UNESCO : United Nations Educational, Scientific and Cultural Organization

WHO : World Health Organization

WTTC : World Travel and Tourism Council

WWF : World Wildlife Fund

# បញ្ជីក្រាហ្វិក


ក្រាហ្វិច ៣.១. អត្រានៃភេទ ........................................ ៤៣

ក្រាហ្វិច ៣.២. អត្រាអាយុ ........................................ ៤៤

ក្រាហ្វិច ៣.៣. អត្រានៃមុខរបរ ........................................ ៤៤

ក្រាហ្វិច ៣.៤. ការយល់ឃើញលើបញ្ហាបរិយាកាស ........................................ ៤៥

ក្រាហ្វិច ៣.៥. ការយល់ឃើញលើបញ្ហាអនាម័យ ........................................ ៤៥

ក្រាហ្វិច ៣.៦. ការយល់ឃើញលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ........................................ ៤៦

ក្រាហ្វិច ៣.៧. ការយល់ឃើញលើបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព ........................................ ៤៦

ក្រាហ្វិច ៣.៨. ការយល់ឃើញលើស្ថានភាពប្រជាពលរដ្ឋ ........................................ ៤៧

ក្រាហ្វិច ៣.៩. អត្រានៃភេទរបស់ទេសចរ ........................................ ៤៨

ក្រាហ្វិច ៣.១០. អត្រាអាយុរបស់ទេសចរ ........................................ ៤៨

ក្រាហ្វិច ៣.១១. អត្រាចំនួនដងដែលទេសចរធ្លាប់មកកម្សាន្ត ........................................ ៤៩

ក្រាហ្វិច ៣.១២. ការស្គាល់រមណីយដ្ឋានរបស់ទេសចរ ........................................ ៥០

ក្រាហ្វិច ៣.១៣. គោលបំណងដែលទេសចរមកទស្សនា ........................................ ៥០

ក្រាហ្វិច ៣.១៤. ការយល់ឃើញរបស់ទេសចរទៅលើចំនួនផុងសម្រាម ........................................ ៥១

ក្រាហ្វិច ៣.១៥. ការយល់ឃើញរបស់ទេសចរទៅលើចំនួនបង្គន់អនាម័យ ........................................ ៥២

ក្រាហ្វិច ៣.១៦. ការយល់ឃើញរបស់ទេសចរលើបញ្ហាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ........................................ ៥២

ក្រាហ្វិច ៣.១៧. ការយល់ឃើញរបស់ទេសចរលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ........................................ ៥៣

ក្រាហ្វិច ៣.១៨. ការយល់ឃើញរបស់ទេសចរលើបញ្ហាបរិស្ថាន ........................................ ៥៤

ក្រាហ្វិច ៣.១៩. ការយល់ឃើញរបស់ទេសចរលើផ្នែកដែលគួរអភិវឌ្ឍ ........................................ ៥៤

ក្រាហ្វិច ៣.២០. ការយល់ឃើញរបស់ទេសចរលើកន្លែងចតយានជំនិះ ........................................ ៥៧

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ការធ្វើដំណើរជាតម្រូវការចាំបាច់របស់មនុស្ស ប៉ុន្តែគ្រាន់តែគោលបំណងនៃការធ្វើដំណើរនោះអាចខុសពីគ្នាពីបុគ្គលឬក្រុមមួយ ទៅបុគ្គលឬក្រុមមួយទៀតដោយខ្លះចង់ធ្វើដំណើរដើម្បីរុករកនិងស្វែងរកគោលដៅថ្មីៗខ្លះដើម្បីរកចំណូល និងខ្លះទៀតដើម្បីទទួលបានភាពសប្បាយរីករាយនិងបទពិសោធន៍ថ្មីៗ។ ជាក់ស្តែង បើយើងក្រឡេកទៅមើលប្រភពនៃការធ្វើដំណើរកម្សាន្តវិញ យើងឃើញថាប្រភពដើមរបស់វាមាន តាំងពីសតវត្ស ១៧ នៅពេលដែលអភិជនវ័យក្មេងមកពីបណ្តាប្រទេសអឺរ៉ុបបានធ្វើដំណើរកម្សាន្តជុំវិញអឺរ៉ុបជាមួយនឹង គោលបំណងសំខាន់ៗដូចជាការស្រូបយកប្រវត្តិសាស្ត្រ សិល្បៈ និងបេតិកភណ្ឌវប្បធម៌។ វិស័យទេសចរណ៍ចាប់តាំងពីពេលមកចាប់ផ្តើមវិវត្តន៍ និងរីកចម្រើនទៅមុខមិនឈប់មិនឈរពីមួយឆ្នាំទៅមួយឆ្នាំ។ មកដល់ទសវត្សរ៍១៩៩០ វិស័យទេសចរណ៍ត្រូវបានដើរតួយ៉ាងសំខាន់ ដោយសារតែវាបានអូសទាញទេសចររាប់ពាន់លាននាក់នៅទូទាំងពិភពលោកឱ្យចាប់ផ្តើមធ្វើដំណើរកម្សាន្តទៅកាន់គោលដៅទេសចរណ៍ផ្សេងៗទាំងក្នុងប្រទេសនិងក្រៅប្រទេស។

ការរីកចម្រើននៃវិស័យទេសចរណ៍នេះបានជះឥទ្ធិពលយ៉ាងខ្លាំងមកដល់ប្រទេសកម្ពុជាដែលជាប្រទេសមួយស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ផងដែរ។ ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយដែលមានសក្តានុពលយ៉ាងខ្លាំងក្លាក្នុងវិស័យទេសចរណ៍ ដោយសារតែប្រទេសនេះសម្បូរទៅដោយធនធានធម្មជាតិជាច្រើនអណោកដូចជា៖ព្រៃស្ងួត ព្រៃ លិចទឹក ភ្នំ បឹងបួរ ទន្លេ ព្រមទាំងសមុទ្រ ដែលបានផ្តល់ជាកន្លែងស្នាក់អាស្រ័យដ៏ធំទូលំទូលាយទៅដល់សត្វគ្រប់ប្រភេទមិនថាតូចឬធំ។ លើសពីនេះទៀត កម្ពុជាក៏ជាប្រទេសមួយដែលមានវប្បធម៌ដ៏ល្អប្រពៃដែលប្រទេសភូមិផងរបងជាមួយ ក៏ដូចជាបណ្តាប្រទេសផ្សេងៗនៅជុំវិញពិភពលោកតែងស្ងោចសរសើរមិនដាច់ពីមាត់។ បើនិយាយអំពីតំបន់ទេសចរណ៍បែបវប្បធម៌ប្រវត្តិសាស្ត្រវិញ ប្រទេសដែលជាទឹកដីសុវណ្ណភូមិមួយនេះគឺជាជម្រកនៃប្រាសាទបុរាណជាង៤០០០ ឯណោះ ដែលប្រាសាទនីមួយៗមានភាពប្លែកៗពីគ្នាទាំងក្បូរក្បាច់រចនាសម្ព័ន្ធនៃការសាងសង់និងសារសំខាន់នៃប្រាសាទទាំងនោះក្នុងការឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្ររបស់ខ្មែរនាសម័យបុរាណ។ ដោយសារតែភាពអស្ចារ្យនៃសំណង់ប្រាសាទបុរាណខ្មែរបែបនេះហើយ ទើបធ្វើឱ្យអង្គការ UNESCO បានសម្រេចចិត្តកំណត់ប្រាសាទសំខាន់ៗ៣ដែលរួមមាន ប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ និងប្រាសាទសំបូរព្រៃគុកដាក់ជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ការទទួលស្គាល់មួយនេះបានទាក់ទាញទឹកចិត្តទេសចររាប់លាននាក់ឱ្យមកកម្សាន្តនៅប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ ដើម្បីបានស្គាល់ពីប្រាសាទទាំងអស់ដែលជាកេរ្តិ៍ដំណែលដ៏មានតម្លៃដែលបានបន្សល់ទុកតាំងពីយូរលង់ណាស់មកហើយ។

ដោយសង្កេតឃើញពីសន្ទុះនៃការរីកចម្រើនក្នុងវិស័យទេសចរណ៍ និងកំណើននៃទេសចរទាំងក្នុងស្រុក និងក្រៅស្រុកបែបនេះ រាជរដ្ឋាភិបាលបានសម្រេចចិត្តជ្រើសវិស័យទេសចរណ៍ជាវិស័យចម្បងមួយក្នុងចំណោមវិស័យជាច្រើនរួមមាន វិស័យសេដ្ឋកិច្ច វិស័យកសិកម្ម ព្រមទាំងវិស័យឧស្សាហកម្ម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលគ្រប់កម្រិតថ្នាក់បានប្ដេជ្ញាចិត្តយ៉ាងមុះមុតក្នុងការពង្រីកវិសាលភាពនៃសកម្មភាពទេសចរណ៍កម្ពុជា ដើម្បីឱ្យទេសចរកាន់តែច្រើនបានស្គាល់ពីសក្ដានុពលដ៏ខ្លាំងក្លារបស់ប្រទេសខ្លួន ដោយលោកបានចូលរួមនូវកិច្ចសហប្រតិបត្តិការជាមួយអង្គការទេសចរណ៍អន្តរជាតិ ក៏ដូចជាសន្និសីទអន្តរជាតិដែលធ្វើឡើងទាំងក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសដើម្បីចូលរួមផ្សព្វផ្សាយអំពីតំបន់ទាក់ទាញទាំងឡាយ។ ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បានគិតគូរពីស្ថានភាពទេសចរណ៍ពីផ្ទៃក្នុងផងដែរ ដោយលោកបានបង្កើតនូវលក្ខខណ្ឌទេសចរណ៍ និងបទប្បញ្ញត្តិជាច្រើនក្នុងគោលបំណងចង់ការពារសុវត្ថិភាពទេសចរទាំងអស់ដែលបានទៅកម្សាន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាចូលរួមអភិរក្សបេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រ និងការពារបរិស្ថានជុំវិញតំបន់ទេសចរណ៍ផ្សេងៗដូចជា៖ តំបន់ព្រៃភ្នំ តំបន់ជុំវិញបឹងទន្លេសាប និងតំបន់ភូមិភាគឥសានជាដើម។

ការរីកចម្រើននៃវិស័យទេសចរណ៍បានផ្ដល់នូវអត្ថប្រយោជន៍ជាច្រើនដល់ប្រទេសជាតិទាំងមូល។ ដូចដែលបានឃើញជាក់ស្ដែង វិស័យទេសចរណ៍ជាវិស័យមួយដែលមានសមត្ថភាពក្នុងការបង្កើនប្រាក់ចំណូលចូលក្នុងចរន្តសេដ្ឋកិច្ចជាតិ តាមរយៈការចំណាយរបស់បរទេសក្នុងការជាវផលិតផល និងសេវាកម្មក្នុងស្រុក។ បន្ថែមពីនេះទៀត វិស័យទេសចរណ៍បានបង្កើត និងបង្កើនការងារជាច្រើនអណោកដល់ប្រជាជននៅក្នុងតំបន់ផងដែរ ហើយការងារទាំងនោះមិនត្រឹមតែនៅក្នុងវិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចជាការងារនៅក្នុងវិស័យកសិកម្ម វិស័យសុខាភិបាល និងវិស័យទំនាក់ទំនងផងដែរ ដើម្បីបំពេញនូវតម្រូវការឥតព្រំដែនរបស់ទេសចរគ្រប់រូប។ ជាងនេះទៀត ទេសចរណ៍ក៏បានផ្ដល់ឱកាសដ៏ល្អសម្រាប់ជនបរទេស និងប្រជាពលរដ្ឋក្នុងស្រុកការផ្លាស់ប្ដូរវប្បធម៌ ទំនៀមទម្លាប់ និងសិល្បៈទៅវិញទៅមក ដើម្បីពង្រឹងនូវគុណតម្លៃនៃសម្បត្តិខ្មែរ និង ដើម្បីផ្សព្វផ្សាយវប្បធម៌របស់កម្ពុជាឱ្យប្រទេសនានានៅក្នុងឆាកអន្តរជាតិបានស្គាល់។

បើយើងក្រឡេកមកមើលខេត្តកំពង់ធំវិញ យើងប្រាកដជាបានឃើញហើយថាខេត្តនេះជាខេត្តមួយក្នុងចំណោមខេត្តមួយចំនួនទៀតដែលមានរមណីយដ្ឋានទាំងបែបធម្មជាតិ ព្រមទាំងវប្បធម៌ប្រវត្តិសាស្ត្រច្រើនជាងគេបង្អស់។ ដោយសារតែសក្ដានុពលទេសចរណ៍ដ៏អស្ចារ្យនេះហើយ វាបានជំរុញឱ្យរាជរដ្ឋាភិបាលចាប់ផ្ដើមអភិវឌ្ឍនៅគ្រប់ផ្នែកទាំងអស់ ដែលរួមបញ្ចូលទាំងការស្ថាបនាផ្លូវជាតិ ផ្លូវថ្នល់និងផ្លូវលំចូលទៅកាន់តំបន់ទាក់ទាញនានា ការកសាងមន្ទីរពេទ្យ សាលារៀនជាដើម ដើម្បីបង្កើនភាពងាយស្រួលដល់ប្រជាពលរដ្ឋនិងដំណើរការនៃទេសចរណ៍។ ចំណែករឿងមុខរបរ ព្រោះតែវិស័យទេសចរណ៍មានភាពរីកស្គុះស្គាស់យ៉ាងខ្លាំង ដូច្នេះហើយប្រជា

ពលរដ្ឋជាពិសេសអ្នកដែលរស់នៅជិតតំបន់ទេសចរណ៍ទទួលបានឱកាសក្នុងការរកប្រាក់ចំណូល ដើម្បីផ្គត់ផ្គង់ការចាយវាយប្រចាំថ្ងៃនៅក្នុងគ្រួសារនិងអាចបញ្ជូនកូនទៅសាលារៀនយកចំណេះទុកប្រើប្រាស់នាពេលអនាគតផងដែរ។ សម្រាប់ស្ថានភាពទូទៅវិញ គេបានឃើញថាហេដ្ឋារចនាសម្ព័ន្ធនៃខេត្តទាំងមូលមានការរីកចម្រើនគួរជាទីកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយជាហេតុវាបានទាក់ទាញវិនិយោគិនជាច្រើនរូបមកធ្វើការបោះទុនក្នុងខេត្តកំពង់ធំ។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍទេសចរណ៍ទាំងនេះនៅមានកម្រិតនៅឡើយ។ ជាក់ស្តែងតំបន់មួយចំនួនដូចជា តំបន់ទេសចរណ៍ប្រាសាទសំបូរព្រៃគុកជាដើមកំពុងប្រឈមនឹងបញ្ហាផ្សេងៗច្រើនដែលទាមទារការយកចិត្តទុកដាក់បន្ថែមពីសំណាក់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហា និងបង្កើនភាពងាយស្រួលដល់ទេសចរ។

ដោយមើលឃើញអំពីសក្តានុពលទេសចរណ៍ និងបញ្ហាទាំងអស់របស់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកបែបនេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី "ការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ករណីសិក្សាប្រាសាទសំបូរព្រៃគុក" មកធ្វើការសិក្សាស្រាវជ្រាវដើម្បីកាត់បន្ថយនិងលុបបំបាត់បញ្ហានានា ព្រមទាំងចូលរួមថែរក្សាសម្បត្តិវប្បធម៌បុរាណឱ្យបានគង់វង្ស។

## ២. ចំណោទបញ្ហា

ស្ថិតនៅក្នុងភូមិសំបូរ ឃុំសំបូរ ស្រុកសំបូរ ខេត្តកំពង់ធំ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកមានសក្តានុពលទេសចរណ៍យ៉ាងខ្លាំងក្លានៅក្នុងការទាក់ទាញភ្ញៀវទេសចរទាំងជាតិនិងអន្តរជាតិឱ្យមកទស្សនាជាច្រើនជារៀងរាល់ឆ្នាំ។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះគឺកំណើននៃទេសចរមិនត្រឹមតែនាំមកនូវគុណសម្បត្តិដល់ប្រជាជនក្នុងតំបន់ទេ តែវាក៏នាំមកនូវភាពអវិជ្ជមានមួយចំនួនដែរ។ តើបញ្ហាប្រឈមទាំងនោះមានអ្វីខ្លះ? តើគួរមានយន្តការបែបណា ដើម្បីគ្រប់គ្រងបញ្ហាទាំងឡាយដែលកំពុងកើតមាន និងបន្តការអភិវឌ្ឍរមណីយដ្ឋាននេះឱ្យកាន់តែរីកចម្រើន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវនេះគឺចង់ផ្តល់នូវទស្សនវិស័យបន្ថែម ដើម្បីចូលរួមក្នុងការស្តាបនាកែលំអរមណីយដ្ឋានបែបវប្បធម៌ប្រវត្តិសាស្ត្រមួយនេះឱ្យកាន់តែប្រសើរឡើង។ ដើម្បីសម្រេចនូវគោលបំណងនេះ កម្មវត្ថុមួយចំនួនក៏ត្រូវបានលើកយកមកសិក្សា ដែលក្នុងនោះមាន៖

- សិក្សាពីប្រជាសាស្ត្រក្នុងសហគមន៍សំបូរព្រៃគុក
- របកកំហើញអំពីការយល់ឃើញ និងសំណូមពររបស់ទេសចរ
- ស្វែងយល់ពីសក្តានុពលនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- យន្តការក្នុងការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុករបស់អាជ្ញាធរពាក់ព័ន្ធ
- ទប់ស្កាត់ផលប៉ះពាល់នានាទៅលើរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

## ៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពនៃការស្រាវជ្រាវនេះផ្ដោតសំខាន់ទៅលើរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងតំបន់មួយចំនួននៅក្នុងភូមិសំបូរ ឃុំសំបូរ ស្រុកសំបូរ ខេត្តកំពង់ធំ។ រីឯឯកសារវិញ ការស្រាវជ្រាវនេះសម្រេចចិត្តយកតែពីឆ្នាំ ២០១៧ដល់ ២០២១ តែប៉ុណ្ណោះ។ ប៉ុន្តែឯកសារមុនៗដែលនៅក្រៅដែនកំណត់នេះក៏ត្រូវបានយកមកសិក្សាផងដែរ ដើម្បីយកមកធ្វើជាឯកសារនាំផ្លូវ និងដើម្បីជួយក្នុងការវិភាគទិន្នន័យ។

## ៥. អត្ថប្រយោជន៍នៃការស្រាវជ្រាវ

- ដើម្បីបំពេញចន្លោះខ្វះខាតរបស់ការសិក្សាស្រាវជ្រាវមុនៗ
- ដើម្បីបន្សល់ជាស្នាដៃដល់សិក្សានុសិស្សផ្នែកទេសចរណ៍ទាំងអស់
- ដើម្បីស្វែងរកយុទ្ធសាស្ត្រថ្មីៗក្នុងការដោះស្រាយបញ្ហាប្រឈម
- ដើម្បីចូលរួមក្នុងការជំរុញឱ្យមានការអភិវឌ្ឍទេសចរណ៍សហគមន៍ និងស្រូបទាញនូវទេសចរឱ្យមកកម្សាន្តកាន់តែច្រើន

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឱ្យកិច្ចការស្រាវជ្រាវនេះសម្រេចបានលទ្ធផលល្អ វិធីសាស្ត្រចំនួន ២ ត្រូវបានជ្រើសរើសយកមកអនុវត្តដែលក្នុងនោះមានវិធីសាស្ត្របែបពណ៌នា និងបែបពន្យល់បកស្រាយ។ វិធីសាស្ត្របែបពណ៌នាត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់ពិពណ៌នាអំពីស្ថានភាពទេសចរណ៍នៅក្នុងខេត្តកំពង់ធំ ជាពិសេសគឺនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។ ចំណែកឯវិធីសាស្ត្របែបពន្យល់បកស្រាយវិញត្រូវបានកំណត់យកមកប្រើប្រាស់នៅក្នុងគោលបំណងចង់ស្វែងយល់បន្ថែមអំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមដែលទេសចរ ប្រជាជនក្នុងតំបន់ និងសហគមន៍ទាំងមូលបានជួបប្រទះនារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

### ៦.១. ប្រភពទិន្នន័យ

ទិន្នន័យបន្ទាប់បន្សំត្រូវបានដកស្រង់ចេញពីក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ មន្ទីរពាក់ព័ន្ធមួយចំនួននៅក្នុងខេត្តកំពង់ធំ និងបណ្ណាល័យមួយចំនួននៅក្នុងទីក្រុងភ្នំពេញ ជាពិសេសគឺបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្រៅពីនេះ ឯកសារមួយចំនួនតូចក៏ត្រូវបានទាញចេញពីប្រភពផ្សេងៗដូចជា គេហទំព័រលើបណ្ដាញអ៊ីនធឺណិត និងវចនានុក្រមរបស់ព្រះសង្ឃរាជជួនណាតជាដើម។

ទិន្នន័យបឋមត្រូវបានសំយោគចេញពីការចុះសង្កេត និងសាកសួរដោយផ្ទាល់ពីស្ថានភាព សកម្មភាព ព្រមទាំងទស្សទានរបស់ប្រជាជនក្នុងភូមិសំបូរ ស្រុកសំបូរ ខេត្តកំពង់ធំ ក៏ដូចជាការចុះសម្ភាសជាមួយលោកអភិបាលប្រធានសហគមន៍ និងមន្ត្រីពាក់ព័ន្ធនានានៅក្នុងខេត្តនោះផងដែរ។

### ៦.២. ការប្រមូលទិន្នន័យ

ទិន្នន័យបន្ទាប់បន្សំរួមមាន៖ ទ្រឹស្តី របាយការណ៍ផែនការ អត្ថបទរបស់អ្នកកាសែត និងការស្រាវជ្រាវរបស់សិស្សច្បងជំនាន់មុនៗជាដើម។

ទិន្នន័យបឋមសំដៅដល់បណ្តុំទិន្នន័យទាំងឡាយដែលបានដកស្រង់ដោយផ្ទាល់ចេញពីការចុះសង្កេត និងការសម្ភាស ដើម្បីទទួលបានព័ត៌មានបន្ថែមទាក់ទងទៅនឹងស្ថានភាពទូទៅនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។ មុននឹងទទួលបានព័ត៌មានទាំងនោះ យើងត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួនដូចខាងក្រោម៖

- **ការកំណត់គំរូតាង**៖ការប្រមូលទិន្នន័យបឋមត្រូវបានធ្វើឡើងតាមរយៈការសម្ភាសន៍ដោយផ្ទាល់ជាមួយនឹងបុគ្គលសំខាន់ៗចំនួន៣៨។ បុគ្គលទាំងនេះត្រូវបានបែងចែកជា ៣ ក្រុម ដែលរួមមានប្រជាពលរដ្ឋទូទៅក្នុងសហគមន៍ចំនួន១០នាក់ ទាំងបុរសនិងស្ត្រីដែលមានអាយុចាប់ពី១៨ដល់៦១ឆ្នាំឡើងដោយមិនគិតពីកម្រិតជីវភាពនិងចំណេះដឹង ទេសចរជាតិដែលមកទស្សនានៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដែលមានអាយុចាប់ពី១៨ដល់៦១ឆ្នាំឡើងចំនួន២៥នាក់ និងអាជ្ញាធរពាក់ព័ន្ធចំនួន៣រូប។
- **ការសម្ភាសន៍**៖ការសម្ភាសន៍នីមួយៗត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គល ដែលយើងនឹងធ្វើការសាកសួរម្នាក់ម្តងៗតាមលំនៅស្ថានរបស់ប្រជាពលរដ្ឋនីមួយៗ ឬចុះសំណេះសំណាលជាមួយអាជ្ញាធរ និងមន្ត្រីនៃខេត្តកំពង់ធំ ឬសម្ភាសទេសចរដែលបានមកកម្សាន្តនៅប្រាសាទសំបូរព្រៃគុក។
- **ការចុះសង្កេត**៖ការចុះសង្កេតត្រូវបានធ្វើឡើងក្នុងគោលបំណងពិនិត្យមើលធនធានទេសចរណ៍ ទាំងបែបវប្បធម៌និងបែបធម្មជាតិ និងស្វែងយល់បន្ថែមពីអត្ថប្រយោជន៍ ព្រមទាំងផលវិបត្តិនៃទេសចរណ៍ទៅលើប្រជាពលរដ្ឋក្នុងភូមិសំបូរ ឃុំសំបូរ ស្រុកសំបូរ ខេត្តកំពង់ធំ។ លើសពីនេះទៀត ការចុះសង្កេតត្រូវបានធ្វើឡើងដើម្បីចុះអង្កេតមើលពីចំណុចដែលគួរកែលំអបន្ថែម ដើម្បីអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកឱ្យក្លាយជាគោលដៅទាក់ទាញដ៏មានសក្តានុពលមួយ។

### ៦.៣. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យត្រូវបានធ្វើឡើងដោយយកចម្លើយទាំងអស់ដែលប្រមូលបានពីគំរូតាងទាំង ៣៨ នាក់ទៅដាក់បញ្ចូលក្នុងកម្មវិធីកំព្យូទ័រ Microsoft Excel។ បន្ទាប់មក យើងនឹងគណនាចម្លើយទាំងនោះទៅជាភាគរយ ហើយបង្កើតជាក្រាបផ្ចិត (pie chart) និងក្រាបសសរ (table chart) ដើម្បីឱ្យមានភាពងាយស្រួលក្នុងការ

បកស្រាយ និងពណ៌នាពីទិន្នន័យដែលបានរកឃើញ។ ដូចនេះ ដើម្បីឱ្យការចុះសង្កេត និងការគណនាចំនួនគំរូតាងកាន់តែមានប្រសិទ្ធភាពនិងអាចយកទៅប្រើការបាន ការវិភាគទិន្នន័យគឺត្រូវតែអនុវត្តទាំងតាមបែបបរិមាណវិស័យ និងគុណវិស័យ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានបែងចែកជា៥ផ្នែកធំៗដូចខាងក្រោម៖

ផ្នែកទី១: សេចក្ដីផ្ដើម ដែលផ្ដោតលើចំណុចចំនួន៧ រួមមានដូចជា៖ ប្រវត្តិបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ អត្ថប្រយោជន៍នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះតែម្ដង។

ផ្នែកទី២: ខ្លឹមសារ: បង្ហាញពីខ្លឹមសារនៃសារណា ដែលក្នុងនោះមាន៣ជំពូកធំៗដូចខាងក្រោម៖

ជំពូក១: ផ្ដោតលើការរំលឹកទ្រឹស្ដីនៃការគ្រប់គ្រង និងអភិវឌ្ឍដែលទាក់ទងនឹងប្រធានបទ

ជំពូក២: ស្ថានភាពទូទៅនៃទេសចរណ៍ខេត្តកំពង់ធំ

ជំពូក៣: លទ្ធផលនៃការស្រាវជ្រាវ និងទស្សនៈទានក្នុងការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទ សំបូរព្រៃគុក។

ផ្នែកទី៣: សេចក្ដីសន្និដ្ឋាន និងអនុសាសន៍: ជាការសរុបសេចក្ដីអំពីសារណា និងផ្ដល់អនុសាសន៍ជាយោបល់ ពីអ្វីដែលបានបកស្រាយ និងរកឃើញ ដើម្បីចូលរួមក្នុងការកែលំអនិងអភិវឌ្ឍបន្ថែម។

ផ្នែកទី៤:ឯកសារយោង: ជាផ្នែកមួយដែលមានផ្ទុកនូវរាល់ប្រភពឯកសារពាក់ព័ន្ធទាំងឡាយណាដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងកិច្ចការស្រាវជ្រាវនេះ។

ផ្នែកទី៥: ឧបសម្ព័ន្ធ: សម្ដៅដល់ភស្ដុតាងជាលិខិតរដ្ឋបាលពាក់ព័ន្ធ ឯកសារស្រាវជ្រាវ កម្រងសំណួរ និងកម្រងរូបភាពដែលទាក់ទងនឹងស្ថានភាពនៃទីតាំងរបស់ប្រធានបទ។

# ជំពូកទី ១
# រំលឹកទ្រឹស្តីដែលទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍

## ១.១. និយមន័យទេសចរណ៍

វិស័យទេសចរណ៍គឺជាការធ្វើដំណើរកំសាន្តរបស់អ្នកដែលមិនមែនជាម្ចាស់ស្រុកក្នុងរយៈពេលខ្លី និងជាបណ្តោះអាសន្ន ដែលធ្វើដំណើរទៅប្រទេសគោលដៅហើយត្រឡប់មកវិញ។ វិស័យទេសចរណ៍រួមមាន ការស្នាក់នៅ អាហារភេសជ្ជះ ភាពទាក់ទាញ ការដឹកជញ្ជូន ព័ត៌មាន និងសេវាកម្មផ្សេងៗទៀត។ សម្បទា និងសេវាកម្មទាំងនេះបំរើឲ្យផ្សេងៗដែលក្រៅពីទេសចរណ៍។ ភាពខុសគ្នារវាងភ្ញៀវទេសចរ និងទេសចរណ៍គឺភ្ញៀវទេសចរសំដៅដល់ បុគ្គលទាំងឡាយណាដែលធ្វើដំណើរចាកចេញពីលំនៅអចិន្ត្រៃយ៍ រួចហើយឆ្ពោះទៅលើទៅកាន់កន្លែងណាមួយដោយស្នាក់នៅទីនោះលើសពីរយៈពេល២៤ម៉ោង ដោយគិតលើរយៈពេលដែលភ្ញៀវស្នាក់នៅពីពេលដែលគេចូលមកក្នុងប្រទេស រហូតដល់ពេលដែលគេចាកចេញទៅវិញ[1]។ រីឯទេសចរណ៍គឺជាឧស្សាហកម្ម និងពាណិជ្ជកម្មទាំងមូល។ បច្ចុប្បន្នមានប្រទេសជាច្រើននៅលើពិភពលោកបានចាប់ទុកវិស័យទេសចរណ៍ គឺជាកម្លាំងចលករដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច បង្កើនឱកាសការងារ បង្កើនប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅជំរុញកំណើនផលិតផលក្នុងស្រុក រក្សាលំនឹងពាណិជ្ជកម្ម និងជួយកាត់បន្ថយភាពក្រីក្រ ជាពិសេសវិស័យនេះក៏បាននាំមកនូវកិត្យានុភាពប្រទេសជាតិ ជួយថែរក្សាមរតកវប្បធម៌ ប្រពៃណីវប្បធម៌សង្គម និងបូរណៈភាពទឹកដី ព្រមទាំងជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម[2]។ ពីមួយឆ្នាំទៅមួយឆ្នាំ វិស័យទេសចរណ៍បាននាំយកមកនូវចំណូលរូបិយប័ណ្ណអន្តរជាតិរាប់ពាន់លានដុល្លារសហរដ្ឋអាមេរិចចូលទៅក្នុងចរន្តសេដ្ឋកិច្ចរបស់ប្រទេស ដែលក្នុងនោះក៏មានរួមទាំងកម្ពុជាផងដែរ។ វឌ្ឍភាពសេដ្ឋកិច្ចនៃឧស្សាហកម្មទេសចរណ៍ពេលបច្ចុប្បន្នបានចូលរួមបង្កើតឱកាស ការងារដល់ប្រជាពលរដ្ឋស្មើនឹង១១%នៃការងារសរុប និងអាចដោះស្រាយវិបត្តិសេដ្ឋកិច្ចសង្គមបានយ៉ាងមានប្រសិទ្ធភាព។ ជាក់ស្តែងក្នុងឆ្នាំ២០០៨ ទោះជាពិភពលោកមានវិបត្តិយ៉ាងណាក៏ដោយក៏វិស័យនេះត្រូវបានគេមើលឃើញថានៅរក្សាប្រភពចំណូលរូបិយបណ្ណបរទេសមួយ នៅក្នុងចំណោមប្រភេទរូបិយប័ណ្ណបរទេសធំៗទាំងប្រាំរបស់ប្រទេសកំពុងអភិវឌ្ឍន៍គឺប្រមាណជាង៨៣% និងបានផ្តល់ឱកាសការងារប្រមាណជា២៣០លាននាក់ ឬស្មើនឹងចំនួន១១%នៃកម្លាំងការងារសរុប[3]។

[1] សួន វ៉ានី ទ្រឹស្តី និងទស្សនៈមូលដ្ឋាន ២០០៦

[2] ផែនការអភិវឌ្ឍន៍ទេសចរណ៍របស់ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ២០១៧

[3] របាយការណ៍របស់អង្គការទេសចរណ៍ពិភពលោក

ពាក្យថា "ទេសចរណ៍" មានន័យទូលំទូលាយណាស់ ហើយនិយមន័យរបស់វាត្រូវបានគេជួបប្រទះនៅក្នុងលក្ខណៈផ្សេងៗពីគ្នាជាច្រើនទៅតាមប្រភេទអ្នកនិពន្ធ និងប្រភេទឯកសារ។ ពាក្យ "ទេសចរណ៍" កើតចេញពីពាក្យនៃភាសាអង់គ្លេសហៅថា "Tourism" មានន័យថាការដើរកម្សាន្តចេញពីកន្លែងណាមួយ (ចំនុចចាប់ផ្តើម) តាមមធ្យោបាយផ្សេងៗដូចជាធ្វើដំណើរដោយថ្មើរជើង ជិះរទេះ ជិះសត្វពាហនៈ ឬដោយមធ្យោបាយយានជំនិះណាមួយក្រោយអំពីបានបញ្ចប់ការងារ ឬសកម្មភាពរបស់ពួកគេ។

នៅក្នុងច្បាប់ស្តីពីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់និយមន័យឱ្យពាក្យ "ទេសចរណ៍" ថាជាសកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរ និងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេសម្រាប់រយៈពេលកំណត់ណាមួយដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នាដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របតាមច្បាប់ផ្សេងទៀត[4]។

នៅក្នុងច្បាប់ទេសចរណ៍របស់សាធារណៈរដ្ឋបារាំង និយមន័យរបស់ទេសចរណ៍ត្រូវគេបានកំណត់ថាជាការធ្វើដំណើរក្នុងរយៈពេលមួយរបស់ពលរដ្ឋ ឬមហាជនពីទីស្នាក់នៅជាអចិន្ត្រៃយ៍របស់ខ្លួនទៅកាន់ប្រទេសណាមួយ ឬតំបន់ណាមួយក្នុងប្រទេសក្នុងពេលទំនេរក្រៅពីការងារនៅក្នុងគោលបំណងទទួលយកការសប្បាយរីករាយ សំរាក ព្យាបាល ទស្សនកិច្ចស្វែងយល់ សាសនា និងការងារអាជីវកម្ម តែមិនបានត្រូវអនុញ្ញាតឱ្យបំពេញការងារដែល ទទួលបាននូវទឹកប្រាក់ក្នុងតំបន់ដែលបានទៅដល់។

រីឯក្នុងច្បាប់ទេសចរណ៍របស់សហព័ន្ធរុស្សីវិញ ទេសចរណ៍គឺជាការធ្វើដំណើរក្នុងរយៈពេលមួយរបស់ជនជាតិរុស្សីជនជាតិបរទេសដែលគ្មានសញ្ជាតិពីតំបន់របស់ខ្លួនរស់នៅក្នុងគោលដៅព្យាបាល ថែរក្សា ទស្សនកិច្ចស្វែងយល់ដឹង អាជីវកម្ម កីឡា សាសនា និងគោលបំណងផ្សេងៗក្រៅពីការស្វែងរកការងារដែលទទួលបានទឹកប្រាក់ក្នុងប្រទេស ឬតំបន់ដែលខ្លួនទៅដល់ក្នុងរយៈពេលដំណើរនេះ[5]។

## ១.២. ប្រភេទនៃទេសចរណ៍

ចំពោះទេសចរណ៍គិតតាមទ្រង់ទ្រាយ យោងតាមសេវាកម្មដែលត្រូវបានបញ្ចូលជាសមាសធាតុរួមគ្នា និងទីកន្លែងដែលត្រូវផ្តល់សេវាកម្មដល់អ្នកទេសចរត្រូវបានបែងចែកជា ៤ ប្រភេទសំខាន់ៗគឺ[6]:

### ១.២.១. ទេសចរណ៍ជាតិ (National Tourism)

ទេសចរណ៍ជាតិត្រូវបានបែងចែកជាពីរ គឺ:

---

[4] ច្បាប់ស្តីពីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[5] ច្បាប់ទេសចរសហព័ន្ធរុស្ស៊ី សួន វ៉ានី "សញ្ញាណ និងទ្រឹស្តីទេសចរណ៍", (ភ្នំពេញ៖ ២០១២), ៣២

[6] បណ្ឌិត ឈុន ពហុ អនុបណ្ឌិត ជា ស៊ីថា ហុង វណ្ណៈ និង សាំង ចន្ទ "សេចក្តីផ្តើមទេសចរណ៍", (ភ្នំពេញ៖ ២០១៤)

- **ទេសចរណ៍ក្នុងស្រុក (Domestic Tourism)**៖ ទេសចរណ៍ក្នុងស្រុកគឺជាសកម្មភាពទេសចរណ៍ដែលភ្ជាប់ជាមួយនឹងការធ្វើដំណើរជាទេសចរណ៍ និងធ្វើសកម្មភាពទេសចរណ៍របស់ប្រជាពលរដ្ឋនៅលើទឹកនៃប្រទេសកំណើត (ប្រទេសដែលគេរស់នៅជាអចិន្ត្រៃយ៍)។
- **ទេសចរណ៍ក្រៅប្រទេស (Outbound Tourism)**៖ ទេសចរណ៍ក្រៅប្រទេសជាសកម្មភាពទេសចរណ៍របស់ទេសចរដែលបានចាកចេញទៅក្រៅប្រទេសកំណើតរបស់ខ្លួនក្នុងគោលបំណងទេសចរណ៍។

**១.២.២. ទេសចរណ៍អន្តរជាតិ** ( International Tourism )

ទេសចរណ៍អន្តរជាតិ គឺជាសកម្មភាពដែលបានចង់ភ្ជាប់ជាមួយនឹងការធ្វើដំណើរជាទេសចរណ៍របស់ប្រជាពលរដ្ឋប្រទេសមួយទៅប្រទេសមួយទៀត។ អ្នកទេសចរទាំងនេះត្រូវបានគេចាត់ទុកថាជាទេសចរណ៍អន្តរជាតិ។ ឆ្លងតាមរយៈ ដំណើរនេះ ទេសចរណ៍អន្តរជាតិត្រូវបានបែងចែកជាពីរគឺៈ

- **ទេសចរណ៍បរទេស (Inbound Tourism)**៖ ទេសចរណ៍បរទេសគឺជាការធ្វើដំណើរទេសចរណ៍ និងធ្វើសកម្មភាពទេសចរណ៍របស់ទេសចរ នៅប្រទេសណាមួយក្នុងលក្ខណៈជាការមកដល់។
- **ទេសចរណ៍ក្រៅប្រទេស (Outbound Tourism)**៖ ទេសចរណ៍ក្រៅប្រទេស គឺជាការធ្វើដំណើរទេសចរណ៍ និងធ្វើសកម្មភាពទេសចរណ៍របស់ទេសចរនៅបរទេស ឬប្រទេសណាមួយក្នុងលក្ខណៈជាការដើរចេញទៅក្រៅប្រទេស។

**១.២.៣. ទេសចរណ៍សង្គម** ( Social Tourism )

ទេសចរណ៍សង្គមជាប្រភេទមួយនៃទេសចរណ៍ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលសម្រាប់បង្កជាលទ្ធភាពដល់ស្រទាប់មហាជនដូចជា សិស្ស និស្សិត យុវវ័យ អ្នកចូលនិវត្តន៍ ជនពិការ និងពលរដ្ឋប្រទេសនេះធ្វើដំណើរកម្សាន្តលំហែជាទេសចរណ៍ក្នុងរដូវទេសចរណ៍តិច (Low Season)។ កម្មវត្ថុសំខាន់ៗនៃទេសចរណ៍សង្គម គឺសេវាកម្មដែលបំរើអោយទេសចរណ៍សង្គមរួមមាន សេវាកម្មដឹកជញ្ជូន ស្នាក់នៅ ចំណីអាហារ សម្រាក លំហែ មជ្ឈមណ្ឌលរក្សាសុខភាពព្យាបាលដែលចរិតលក្ខណៈជាសេវាកម្មទេសចរណ៍មជ្ឈមណ្ឌលសម្រាប់ផ្តល់ការទស្សនាប្រាង្គប្រាសាទ សម្បត្តិវប្បធម៌ អរិយធម៌ និងធាតុផ្សេងៗនៃទេសចរណ៍ដែលបំរើឱ្យនូវសេចក្តីត្រូវការក្នុងប្រព័ន្ធទេសចរណ៍ ប្រភេទនេះ។

**១.២.៤. ទេសចរណ៍ផ្ទៃក្នុង** ( Internal Tourism )

ទេសចរណ៍ផ្ទៃក្នុងជាចង្កោមនៃសកម្មភាពការងារមាននៅផ្ទៃខាងក្នុងនៃតំបន់មួយ ទីកន្លែងមួយ ឬក៏ប្រទេសមួយ។ សកម្មភាពទេសចរណ៍បែបនេះជាទូទៅជាសកម្មភាពដែលបំរើអោយទេសចរណ៍ក្នុងស្រុក និង

ទេសចរណ៍បរទេស។ បើតាមរយៈអង្គការទេសចរណ៍ពិភពលោករបស់អង្គការសហប្រជាជាតិ (UNWTO) បានចែកប្រភេទទេសចរណ៍ជាពីរគឺ:

- **ទេសចរណ៍ក្នុងស្រុក៖** ទេសចរណ៍ក្នុងស្រុកជាប់ទាក់ទងនឹងការធ្វើដំណើរកំសាន្តរបស់ប្រជាជនម្ចាស់ស្រុកនៅក្នុងប្រទេសរបស់ពួកគេ។
- **ទេសចរណ៍អន្តរជាតិ៖** ទេសចរណ៍អន្តរជាតិជាប់ទាក់ទងនឹងការធ្វើដំណើររវាងពីរប្រទេស។

## ១.៣. គោលបំណងទេសចរណ៍

ចំពោះទេសចរណ៍តាមគោលបំណង នៅក្នុងស្ថានភាពនៃតម្រូវការក្នុងការធ្វើដំណើរកំសាន្តជាទេសចរការបែងចែកដូចខាងក្រោមត្រូវបានធ្វើឡើងក្នុងបំណងធ្វើឱ្យមានភាពងាយស្រួលទៅដល់ការរៀបចំ និងផ្គត់ផ្គង់ផលិតផលទេសចរណ៍ឱ្យត្រូវតាមតម្រូវការរបស់ទេសចរ។ ការបែងចែកទាំងនោះមានដូចជា:

- **ទេសចរណ៍សុខភាព៖** ជាការធ្វើដំណើររបស់ទេសចរក្នុងបំណងព្យាបាល ដែលធ្វើឡើងតាមរយៈតម្រូវការព្យាបាលសុខភាព។ ទេសចរណ៍ប្រភេទនេះត្រូវបានកំណត់លើចរិតលក្ខណៈផ្សេងៗគ្នាដូចជា: ធាតុអាកាស តំបន់សមុទ្រ ដីកខ្វក់ តំបន់ កីឡា សុខភាព ថ្នាំបុរាណ ទឹកដោះគោ គ្លីនីក មន្ទីរពេទ្យ។ ទេសចរណ៍ស្វែងយល់ និងទស្សនា:គឺជាប្រភេទទេសចរណ៍ដែលធ្វើសកម្មភាពជាមួយ និងត្រូវបានកំណត់ទៅតាមតម្រូវការលើការពង្រឹងកម្លាំងកាយ កម្លាំងចិត្ត និងថាមពល។
- **ទេសចរណ៍កីឡា៖** កំណត់ឡើងដោយសារការធ្វើដំណើរជាទេសចរណ៍ ដើម្បីហាត់លេងកីឡាដោយខ្លួនឯង ដូចជាកីឡាឡើង ភ្នំ ប្រណាំងទូក ឬដើរដើម្បីសុខភាព។
- **ទេសចរណ៍ធុរកិច្ច៖** ជាការធ្វើដំណើរក្នុងគោលបំណងកំណត់បញ្ជាក់ និងបង្កើតទំនាក់ទំនងសម្រាប់ការងាររអាជីវកម្មជាមួយអ្នកមានលទ្ធភាពជាដៃគូ។
- **ទេសចរណ៍សាសនា៖** ទេសចរណ៍សាសនាធ្វើឡើងតាមតំរូវការសាសនា គោរពសាសនា ស្វែងយល់ពីសាសនាចូលរួមក្នុងពិធីបុណ្យសាសនា ការគោរពប្រណិបត្តិសាសនានិងស្វែងយល់ពីទីសក្ការៈប្រវត្តិកំណើតរបស់ព្រះ និងជំនឿសាសនា។
- **ទេសចរណ៍ផ្សងព្រេង៖** គឺជាប្រភេទទេសចរណ៍ដែលធ្វើដំណើរ ឬធ្វើសកម្មភាពទេសចរណ៍បែបផ្សងព្រេងដើម្បីការសប្បាយរីករាយផង ឬដើម្បីសិក្សាស្រាវជ្រាវផងសកម្មភាព និងការធ្វើដំណើរបែបទេសចរណ៍ផ្សងព្រេងមានការរុករក ចូលព្រៃ ឡើងភ្នំ ចូលរូងភ្នំ។

- **អេកូទេសចរណ៍៖** ជាប្រភេទទេសចរណ៍ដែលធ្វើសកម្មភាពទេសចរណ៍ជាមួយនឹងការសម្រាក លំហែរីករាយជាមួយនឹងធម្មជាតិដែលមិនទាន់រងការបំផ្លិចបំផ្លាញដោយសកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍន៍។
- **ទេសចរណ៍ស្ម័គ្រចិត្ត៖** ជាទេសចរណ៍ដែលស្ម័គ្រចិត្តធ្វើដំណើរកម្សាន្តជាប់ទាក់ទងនឹងគំរោងសហគមន៍ និងតំបន់មួយចំនួនដូចជា ការស្រាវជ្រាវបែបវិទ្យាសាស្ត្រ គំរោងអភិរក្ស ជំនួយការផ្នែកពេទ្យ ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។
- **ទេសចរណ៍ម្ហូបអាហារ៖** ជាទេសចរណ៍ដែលធ្វើដំណើរទៅក្នុងតំបន់គោលដៅណាមួយ ដើម្បីទទួលបាននូវបទពិសោធន៍តាមរយៈការទទួលទានអាហារ
  ឬភេសជ្ជៈដែលជាលក្ខណៈប្រពៃណីរបស់ប្រជាជនម្ចាស់ស្រុក ឬតំបន់។
- **ទេសចរណ៍ជនជាតិ៖** ជាទេសចរណ៍ដែលធ្វើដំណើរក្នុងគោលបំណងដើម្បីស្វែងយល់ពីវប្បធម៌ ប្រពៃណីទំនៀមទំលាប់របៀបរបបរស់នៅប្រចាំថ្ងៃរបស់ប្រជាជនជនជាតិភាគតិចនៅក្នុងតំបន់
  ឬប្រទេសណាមួយ។
- **ទេសចរណ៍សិល្បៈ និងមរតកវប្បធម៌៖** ជាប្រភេទទេសចរណ៍ដែលធ្វើដំណើរទៅតំបន់ទាក់ទាញបែបប្រវត្តិ និងវប្បធម៌ក្នុងគោលបំណងទស្សនា សិក្សាស្វែងយល់ពីប្រពៃណី ទំនៀមទំលាប់ ជំនឿ សាសនា វប្បធម៌របស់ប្រជាជនម្ចាស់ស្រុកតាំងពីសម័យអតីតកាលរហូតមកដល់បច្ចុប្បន្ន។
- **ទេសចរណ៍ទុក្ខព្រួយ៖** ជាការធ្វើដំណើររបស់ទេសចរទៅទស្សនា និងសិក្សាស្វែងយល់ពីតំបន់ដែលធ្លាប់ជាកន្លែងបូជាសព សម្លាប់មនុស្ស គុក សមរភូមិ និងទីកប់ខ្មោចជាដើម។
- **ទេសចរណ៍យុវជន៖** ជាការធ្វើដំណើររបស់យុវជននៅក្នុងប្រទេសណាមួយ ឬធ្វើដំណើរកម្សាន្តទៅក្រៅប្រទេសនៅក្នុងបំណងសួរសុខទុក្ខ សិក្សា ការស្វែងយល់អំពីវប្បធម៌ផ្សេងៗ ក៏ដូចជាការផ្សងព្រេង លំហែកាយផងដែរ។
- **ទេសចរណ៍ផ្លូវភេទ៖** ជាការធ្វើដំណើររបស់ទេសចរទៅកាន់ប្រទេសអភិវឌ្ឍន៍ ដែលគោលបំណងចម្បងនៃដំណើរកម្សាន្តនេះគឺជាការរួមភេទ។
- **កសិទេសចរណ៍៖** ជាការធ្វើដំណើររបស់ទេសចរទៅទស្សនា និងសិក្សាស្វែងយល់ពីរបៀបរបបនៃការចិញ្ចឹមសត្វ និងដាំដំណាំ។

- **ទេសចរណ៍សិក្សា៖** ជាការធ្វើដំណើររបស់ទេសចរណ៍ដែលអាចមានលក្ខណៈជាក្រុមក្នុងបំណងសិក្សាស្វែងយល់ពីភាសាវប្បធម៌ ប្រពៃណីទំនៀមទំលាប់ សិល្បៈ និងមុខវិជ្ជាមួយចំនួនទៀត ដែលទាក់ទងនឹងការធ្វើដំណើររបស់ពួកគេ។
- **ទេសចរណ៍សត្វព្រៃ៖** ជាការធ្វើដំណើររបស់ទេសចរនៅក្នុងគោលបំណងចង់ទស្សនា ជីវិតរស់នៅជាលក្ខណៈធម្មជាតិរបស់សត្វ។
- **ទេសចរណ៍ប្រវត្តិសាស្ត្រ៖** ជាដំណើរកម្សាន្តរបស់ទេសចរនៅក្នុងគោលបំណងទស្សនាប្រាង្គប្រាសាទបុរាណណ និងសារមន្ទីនានា ដែលឆ្លុះបញ្ចាំងពីរបៀបរស់នៅ និងវប្បធម៌ប្រពៃណីនាសម័យមុន[7]។

## ១.៤. ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

ភាសាវប្បធម៌ ប្រពៃណីទំនៀមទំលាប់ សិល្បៈ និងមុខវិជ្ជាមួយចំនួនទៀត ដែលទាក់ទងនឹងការធ្វើដំណើររបស់ពួកគេ។ ប្រទេសនីមួយៗក្នុងសកលលោកតែងតែមាននូវ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ប្រវត្តិសាស្ត្រ ជំនឿ សាសនាទៅតាមប្រទេសរៀងៗខ្លួនក្នុងការគោរពប្រត្តិបត្តិ និងឱ្យតម្លៃ ។ ប្រទេសកម្ពុជាយើងក៏មាននូវប្រពៃណី វប្បធម៌ ប្រវត្តិសាស្ត្រផ្សេងៗសម្រាប់ប្រជាជនផងដែរ ពិសេសជាងនេះទៅទៀតសម្បូរដោយរមណីយដ្ឋានទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រដែលជាភាពទាក់ទាញទេសចរជាតិ និងអន្តរជាតិដែលជាមកកម្សាន្តថែមទៀតផង។ ចំពោះធនធានវប្បធម៌ប្រវត្តិសាស្ត្រសំដៅលើវប្បធម៌ ប្រាង្គប្រាសាទ អគារប្រវត្តិសាស្ត្រ ទីតាំងបុរាណវិទ្យា សារមន្ទីរ ស្ថាប្បកម្ម ប្រពៃណី ទំនៀមទម្លាប់ សិល្បៈ តន្ត្រី របាំ ល្ខោន។ល។

យោងតាមនិយមន័យទេសចរណ៍វប្បធម៌នៅក្នុងសៀវភៅលំនាំដើមទេសចរណ៍បានកំណត់ថា "ទេសចរណ៍វប្បធម៌" គឺជាការធ្វើដំណើរទៅកាន់តំបន់ទាក់ទាញបែបបុរេប្រវត្តិ និងវប្បធម៌ក្នុងគោលបំណងទស្សនាសិក្សាស្វែងយល់ពីប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា វប្បធម៌របស់ប្រជាជនម្ចាស់ស្រុកតាំងពីសម័យអតីតកាលរហូតដល់ពេលបច្ចុប្បន្ន[8]។

យោងតាមគេហទំព័របរទេសបានបង្ហាញថាទេសចរណ៍វប្បធម៌ គឺជាចលនារបស់មនុស្សសម្រាប់ការលើកទឹកចិត្តផ្នែកវប្បធម៌សំខាន់ៗដូចជា ដំណើរទស្សនាកិច្ច ការសម្តែង សិល្បៈ និងទេសចរណ៍បែបវប្បធម៌ ការធ្វើដំណើរទៅពិធីបុណ្យ និងព្រឹត្តិការណ៍វប្បធម៌ផ្សេងទៀត ទស្សនាតំបន់ និងបូជនីយដ្ឋាន ការធ្វើដំណើរដើម្បីសិក្សាធម្មជាតិ រឿងព្រេង ឬសិល្បៈផ្សេងៗ[9]។

[7] ហុង វណ្ណៈ ឈុន ពហុ និងសហការី "លំនាំដើមទេសចរណ៍", ៩៧

[8] ហុង វណ្ណៈ ឈុន ពហុ និងសហការី "លំនាំដើមទេសចរណ៍", ៤៩

[9] https://dos.myflorida.com/cultural/info-and-opportunities/resources-by-topic/cultural-tourism-toolkit/what-is-cultural-tourism-basic-information/

## ១.៥. ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

មានទស្សនៈជាច្រើនបានលើកឡើងទាក់ទងទៅនឹងការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍។ បើទោះបីជាទស្សនៈនីមួយៗមានការប្រើប្រាស់ពាក្យពេជន៍ឬឃ្លាឃ្លោងខុសៗពីគ្នាក្នុងការពន្យល់ និងបកស្រាយអំពីខ្លឹមសាររបស់វាក៏ដោយ នៅចុងបញ្ចប់សេចក្តីគេនៅតែសង្កេតឃើញថា អត្ថន័យនៃទស្សនៈទាំងនោះនៅតែមានភាពស្រដៀងៗគ្នា។ ដើម្បីជាស្ពានឈានទៅរកការបកស្រាយពីនិយមន័យនៃប្រយោគខាងលើ យើងគម្បីត្រូវយល់ឱ្យលម្អិតពីពាក្យសំខាន់ៗ ចំនួនពីរដែលមានដូចជាពាក្យ "**គ្រប់គ្រង**" និងពាក្យ "**អភិវឌ្ឍ**" ជាមុនសិន។ គិតមកដល់ពេលបច្ចុប្បន្ននេះ និយមន័យនៃពាក្យ "**ការគ្រប់គ្រង**" ត្រូវបានកំណត់ និងពន្យល់ដោយអ្នកប្រាជ្ញ សាស្ត្រាចារ្យ ក៏ដូចជាប្រភពជាច្រើន ដែល និយមន័យទាំងនោះមានដូចខាងក្រោម៖

បើយោងតាមវចនានុក្រមព្រះសង្ឃរាជ **ជួន ណាត** "គ្រប់គ្រង" ត្រូវបានពន្យល់ថា ការបីបាច់ ថែរក្សា ថែទាំដោយទទួលរងបន្ទុកទាំងឡាយដែលកើតមាន[10]។

វចនានុក្រម**ខេមប្រ៊ីជ** (Cambridge Dictionary) បានពោលថា "គ្រប់គ្រង" គឺជាការទទួលខុសត្រូវលើការរៀបចំ នរណាម្នាក់ ឬវត្ថុអ្វីមួយដើម្បីឈានទៅរកភាពជោគជ័យ[11]។

វេបសាយ**ខេមបូឌៀអ៊ីនធីប្រ៊ីណឺ** (Cambodia Entrepreneur) បានឱ្យនិយមន័យពាក្យ "គ្រប់គ្រង" ថាជាដំណើរការនៃការធ្វើផែនការ ការចាត់ចែង ការដឹកនាំ និងការត្រួតពិនិត្យលើការប្រើប្រាស់ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានដ៏ទៃទៀតដើម្បីសម្រេចគោលដៅរបស់អង្គភាព[12]។

ចំណែកឯពាក្យ "**អភិវឌ្ឍ**" តាមការដកស្រង់ពីវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** មានន័យថា ចម្រើនក្រៃលែង និងលូតលាស់ចម្រើន។

តាមវចនានុក្រម**អេនកាតា** (Encarta Dictionary) បានរៀបរាប់ថា "អភិវឌ្ឍ" គឺជាបាតុភូត ឬអង្គហេតុមួយដែលបណ្តាលឱ្យសភាពការណ៍មួយមានការផ្លាស់ប្តូរ ឬរីកចម្រើន[13]។

តាមការស្រាវជ្រាវរបស់**សួន រ៉ានី** និងសហការីបានឱ្យដឹងថា ការអភិវឌ្ឍ គឺជាដំណើរការនៃការកែប្រែធនធាន ឬសម្ភារពីមិនទាន់ល្អឱ្យក្លាយទៅជាល្អប្រសើរជាងមុន។ ធនធានទាំងនោះសម្តៅទៅដល់ធនធានទាំង

---

[10] សម្តេច សង្ឃរាជ ជួនណាត "វចនានុក្រមខ្មែរ", ២០០៩

[11] https://dictionary.cambridge.org

[12] ខេមបូឌៀអ៊ីនធីប្រ៊ីណឺ "អ្វីជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង, ២០២១

[13] https://encartadictionaryonlinefid.wordpress.com

អស់ ទាំងធនធានធម្មជាតិ និងធនធានកែច្នៃ រីឯសម្ភារវិញសម្ដៅដល់ទូរស័ព្ទដៃ មធ្យោបាយធ្វើដំណើរ មន្ទីរពេទ្យ ផ្លូវថ្នល់ សាលារៀនជាដើម[14]។

លើសពីនេះទៅទៀត ក៏មានអ្នកឯកទេស ព្រមទាំងបញ្ញវន្តដែលមានជំនាញខាងគ្រប់គ្រងនិងអភិវឌ្ឍន៍ជាច្រើនរូបបានចូលរួមក្នុងការកំណត់និយមន័យរបស់ប្រយោគទាំងមូលគឺ **"ការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ"** ផងដែរ ដែលនិយមន័យទាំងអស់នោះមានដូចខាងក្រោម៖

គេហទំព័រ**ធួររីសឹម ធីចឈើ** (Tourism Teacher) បានកំណត់ថា "ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍" គឺជាការប្ដេជ្ញាចិត្តក្នុងការរៀបចំយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលកើតមាននៅគោលដៅទេសចរណ៍ណាមួយ ដើម្បីជួយថែរក្សានិងការពារធនធានទាំងនោះឱ្យមានសោភ័ណ្ឌភាព និងបានគង់វង្សយូរអង្វែង ដើម្បីបន្សល់ទុកទៅដល់ប្រជាជនក្នុងតំបន់ និងទេសចរជំនាន់ក្រោយៗ[15]។

យោងតាមគេហទំព័រ **ធូធើរៀល ភ័ណ្ឌ** (Tutorial Point) "ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍" សម្ដៅទៅដល់កិច្ចការជាច្រើនរួមមាន ការសិក្សាពីគោលដៅទេសចរណ៍ ការធ្វើផែនការទេសចរណ៍ ការរៀបចំបង្កើតដំណើរកម្សាន្ត ការផ្សព្វផ្សាយពីគោលដៅទេសចរណ៍ និងការអភិវឌ្ឍន៍កសាងនូវ ហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវដែលអាចចូលទៅដល់តំបន់គោលដៅ មធ្យោបាយធ្វើដំណើរ សណ្ឋាគារសម្រាប់ស្នាក់នៅ និងគ្រឿងបរិក្ខារចាំបាច់នានា ដើម្បីទាក់ទាញ ទេសចរឱ្យធ្វើដំណើរមកកាន់គោលដៅទេសចរណ៍ណាមួយនោះ[16]។

សរុបជារួមមក ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ គឺសម្ដៅដល់សកម្មភាពទាំងឡាយណាដែលធ្វើអាចឱ្យគ្រប់ផ្នែកទាំងអស់នៃវិស័យទេសចរណ៍រួមមាន៖ ផ្នែកសេវាកម្ម បដិសណ្ឋារកិច្ចហេដ្ឋារចនាសម្ព័ន្ធ និងវប្បធម៌ទំនៀមទម្លាប់ក្នុងស្រុកឱ្យមានការរីកចម្រើនលូតលាស់។ និយាយក្នុងន័យសាមញ្ញ វាគឺជាដំណើរការនៃការរៀបចំថែរក្សាតំបន់ទាក់ទាញបែបបុរេប្រវត្តិនិងវប្បធម៌ប្រពៃណី ព្រមទាំងកែប្រែធនធានទាំងនោះឱ្យមានភាពល្អប្រសើរ និងសម្បូរបែបជាងមុន ដើម្បីបម្រើផលប្រយោជន៍ ក៏ដូចជាបង្កើនភាពងាយស្រួលដល់ទេសចរ និងពលរដ្ឋក្នុងសហគមន៍។ ប៉ុន្តែការអភិវឌ្ឍទាំងនោះត្រូវធានាថានឹងឆ្លើយតបទៅនឹងការអភិរក្សមានន័យថាសំណង់ប្រាង្គប្រាសាទ ឬធនធានធម្មជាតិទាំងឡាយនឹងមិនត្រូវទទួលរងនូវការបំផ្លិចបំផ្លាញណាមួយឡើយ។ ដើម្បីទទួលបានលទ្ធផលមួយនេះ រាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យទេសចរណ៍ត្រូវតែមានវិធានការច្បាស់លាស់ក្នុងការគ្រប់គ្រងធនធានធម្មជាតិទាំងឡាយទាំងពួងឱ្យបានសមរម្យ

[14] សួន វ៉ានី និងសហការី "និរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍, ២០១២

[15] https://tourismteacher.com/why-tourism-development-planning-is-important/

[16] https://www.tutorialspoint.com/tourism_management/tourism_management_introduction.htm

ដើម្បីរក្សាសម្រស់ដ៏ល្អរបស់វាសម្រាប់យកមកធ្វើជានុយក្នុងការទាញយកផលប្រយោជន៍ជូនជាតិ។ បន្ថែមពីនេះទៅទៀត រាជរដ្ឋាភិបាលក៏ត្រូវទាមទារឱ្យមានការចុះត្រួតពិនិត្យលើទង្វើ និងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងតំបន់ ដើម្បីធានាថាការអភិវឌ្ឍន៍នឹងមានភាពស៊ីមេទ្រីទៅនឹងតម្លៃវប្បធម៌ និងអត្តសញ្ញាណនៃប្រទេស ជៀសវាងការប៉ះពាល់ណាមួយលើបែបបទសង្គម។

## ១.៦. ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

នៅពេលដែលប្រទេសមួយមានយន្តការ ក៏ដូចជាចក្ខុវិស័យច្បាស់លាស់នៅក្នុងការគ្រប់គ្រងគោលដៅទេសចរណ៍នានានៅក្នុងវិស័យទេសចរណ៍ នោះប្រទេសនោះប្រាកដណាស់នឹងទទួលបានការអភិវឌ្ឍ។ ដែលជាលទ្ធផល ការអភិវឌ្ឍនោះនឹងសាយភាយនូវផលចំណេញមួយចំនួនធំទៅកាន់ផ្នែកផ្សេងៗនៅក្នុងប្រទេសទាំងមូល។ និយាយក្នុងន័យសាមញ្ញមក ការអភិវឌ្ឍនៃវិស័យទេសចរណ៍មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់វិស័យខ្លួនផ្ទាល់ទេ ប៉ុន្តែវាក៏មានឥទ្ធិពលទៅលើ៖ វប្បធម៌ទំនៀមទម្លាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថានផងដែរ។

ទន្ទឹមនឹងនេះ ការអភិវឌ្ឍទេសចរណ៍ក៏អាចជាប្រភពនៃបញ្ហាផងដែរ។ ផលប៉ះពាល់អវិជ្ជមានទាំងនោះអាចដូចជា៖ ការប៉ះទង្គិចនៃវប្បធម៌ ការពឹងផ្អែកហួសកម្រិតលើវិស័យទេសចរណ៍ អសន្តិសុខសង្គម និងការខូចខាត បរិស្ថានជាដើម។

**ផលប៉ះពាល់វិជ្ជមានលើវប្បធម៌ទំនៀមទម្លាប់៖** ការអភិវឌ្ឍច្បាស់ណាស់នឹងទាក់ទាញចំណាប់អារម្មណ៍របស់ទេសចរ ជាពិសេសទេសចរអន្តរជាតិឱ្យមានទស្សនាកម្សាន្តនៅតំបន់គោលដៅដើម្បីស្វែងយល់ និងបានឃើញផ្ទាល់ពីតំបន់ដែលគេតែងតែលឺនោះ។ កំណើននៅទេសចរបានផ្តល់ជាឱកាសដ៏ល្អក្នុងការលើកកម្ពស់វប្បធម៌របស់ប្រជាជនក្នុងតំបន់ ក៏ដូចជាប្រទេសទាំងមូល។ នេះដោយសារតែទេសចរដែលមកដល់ និងអ្នកស្រុកអាចចែករំលែកការយល់ ដឹង ទំនៀមទម្លាប់ សិល្បៈ វត្ថុអនុស្សាវរីយ៍ ឬពិធីបុណ្យប្រពៃណីក្នុងស្រុកផ្សេងៗ ដើម្បីបន្សល់ទុកជាការចងចាំ និងកសាងជាស្ពានក្នុងការផ្សារភ្ជាប់វប្បធម៌ទាំងឡាយនៅទូទាំងពិភពលោក[17]។

ពិសេសជាងនេះទៀត ទេសចរណ៍ក៏បានជួយបង្កើតទំនាក់ទំនងរវាងក្រុមមនុស្សទាំងអស់ដែលមកពីគ្រប់មជ្ឈដ្ឋាន និងឋានៈសង្គមឱ្យបានស្វែងយល់បន្ថែមអំពីប្រវត្តិសាស្ត្រ និងវប្បធម៌របស់គ្នាទៅវិញទៅមកផងដែរ ដើម្បីជំរុញឱ្យមានការរួបរួមគ្នារវាងក្រុមមនុស្សផ្សេងៗគ្នានិងជៀសឱ្យឆ្ងាយពីការប្រយុទ្ធគ្នាដែលជាដើមហេតុនាំឱ្យបែកបាក់សាមគ្គីនៅក្នុងមនុស្សជាតិ។

**ផលប៉ះពាល់វិជ្ជមានលើសេដ្ឋកិច្ច៖** ការរីកចម្រើននៃវិស័យទេសចរណ៍បានផ្តល់នូវអត្ថប្រយោជន៍ទាំងផ្ទាល់ និងប្រយោលជាច្រើនលើសលុបមកលើសេដ្ឋកិច្ច។ អត្ថប្រយោជន៍ផ្ទាល់នោះគឺ វិស័យទេសចរណ៍បាន

[17] https://ticketsntour.com/pros-cons-tourism/

ដើរតួនាទីយ៉ាង សំខាន់ក្នុងការបង្កើតឱកាសការងារសម្រាប់ប្រជាជននៅទូទាំងពិភពលោក។ បើយោងទៅតាមរបាយការណ៍របស់ក្រុមប្រឹក្សានៃការធ្វើដំណើរ និងទេសចរណ៍ពិភពលោក (WTTC) បានរាយរាប់ឱ្យឃើញថាការងារទូទៅក្នុងវិស័យទេសចរណ៍នៅទូទាំងពិភពលោកមានចំនួន ២៨៩ លាននៅក្នុងឆ្នាំ ២០២១ បើធៀបនឹង ៣៣៣ លានក្នុងឆ្នាំ ២០១៩។បើទោះបីជាមានការធ្លាក់ចុះគួរជាទីកត់សម្គាល់ដោយសារតែការរាតត្បាតនៃវិបត្តិកូវីដ-១៩ក៏ពិតមែន ប៉ុន្តែការងារក្នុងវិស័យនេះនៅតែឈរនៅកម្រិតខ្ពស់បើធៀបនឹងវិស័យផ្សេងៗទៀត។ ការងារទាំងនោះភាគច្រើនទាក់ទងនឹងការបម្រើសេវាកម្មដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ភ្នាក់ងារទេសចរណ៍ ក្រុមហ៊ុនអាកាសចរណ៍ និងមុខងារផ្សេងទៀតដែលបម្រើដល់ភ្ញៀវទេសចរ។ ចំណែកអត្ថប្រយោជន៍មួយទៀតគឺទេសចរណ៍មានសមត្ថភាពដ៏ខ្លាំងក្លាក្នុងការរកចំណូល តាមរយៈប្រាក់ចំណូលលើការប្តូរប្រាក់បរទេស ដែលនិយាយឱ្យស្រួលយល់មានន័យថាប្រាក់ចំណេញដែលបានមកពីការលក់ទំនិញ និងសេវាកម្ម ឬដោយការផ្លាស់ប្តូររូបិយប័ណ្ណនៅក្នុងទីផ្សារពិភពលោក។ លើសពីនេះ ពន្ធលើប្រាក់ចំណូលពីការងារទេសចរណ៍ អាជីវកម្មទេសចរណ៍ និងថ្លៃសេវាកម្មដែលគិតលើភ្ញៀវទេសចរដែលមានដូចជា ពន្ធអេកូឡូស៊ី (ecological taxation) ឬពន្ធលើការចាកចេញ (departure taxes)។ ចំណូលទាំងប៉ុន្មាននេះបានអាចអនុញ្ញាតឱ្យប្រទេសនីមួយៗយកមកវិនិយោគបន្ថែម ដើម្បីពង្រីកវិស័យទេសចរណ៍ និងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។ រីឯអត្ថប្រយោជន៍ដោយប្រយោលវិញ ទេសចរណ៍បានជួយដល់សហគ្រាសខ្នាតតូចៗមួយចំនួនក្នុងស្រុក ជាពិសេសសហគ្រាសដែលផ្គត់ផ្គង់គ្រឿងបរិក្ខារ និងគ្រឿងសង្ហារិមដើម្បីបំពេញតម្រូវការចាំបាច់របស់សណ្ឋាគារឬភោជនីយដ្ឋាននៅពេលដែលទេសចរមានការកើនឡើង។ ស្របគ្នានេះដែរ ប្រជាជនក្នុងតំបន់ក៏អាចទទួលបានផលចំណេញតាមរយៈការលក់ទំនិញទៅកាន់អ្នកទេសចរដូចជា ម្ហូបអាហារ ឬវត្ថុអនុស្សាវរីយ៍ដែលធ្វើដោយដៃផ្ទាល់[18]។

**ផលប៉ះពាល់វិជ្ជមានលើសង្គម៖** ថវិការដែលទទួលបានពីទេសចរណ៍អាចឱ្យប្រទេសយកមកអភិវឌ្ឍបន្ថែម លើហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ បណ្តាញផ្លូវដែក និងស្ពានដែលអាចតភ្ជាប់ពីតំបន់ ឬប្រទេសមួយទៅកាន់តំបន់ឬប្រទេសមួយទៀត។ មិនតែប៉ុណ្ណោះ ប្រទេសខ្លះបានចំណាយប្រាក់ចំណូលនេះទៅលើសេវាសាធារណៈដូចជាការអប់រំ និងសេវាកម្មសុខាភិបាល។ សេវាទាំងពីរនេះមានសារៈសំខាន់ក្រៃលែងចំពោះការបង្កើនស្តង់ដានៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងស្រុក ព្រោះនៅពេលដែលប្រជាជនទទួលបានចំណេះដឹងខ្ពស់ ពួកគេនឹងមានសមត្ថភាពក្នុងការរកចំណូលបានច្រើន។ ប៉ុន្តែទន្ទឹមនឹងនោះ ដើម្បីបំពេញការងារឱ្យបានជោគជ័យ បុគ្គលម្នាក់ៗត្រូវទាមទារឱ្យមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្តផងដែរ។ ដូច្នេះ ការចំណាយ

[18] https://wttc.org/Research/Economic-Impact

ថវិការដែលបានពីទេសចរណ៍មកលើសេវាសាធារណៈ ក៏អាចជាកត្តាមួយដែលដ៏ចម្បងក្នុងការជួយកាត់បន្ថយភាពក្រីក្រ ក៏ដូចជាភាពគ្មានការងារធ្វើនៅក្នុងប្រទេសដែរ[19]។

**ផលប៉ះពាល់វិជ្ជមានលើបរិស្ថាន៖** ទេសភាពដ៏ស្រស់ស្អាតនៃប្រាង្គប្រាសាទ សំណង់ចម្លាក់បុរាណ ទីតាំងប្រវត្តិសាស្ត្រ បំណែកកស្តុតាង និងធនធានធម្មជាតិដែលមានដូចជា ព្រៃព្រឹក្សា សត្វព្រៃ និងទន្លេ បឹងបួរ អូរ និងស្ទឹងសុទ្ធសឹងតែជាកន្លែងដែលទាក់ទាញទេសចរមកពីជុំវិញពិភពលោកឱ្យមកទស្សនាប្រទេសនីមួយៗ ដើម្បីបានលំហែអារម្មណ៍ និងទទួលបានបទពិសោធន៍ថ្មីៗ។ ហេតុដូចនេះហើយ កំណើននៃទេសចរបានក្លាយជាកាតាលីករជំរុញឱ្យរាជរដ្ឋាភិបាល មន្ត្រីពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងតំបន់ទាំងអស់ចាប់ផ្តើមក្រឡេកមកយកចិត្តទុកដាក់និងចូលរួមក្នុងការអនុវត្តបទប្បញ្ញត្តិ ដើម្បីការពារនិងអភិរក្សធនធានធម្មជាតិឱ្យមានសុវត្ថិភាពជៀសផុតពីការខូចខាត និងបាត់បង់នាពេលអនាគត[20]។

ទោះបីជាការរីកលូតលាស់នៃទេសចរណ៍បានផ្តល់គុណសម្បត្តិជាច្រើនក៏ដោយ ពេលខ្លះវាក៏អាចនាំមកនូវគុណវិបត្តិដល់ប្រទេសផងដែរ ប្រសិនបើមិនបានគ្រប់គ្រងឱ្យបានដិតដល់ទេ។

**ផលប៉ះពាល់អវិជ្ជមានលើវប្បធម៌ទំនៀមទម្លាប់៖** វិស័យទេសចរណ៍ជាកម្លាំងមួយក្នុងចំនោមកម្លាំងជាច្រើនដែលអាចជះឥទ្ធិពល និងបង្កផលប៉ះពាល់មកលើវប្បធម៌ទំនៀមទម្លាប់របស់ប្រទេសនីមួយៗ។ ផលប៉ះពាល់ដំបូងគេនោះ គឺការប៉ះទង្គិចនៃវប្បធម៌រវាងប្រជាជនក្នុងតំបន់ដែលជាម្ចាស់ផ្ទះ និងទេសចរ។ ជាធម្មតាទេសចរណ៍មានការពាក់ព័ន្ធនឹងការផ្លាស់ទីរបស់ក្រុមមនុស្សពីភូមិសាស្ត្រផ្សេងៗគ្នា ដែលតំបន់នីមួយៗតែងតែមានវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី សាសនា របៀបរស់នៅ សីលធម៌ និងភាសាខុសៗគ្នា។ ភាពខុសគ្នានេះហើយដែលជាហេតុនាំឱ្យមានការយល់ច្រលំកើតឡើង ហើយបើមិនបានដោះស្រាយទាន់ពេលវេលាទេ វាអាចនឹងបង្កឱ្យមានជម្លោះ និងឈានដល់ការប្រើប្រាស់អំពើហិង្សា។ ឧទាហរណ៍ ប្រទេសមួយចំនួននៅមជ្ឈិមបូព៌ា ឥណ្ឌា ស្រីលង្កានិងផ្នែកខ្លះនៃទ្វីបអាហ្វ្រិកបានចាត់ទុកដៃឆ្វេងជាដៃកខ្វក់ ព្រោះគេប្រើវាបន្ទាប់ពីប្រើប្រាស់បង្គន់ហើយ។ ដូច្នេះហើយ ប្រសិនបើទេសចរប្រើដៃនេះពេលបរិភោគ ឬធ្វើសកម្មភាពផ្សេងៗ នោះវាអាចនឹងបណ្តាលឱ្យប្រជាជនក្នុងតំបន់មានការអាក់អន់ចិត្ត។ ផលប៉ះពាល់មួយទៀត គឺការសឹករិចរិលនៃវប្បធម៌ប្រពៃណី។ នៅពេលដែលវប្បធម៌ប្រពៃណីបានក្លាយទៅជាការទាក់ទាញដែលមនុស្សចំណាយថវិការដើម្បីបានមើល នោះវានឹងជំរុញឱ្យប្រជាជនក្នុងតំបន់ និងសហគមន៍ពាក់ព័ន្ធចាប់ផ្តើមកែប្រែរបាំប្រពៃណី និងសំលៀកបំពាក់ ព្រមទាំងកាត់បន្ថយរយៈពេលនៃការប្រារព្ធពិធីសាសនានានា ដើម្បីឱ្យមានលក្ខណៈសមស្របទៅនឹងកាលវិភាគកម្សាន្ត

[19] https://tourismteacher.com/social-impacts-of-tourism/#1-positive-social-impacts-of- tourism

[20] https://greentumble.com/positive-impacts-of-tourism-on-environment/

របស់ទេសចរ។ នៅពេលទង្វើបែបនេះត្រូវបានធ្វើឡើងជាញឹកញាប់ វាអាចនឹងបណ្តាលឱ្យវប្បធម៌ជាតិមានការបាត់បង់បន្តិចម្តងៗរហូតទាល់តែអស់តែម្តង។ មួយវិញទៀត កំណើននៃទេសចរចូលមកក្នុងប្រទេសដែលជាលទ្ធផលនៃការអភិវឌ្ឍអាចនាំឱ្យមានការផ្លាស់ប្តូរវប្បធម៌ក្នុងតំបន់ ដោយសារតែប្រជាជន ជាពិសេសសមាជិកវ័យក្មេងក្នុងសហគមន៍បានទទួលឥទ្ធិពលពីទេសចរបរទេស ហើយពួកគេចាប់ផ្តើមធ្វើត្រាប់តាមនិងចម្លងវប្បធម៌របស់ទេសចរដែលមកដល់ ដែលជាហេតុធ្វើឱ្យមានការចាកឆ្ងាយពីទំនៀមទម្លាប់ និងប្រពៃណីផ្ទាល់ខ្លួនរបស់ពួកគេ។ មិនត្រឹមតែប៉ុណ្ណោះ ការចូលមកកម្សាន្តរបស់ទេសចរចំនួនរាប់ពាន់នាក់ ជួនកាលរាប់លាននាក់ជារៀងរាល់ឆ្នាំអាចធ្វើឱ្យរចនាសម្ព័ន្ធ និងផ្ទាំងសិលាលើជញ្ជាំងថ្មមានភាពសឹករិចរិល និងខូចខាត ដោយសារតែការប៉ះពាល់ ការប្រើប្រាស់កាមេរ៉ា ឬវត្ថុរឹងទៅទង្គិចជាមួយនឹងជញ្ជាំងពេលកំពុងចូលទស្សនា។ បច្ចុប្បន្ននេះ កន្លែងទាក់ទាញបែបវប្បធម៌ប្រវត្តិសាស្ត្រជាច្រើននៅក្នុងពិភពលោកកំពុងតែទទួលរងនូវផលវិបាកដែលបានបន្សល់ពីសកម្មភាព និងភាពគ្មានការទទួលខុសត្រូវរបស់ទេសចរ[21]។

**ផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច៖** ការរីកចម្រើនឥតព្រំដែនរបស់វិស័យទេសចរណ៍បានក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះបានជំរុញឱ្យប្រទេសជាច្រើនចាប់ផ្តើមពឹងផ្អែកយ៉ាងខ្លាំងលើវិស័យនេះ។ ការរីកចម្រើនមួយនេះប្រៀបដូចជាកាំបិតមុខពីរអញ្ចឹង មានន័យថាទន្ទឹមនឹងការផ្តល់ផលប្រយោជន៍យ៉ាងច្រើនសម្បារដល់សេដ្ឋកិច្ចជាតិ វាក៏អាចនាំមកនូវគុណវិបត្តិផងដែរ។ ជាក់ស្តែងរដ្ឋាភិបាលនៃប្រទេសមួយចំនួន ជាពិសេសប្រទេសដែលបានចាត់ទុកវិស័យទេសចរណ៍ជាវិស័យដែលសំខាន់ជាងគេស្រុក តែងតែផ្តោតការខិតខំប្រឹងប្រែងនិងចំណូលមួយភាគធំទៅលើវិស័យទេសចរណ៍ ឯឧស្សាហកម្មសំខាន់ៗផ្សេងទៀតដែលមិនសូវអាចទាក់ទាញទេសចរបានដូចជាហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខាភិបាល និងផ្នែកសន្តិសុខត្រូវបានគេមិនអើពើយកចិត្តទុកដាក់។ ជាលទ្ធផល វាអាចបង្កឱ្យមានការអភិវឌ្ឍមិនស្មើភាពគ្នានៅក្នុងសង្គមរវាងឧស្សាហកម្មទេសចរណ៍និងឧស្សាហកម្មក្រៅពីទេសចរណ៍។ យោងទៅតាមគេហទំព័រ ហ្វប (Forbes) វាជាការពិតណាស់ដែលថាវិស័យទេសចរណ៍ជាឧស្សាហកម្មមួយដ៏ធំបំផុតក្នុងពិភពលោកដែលរកចំណូលបាន៩,២ ទ្រីលានដុល្លារស្មើនឹងជាង១០%នៃGDPរបស់ពិភពលោក។ ការបង្កើតការងារជាច្រើនសម្រាប់ប្រជាពលរដ្ឋនៅក្នុងវិស័យទេសចរណ៍បានបង្ខំឱ្យកម្មករផ្លាស់ប្តូរពីការងារប្រពៃណីរួមមានដូចជា កសិកម្ម ការជីកយករ៉ែ និងនេសាទត្រីឱ្យមកធ្វើការនៅក្នុងឧស្សាហកម្មទេសចរណ៍វិញ។ ប៉ុន្តែជារឿយៗការងារទាំងនោះផ្តល់ប្រាក់ខែទាប និងមិនមានភាពនោះទេដែលមានន័យថាតម្រូវការនៃបុគ្គលិកគឺអាស្រ័យនឹងរដូវកាល និងស្ថានភាពជាក់ស្តែងនៅក្នុងពិភពលោក។ ជាឧទាហរណ៍ នៅពេលដែលវិបត្តិកូវីដ-១៩ផ្ទុះឡើង ទេសចរទូទាំងសកលលោកបានផ្អាកការធ្វើដំណើរកម្សាន្ត

[21] https://localizejs.com/articles/cultural-differences-9-surprising-customs-from-around-the-world/

ដោយសារតែការដាក់កំហិតលើការធ្វើដំណើរ និងការរាតត្បាតនៃជម្ងឺ ដូច្នេះហើយបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ជាច្រើននាក់ត្រូវបាត់បង់ការងារ និងចំណូលចូលគ្រួសារ។ ផលប៉ះពាល់អវិជ្ជមានមួយទៀត គឺភ្នាក់ងារទេសចរណ៍ សណ្ឋាគារ ឬភោជនីយដ្ឋានជាច្រើនត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនធំៗរបស់បរទេស ហើយពួកគេតែងតែជួលកម្មករដែលមានជាតិសាសន៍មួយផ្សេងទៀតជាជាងកម្មករក្នុងស្រុក ព្រោះបុគ្គលទាំងនោះទាមទារប្រាក់ឈ្នួលទាប។ ការធ្វើបែបនេះអនុញ្ញាតឱ្យវិនិយោគិនបរទេសទាញយក ប្រាក់ចំណេញភាគច្រើនពីវិស័យទេសចរណ៍ ស្របពេលដែលឧស្សាហកម្មក្នុងស្រុកខ្នាតតូចនិងមធ្យម និងប្រជាពលរដ្ឋក្នុងតំបន់បាត់បង់ឱកាសក្នុងការរកប្រាក់ចំណូលពីវិស័យទេសចរណ៍ដែលជាប្រភពដ៏សំខាន់[22]។

**ផលប៉ះពាល់អវិជ្ជមានលើសង្គមៈ** ជាអកុសល ការរីកអភិវឌ្ឍនៃវិស័យទេសចរណ៍បានបន្សល់ទុកនូវផលប៉ះពាល់អវិជ្ជមានជាច្រើនដល់ប្រទេសម្ចាស់ផ្ទះ។ ដូចដែលបានឃើញ លំហូរនៃទេសចរជាហេតុនាំឱ្យសកម្មភាពអសន្តិសុខមួយចំនួនត្រូវបានកើតឡើង។ ការរីកចម្រើននៃកាស៊ីណូ និងកន្លែងលេងល្បែងផ្សេងៗអាចជំរុញទឹកចិត្តទេសចរឱ្យចូលរួមលេងល្បែងស៊ីសងនៅពេលកំពុងមកកម្សាន្តនៅប្រទេសគោលដៅ។ បើឈ្នះគឺជាការប្រសើរ ប៉ុន្តែនៅពេលដែលចាញ់ វាអាចនឹងបង្កបញ្ហាដែលនាំឱ្យសង្គមមានភាពអនាធិបតេយ្យដូចជា ការប្រើអំពើហិង្សា និងឈានដល់ការធ្វើអត្តឃាតទៀតផង។ ក្រៅពីល្បែង ទេសចរណ៍អាចរួមចំណែកក្នុងការធ្វើឱ្យមានការកើនឡើងនៃឧក្រិដ្ឋកម្មផ្សេងៗរួមមាន ការឆក់ប្លន់ ការឆបោក និងការចាប់ជំរិត។ នេះដោយសារតែអ្នកស្រុកតែងសន្មតទេសចរថាជាអ្នកមានទ្រព្យសម្បត្តិ ព្រោះពួកគេមានលុយច្រើនក្នុងការចំណាយ និងមានវត្ថុមានតម្លៃដូចជា កាមេរ៉ា និងគ្រឿងអលង្ការជាប់ខ្លួន ដែលជា លទ្ធផល ទាក់ទាញចំណាប់អារម្មណ៍ឧក្រិដ្ឋជនឱ្យប្រព្រឹត្តអំពើអបាយមុខ។ បន្ថែមពីនេះ ការមកដល់របស់ទេសចរអាចជាកត្តាធ្វើឱ្យការនាំចូលគ្រឿងញៀនខុសច្បាប់ដូចជា អាភៀន និងកញ្ឆាមានការកើនឡើង ព្រោះតែទេសចរបាននាំយក សារធាតុខុសច្បាប់ទាំងនេះពីប្រទេសកំណើតរបស់គេដើម្បីចែកចាយដល់ប្រជាជនក្នុងតំបន់គោលដៅ។ ការប្រើប្រាស់គ្រឿងញៀនមិនត្រឹមតែជះឥទ្ធិពលអវិជ្ជមានដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកប្រើប្រាស់ទេ តែវាក៏ផ្តល់ផលវិបាកដល់គ្រួសារ និងសង្គមទាំងមូលផងដែរ។ អ្វីដែលមិនអាចមើលរំលងបាននោះគឺការនាំចូលនូវជម្ងឺឆ្លងផ្សេងៗ ចូលមកក្នុងប្រទេសម្ចាស់ផ្ទះ។ ចលនាបម្លាស់ទីឥតឈប់ឈររបស់ទេសចរបានក្លាយជាមធ្យោបាយដ៏សំខាន់មួយក្នុងការជួយឱ្យជម្ងឺមានការឆ្លងរីករាលដាលពីតំបន់ភូមិសាស្ត្រទៅតំបន់ភូមិសាស្ត្រថ្មីមួយទៀត។ ការរាតត្បាតនៃជម្ងឺកូវីដ-១៩ គឺជាឧទាហរណ៍ជាក់ស្តែង។ យោងតាមអង្គការសុខភាពពិភពលោក (WHO) ជម្ងឺនេះត្រូវបានរក

---

[22] https://www.forbes.com/sites/forbesbusinessdevelopmentcouncil/2022/04/04/how-one- of-the-worlds-largest-industries-could-emerge-stronger-from-this- pandemic/?sh=53384d1b34f2

ឃើញដំបូងនៅទីក្រុងវូហាន ប្រទេសចិនក្នុងខែធ្នូ ឆ្នាំ២០១៩ តែដោយសារការបរាជ័យក្នុងការទប់ស្កាត់ការធ្វើដំណើររបស់ទេសចរពេលភ្លាមៗ ទើបមេរោគត្រូវបានរីករាលដាលពាសពេញពិភពលោក[23]។

**ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន៖** ការអភិវឌ្ឍវិស័យទេសចរណ៍ប្រៀបបីដូចជាការអញ្ជើញទេសចររាប់លាននាក់ឱ្យចូលមកក្នុងប្រទេសសម្រាប់លំហែកម្សាន្ត ទង្វើទាំងនេះអាចនាំឱ្យមានការខូចខាតយ៉ាងសម្បើមដល់បរិស្ថាន ជាពិសេសនៅគោលដៅដែលមានប្រជាប្រិយភាពខ្លាំង។ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP) បានលើកឡើងថា វិស័យទេសចរណ៍មានបន្សល់នូវផលប៉ះពាល់ធំៗចំនួនបី ដែលក្នុងនោះមានការថយចុះនៃធនធានធម្មជាតិ ការបំពុលបរិស្ថាន និងផលប៉ះពាល់ដោយផ្ទាល់លើកន្លែងគោលដៅ។ កំណើនទេសចរអាចដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរលើការប្រើប្រាស់នៃធនធានធម្មជាតិដូចជា ទឹក និងធនធានផ្សេងៗក្នុងតំបន់ ដែលជាលទ្ធផលនាំឱ្យមានភាពខ្វះខាតពេលអនាគត។ ការប្រើប្រាស់ទឹកហួសកម្រិតនៅក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីបំពេញតម្រូវការទេសចរបានក្លាយជាការព្រួយបារម្ភយ៉ាងខ្លាំងដ៏ប្រទេសជាច្រើន ជាពិសេសប្រទេសនៅតំបន់ស្ងួត។ នេះដោយសារតែនៅពេលមកសម្រាកលំហែ ទេសចរមានទំនោរប្រើប្រាស់ទឹកច្រើនជាងពេលពួកគេនៅផ្ទះចំនួនពីរដង។ ធនធានក្នុងស្រុកដូចជាថាមពល អាហារ និងវត្ថុធាតុដើមនានាក៏អាចនឹងបាត់បង់ដោយសារការកើនឡើងនៃការប្រើប្រាស់របស់ប្រជាជនក្នុងតំបន់ដើម្បីបម្រើទេសចរ។ និយាយពីការបំពុលបរិស្ថាន វិស័យទេសចរណ៍ក៏ចូលរួមចំណែកដល់ការបំពុលមិនចាញ់វិស័យផ្សេងៗប៉ុន្មានទេ។ ពោលគឺការដឹកជញ្ជូនតាមផ្លូវអាកាស ផ្លូវគោក និងផ្លូវដែកដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃចំនួនទេសចរបានចូលរួមចំណែក យ៉ាងសំខាន់ក្នុងការបញ្ចេញឧស្ម័នពុល ($CO_2$) ទៅបំផ្លាញស្រទាប់អូហ្សូន និងធ្វើឱ្យសីតុណ្ហភាពកើនឡើង។ បន្ថែមពីលើ សម្លេងចេញពីមធ្យោបាយទាំងនោះក៏បានបង្កការរំខាន ភាពតានតឹង និងឈានដល់ការបាត់បង់ការស្តាប់លឺរបស់មនុស្សចំនួនតូចទៀតផង។ ការចោលកាកសំណល់រឹង និងការទុកដាក់សំរាមគ្មានសណ្តាប់ធ្នាប់របស់ទេសចរ នៅក្នុងតំបន់ដែលមានសកម្មភាពទេសចរណ៍ច្រើនជាបញ្ហាមួយទៀតដែលរុញច្រានឱ្យបរិស្ថានធម្មជាតិនៅតំបន់ទាក់ទាញមានការខូចខាត និងបាត់បង់សោភណ្ឌភាព។ ទន្ទឹមគ្នានេះដែរ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ រួមមាន សណ្ឋាគារ ភោជនីយដ្ឋានកន្លែងកម្សាន្ត ក៏ធ្វើឱ្យមានការបំពុលទឹកសមុទ្រ បឹងបួរ និង និងប្រភពទឹកផ្សេងៗ និងការរិចរិលដីនាំឱ្យបាត់បង់ជីវចម្រុះ និងជម្រកសត្វព្រៃធ្វើឱ្យប៉ះពាល់ដោយផ្ទាល់លើតំបន់ទេសចរណ៍[24]។

## ១.៧. បទពិសោធន៍បរទេសទាក់ទងនឹងការអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

[23] https://tourismteacher.com/social-impacts-of-tourism/#8-negative-social-impacts-of- tourism

[24] Ugur Sunlu, Environmental impacts of tourism (Turkey៖ Turkey, 2003), 263-270, https://om.ciheam.org/om/ pdf/a57/040019 77.pdf

ដោយសារតែវិស័យទេសចរណ៍បានក្លាយជាកាតាលីករយ៉ាងសំខាន់ក្នុងការស្វែងរកចំណូលជូនជាតិ និងប្រជាជនក្នុងស្រុក ទើបបណ្តាលឱ្យប្រទេសជាច្រើននៅទូទាំងសកលលោកចាប់ផ្តើមបង្កើតផែនការក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់គោលដៅជាពិសេសគឺរមណីយដ្ឋានបែបវប្បធម៌ប្រវត្តិសាស្ត្រ ដើម្បីឱ្យមានភាពរីកលូតលាស់ទៅមុខបន្តទៀត។ ខាងក្រោមនេះជាបទពិសោធន៍របស់ប្រទេសមួយចំនួនដែលទទួលបានភាពជោគជ័យនៅក្នុងការគ្រប់គ្រង រមណីយដ្ឋានទេសចរណ៍របស់ខ្លួនដែលប្រទេសផ្សេងគួរយកគម្រូតាម។

- **ប្រទេសហ្ស៊កដានី: ករណីឧទ្យានបុរាណវិទ្យា Petra**

Petra គឺជាគោលដៅទេសចរណ៍ដ៏ចាស់ចំណាស់មួយនៅក្នុងប្រទេសហ្ស៊កដានី ដែលត្រូវបានសាងសង់ឡើង នៅឆ្នាំ៣១២មុនគ.ស។ Petra ត្រូវបានគេទទួលស្គាល់ជាសកលថាជាតំបន់បែបវប្បធម៌ប្រវត្តិសាស្ត្រដ៏សំខាន់មួយ ដោយសារតែវប្បធម៌របស់វាមានទំនាក់ទំនងជាមួយនឹងអរិយធម៌ Nabataean ដែលជាអរិយធម៌ដែលនាំមុខ និងជោគជ័យបំផុតក្នុងយុគមាស (Golden Age)។ ភាពអស្ចារ្យនៃ Petra ស្ថិតនៅលើផ្ទៃរបស់ខ្សែរាជវង្សដ៏ឧឡារិក ស្ថាបត្យកម្មរបស់ប្រាសាទ ផ្លូវរូងក្រោមដី និងទំនប់សម្រាប់ស្តុកទឹកភ្លៀង និងកាកសំណល់សល់ពីសម័យបុរាណដូចជាវីទង់ដែង ព្រះវិហារ និងអគារសាធារណៈផ្សេងៗ។ គោលដៅទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រមួយនេះត្រូវបានចុះក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៨៥ ដោយអង្គការយូណេស្កូ (UNESCO)។ នៅក្រោមច្បាប់ជាតិហ្ស៊កដានី ឧទ្យានបុរាណវិទ្យា Petra នេះត្រូវបានការពារដោយនាយកដ្ឋានវត្ថុបុរាណ (Department of Antiquities) ដែលជាអង្គភាពមួយនៅក្រោមក្រសួងទេសចរណ៍ និងវត្ថុបុរាណ (Ministry for Tourism and Antiquities)។ ប៉ុន្តែជាទូទៅ ទំនួលខុសត្រូវក្នុងការរៀបចំផែនការ និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅកន្លែងនោះភាគច្រើនត្រូវបានធ្លាក់ទៅលើដៃរបស់អាជ្ញាធរអភិវឌ្ឍន៍ និងទេសចរណ៍តំបន់ Petra (PDTRA)។ បទប្បញ្ញត្តិ និងគោលនយោបាយទាំងនោះគ្របដណ្តប់លើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ការដាំដើមឈើ ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងឧទ្យានបុរាណ Petra និងការរៀបចំគម្រោងទាក់ទងនឹងកសិកម្មកែច្នៃទឹក។ លើសពីនេះ វិសោធនកម្មឆ្នាំ២០១៦ ក៏បានផ្តល់នូវស្វ័យភាពកាន់តែច្រើនទៅដល់អាជ្ញាធរ PDTRA ដើម្បីទាក់ទាញការវិនិយោគិនបរទេសមកវិនិយោគលើបរិក្ខារសម្រាប់ទេសចរណ៍ដូចជា ភោជនីយដ្ឋាន កន្លែងស្នាក់នៅ ហាងលក់ទំនិញ សួនច្បារ កន្លែងកម្សាន្ត ព្រមទាំងព្រឹត្តិការណ៍សាធារណៈ និងសកម្មភាពនានាក្នុងឧទ្យានផងដែរ។ ផងនោះដែរ ច្បាប់ទេសចរណ៍ដែលបានចុះក្នុងឆ្នាំ១៩៨៨ បានកំណត់កាតព្វកិច្ចរបស់ក្រសួងទេសចរណ៍ឱ្យចូលរួមក្នុងការផ្សព្វផ្សាយ រៀបចំ និងគ្រប់គ្រងសកម្មភាពទេសចរណ៍ ព្រមទាំងការពាររមណីយដ្ឋានទេសចរណ៍ និងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដើម្បីឱ្យពួកគេយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារសម្បត្តិធម្មជាតិឱ្យបានត្រឹមត្រូវ ជៀសពីការខូចខាតដែលបណ្តាលមកពីការធ្វេសប្រហែស

ដោយបង្ការណាមួយ។ ដោយសារតែចំនួនទេសចរត្រូវបានកើនឡើងជាលំដាប់ អាជ្ញាធរក្នុងតំបន់បានបញ្ជារឱ្យកងកម្លាំងប៉ូលីសទេសចរណ៍និងកងការពារជនស៊ីវិលហ្សកដានីឱ្យចុះយាមនៅក្នុងឧទ្យានដើម្បីធានានូវសុវត្ថិភាពទេសចរ[25]។

- **ប្រទេសនេប៉ាល់: ករណីតំបន់ Lumbini**

Lumbini ជាសម្បត្តិបេតិកភណ្ឌពិភពលោកដែលមានស្ថិតនៅក្នុងស្រុក Rupandehi នៃ Lumbini Zone ដែលមានទីតាំងនៅភាគខាងត្បូងនៃប្រទេសនេប៉ាល់។ កន្លែងនេះត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩៧ ថាជាកន្លែងដែលព្រះពុទ្ធសមណគោតម (Siddhartha Gautama) ប្រសូត។ ជាក់ស្តែងគំនិតនៃការកែប្រែ Lumbini ឱ្យក្លាយទៅជាគោលដៅថ្មីសម្រាប់ទេសចរបានផ្តួចផ្តើមឡើងតាំងពីឆ្នាំ១៩៦៧ នៅពេលដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក U Thant ដែលជាពុទ្ធសាសនិកអញ្ជើញមកពីប្រទេសមីយ៉ាន់ម៉ាមកទស្សនានៅ Lumbini ប៉ុន្តែផែនការអភិវឌ្ឍនេះទើបត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនេប៉ាល់ និងអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៧៨ ប៉ុណ្ណោះ។ នៅឆ្នាំ១៩៨៥ រាជរដ្ឋាភិបាលនេប៉ាល់បានបង្កើត Lumbini Development Trust ដែលជាស្ថាប័នស្វយ័តមានតួនាទីទទួលខុសត្រូវលើការអនុវត្តផែនការ អភិរក្ស និងផ្សព្វផ្សាយពី Lumbini និងទីតាំងព្រះពុទ្ធសាសនាផ្សេងៗនៅក្បែរនោះ។ ផែនការ Lumbini (Lumbini Master Plan) បានគ្របដណ្តប់លើផ្ទៃដី 1×3 ម៉ាយការ៉េ និងមានបីតំបន់។ តំបន់ទី១ គឺភូមិ Lumbini ថ្មី ដែលក្នុងនោះមានបរិក្ខារសម្រាប់បម្រើទេសចរណ៍ជាច្រើនដូចជា សណ្ឋាគារ តូបលក់អាហារ កន្លែងទិញឥវ៉ាន់ និងសារមន្ទីរ។ តំបន់ទី២ ហៅថា តំបន់វប្បធម៌ និងព្រះសង្ឃ ដែលតំបន់នេះតំណាងឱ្យចំណេះដឹង និងការបន្សុតវិញ្ញាណ ឯតំបន់ទី៣ ដែលជាតំបន់ពិសិដ្ឋបំផុត ព្រោះវាជាកន្លែងដែលព្រះពុទ្ធបានប្រសូត។ ក្រៅពីផែនការ Lumbini ក្រសួងវប្បធម៌ ទេសចរណ៍ និងអាកាសចរណ៍ស៊ីវិល (The Ministry of Culture, Tourism and Civil Aviation) របស់នេប៉ាល់ក៏បានអនុម័តផែនការទេសចរណ៍រយៈពេល១០ ឆ្នាំ ក្នុងគោលបំណងចង់ប្រែ Lumbini ឱ្យក្លាយទៅជាមជ្ឈមណ្ឌលទេសចរណ៍ និងធម្មយាត្រាលំដាប់ពិភពលោក។ គោលបំណងមួយដ៏សំខាន់នៃផែនការនេះ គឺការបង្កើនរយៈពេលស្នាក់នៅ និងការចំណាយរបស់ទេសចរ ដើម្បីជួយសម្របសម្រួលជីវភាពរស់នៅប្រចាំថ្ងៃរបស់សហគមន៍មូលដ្ឋាន។ បន្ថែមពីលើ ផែនការនេះក៏បានផ្តោតសំខាន់ក្នុងការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ អាកាសយានដ្ឋាន និងកន្លែងកម្សាន្តនានា ដើម្បីទាក់ទាញក្រុមហ៊ុនទេសចរណ៍ឱ្យរៀបចំកញ្ចប់ដំណើរកម្សាន្តមកកាន់ Lumbini។ អ្វីដែលគួរយកគំរូតាមនោះគឺស្ថាប័ន Lumbini

[25] United Nations Educational, Scientific and Cultural Organization, Petra World Heritage Site: INTEGRATED MANAGEMENT PLAN 2019 (Jordan៖ Jordan, 2019), 79-81, https://en.unesco.org/sites/default/files/petra_integrated_management_plan_1.pdf

Development Trust បានសហការជាមួយមូលនិធិសត្វព្រៃពិភពលោក (WWF) ក្នុងការបង្កើតផែនការ Lumbini បៃតង (Green Lumbini Initiative) ដើម្បីចូលរួមថែរក្សាប្រព័ន្ធអេកូឡូស៊ី អភិរក្សសត្វព្រៃ និងជម្រករបស់ពួកគេ។ មួយទៀត ផែនការនេះក៏បានសង្កត់យ៉ាងធ្ងន់លើការលើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយការទទួលខុស និងការយល់ដឹងរបស់ទេសចរ និងប្រជាជនក្នុងតំបន់ទាក់ទងនឹងផលប៉ះពាល់នានាដែលអាចបង្កការខូចខាតដល់បរិស្ថាន និងសង្គម[26]។

- **ប្រទេសចិន: ករណីមហាកំផែង Badaling**

មហាកំផែងនៅទីក្រុងប៉េកាំង (the Great Wall) ដែលជាកន្លែងទាក់ទាញបំផុតមួយនៅទូទាំងពិភពលោក គឺជានិមិត្តសញ្ញាដែលមានតម្លៃបំផុតសម្រាប់អត្តសញ្ញាណ និងវប្បធម៌ប្រវត្តិសាស្ត្រចិន។ The Great Wall ត្រូវបានគេចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូក្នុងឆ្នាំ១៩៨៧ ដោយសារតែភាពអស្ចារ្យនៃស្ថាបត្យកម្ម និងសារៈសំខាន់នៃប្រវត្តិសាស្ត្ររបស់វា។ មហាកំផែងនេះលាតសន្ធឹងប្រមាណ៦៧00 គីឡូម៉ែត្រពីច្រក Shanhaiguan នៅភាគឦសានដល់ច្រក Jiayuguan នៅភាគពាយព្យនៃប្រទេសចិន ដោយឆ្លងកាត់ខេត្ត Liaoning, Hebei, Beijing, Tianjin, Shanxi, Inner Mongolia, Ningxia, Shaanxi and Gansu។ គោលបំណងដំបូងនៃការស្ថាបនាមហាកំផែង គឺដើម្បីធ្វើជាបន្ទាយការពារឯករាជ្យរបស់រដ្ឋ Qin ប៉ុន្តែក្រោយមកវាក៏ក្លាយជាប្រព័ន្ធការពារដ៏សំខាន់សម្រាប់ប្រឆាំងនឹងសត្រូវភាគខាងជើង។ ដោយសារតែ Great Wall បានដើរតួយ៉ាងសកម្មក្នុងការពង្រីកវិស័យទេសចរណ៍ និងស្វែងរកចំណូលជាច្រើនអណោកជូនសេដ្ឋកិច្ចជាតិ វាបានជំរុញឱ្យថ្នាក់ដឹកនាំនៃប្រទេសចិនចាប់ផ្តើមយកចិត្តទុកដាក់លើការការរៀបចំផែនការអភិវឌ្ឍ ព្រមទាំងពង្រឹងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ដើម្បីផ្តល់ភាពងាយស្រួលដល់ទេសចរពេលមកដល់។ នៅក្នុងផែនការទេសចរណ៍រយៈពេល ៥ ឆ្នាំរបស់ប្រទេសចិនក៏មានបញ្ចូលនូវការគ្រប់គ្រងនិងអភិវឌ្ឍមហាកំផែង Badaling ដែលជាមហាកំផែងមួយនៃតំបន់ Great Wall ក្នុងទីក្រុងប៉េកាំង។ មហាកំផែង Badaling ជាផ្នែកមួយដំបូងគេដែលបានបើកឱ្យទេសចរចូលទស្សនា។ Badaling ស្ថិតនៅក្នុងសង្កាត់ Yanqing ដែលមានចម្ងាយប្រហែល ៦0គីឡូម៉ែត្រពីទីក្រុងប៉េកាំង និងមានប្រវែងសរុប ៧៤៤១ ម៉ែត្រ រាប់ចាប់ពីប៉មយាមខាងត្បូងទីដប់ប្រាំមួយដល់ប៉មយាមខាងជើងទីដប់ប្រាំបួន។ ប៉ុន្តែបច្ចុប្បន្នវាបើលត្រឹមតែ៣៧៤១ ម៉ែត្រប៉ុណ្ណោះឱ្យទេសចចូលទស្សនា គឺពីប៉មយាមខាងត្បូងទីប្រាំពីរដល់ប៉មយាមខាងជើងទីដប់ពីរ។ លក្ខណៈសំខាន់មួយរបស់ Badaling Great Wall គឺទីក្រុង Guan ដែលទីក្រុងនេះជាសំណង់ការពារមួយប្រភេទស្ថាបនាឡើងសម្រាប់គ្រប់គ្រងផ្លូវដឹកជញ្ជូនសំខាន់ៗនៅតំបន់ជុំវិញ។ នៅឆ្នាំ ១៩៨១ រាជរដ្ឋាភិបាលបានបង្កើតតំបន់ពិសេស Badaling (Badaling

[26] https://www.timetravelturtle.com/best-places-to-visit-lumbini-nepal/

Special Zone) ក្នុងគោលបំណងចង់ពង្រឹងការអភិរក្សសម្បត្តិបេតិកភណ្ឌ និងការអភិវឌ្ឍន៍ទិសដៅទេសចរណ៍តំបន់។ ទាក់ទងនឹងរចនាសម្ព័ន្ធនៃការគ្រប់គ្រង គេឃើញថាការគ្រប់គ្រង Badaling Great Wall ត្រូវបានធ្វើតាមឋានានុក្រម ពោលគឺចាប់ផ្តើមពីកម្រិតតំបន់ រហូតដល់រដ្ឋាភិបាលកណ្តាលនៃប្រទេស។ មិនតែប៉ុណ្ណោះអាជ្ញាធរគ្រប់កម្រិតថ្នាក់បានចូលរួមក្នុងការអភិវឌ្ឍន៍តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា ខ្សែកាបសម្រាប់ដឹកជញ្ជូនទេសចរឡើងទៅលើភ្នំ និងផ្លូវតភ្ជាប់ឡើងទៅលើភ្នំ។ ជាងនេះទៀត គ្រឿងបរិក្ខារសេវាកម្មមួយចំនួនក៏ត្រូវបានបង្កើតឡើងដែលក្នុងនោះមាន រោងមហោស្រព Great Wall Circle Vision ភោជនីយដ្ឋានហាងទំនិញ និងមជ្ឈមណ្ឌលកម្សាន្តនានាសម្រាប់បំពេញតម្រូវការទេសចរពេលមកដល់។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល និងមន្ទីរទេសចរណ៍ បេតិកភណ្ឌវប្បធម៌ និងការដឹកជញ្ជូនរបស់រដ្ឋាភិបាលក្រុងប៉េកាំងក៏បានយល់ព្រមក្នុងការបង្កើតគោលនយោបាយ និងបទប្បញ្ញត្តិសម្រាប់ការការពារវប្បធម៌ និងស្ថាបត្យកម្មប្រពៃណីរបស់ ស្រុក Badaling និងភូមិក្បែរនោះដូចជាភូមិ Chadao ផងដែរ[27]។

[27] Su, M. Ming, Preservation and Development at the Great Wall World Heritage Sites, China (Canada៖ Waterloo, 2009), 115-122, https://uwspace.uwaterloo.ca/bitstream/handle/10012/4989/Su_MingMing.pdf?sequence=1

# ជំពូកទី ២

# ស្ថានភាពទូទៅនៃទេសចរណ៍ខេត្តកំពង់ធំ

## ២.១. ស្ថានភាពទូទៅនៃខេត្តកំពង់ធំ

### ២.១.១. ទីតាំងភូមិសាស្ត្រ

ខេត្តកំពង់ធំជាខេត្តមានផ្ទៃដីធំទី២ និងមានចម្ងាយ ១៦៨គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ខេត្តនេះមានព្រំប្រទល់ជាប់ខេត្តសៀមរាបនៅភាគពាយព្យ ព្រះវិហារនៅភាគខាងជើង ស្ទឹងត្រែងនៅភាគឦសាន ក្រចេះនៅខាងកើត កំពង់ចាមនិងកំពង់ឆ្នាំងខាងត្បូង និងបឹងទន្លេសាបនៅភាគខាងលិច។ បច្ចុប្បន្ន ខេត្តកំពង់ធំមានទីរួមខេត្តឈ្មោះក្រុងស្ទឹងសែន និងមានផ្ទៃដីសរុបចំនួន១៥,០៦១គីឡូម៉ែត្រការ៉េ ហើយត្រូវបានចែកចេញជា ៨ស្រុក ៧៣ឃុំ ៨សង្កាត់ និង៧៦៧ភូមិ ដែលមានមានប្រជាពលរដ្ឋសរុបចំនួន៨៣៩,៩៩១នាក់ ស្មើនឹង ១៧៧,៧២៨ គ្រួសារ និងមានដង់ស៊ីតេប្រជាពលរដ្ឋ ៥៥នាក់/គ.ម$^{២}$។ ខេត្តនេះត្រូវបានបែងចែកជាពីរសណ្ឋានដីគឺ តំបន់ខាងក្រោមផ្លូវជាតិលេខ៦ ដែលជាតំបន់វាលទំនាបលាតសន្ធឹងរហូតដល់មាត់បឹងទន្លេសាប និងតំបន់ខាងក្រោមផ្លូវជាតិលេខ៦ដែលជាតំបន់ខ្ពង់រាប[28]។

ខេត្តកំពង់ធំ គឺជាខេត្តដ៏ចាស់ចំណាស់មួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជារាជធានីដ៏មានឥទ្ធិពលមួយនៅអាស៊ីអាគ្នេយ៍ក្នុងសម័យហ្វូណន។ បន្ទាប់មកនៅក្នុងសម័យបារាំងគ្រប់គ្រង ខេត្តនេះបានក្លាយជាកន្លែងរស់នៅរបស់មនុស្សមួយក្រុមធំដែលមានឈ្មោះថា "**ស្មៀង**" ប៉ុន្តែក្រុមនេះត្រូវបានរួបបញ្ចូលជាមួយប្រជាជនខ្មែរតាំងពីយូរយារណាស់មកហើយ។ ជាក់ស្តែង ឈ្មោះដើមរបស់ខេត្តកំពង់ធំ គឺកំពង់ពស់ធំ ព្រោះតាំងពីយូរយារណាស់មក ហើយប្រជាជនក្នុងតំបន់តែងតែប្រទះឃើញពស់ធំមួយគូវារចេញពីរូងភ្នំនៅជាប់នឹងមាត់ទន្លេស្ទឹងសែននារៀងរាល់ថ្ងៃបុណ្យពុទ្ធសាសនាជាពិសេសថ្ងៃសីល។ ពេលវេលាក្រោយមក សត្វពស់នោះក៏បានបាត់ខ្លួន ហើយអ្នកស្រុករស់នៅតំបន់នោះបានហៅតំបន់នោះថា កំពង់ពស់ធំ ប៉ុន្តែពេលក្រោយមក គេបាននិយាយបង្រួមពាក្យមកត្រឹមកំពង់ធំវិញ។

ចំពោះជំនឿសាសនា សាសនាដែលលេចធ្លោជាងគេនៅកម្ពុជាគឺព្រះពុទ្ធសាសនា (៩៧%) បន្ទាប់មកគឺសាសនាឥស្លាម (២%) និងសាសនាផ្សេងទៀត (០,៨%)។ សាសនាផ្សេងទៀតភាគច្រើនសំដៅទៅលើប្រព័ន្ធសាសនានៃក្រុមកុលសម្ព័ន្ធតំបន់ខ្ពង់រាប និងជាតិភាគតិចមួយចំនួនមកពីប្រទេសផ្សេង។ សម្រាប់ខេត្តកំពង់ធំបើយោងតាមរបាយការណ៍ជាតិ អ្នកកាន់ព្រះពុទ្ធសាសនាមានរហូតដល់ ៩៨,៦% សាសនាឥស្លាម ១% និងសាសនាគ្រីស្ត ០,៣%។ ប្រជាជនទាំងនោះខ្លះប្រកបមុខរបរតាមបែបប្រពៃណីដូចជា ធ្វើស្រែចំការ រុក្ខាប្រមាញ់

[28] រដ្ឋបាលខេត្តកំពង់ធំ "ស្ថានភាពទូទៅ និងសក្តានុពលរបស់ខេត្តកំពង់ធំ", ២០២១

នៃសាទត្រី ចិញ្ចឹមសត្វ ឬដាំដំណាំ ខ្លះបម្រើការងារក្នុងវិស័យសំខាន់ៗរួមមាន ទេសចរណ៍ វាយនភណ្ឌ សេដ្ឋកិច្ច រីឯខ្លះទៀតបើកសិប្បកម្ម ឬអាជីវកម្មផ្ទាល់ខ្លួន ដើម្បីផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ និងនាំចេញទៅក្រៅប្រទេស។

ខេត្តកំពង់ធំសម្បូរធនធានធម្មជាតិដ៏មានតម្លៃជាច្រើនរួមមាន៖ ដីមានជីវជាតិដ៏ធំលាតសន្ធឹងដែលសមប្រកបបំផុតសម្រាប់ការដាំដំណាំភោគផលដូចជាកៅស៊ូ ស្វាយចន្ទី និងដំឡូងមី ធនធានជលផលដែលបានមកពីបឹងទន្លេសាប ព្រមទាំងរ៉ែធម្មតាយ៉ាងច្រើនប្រភេទ ដែលអាចយកមកផលិតសម្ភារៈសំណង់ដូចជា ថ្មបាយក្រៀម ថ្មម៉ាប ថ្មក្រានីត ថ្មកំបោរ ក្រួស និងខ្សាច់[29]។

## ២.១.២. វិស័យអទិភាពរបស់ខេត្ត

**វិស័យកសិកម្ម** ជាកាតាលីករយ៉ាងសំខាន់ និងធំជាងគេក្នុងការលើកតម្កើងសេដ្ឋកិច្ចជាតិ ដើម្បីឈានទៅរកការអភិវឌ្ឍបន្ថែមនៅក្នុងប្រទេស។ យោងតាមប្រសាសន៍របស់លោក ប៉ែន វណ្ណរិទ្ធ ដែលជាប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំបានឱ្យដឹងថាពីឆ្នាំ២០២១-២០២២ ប្រជាកសិករក្នុងខេត្តបានប្រមូលស្រូវប្រាំងបានសរុប៦៥,៤២៥ហិកតា ដែលលទ្ធផលនេះបានលើសគោលដៅខេត្តជាង ១៥០ ភាគរយ។ ក្រៅពីស្រូវប្រាំង លោក វណ្ណរិទ្ធ បានបន្ថែមថា កសិករនៃខេត្តកំពង់ធំក៏ទទួលបាននូវភាពជោគជ័យនៅក្នុងការដាំដំណាំបន្លែ ផ្លែឈើ និងសណ្តែកផ្សេងៗជាច្រើនមុខ។ នេះស្តែងឱ្យឃើញអំពីគុណសម្បត្តិរបស់វិស័យកសិកម្ម ដោយសារតែវាជាកត្តាជំរុញដ៏ចាំបាច់ក្នុងការលើកស្ទួយជីវភាពប្រចាំថ្ងៃរបស់ប្រជាកសិករក្រីក្រនៅតំបន់ជនបទ ព្រមទាំងធានានូវសន្តិសុខស្បៀង អាហារសម្រាប់ផ្គត់ផ្គង់ឱ្យប្រជាជនទាំងអស់នៅក្នុងប្រទេស និងនាំចេញទៅប្រទេសមួយចំនួនដែលជាដៃគូពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជាដូចជា សហរដ្ឋអាមេរិក បណ្តាប្រទេសអាស៊ាន ចិន ជប៉ុន ព្រមទាំងចក្រភពអង់គ្លេស[30]។

**វិស័យអប់រំ** មន្ត្រីពាក់ព័ន្ធដែលបម្រើការក្នុងខេត្តកំពង់ធំទាំងអស់សុទ្ធសឹងតែបានទទួលការអប់រំ និងបណ្តុះបណ្តាលជាប្រចាំ ដើម្បីឱ្យការបំពេញការងារ ការដឹកនាំ ការគ្រប់គ្រង និងការអភិវឌ្ឍអាចធ្វើទៅបានយ៉ាងរលូន និងមានឱកាសជោគជ័យច្រើនជាងមុន។ លើសពីនេះទៀត ប្រជាពលរដ្ឋជាពិសេសបុគ្គលិក និងអាជីវករបម្រើសេវាកម្មជូនទេសចរក្នុងខេត្តក៏បានទទួលការអប់រំដែរ ដោយការប្រជុំអប់រំនោះផ្តោតសំខាន់លើសុវត្ថិភាពចំណីអាហារ បដិសណ្ឋារកិច្ច និងការថែរក្សាបរិស្ថានក្នុងន័យទប់ស្កាត់ការទុកដាក់សម្រាមគ្មានសណ្តាប់ធ្នាប់ដែលអាចប៉ះពាល់ដល់គុណភាពទឹក។

---

[29] http://nis.gov.kh/nis/Census2019/Final%20General%20Population%20Census%202019-English.pdf

[30] https://www.khmertimeskh.com/501021335/kampong-thom-farmers-cultivation-of-rice-surpasses-target/

**វិស័យទេសចរណ៍** ជាវិថីដ៏សំខាន់ក្នុងការស្រូបយកថវិការចូលស្រុក ដើម្បីចូលរួមស្ដាបនានូវគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសក៏ដូចជាបង្កើតឱកាសការងារទៅដល់ប្រជាជនក្នុងតំបន់ដែលអាចចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺខុសពីវិស័យផ្សេងៗ ការងារក្នុងវិស័យទេសចរណ៍បានបើកចំហរឱ្យប្រជាជនមកពីគ្រប់មជ្ឈដ្ឋាន ទាំងជនពិការដែលងាយរងគ្រោះ ជនជាតិភាគតិច ស្ត្រី និងយុវជនដែលនេះជាជំហានដ៏សំខាន់ក្នុងការកាត់បន្ថយ និងបង្រួមគម្លាតវិសមភាពនៃប្រាក់ចំណូលរវាងប្រជាជនទាំងឡាយក្នុងប្រទេស។ លំហូមិនឈប់ឈររបស់ទេសចរទាំងជាតិនិងអន្តរជាតិក៏បានជំរុញឱ្យកើតមាននូវសន្តិភាពក្នុងខេត្ត ដោយសារតែវាជួយលើកកម្ពស់ការអត់ឱនរវាងប្រជាជនម្ចាស់ស្រុកនិងទេសចរ និងការស្វែងយល់អំពីវប្បធម៌របស់គ្នាទៅវិញទៅមក។

យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារទេសចរណ៍ប្រចាំឆ្នាំ២០២១ បានឱ្យដឹងថា៖ នៅឆ្នាំ២០២១ ខេត្តកំពង់ធំមានទេសចរសរុបចំនួន ៦៤,៧១០នាក់ បើប្រៀបនឹងចំនួនទេសចរប្រចាំឆ្នាំ២០២០ កន្លងមកមានចំនួនសរុបចំនួន ១៤៨,០៦៥នាក់ ដែលមានការថយចុះរហូតដល់ ៥៦,៣០%។

នៅក្នុងឧស្សាហកម្មទេសចរណ៍ កន្លែងបម្រើទេសចរណ៍ដែលបានចុះអាជ្ញាប័ណ្ណទេសចរណ៍ ព្រមទាំងបញ្ជូនឯកសារ ស្នើសុំទៅកាន់ក្រសួងទេសចរណ៍ខេត្តកំពង់ធំមានចំនួន ១៩១ ទីតាំងដូចខាងក្រោម៖

ក. រមណីយដ្ឋាន ចំនួន២ទីតាំង និងមានបុគ្គលិកចំនួន ៣៧នាក់ ស្រី ១៤នាក់

ខ. សណ្ឋាគារ ចំនួន៨ទីតាំង មានចំណុះ៣០៩បន្ទប់ និងមានបុគ្គលិកចំនួន ៦៤នាក់ ស្រី ៤២នាក់

គ. ផ្ទះភ្ញៀវ ចំនួន៥៣ទីតាំង មានចំណុះ៨៥៦បន្ទប់ និងមានបុគ្គលិកចំនួន ១៤៥នាក់ ស្រី ១០៥នាក់

ឃ. ភោជនីយដ្ឋានអាហារ ចំនួន៥២ទីតាំង មានចំណុះ៣,០៤៩កៅអី និងមានបុគ្គលិកសរុបចំនួន ៣១៣នាក់ ស្រី ២២១នាក់

ង. ម៉ាស្សាសុខភាព ចំនួន៥ទីតាំង មានចំណុះ២៨គ្រែ និងមានបុគ្គលិកសរុបចំនួន ១២នាក់ ស្រី ១២នាក់

ច. ខារ៉ាអូខេ ចំនួន១៣ទីតាំង មានចំណុះ៨៤បន្ទប់ និងមានបុគ្គលិកសរុបចំនួន ៧៨នាក់ ស្រី ៦១នាក់

ឆ. ហាងលក់គុយទាវកាហ្វេ ចំនួន២៤ទីតាំង មានចំណុះ៨៦៨កៅអី និងមានបុគ្គលិកសរុបចំនួន ៥៨នាក់ ស្រី ៥០នាក់

ជ. ផ្ទះជួលបន្ទប់ស្នាក់នៅ ចំនួន២៧ទីតាំង មានចំណុះ២០៩បន្ទប់

ឈ. កីឡាស្នូកឃ័រ ចំនួន៧ទីតាំង មានចំណុះ៣២តុ និងមានបុគ្គលិកសរុបចំនួន ១១នាក់ ស្រី ០៨នាក់[31]។

## ២.២. ស្ថានភាពទេសចរណ៍ខេត្តកំពង់ធំ

ដោយស្ថិតនៅចំកណ្តាលរវាងខេត្តសៀមរាប ព្រះវិហារ ស្ទឹងត្រែង ក្រចេះ និងបឹងទន្លេសាបនៅភាគខាងលិច ដូចនេះខេត្តកំពង់ធំទទួលបានអំណោយផលធម្មជាតិជាច្រើនបើប្រៀបទៅនឹងខេត្តផ្សេងៗទៀត។ ដូចដែលបានឃើញ មិនត្រឹមតែខេត្តនេះសម្បូរទៅដោយធនធានធម្មជាតិដូចជា ដីដ៏មានជីវជាតិដែលអាចជួយដល់ការដាំដុះប៉ុណ្ណោះទេ តែវាក៏សម្បូរទៅដោយធនធានវប្បធម៌ប្រវត្តិសាស្ត្រដូចជា ប្រាង្គប្រាសាទបុរាណ សំណង់ចាស់ៗ ភស្តុតាងដែលនៅសល់តាំងពីបុរាណកាល ព្រមទាំងតំបន់ទេសចរណ៍ដ៏ស្រស់សោភាជាច្រើនកន្លែងដែលទាក់ទាញចំណាប់អារម្មណ៍ ទេសចរឱ្យមកកាន់ខេត្តកំពង់ធំជារៀងរាល់ឆ្នាំ។ បន្ថែមពីនេះទៀត ខេត្តនេះក៏មានផលិតផលទេសចរណ៍ដទៃទៀត ដែលដើរតួយ៉ាងសំខាន់ក្នុងការបំពេញតម្រូវការរបស់ទេសចរនៅពេលមកដល់ដែលក្នុងនោះមាន ហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាព បរិស្ថាន និងបដិសណ្ឋារកិច្ចរបស់ប្រជាពលរដ្ឋម្ចាស់ស្រុក។

### ២.២.១. សក្តានុពលទេសចរណ៍ខេត្តកំពង់ធំ

ខេត្តកំពង់ធំ គឺជាខេត្តមួយក្នុងចំណោមខេត្តមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលមានសក្តានុពលទេសចរណ៍យ៉ាងខ្លាំងក្លាក្នុងការទាក់ទាញទេសចរទាំងជាតិ និងអន្តរជាតិឱ្យឈានមកចូលទស្សនាជារៀងរាល់ឆ្នាំ។ ក្នុងខេត្តនេះមានរមណីយដ្ឋានទេសចរណ៍ជាច្រើនដូចជា៖

**ប្រាសាទគុកនគរ៖** ប្រាសាទនេះជាតំបន់ប្រាសាទដ៏ធំបំផុត និងត្រូវបានថែរក្សាយ៉ាងល្អបំផុតរបស់ខេត្តកំពង់ធំបន្ទាប់ពីប្រាសាទសំបូរព្រៃគុក។ ប្រាសាទគុកនគរស្ថិតនៅក្នុងទីតាំងវត្តគុហ៍នគរខាងលិចទីប្រជុំជនតាំងគោកក្នុងភូមិត្រដក់ពង ឃុំពង្រ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ដើម្បីទៅដល់ទីនោះ ទេសចរអាចធ្វើដំណើរដោយយានជំនិះគ្រប់ប្រភេទតាមផ្លូវជាតិលេខ៦ បន្ទាប់មកបត់ខាងលិចតាមបណ្តោយខ្លោងទ្វារវត្តគុហានគរក្នុងចម្ងាយប្រមាណជា២គីឡូម៉ែត្រ។ ប្រាសាទនេះមានចម្ងាយ៧៩គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ ដែលត្រូវការពេលវេលា ១ម៉ោង ១០នាទី បើគេធ្វើដំណើរពីរង្វង់មូលស្គន់ គេត្រូវចំណាយពេលប្រហែល ៣០នាទី ក្នុងចម្ងាយផ្លូវ២៥គីឡូម៉ែត្រ ប៉ុន្តែបើគេចេញដំណើរពីទីក្រុងភ្នំពេញវិញ គេត្រូវប្រើពេលយ៉ាងតិច ២ម៉ោង ដោយសារតែវាមានចម្ងាយរហូតដល់ ១០៥គីឡូម៉ែត្រ។ រមណីយដ្ឋាននេះត្រូវបានកសាងឡើងលើដីរាបស្មើលើខឿនតែមួយដែលធ្វើអំពីថ្មបាយក្រៀម និងថ្មភក់។ ប្រាសាទនេះបានស្ថាបនាក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ ក្នុងសតវត្សរ៍ទី១១តាម

[31] មន្ទីរទេសចរណ៍កំពង់ធំ "របាយការណ៍បូកសរុបលទ្ធផលការងារទេសចរណ៍ប្រចាំឆ្នាំ២០២១" ២០២២

រចនាបថឃ្លាំង និងបែរមុខទៅទិសខាងកើត ព្រមទាំងមានកំពែងព័ទ្ធជុំវិញលាតសន្ធឹងពីកើតទៅលិច។ នៅក្នុងប្រាសាទនេះ គេបានឃើញជញ្ជាំងព័ទ្ធជុំវិញ បណ្ណាល័យ និងទីសក្ការៈបូជាជាច្រើនកន្លែងដូចជាៈ ផ្ទាំងថ្មភក់ដែលពណ៌នាព្រះឥន្ទ្រលើដំរីក្បាលបីរបស់ព្រះអង្គ បល្ល័ង្កមានរាងការ៉េធ្វើអំពីថ្មភក់ និងលម្អដោយផ្កាឈូក រូបសំណាកបុរសឈរនៅសល់តែពីភ្លៅដល់ស្មា និងរូបសំណាកបុរសអ្នកស្រុកហៅថា អ្នកតាបាក់ក។ ប្រាសាទនេះត្រូវបានកសាងឡើងក្នុងគោលបំណងឧទ្ទិសថ្វាយដល់ព្រះសិវៈ ប៉ុន្តែមកដល់បច្ចុប្បន្នវាត្រូវបានឈរជើងនៅក្នុងបរិវេណវត្តពុទ្ធសាសនា។ ប្រាសាទនេះបានទាក់ទាញទេសចររាប់ពាន់នាក់ឱ្យទៅទស្សនា ដោយសារតែរចនាសម្ព័ន្ធ និងភស្តុតាងដែលបានបន្សល់មកតាំងពីសម័យបុរាណមក[32]។

**ភ្នំសន្ទុក**៖ ភ្នំនេះស្ថិតនៅភូមិកកោះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។ គេអាចទៅដល់រមណីយដ្ឋាននេះតាមផ្លូវជាតិលេខ៦ ហើយវាមានចម្ងាយ១៧គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំស្មើនឹង ៣០នាទីនៃការធ្វើដំណើរ។ បើគេធ្វើដំណើរពីរាជធានីភ្នំពេញ តំបន់ទេសចរណ៍ធម្មជាតិនិងវប្បធម៌មួយកន្លែងនេះមានចម្ងាយប្រមាណជា ១៥០គីឡូម៉ែត្រ ដែលត្រូវការថេរវេលាប្រមាណជា៣ម៉ោង ហើយនៅពេលទៅដល់ក្លោងទ្វារមានរូបប្រាសាទកំពូលបី និងខាងឆ្វេងដៃមានស្លាកសញ្ញាជាអក្សរថា "រមណីយដ្ឋានភ្នំសន្ទុក" គេត្រូវជិះចូលប្រមាណ ២០០០ ម៉ែត្រទើបទៅដល់ភ្នំសន្ទុក។ ពេលមកដល់ជើងភ្នំ គេមានជម្រើសពីរក្នុងការឡើងទៅលើកំពូលភ្នំសម្រាប់ឱ្យទេសចរជ្រើសរើស។ របៀបទី១ គេអាចធ្វើដំណើរដោយបើកបរយានយន្ត ឬម៉ូតូផ្ទាល់ខ្លួនឡើងតាមផ្លូវក្រវិចក្រវៀនតាមចង្កេះភ្នំរហូតដល់កំពូលភ្នំតាមរយៈថ្នល់ចាក់បេតុងយ៉ាងមាំ និងមានចំណតយានយន្តដ៏ធំទូលាយសម្រាប់ចត។ រីឯរបៀបទី២វិញគឺ ទេសចរអាចដើរឡើងតាមកាំជណ្តើរពីរជើងភ្នំដល់កំពូលភ្នំ ដែលកាំជណ្តើរសរុបមានចំនួន៨០៩កាំ ហើយកាំជណ្តើរខ្លះទាប កាំជណ្តើរខ្លះខ្ពស់ អាស្រ័យតាមកន្លែងនីមួយៗ ប៉ុន្តែជណ្តើរទាំងនោះសុទ្ធតែមានបង្កាន់ដៃអមតាមផ្លូវ ដើម្បីធានាសុវត្ថិភាពជូនទេសចរ ក៏ដូចជាអាជីវករទាំងឡាយដែលត្រូវឆ្លងកាត់ជណ្តើរនោះ ដើម្បីជញ្ជូនទំនិញ។ ពេលឡើងដល់កំពូលភ្នំ ទេសចរនឹងឃើញ រូបព្រះពុទ្ធបដិមា ដែលធ្វើឡើងពីថ្មភ្នំជាមួយនឹងឥរិយាបថចូលព្រះនិព្វាន និងមានប្រវែងជាង១០ម៉ែត្រ។ ក្រៅពីនេះក៏មានរូបចម្លាក់ព្រះពុទ្ធរូបដទៃទៀត ដែលហាក់ដូចជាផុសចេញពីថ្មភ្នំអញ្ចឹង ដែលរូបទាំងនោះត្រូវបានគេសិក្សាថាសាងសង់ឡើងក្នុងរាជ្យព្រះបាទ ព្រះពញាធម្មរាជា អំឡុងឆ្នាំ១៤៧៤-១៤៩៤ មកម្ល៉េះ។ ផងនោះដែរ លើកំពូលភ្នំក៏មានប្រាសាទតេជោក្រហមក ដែលជាប្រាសាទដ៏ល្បីស័ក្តិសិទ្ធិតាមបែបប្រវត្តិសាស្ត្រ និងអប្បិយជំនឿមួយ ដែលតែងតែមានអ្នកមកបន់ស្រន់ឱ្យរកស៊ីមានបានប្រលងជាប់ និងសុំកូនជាហូរហែ ព្រោះការប្រាថ្នាទាំងអស់នោះភាគ

[32] https://www.tourismcambodia.com/travelguides/provinces/kampong-thom/what-to-see/179_prasat-kuhak-nokor.htm

ច្រើនបានសម្រេចដូចបំណងមែន។ លើសពីនេះទៀត លើភ្នំសន្ទុកនេះមាន អណ្តូងផ្សងព្រេង កន្លែងបោះកាក់ ព្រះវិហារ ប្រាសាទថ្មអណ្តែត ព្រមទាំងសំណង់បុរាណដូចជា ចេតិយព្រះធម្មរាជាជាដើម។ ជាទូទៅ នៅពេលមានពិធីបុណ្យផ្សេងៗ និងថ្ងៃឈប់សំរាកនានា ប្រជាជនតែងតែនាំគ្នាទៅ ដើរកំសាន្តនៅទីនោះ លក្ខណៈជាក្រុមគ្រួសារ ឬមិត្តភក្តិ ដោយសារតែភ្នំនេះជាភ្នំដ៏ពិសិដ្ឋបំផុតនៅក្នុងខេត្តកំពង់ធំ និងជារមណីដ្ឋានដែលមានធម្មជាតិ និងសត្វរាប់រយប្រភេទដែលប្រជាពលរដ្ឋ និងទេសចរអាចគយគន់បាន[33]។

**ប្រាសាទគោករកា៖** ប្រាសាទនេះស្ថិតនៅភូមិរកាខ្ពស់ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ និងមានចម្ងាយប្រមាណ១៤គីឡូម៉ែត្រ ដែលទាមទារត្រឹមតែ២០នាទីប៉ុណ្ណោះដើម្បីទៅដល់។ ប្រាសាទនេះត្រូវបានសាងសង់អំពីថ្មភក់ និងថ្មបាយក្រៀមក្នុងរចនាបថឃ្លាំង នៅចុងសតវត្សទី១១ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ ដើម្បីឧទ្ទិសថ្វាយដល់ព្រះសិវៈ។ រមណីយដ្ឋានបែបវប្បធម៌ប្រវត្តិសាស្ត្រនេះមានទំហំ ៦ម៉ែត្រx៥ម៉ែត្រ និងកម្ពស់ ៨ម៉ែត្រ ត្រូវបានសាងសង់នៅលើភ្នំ ហើយបែរមុខទៅទិសខាងកើត ឯតួប្រាសាទកណ្តាលមានទម្រង់រាងសាជី មានរានហាលបើកទៅទិសខាងកើត ហើយទ្វារចូលពីច្រកចូលខាងកើត។ ដោយផ្អែកលើការសិក្សា ប្រាសាទនេះត្រូវបានបង្កើតឡើងជារាងចតុកោណ និងមានកំពែងខាងក្រៅដែលមានទំហំ ២៥ម៉ែត្រx២៥ម៉ែត្រ ព្រមទាំងមានគោបុរៈនៅគ្រប់ទិសទាំងបួន។ មិនត្រឹមតែប៉ុណ្ណោះ នៅខាងក្រៅកំពែងក៏មានប្រឡាយព័ទ្ធជុំវិញផងដែរ ហើយគេក៏សម្គាល់ឃើញថាមានផ្ទាំងថ្ម សិលាចារឹក និងធ្នឹមមានរចនាបថផ្សេងៗនៅជុំវិញប្រាសាទនេះ។ បើយោងតាមសម្តីរបស់ប្រជាពលរដ្ឋក្នុងតំបន់បាននិយាយថា នេះមកពីក្នុងសម័យអាណានិគមបារាំង ពួកបារាំងបាននាំយកវត្ថុបុរាណទាំងនេះពីប្រាសាទផ្សេងៗមកប្រមូលផ្តុំនៅទីនេះ ក្នុងគោលបំណងបំបែកជាផ្នែកតូចៗ និងយកមករៀបចំធ្វើជាផ្លូវសម្រាប់ចូលក្នុងប្រាសាទ ប៉ុន្តែមិនទាន់បានសាងសង់ផងប្រទេសក៏ត្រូវធ្លាក់ចូលក្នុងភ្លើងសង្គ្រាម។ តាមការសិក្សារបស់ប្រវត្តិវិទូបានឱ្យដឹងថា នៅលើភ្នំចម្ងាយ១គីឡូម៉ែត្រពីប្រាសាទជាកន្លែងដែលគេរៀបចំធ្វើពិធីនាសម័យមុន ដោយពាក់កណ្តាលអធ្រាត្ររៀងរាល់ថ្ងៃពេញបូណ៌មី គេតែងឱ្យស្រីព្រហ្មចារីរាំជុំវិញកន្លែងដុតភ្លើងដើម្បីបួងសួងសុំទឹកភ្លៀង ហើយពិធីនេះអាចចូលរួមបានតែនារីព្រហ្មចារីតែប៉ុណ្ណោះ[34]។

**ជម្រកសត្វស្លាបនៃបឹងទន្លេឆ្មា៖** បឹងឆ្មារមានឡូត៍នេសាទលេខ៥ និងឡូត៍លេខ៦ ហើយមានចម្ងាយ ៣០គីឡូម៉ែត្រពីទីរួមស្រុកស្ទោង ខេត្តកំពង់ធំ។ ដែនជម្រកសត្វព្រៃបឹងឆ្មាមានផ្ទៃដី ៤០០ ហិកតា មានបណ្តាញប្រឡាយទឹកតភ្ជាប់គ្នាតាមមាត់បឹងបឹងខ្លា ដែលសម្បូរទៅដោយព្រៃលិចទឹក។ តំបន់នេះតភ្ជាប់ដោយដៃទន្លេធំៗ ចំនួនពីរស្ទោង និងស្ទឹងជីក្រែង។ បឹងទន្លេឆ្មាជាជម្រកសត្វស្លាបច្រើនប្រភេទរួមមាន សត្វ ត្រដក់ សត្វ ក្រៀល

33 https://news.sabay.com.kh/article/894714

34 https://www.smartsinntravel.com/attraction-detail.html?name=prasat-kok-rokar-sart-sinn-travel

ទុង កុក ក្អែក ទឹក ននៀល ត្រយង់ ខ្យង ជាដើម។ ដោយសារតែភាពសម្បូរបែបនៃធនធានធម្មជាតិដូចជា សត្វស្លាប ព្រៃព្រឹក្សាដុះនៅជុំវិញបឹងនោះហើយ វាបានទាក់ទាញទេសចរជាតិ និងអន្តរជាតិជាច្រើនឱ្យមកទស្សនា ដើម្បីបានស្គាល់ និងឃើញនូវទេសភាពដ៏អស្ចារ្យមួយនេះ។ ប៉ុន្តែបច្ចុប្បន្ន អាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងតំបន់កំពុងតែមានភាពព្រួយបារម្ភ ដោយសារតែគេបានកត់សម្គាល់ឃើញថាចំនួនសត្វស្លាបមានការធ្លាក់ចុះយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ឯតំបន់ព្រៃលិចទឹកវិញគឺត្រូវបានឆាបឆេះអស់ប្រមាណជាង២០០ហិកតា ដោយសារតែអាកាសធាតុក្តៅខ្លាំង ព្រមទាំងសកម្មភាពធ្វេសប្រហែសពីសំណាក់ពលរដ្ឋរស់នៅតំបន់នោះ។ កត្តានេះបានធ្វើឱ្យមន្ត្រីពាក់ព័ន្ធ និងប្រជាជនក្នុងតំបន់ចាប់ផ្តើមស្វះស្វែងរកវិធានការ ដើម្បីជួយទប់ស្កាត់ករណីភ្លើងឆេះព្រៃលិចទឹកក្នុងតំបន់នេះ ពីព្រោះភ្លើងឆេះព្រៃអាចនឹងបណ្តាលឱ្យប៉ះពាល់ដល់ជម្រកត្រី និងជម្រករបស់សត្វស្លាប[35]។

**ប្រាសាទភូមិប្រាសាទ៖** ប្រាសាទនេះស្ថិតនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ២៩គីឡូម៉ែត្រខាងត្បូងទីរួមខេត្តកំពង់ធំ។ ប្រសិនបើគេធ្វើដំណើរពីស្ទូន់វិញ វាមានចម្ងាយប្រហែល៦៣គីឡូម៉ែត្រ និងត្រូវប្រើពេលប្រហែល១ម៉ោង ដោយពេលមកដល់ គេនឹងឃើញក្លោងទ្វារចូលមួយស្ថិតនៅខាងឆ្វេងដៃដែលមានពណ៌ផ្កាឈូក និងមានរូបតោពីរឈរយាមអមសងខាងផ្លូវចូល ហើយខាងលើមានឈ្មោះថា វត្តប្រាសាទ។ សម្រាប់ផ្លូវចូលទៅក្នុងប្រាសាទភូមិប្រាសាទវិញមានចម្ងាយ ៥០០ ម៉ែត្រតែប៉ុណ្ណោះ។ ប្រាសាទនេះត្រូវបានសាងសង់ឡើងពីឥដ្ឋកំបោរ និងថ្មភក់ក្នុងសតវត្សទី៨ ព្រមទាំងមានរចនាបទកំពង់ព្រះ ដើម្បីឧទ្ទិសថ្វាយដល់ព្រះសិវៈ។ ប្រាសាទនេះមានរាងបួនជ្រុងទ្រវែង បែរមុខទៅទិសខាងកើតអមដោយបដិមាតោពីរនៅយាមខាងមុខ ហើយត្រូវបានសង់នៅលើផ្ទៃរាបស្មើ និងគ្មានទ្វារក្លែងក្លាយដែលជាទ្វារបញ្ឆោតដូចប្រាសាទដទៃទៀតទេ។ តែផ្ទុយទៅវិញ វាមានទ្វារធ្វើដោយក្តារឈើពីរ ដោយមួយឆ្លាក់ដោយរូបចម្លាក់ទេវៈបុរស និងមួយទៀតឆ្លាក់ដោយទេវៈស្រី ឯទ្វារស៊ុមខាងត្បូងត្រូវបានចារឹកដោយសិលាចារឹកប្រាំជួរ តែផ្នែកខាងក្រោយរបស់វាភាគច្រើនខូចខាត។ នៅសម័យបុរាណ កន្លែងនេះគឺជាអតីតព្រះបរមរាជវាំងដែលរក្សាទុកនូវវត្ថុដ៏មានតម្លៃ បន្ទាប់មកវាត្រូវបានគេជីកកកាយ និងលួចយកទៅមួយចំនួនក្នុងសម័យអាណានិគមបារាំង។ ក្រៅពីប្រាសាទនេះ គេក៏បានប្រទះឃើញសិលាចារឹកមួយដែលគេកប់ក្នុងដី ដែលផ្នែកខាងលើរបស់វាត្រូវបានចារជាអក្សរសំស្ក្រឹតចំនួនប្រាំមួយជួរ។ ប្រាសាទនេះស្ថិតក្នុងស្ថានភាពខូចខាតយ៉ាងធ្ងន់ធ្ងរ ហើយក្នុងឆ្នាំ១៩៩៦ ឥដ្ឋនៃប៉មខាងត្បូង និងខាងលិចបានធ្លាក់ចុះដោយសារដើមឈើដុះឡើង និងខ្យល់ខ្លាំងបក់មកលើ

[35] https://www.rfa.org/khmer/news/environment/birds-at-tonle-chhmar-lake-05042016045217.html

ប៉មទាំងនោះ។ ដូច្នេះហើយមិនសូវមានទេសចរមកទស្សនានៅប្រាសាទនេះទេ បើទោះបីជាវាមានទេសភាពស្រស់សោភា និងមានផ្ទុកនូវអត្ថន័យប្រវត្តិសាស្រ្តជាច្រើនដែលបានបន្សល់តាំងពីបុរាណកាលក៏ដោយ[36]។

**ប្រាសាទអណ្តែត៖** ប្រាសាទនេះស្ថិតនៅភូមិប្រាសាទ ឃុំសាគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានចម្ងាយប្រហែល៥គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ ដោយធ្វើដំណើរតាមបណ្តោយផ្លូវជាតិលេខ ៦ នៅខាងឆ្វេងដៃ។ ប្រាសាទនេះត្រូវបានអ្នកស្រាវជ្រាវចាត់ទុកថាជាសម្បត្តិវប្បធម៌ខ្មែរមួយដ៏ចំណាស់ ដែលបានសាងសង់តាំងពីពាក់កណ្តាលសតវត្សរ៍ទី៧ដែលមនុស្សភាគច្រើនស្គាល់ថាជាសម័យចេនឡា នៅក្រោមរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ ដើម្បីឧទ្ទិសថ្វាយដល់ព្រះហរិហរាល័យ។ កន្លែងនេះបានស្ថាបនាក្នុងរចនាបថកំពង់ព្រះ ធ្វើអំពីឥដ្ឋដោយកំបោរ ថ្មបាយ ក្រៀម និងថ្មភក់ ហើយត្រូវបានសង់លើភ្នំសិប្បនិមិត្តកម្ពស់៥,៣០ ម៉ែត្រ និងមានទម្រង់ជារាងចតុកោណប្រវែង៧,៥០ម៉ែត្រ ទទឹង៥,៥០ម៉ែត្រ និងកំរាស់១ម៉ែត្រ។ ដូចគ្នានឹងប្រាសាទបុរាណដទៃទៀតដែរ ប្រាសាទអណ្តែតបែរមុខទៅទិសខាងកើត ជាមួយនឹងរចនាបថខ្មែរដ៏ស្រស់អស្ចារ្យ។ កាលពីដើម ប្រាសាទនេះមានរូបសំណាកព្រះហរិហរាឈរលើបល្ល័ង្ក ដែលព្រះហរិហរាជាអទិទេពមួយអង្គដែលបានកើតចេញពីការផ្សំគ្នារវាងព្រះសិវៈ និងព្រះវិស្ណុដើម្បីលើកកម្ពស់សន្តិភាព និងកាត់បន្ថយសង្គ្រាមសាសនា។ បច្ចុប្បន្ន រូបសំណាកនេះត្រូវបាននាំយកទៅតម្កល់ទុកនៅសារមន្ទីរជាតិភ្នំពេញ។ លើសពីនោះទៀត ប្រាសាទនេះមានទ្វារស៊ុមដែលមានទទឹង១ម៉ែត្រ កម្ពស់២ម៉ែត្រ និងកម្រាស់០,២ម៉ែត្រ ហើយនៅលើទ្វារស៊ុមខាងជើងគេឃើញស្លាកស្នាមនៃជើងឆ្មាខ្លា ដែលធ្លាប់លោតទៅប្រអប់ខាងលើនៃទ្វារ។ ស្លាកស្នាមបានបន្សល់រហូតមកដល់បច្ចុប្បន្ន។ ប្រាសាទអណ្តែតជាប្រាសាទមួយក្នុងចំណោមប្រាសាទជាច្រើននៅក្នុងខេត្តកំពង់ធំ ដែលប្រជាជននិងទេសចរតែងតែមកលេងកម្សាន្តក្នុងឱកាសបុណ្យប្រពៃណីជាតិខ្មែរដូចជាបុណ្យចូលឆ្នាំខ្មែរ ឬបុណ្យភ្ជុំបិណ្ឌជាដើម[37]។

**បឹងសំរិទ្ធ៖** ជារមណីយដ្ឋានកែច្នៃមួយដែលត្រូវបានសាងសង់ក្នុងឆ្នាំ២០០៦ និងបញ្ចប់ក្នុងឆ្នាំ២០១២ ហើយបើកដំណើរការឱ្យភ្ញៀវចូលកម្សាន្តនៅក្នុងឆ្នាំ២០១៣។ វាស្ថិតនៅក្នុងភូមិដូង ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដែលមានផ្ទៃដីសរុបចំនួន៤៧ហិកតា។ គេអាចធ្វើដំណើរតាមផ្លូវជាលេខ៦ ចម្ងាយប្រមាណ ៤២ គីឡូម៉ែត្រពីក្រុងកំពង់ធំ រួចបត់ស្តាំប្រមាណ៣គីឡូម៉ែត្រ នោះគេនឹងរកឃើញតំបន់ទេសចរណ៍បឹងសំរិទ្ធនេះហើយ។ រមណីយដ្ឋាននេះមានសេវាកម្មជាច្រើនជូនភ្ញៀវដូចជា ម៉ូតែលសម្រាប់ស្នាក់នៅ សេវាម្ហូបអាហារ សួនកុមារ អាងទឹកសាធារណៈដ៏ធំ និងកន្លែងកម្សាន្តផ្សេងៗទៀតរួមមាន ការជិះខ្សែរ័តលើផ្ទៃបឹង ជិះទូក ជិះទាទឹក ជិះប៉េដាឡូ ជិះកង់ ការជិះស្លាយរំអិលខ្លួនធ្លាក់ពីលើភ្នំចូលទៅទឹកបឹង ទីលានវាយកូនបាល់ ទីលានហាត់វាយ

36 https://ams.com.kh/khmercivilization/detail/19134

37 https://www.tourismcambodia.com/attractions/kampong-thom.htm

កូនហ្គោ និងល្បែងកីឡាជាច្រើនប្រភេទ។ រមណីយដ្ឋានបឹងសំរិទ្ធិ គឺជាស្ថាបត្យកម្មដែលសាងសង់តាមរចនាបទខ្មែរមានដូចជា ក្លោងទ្វារចូលគឺសង់តាមលំនាំរចនាបទប្រាសាទព្រះវិហារ សំណង់រូបបង្រួមប្រាសាទអង្គរវត្ត រូបផ្ដិលសំរិទ្ធិ និងភ្នំកែច្នៃ។ ដោយសារតែទេសភាព ស្រស់ស្អាត លាយឡំជាមួយនឹងរចនាសម្ព័ន្ធដ៏គួរឱ្យស្ញើចសរសើរនេះហើយ រមណីយដ្ឋានបឹងសំរិទ្ធបានទាក់ទាញទេសចរជាតិ និងអន្តរជាតិឱ្យមកលេងកម្សាន្តនៅពេលបានមកដល់។ យោងតាមលោក សេង អាន ដែលជាប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំបានឱ្យដឹងថា កាលពីមុនកន្លែងកម្សាន្តនេះមានភ្ញៀវចូលកម្សាន្តតិចតួចប៉ុណ្ណោះ ដោយសារតែសំបុត្រចូលមានតម្លៃថ្លៃរហូតដល់តែ ២៨,០០០រៀល (៧ដុល្លារ) ដោយបូករួមជាមួយតម្លៃលេងមួយចំនួន។ ប៉ុន្តែបច្ចុប្បន្នម្ចាស់រមណីយដ្ឋានបានកាត់បន្ថយតម្លៃសំបុត្រចូលមកត្រឹមតែ៥,០០០រៀលប៉ុណ្ណោះ ដើម្បីផ្ដល់លទ្ធភាពឱ្យភ្ញៀវគ្រប់កម្រិតថ្នាក់ និងសង្គមមជ្ឈដ្ឋានអាចចូលមកលេងកម្សាន្តគ្រប់ៗគ្នា នេះជាហេតុនាំឱ្យចំនួនភ្ញៀវចូលទៅលេងកម្សាន្តនៅទីនោះមានការកើនឡើងយ៉ាងខ្លាំង[38]។

**រមណីយដ្ឋានធម្មជាតិកែច្នៃស្ទឹងព្រៃប្រស់៖** ជារមណីយដ្ឋានដ៏ស្រស់ត្រកាលមួយ ដែលស្ថិតនៅភូមិព្រៃប្រស់ ឃុំព្រៃប្រស់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងមានចម្ងាយប្រមាណជស ១៦គីឡូម៉ែត្រភាគពាយព្យនៃទីរួមខេត្ត។ ដោយប្រទះឃើញពីសក្ដានុពល និងអំណោយផលដ៏ល្អខាងវិស័យទេសចរណ៍របស់ស្ទឹងព្រៃប្រស់ទើបគណៈកម្មាធិការប្រជាជនខេត្តកំពង់ធំបានចេញសេចក្ដីសម្រេចនៅក្នុងឆ្នាំ១៩៩២ ដើម្បីបង្កើតមណ្ឌលទេសចរណ៍នេះឡើង ហើយនៅឆ្នាំ១៩៩៥ អាជ្ញាធរខេត្តក៏បានប្រារព្ធពិធីបើកសម្ពោធអនុញ្ញាតឱ្យទេសចរទូទៅចូលកម្សាន្តជាផ្លូវការក្នុងតំបន់ទេសចរណ៍ធម្មជាតិនិងកែច្នៃដ៏ស្រស់ត្រកាលមួយនេះ។ យោងតាមអនុសាសន៍របស់លោក សេង អាន ដែលជាប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំបានឱ្យដឹងថាតំបន់រមណីយដ្ឋាននេះមានលក្ខណៈធំល្វឹងល្វើយដែលមានទំហំសរុប ទាំងផ្ទៃទឹកប្រមាណ២០០០០០ម៉ែត្រការ៉េ។ ដើម្បីទាក់ទាញទេសចរមន្ទីរទេសចរណ៍ខេត្តបានធ្វើការយ៉ាងស្វាហាប់ក្នុងការរៀបចំកន្លែងកម្សាន្តជូនទេសចរ ដែលក្នុងនោះមានបឹងសម្រាប់ហែលលេងកញ្ចុះជួលសម្រាប់អង្គុយជួបជុំពិសារអាហារ ប៉េដាឡូសម្រាប់ជិះគយគន់ទេសភាព និងមានសេវាកម្មលក់ភេសជ្ជៈនិងចំណីអាហារផ្សេងៗយ៉ាងសម្បូរបែបប្រកបដោយតម្លៃសមរម្យ។ ដោយសារការគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់និងការខិតខំអភិវឌ្ឍបែបនេះហើយ វាបានធ្វើឱ្យរមណីយដ្ឋានស្ទឹងព្រៃប្រស់ក្លាយទៅជារមណីយដ្ឋានគំរូទីមួយដែលអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការជុំវិញប្រទេសយកតម្រាប់តាម។ លើសពីនេះទៀត ដោយសារតែភាពលេចធ្លោរបស់រមណីយដ្ឋាននេះហើយ ទើបសន្ទុះទេសចរមកទស្សនាមានការកើនឡើងជាលំដាប់ ពិសេសនៅរៀងរាល់ថ្ងៃចុងសប្ដាហ៍ ឬថ្ងៃបុណ្យប្រពៃណី ដោយពួកគេភាគច្រើនមក ដើម្បីអង្គុយ

38 https://khmerpostasia.com/archives/57520

ស្ងួចត្រីលំហែកាយ គយគន់មើលទិដ្ឋភាពថ្ងៃរៀបលិច ព្រមទាំងសត្វស្លាបជាច្រើនប្រភេទ និងវាលស្រែដ៏ធំល្វឹងល្វើយ[39]។

**ចំការសូត្រសន្ទុកៈ** ជាកន្លែងមួយក្នុងចំណោមកន្លែងជាច្រើនដែលបង្ហាញឱ្យទេសចរឃើញអំពីដំណើរការទាំងមូលនៃការផលិតសូត្រ ចាប់តាំងពីការយកសូត្រចេញពីដង្កូវនាងបន្ទាប់ពីគេចិញ្ចឹមវាអស់រយៈពេលប្រាំពីរសប្តាហ៍និងឱ្យវាស៊ីតែស្លឹកមន រហូតដល់ដំណាក់កាលដែលគេវេញយកវាមកធ្វើជាសូត្រសម្រាប់ប្រើប្រាស់។ ចំការនេះស្ថិតនៅប៉ែកអាគ្នេយ៍ដែលមានចម្ងាយប្រហែល១៨គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ និងនៅជិតវិទ្យាល័យភ្នំសន្ទុកចម្ងាយប្រហែល៦៥០ម៉ែត្រពីគ្នា។ ចំការសូត្រសន្ទុកជួលអ្នកស្រុកចំនួន១៨នាក់មកធ្វើជាសិប្បករតម្បាញដែលក្នុងនោះភាគច្រើនជាស្ត្រី។ កន្លែងនេះត្រូវបានគ្រប់គ្រងដោយអ្នកស្រី ណាវីន (Navin) ដែលគាត់ជាស្ត្រីមេម៉ាយរបស់អតីតរបស់អតីតទាហានសង្គ្រាមវៀតណាមអាមេរិក ហើយទេសចរអាចមើលពួកគេត្បាញក្រមានិងរបស់របរផ្សេងៗទៀតបាន ប៉ុន្តែត្រូវទូរស័ព្ទប្រាប់គាត់ជាមុន ដើម្បីឱ្យនាងបានយកក្រមាចេញមក[40]។

**វិមានរេស៊ីដង់បារាំងចាស់ និង សត្វប្រចៀវៈ** ដើម្បីទៅដល់កន្លែងទេសចរណ៍នេះ គេអាចជិះតាមផ្លូវធំតាមទិសខាងជើង រួចបត់ឆ្វេងទៅផ្លូវមួយនៅតាមបណ្តោយស្ទឹង រួចបន្តដំណើរប្រហែល៣០០ម៉ែត្រ គេនឹងឃើញកន្លែងអង្គុយសម្រាកដ៏ធំមួយ នោះហើយជាតំបន់គោលដៅ។ ទេសចរអាចមកដើម្បីទស្សនានូវសំណង់បុរាណនិងវិមានដ៏ធំដែលជាកន្លែងស្នាក់នៅរបស់អភិបាលបារាំងនាសម័យអាណានិគមបារាំង។ មិនតែប៉ុណ្ណោះ នៅទីនោះក៏មានដើម មែកធាងចាស់ចំនួន៣ដើម ដែលជាជម្រករបស់សត្វប្រចៀវធំៗរាប់រយក្បាល។ ស្លាបរបស់ពួកវាមានប្រវែងរហូតដល់៤០សង់ទីម៉ែត្រ ហើយពួកគេចំណាយពេលថ្ងៃរបស់ដោយព្យួរចុះក្រោមដូចជាផ្លែឈើមានស្លាបដើម្បីរក្សាភាពត្រជាក់ ប្រសិនបើទេសចរមកកំឡុងម៉ោង៥:៣០ ឬ ៦ល្ងាច នោះគេនឹងឃើញសត្វទាំងនោះហោះហើរស្វែងរកអាហារ[41]។

## ២.៣. ស្ថានភាពនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

### ២.៣.១. ទីតាំងភូមិសាស្ត្រ

ប្រាសាទសំបូរព្រៃគុកជាប្រភេទរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រមួយដែលមានទីតាំងស្ថិតនៅក្នុងភូមិសំបូរ ឃុំសំបូរ ស្រុកសំបូរ ខេត្តកំពង់ធំ។ ប្រាសាទនេះស្ថិតនៅតាមបណ្តោយស្ទឹងសែន និងមានចម្ងាយប្រហែល២៥គីឡូម៉ែត្រភាគឦសាននៃទីរួមខេត្តកំពង់ធំ។ ប្រសិនបើគេធ្វើដំណើរពីរាជធានីអង្គរនៃខេត្តសៀមរាប

[39] https://www.khemaradaily.com/p/26895

[40] https://www.lonelyplanet.com/cambodia/kompong-thom-province/attractions/santuk-silk-farm/a/poi-sig/1381364/1336590

[41] https://www.visitcambodia.travel/kh/item/view/54c494f4a4t27424y2p2u2z2

រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកមានមានចម្ងាយប្រហែល១៨១គីឡូម៉ែត្រ ដែលស្មើនឹងថេរវេលាប្រមាណជា ៣ម៉ោង៣០នាទី តែបើគេចេញដំណើរពីប្រាសាទព្រះវិហារវិញ វាមានចម្ងាយប្រហែល១៧០គីឡូម៉ែត្រ ដោយត្រូវប្រើរយៈពេលប្រហែល៣ម៉ោង បើជិះតាមផ្លូវជាតិលេខ៦២។ ប៉ុន្តែបើធ្វើដំណើរពីរាជធានីភ្នំពេញវិញ គេត្រូវការពេលវេលាជិត៤ម៉ោង ដោយសារតែវាមានចម្ងាយរហូតដល់១៩៦គីឡូម៉ែត្រឯណោះ។ នៅពេលទៅដល់ ទេសចរនឹងឃើញផ្ទាំងបដាដ៏ធំមួយសរសេរថា "រមណីដ្ឋានប្រាសាទសំបូរព្រៃគុក" សម្រាប់ផ្លូវចូលទៅក្នុងប្រាសាទនេះមានចម្ងាយប្រមាណជា៣គីឡូម៉ែត្រ ដោយត្រូវជិះលើដីកៅស៊ូ និងផ្លូវដីក្រហម។ សម្រាប់មធ្យោបាយធ្វើដំណើរ ទេសចរអាចជួលរមកកង់បី ដើម្បីឱ្យគេជូនយើងទៅទស្សនាប្រាង្គប្រាសាទនានាដោយវាមានតម្លៃពី២០-៣០ដុល្លារក្នុងមួយថ្ងៃ ឬក៏គេអាចប្រើប្រាស់យានជំនិះផ្ទាល់ខ្លួនដូចជា ម៉ូតូ ឬឡានគ្រន់ធន។ យោងតាមលោក សំបូរ ម៉ាណារ៉ា ដែលជាអ្នកជំនាញប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរបានឱ្យដឹងថា ទោះប្រាសាទនេះជាតំបន់ដែលសម្បូរទៅដោយវប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរក៏ដោយ ក៏វាមិនមែនគ្រាន់តែជាកន្លែងសម្រាប់តែទាក់ទាញទេសចរអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែវាជាកន្លែងដ៏សំខាន់បំផុតសម្រាប់ប្រវត្តិសាស្ត្រខ្មែរ និងជានិមិត្តរូបនៃការបង្រួបបង្រួមជាតិដែលប្រជាជនកម្ពុជាទាំងអស់គួរស្គាល់[42]។

### ២.៣.២. ប្រវត្តិរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

ប្រាសាទសំបូរព្រៃគុកត្រូវបានកសាងឡើងក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ នៅក្នុងសតវត្សទី៧ ក្នុងគ្រិស្តសករាជ៦១៦ដល់៦៣៥ នាសម័យចេនឡា ដើម្បីឧទ្ទិសថ្វាយដល់ព្រះសិវៈឬព្រះឥសូរនិយម។ ប្រាសាទសំបូរព្រៃគុកជារាជធានីចាស់ឈ្មោះថាឥសានបុរៈ កាលពីសម័យនោះជាមជ្ឈមណ្ឌលនៃព្រាហ្មណ៍សាសនា។ រាជធានីបុរាណ ដែលប្រាសាទសំបូរព្រៃគុកត្រូវបានប្រទះរកឃើញនាពេលបច្ចុប្បន្ននេះត្រូវបានគេកំណត់ថាជាឥសានបុរៈដែលជារាជធានីនៃសម័យចេនឡានៅសតវត្សទី៧។ ចេនឡាគឺជាអតីតសាមន្តរដ្ឋនៃនគរភ្នំនោះគឺជារដ្ឋមួយនៃរដ្ឋដំបូងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែវាត្រូវបានបាត់បង់ទៅវិញ ដោយសារមានធ្វើចម្បាំងជាមួយអាណាចក្រភ្នំ និងការកើនឡើងជាបណ្តើរអំណាចរបស់អាណាចក្រចេនឡា ដោយព្រះបាទភវវរ្ម័នទី១ និងបងប្អូនព្រះបាទមហេន្ទ្រវរ្ម័នទី១ ឬចិត្រសេនារហូតដល់បុត្ររបស់ព្រះអង្គគឺព្រះបាទឥសានវរ្ម័នទី១ ដែលជាបុត្ររបស់ព្រះបាទមហេន្ទ្រវរ្ម័នទី១និងជាព្រះមហាក្សត្របានដណ្តើមអំណាចពីនគរភ្នំដោយជោគជ័យ ដោយវាយបែកនគរភ្នំនៅរាជធានីចុងក្រោយគឺរាជធានីនរវនគរ ឬភាសាចិនហៅថាណាហ្វូណា បច្ចុប្បន្ននៅភ្នំអង្គរបុរី ខេត្តតាកែវ។

លក្ខណៈពិសេសបុរាណវិទ្យាក្រុមចម្បងវិមានទាំងនេះត្រូវបានគេនិយាយថាបានបង្កើតឡើងដោយព្រះបាទឥសានវរ្ម័នទី១ ដែលជាបុត្រារបស់ស្តេចចិត្រសេនា។ ការតុបតែងដែលមានស្ថាបត្យកម្មខ្មែរ និងចម្លាក់ដែល

42 https://www.phnompenhpost.com/national/kampong-thoms-sambor-prei-kuk-gets-unesco-listing

ត្រូវបានចាត់ថ្នាក់ជារចនាបថសំបូរព្រៃគុកឈ្មោះនេះបានមកពីវិមានទាំងនេះក្នុងឆមាសទីមួយនៃសតវត្សរ៍ទី៧ ។ លើសពីនេះទៀតស្នងបន្តជាច្រើនរជ្ជកាលស្តេចប្រហែលជាបានរក្សាវិមានទាំងនេះជារាជធានីស្តេចគ្រប់ព្រះអង្គ។ សតវត្សបន្ទាប់ពីការស្លាប់របស់ព្រះបាទជ័យវរ្ម័នទី១ ដែលជាស្តេចចុងក្រោយនៃនគរនៅក្នុងឆមាសទី២នៃសតវត្សទី៧ នេះគឺជារយៈពេលងងឹតមួយនៅក្នុងប្រវត្តិសាស្ត្រនៃចេនឡា។ ទោះជាយ៉ាងណា វាត្រូវបានឆ្លុះបញ្ចាំងជាថ្មីម្តងទៀតដោយសារមានការចូលរួមរបស់ព្រះបាទជ័យវរ្ម័នទី២ ដែលបានបង្កើតទំរង់នៃការ គ្រប់គ្រងរដ្ឋថ្មីមួយ និងនៅសម័យអង្គរមានការបង្កើតរាជធានីផ្សេងៗទៀតបានសំដៅដល់ប្រាសាទអង្គរនៅដើម សតវត្សទី៩នេះ។ ការតុបតែងនៃប្រាសាទតោ (ក្រុមកណ្តាល) មានលក្ខណៈស្រដៀងគ្នាទៅនឹងរចនាបថនៃប្រាសាទជាកម្មសិទ្ធិអំឡុងពេលនៃព្រះបាទជ័យវរ្ម័នទី២នេះ ជាពិសេសរូបចំលាក់សត្វតោដែលមានលក្ខណៈ ប្រហាក់ប្រហែលនឹងរូបចម្លាក់ដែលបានរកឃើញនៅរាជធានីភ្នំពេញ។ លើសពីនេះ សិលាចារឹកមួយចំនួន នៅក្នុងប្រាសាទសំបូរ (ភាគខាងជើងគ្រុប) ត្រូវបានចុះកាលបរិច្ឆេទនៅសតវត្សរ៍ទី១០ ក្រោមរជ្ជកាលរបស់ស្តេចព្រះបាទរាជិន្ទ្រវរ្ម័នទី២។ របៀបនៃការតុបតែង និងរូបសំណាក់មួយចំនួនផ្សេងៗទៀតគឺជាកម្មសិទ្ធិរបសរចនាបថចុងសម័យអង្គរត្រូវបានបញ្ជាក់ពីប្រាសាទទាំងនេះ។ ភស្តុតាងជាប្រវត្តិសាស្ត្រនេះបានបង្ហាញថា បូជនីយដ្ឋានទាំងនេះត្រូវជាកម្មសិទ្ធិរបស់ទីក្រុងគោលការណ៍ខេត្តសំខាន់បន្ទាប់ពីរយៈពេលមុនសម័យអង្គរ។ យោងតាមទស្សនៈប្រវត្តិសាស្ត្រក្រុមនៃប្រាសាទនេះគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា ដែលមិនត្រឹមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់តំបន់ទាំងមូលនៃភូមិភាគអាស៊ីអាគ្នេយ៍ ព្រោះវាគឺជាសំណង់ស្ថាបត្យកម្មសំឡេងតែមួយគត់ដែលនៅសល់នៅក្នុងបរិមាណច្រើនគួរសម[43]។

### ២.៣.៣. ស្ថានភាពសហគមន៍

សហគមន៍អភិរក្ស និងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុកបានធ្វើការបោះជំហានយ៉ាងរឹងមាំ ហើយថែមទាំងមានភាពម្ចាស់ការក្នុងការស្វែងរកប្រភពចំណូលដោយខ្លួនឯងទៀតផង។ បើយោងតាមអនុសាសន៍របស់លោកឰប្រធានសហគមន៍បានឱ្យដឹងថា កាលពីមុនពេលដែលសហគមន៍សំបូរព្រៃគុកត្រូវបានដាក់បញ្ចូលក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក សហគមន៍នេះត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរវប្បធម៌ និងទេសចរណ៍ ប៉ុន្តែក្រោយមក សហគមន៍នេះបានកែប្រែក្លាយជាសហគមន៍ឯករាជ្យមួយ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរ ក្រុមព្រឹក្សាភិបាល មេភូមិ ចៅសង្កាត់ និងសមាជិកជាច្រើនទៀតនៃសហគមន៍សំបូរព្រៃគុកផ្ទាល់តែម្តង។ បើទោះបីជាសហគមន៍នេះជាសហគមន៍ឯករាជ្យក៏ពិតមែន តែគេក៏ត្រូវធ្វើតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដែលជាអ្នកសម្របសម្រួលគោលការណ៍របស់សហគមន៍ឱ្យត្រូវជាមួយនឹងយន្តការរបស់អង្គការ

[43] ប្រាសាទសំបូរព្រៃគុក - វិគីភីឌា (wikipedia.org)

UNESCO ផងដែរ។ បើយោងតាមលក្ខន្តិកៈគណៈកម្មការប្រតិបត្តិសហគមន៍អភិរក្សនិងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំដែលបានស្រង់ស្ថិតិនៅក្នុងឆ្នាំ២០០៤ បានឱ្យដឹងថាក្នុងសហគមន៍មានការចូលរួមពីប្រជាពលរដ្ឋចំនួន៧ភូមិ ដែលក្នុងនោះមានចំនួន៦០០ គ្រួសារ។ សម្រាប់មុខរបរប្រចាំថ្ងៃ ប្រជាពលរដ្ឋមួយចំនួនជាអ្នកធ្វើស្រែចំការ មួយចំនួនជាអ្នកលក់ដូរ ចំណែកឯមួយចំនួនទៀតមានមុខរបរក្នុងវិស័យទេសចរណ៍ ដូចជា ការលក់វត្ថុអនុស្សាវរីយដល់ទេសចរដែលបានមកកម្សាន្តនៅរមណីយដ្ឋាន និងការបម្រើសេវាកម្មទេសចរណ៍ជាដើម[44]។

## ២.៤. សក្តានុពលរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកជារមណីយដ្ឋានដែលសម្បូរទៅដោយព្រៃឈើធំៗនិងមានប្រាសាទវែយចំណាស់ៗជាច្រើន។ រមណីយដ្ឋាននេះត្រូវបានសង់លើដីរាបស្មើមានទំហំ៣,០០០ហិកតា និងត្រូវបានសន្និដ្ឋានដោយអ្នកសិក្សាស្រាវជ្រាវបរទេសថាជារាជធានីរបស់ខ្មែរក្នុងសម័យចេនឡាដែលមានឈ្មោះថាឥសានបុរៈ ឬឥសានបុរីក្នុងរាជ្យព្រះបាទឥសានវរ្ម័នទី១នាដើមសតវត្សរ៍ទី៧ ដោយដាក់ឈ្មោះស្របតាមព្រះនាមរបស់ទ្រង់។ ចំណែកអ្នកកសាងបន្តទៀតគឺព្រះបាទភវវរ្ម័នទី២ ដោយដាក់នាមថា ភវបុរៈ គឺដូចគ្នាទៅនឹងបច្ឆាមរណនាមរបស់ព្រះអង្គដែលរួមនឹងក្សត្រមួយចំនួនទៀត។ នៅក្នុងបរិវេណរាជធានីបុរាណខ្មែរមួយនេះគឺមានប្រាសាទចំនួន២៩៣ប្រាសាទលើទំហំផ្ទៃដីបច្ចុប្បន្នប្រមាណ៣០គីឡូម៉ែត្រការ៉េ។ ប្រាសាទទាំងនោះត្រូវបានគេបានបែងចែកជា បីក្រុមធំៗ រួមមាន:

- **ប្រាសាទសំបូរឬក្រុមខាងជើង៖** កសាងឡើងនៅដើមសតវត្សរ៍ទី៧ ក្រោមស្នាព្រះហស្តព្រះបាទឥសានវរ្ម័នទី១ ក្នុងគោលបំណងឧទ្ទិសទៅដល់ព្រះសិវៈ ដែលព័ទ្ធជុំវិញដោយក្រុមប្រាសាទតូចៗជាច្រើនកសាងអំពីឥដ្ឋតាន់។
- **ប្រាសាទតោឬក្រុមកណ្តាល៖** ព័ទ្ធដោយកំពែងថ្មបាយក្រៀមពីរជាន់ កំពែងខាងក្រៅមានបណ្តោយប្រមាណ ២៨០ម៉ែត្រ និងទទឹង២៧០ម៉ែត្រ ចំណែកកំពែងខាងក្នុងមានបណ្តោយ១៨៥ម៉ែត្រ និងទទឹង១៣៥ម៉ែត្រ។ កំពែងទាំងពីរជាន់មានច្រកទ្វារនៅទិសខាងកើតនិងខាងលិច ដែលនៅខាងក្នុងកំពែងទាំងពីរមានទួលប្រាសាទចំនួន១២ ដែលខ្លះបន្សល់នូវជើងសសរថ្មបាយក្រៀម។ ចេញពីកំពែងខាងក្រៅឆ្ពោះទៅកើតមានថ្នល់បុរាណមួយមានប្រវែងប្រហែល១គីឡូម៉ែត្រ សំដៅទៅរកបឹងធំមួយនៅវាលទំនាបរួចភ្ជាប់ទៅកាន់ស្ទឹងស្ទឹងសែន។ នៅជ្រុងឥសានខាងក្នុងកំពែងខាងក្រៅមានស្រះបុរាណមួយដែលនៅជុំវិញស្រះមានប្រាំងរៀបជាថ្នាក់ៗថ្មបាយក្រៀម។ រីឯនៅខាងលិចខាងក្រៅកំពែងខាងក្រៅមាន

[44] លក្ខន្តិកៈគណៈកម្មការប្រតិបត្តិសហគមន៍អភិរក្សនិងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំ, ទំព័រ ២

ប្រាសាទតម្រៀបជាជួរដែលភាគច្រើនខូចខាត និងខ្លះសល់ត្រឹមជញ្ជាំង។ ប្រាង្គកណ្តាលមាន កម្ពស់ប្រហែលជា២០ម៉ែត្រធ្វើពីឥដ្ឋរាងចតុកោណកែងសង់នៅលើខឿនមានច្រកទ្វារបែរមុខទៅកើត និងទ្វារបញ្ឆោតនៅតាមជ្រុងផ្សេងៗទៀត ដែលទ្វារទាំងនោះធ្វើពីថ្មភក់។ នៅផ្នែកខាងលើរបស់ស៊ុមទ្វារមានចម្លាក់ផ្តែរស្ថិតនៅក្នុងរចនាបទព្រៃក្មេង (រវាងគ.ស.៦៣៥-៧០០) និងកំពង់ព្រះ (រវាងគ.ស.៧០៦-៨០០) មានលម្អដោយក្បាច់ស្លឹកឈើរាងជាអង្កត់ធ្នូក្បាច់រំយោល និងកម្រងផ្កា។ នៅខាងមុខអមសងខាងជណ្តើរមានលម្អដោយរូបចម្លាក់តោមួយគូ (សរុបទាំងអស់ចំនួន៦លើកលែងតែទ្វារខាងលិចមិនមានចម្លាក់តោ) ដែលជាការលេចឡើងដំបូងនូវចម្លាក់តោនៅក្នុងប្រវត្តិសិល្បៈខ្មែរ។ តាមរយៈការសន្និដ្ឋានប្រាសាទកណ្តាលអាចស្ថាបនាឡើងនៅចន្លោះចុងសតវត្សរ៍ទី៧ និងចុងសតវត្សរ៍ទី៨។

- **ប្រាសាទយាយព័ន្ធឬក្រុមខាងត្បូង៖** ព័ទ្ធជុំវិញដោយកំពែងពីរជាន់ កំពែងខាងក្នុងធ្វើពីឥដ្ឋ និងកំពែងខាងក្រៅធ្វើពីថ្មបាយក្រៀម និងមានច្រកទ្វារពីរខាងកើតខាងលិច និងទ្វារបញ្ឆោតនៅខាងត្បូងនិងខាងជើង។ ភ្ជាប់ពីខ្លោងទ្វារខាងកើតមានថ្នល់បុរាណមួយមានប្រវែងជាង ២ គីឡូម៉ែត្រឆ្ពោះទៅរកស្ទឹងស្ទឹងសែន។ តាមរយៈសិលាចារិកបានបង្ហាញថាសំណង់ប្រាសាទនេះសាងសង់ឡើងក្នុងរាជ្យព្រះបាទឥសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧) ដើម្បីឧទ្ទិសថ្វាយដល់ព្រះឥសូរដែលជាអាទិទេពនៃព្រហ្មញ្ញសាសនា។ នៅក្នុងកំពែងទាំងពីរជាន់នេះមានប្រាង្គប្រាសាទជាច្រើនធ្វើពីឥដ្ឋ និងថ្មបាយក្រៀម ដោយខ្លះមានរាងចតុកោណ និងប្រាំទៀតមានរាងអដ្ឋកោណ ដែលមានលម្អដោយក្បាច់ចម្លាក់ផ្សេងៗជាពិសេសគឺប្រាសាទអណ្តែត។ ចំណែកនៅលើជញ្ជាំងធ្វើពីឥដ្ឋរបស់កំពែងខាងក្នុងភាគខាងលិចមានឆ្លាក់នូវលម្អរាងមូលធំៗចំនួន៧២ (មកដល់សព្វថ្ងៃចម្លាក់ដែលសល់រូបរាងមានចំនួនតែ២៥ប៉ុណ្ណោះ) ខ្លះឆ្លាក់ជារឿងក្នុងទេវកថាផ្សេងៗ។ ក្រៅពីនោះ នៅមានស្រះទឹកបុរាណមួយស្ថិតនៅខាងកើតក្រៅកំពែងក្រៅ និងស្រះទឹកបុរាណមួយតូចទៀតស្ថិតនៅជ្រុងនិរតីនៃកំពែងខាងក្រៅ។ ប្រាសាទសំខាន់ៗនៅក្នុងក្រុមនេះត្រូវបានស្ថាបនាប្លង់ជារាងចតុកោណកែង បែរមុខទៅខាងកើតមានកម្ពស់ប្រហែលជា២៥ម៉ែត្រ និងមានតម្កល់អាទិទេពព្រះនាមប្រហសិតេស្វរៈ (ព្រះឥសូរញញឹម) ជាព្រះនាមមួយរបស់ព្រះឥសូរដែលមានចែងក្នុងគម្ពីរសិវបុរាណ នេះបើយោងតាមសិលាចារឹកចារនៅលើមេទ្វាររបស់ខ្លោងទ្វារខាងកើត។ នៅខាងក្នុងប្រាង្គមានលក្ខណៈពិសេសមួយគឺមានសាងមណ្ឌបអំពីថ្មភក់ ដែលតាមសិលាចារឹកបញ្ជាក់ថាជាទីតម្កល់រូបព្រះគោនន្ទិ (ជំនិះព្រះឥសូរ) ប្រាក់។ ក្រៅអំពីនោះមានសិលាចារឹកដទៃទៀតមាននិយាយពីការតម្កល់បដិមាព្រះព្រហ្ម ព្រះឥសូរ ព្រះហរិហរៈ សិវលិង្គមាស ព្រមទាំងព្រះនាងសរស្វតី (ព្រះមហេសីព្រះព្រហ្ម)។ ប្រភពពីសិលាចារឹកនៅប្រាសាទធ្វើពីថ្មបាយក្រៀម ក្រៅពី

បង្ហាញអំពីកិច្ចប្រតិបត្តិខាងព្រហ្មញ្ញសាសនាក៏មានបង្ហាញអំពីវត្តមានពុទ្ធសាសនាដ៏ចំណាស់ដំបូងគេមួយនៅសម័យចេនឡា (តាំងពីចុងសតវត្សរ៍ទី៦រហូតដល់ដើមសតវត្សរ៍ទី៩)។

ចំណែកឯក្រុមប្រាសាទតូចៗទៀត មានដូចជាក្រុមប្រាសាទក្រោលរមាស ក្រុមប្រាសាទត្រពាំងរពាក់ ក្រុមប្រាសាទឫស្សីរំលែក ក្រុមប្រាសាទសណ្ដាន់ និងក្រុមប្រាសាទបុស្សរាមជាដើម ។ ប្រាសាទនេះក៏មានលក្ខណៈដូចប្រាសាទដទៃទៀតនៅប្រទេសកម្ពុជាដែរ ប៉ុន្តែវាមានកំផែងព័ទ្ធជុំវិញ ស្រះទឹក កន្លែងបូជា ដើមឈើតូចធំ រុក្ខជាតិ និងសត្វផ្សេងៗគួរឱ្យចាប់អារម្មណ៍។

ចំពោះសេវាកម្មដែលមាននៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកមានដូចជា:

- **ការធ្វើដំណើរតាមរទេះគោ៖** កាលពីមុន ប្រជាជនក្នុងសហគមន៍មានរទេះគោជាច្រើនសម្រាប់ទុកឱ្យទេសចរទាំងជាតិនិងអន្តរជាតិដើម្បីជួលយកទៅជិះកម្សាន្តនៅក្នុងតំបន់ដែលសហគមន៍បានអនុញ្ញាត ។ ដោយសារតែទេសចរភាគច្រើនមិនចេះបររទេះគោដោយខ្លួនឯង ដូច្នេះម្ចាស់រទេះគោតែងតែធ្វើដំណើរទៅជាមួយទេសចរ ដើម្បីបរឱ្យទេសចរ ឬពេលខ្លះបង្រៀនទេសចរអំពីរបៀបបររទេះគោ។ សេវាកម្មមួយនេះទទួលបានចំណូលជាច្រើនជារៀងរាល់ថ្ងៃ ប៉ុន្តែបន្ទាប់ពីមានការអភិវឌ្ឍមក ទេសចរមិនសូវចាប់អារម្មណ៍នឹងសេវាកម្មមួយនេះទៀតទេ គេបែរជាក្រឡេកមកជិះយានជំនិះផ្សេងៗទៀត។
- **ការធ្វើដំណើរតាមកង់៖** ក្រៅពីការជួលរទេះគោ សហគមន៍ក៏មានកង់សម្រាប់ឱ្យទេសចរជួលសម្រាប់ជិះមើលទេសភាពនៅជុំវិញសហគមន៍ផងដែរ។ កង់ទាំងនោះមានច្រើនប្រភេទ សម្រាប់ឱ្យទេសចរជ្រើសរើសដូចជា កង់ធម្មតា កង់ភ្នំ (Mountain Bike) និងកង់ទីក្រុង (City Bike) ជាដើម។ សម្រាប់ City Bike គឺសម្រាប់ជិះលើផ្លូវ រាបស្មើទេ មិនអាចយកមកជិះកាត់ខ្សាច់ ឬក្រួសឡើយ។ សម្រាប់ Mountain Bike គឺសម្រាប់ជិះទួលចុះឡើងដូចជាផ្លូវភ្នំជាដើម នេះជាហេតុដែលគេហៅវាថា កង់ភ្នំ។
- **សេវាកម្មមគ្គុទេសក៍៖** សហគមន៍មានសេវាកម្មមគ្គុទេសក៍ផ្ទាល់ខ្លួន ដែលទេសចរអាចជួលដើម្បីបកប្រែ ព្រមទាំងរៀបរាប់ដើមប្រវត្តិនៃប្រាសាទ ឬសិលាចារិកនីមួយៗដែលពួកគេឃើញ។
- **សេវាកម្មផ្ទះស្នាក់៖** មគ្គុទេសក៍ក្នុងសហគមន៍តែងតែណែនាំសេវាកម្មផ្ទះស្នាក់ទៅដល់ទេសចរ ដើម្បីចូលរួមបង្កើនចំណូលជូនបងប្អូនពូមីងក្នុងសហគមន៍។ ទេសចរជាច្រើន បានសម្ដែងក្ដីពេញចិត្តនឹងសេវាកម្មមួយនេះ ដោយសារតែវាបានផ្ដល់នូវបទពិសោធន៍ថ្មីៗដល់ពួកគាត់ ព្រោះផ្ទះស្នាក់ទាំងអស់ត្រូវបានរៀបចំ និងតុបតែងតាមបែបប្រពៃណីបុរាណ។ ជាក់ស្ដែង នៅ ក្នុងបន្ទប់គេង គ្រឿងលំអ និងសំភារប្រើប្រាស់ទាំងឡាយមានលក្ខណៈសាមញ្ញស្របទៅតាមការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ រីឯកន្លែងងូតទឹកគឺ ស្ថិតនៅខាងក្រោមផ្ទះ ដែលទំនៀមទំលាប់នេះមាន

លក្ខណៈខុសពីទំនៀមទំលាប់នាពេលបច្ចុប្បន្នដែលភាគច្រើនគេប្រទះឃើញកន្លែងងូតទឹកស្ថិតនៅក្នុងបន្ទប់ជាមួយនឹងបន្ទប់គេង។

- **សេវាកម្មម្ហូបអាហារ៖** សហគមន៍មានម្ហូបអាហារជាច្រើនប្រភេទដូចជា ម្ហូបបែបខ្មែរ អឺរ៉ុប និងបែបមេឌីទែរ៉ាណេ ដែលម្ហូបទាំងនោះស្ថិតនៅក្នុងតម្លៃមួយសមរម្យល្មមនឹងអាចទទួលយកបាន ពោលគឺវាមានតម្លៃចាប់ពី ៦-៨ដុល្លារក្នុងមួយនាក់។ មួយវិញទៀតផ្ទះនីមួយៗក៏មានសេវាកម្មធ្វើម្ហូប ដែលម្ចាស់ផ្ទះអនុញ្ញាតឱ្យទេសចរមកចូលផ្ទះបាយដើម្បីចម្អិនម្ហូបជាមួយខ្លួនផងដែរ។ សម្រាប់សេវាកម្មម្ហូបអាហារ សហគមន៍បានដាក់កំហិតឱ្យម្ចាស់ផ្ទះស្នាក់ប្រើប្រាស់បន្លែ និងគ្រឿងផ្សំទាំងឡាយណាដែលដាំដុះដោយខ្លួនឯង ដើម្បីធានានូវសុវត្ថិភាពជូនទេសចរពេលបរិភោគ។
- **សេវាកម្មធ្វើនំប្រចាំតំបន់៖** ម្ចាស់ផ្ទះស្នាក់ក៏មានបង្រៀនទេសចរឱ្យធ្វើនំក្នុងតំបន់ដូចជា នំនាឡិដែលជានំប្រពៃណីម្យ៉ាង ដែលគេយកទៅចំហុយនៅលើត្រឡោកដូង ហើយក្នុងការចម្អិនម្តងគឺបានតែមួយទេ។ គេធ្វើនំនេះដោយដាក់លើក្អមហើយចុះរន្ធតូចៗលើត្រឡោកដូង ដើម្បីឱ្យកម្តៅចូលតាមរន្ធនោះទើបវាឆ្អិន។ នំនាឡិធ្វើឡើងពីម្សៅមីបុកលាយជាមួយដូង និងស្ករត្នោត។ ពេលចំហុយនំនាឡិមិនឡើងដូចនំដទៃៗទេ ប៉ុន្តែវាស្រកមកក្រោមវិញ ហេតុនេះហើយទើបចាស់ៗសម័យបុរាណតែងនិយមនិយាយថានំមិនធំជាងនាឡិនោះទេ។ គេតែងចំហុយនំនេះក្នុងពិធីឡើងអ្នកតា ឬការបូជាញ្ញញនៅក្នុងព្រហ្មញ្ញសាសនា ដើម្បីតំណាងឱ្យផែនដី ឬក្នុងពិធីច្រតព្រះនង្គ័លជាដើម។

ក្នុងចំណោមសេវាកម្មទាំងអស់ សេវាកម្មមគ្គុទេសក៍មានភាពលេចធ្លោ និងទទួលបានការចាប់អារម្មណ៍ពីទេសចរជាងគេ ដោយសារតែតំបន់ទេសចរណ៍មួយនេះពាក់ព័ន្ធនឹងប្រាសាទបុរាណ ដែលទេសចរនីមួយៗត្រូវការមគ្គុទេសក៍ដើម្បីពន្យល់ និងបកស្រាយ ទើបពួកគាត់អាចទទួលបានចំណេះដឹងបន្ថែមទាក់ទងនឹងប្រវត្តិ និងព័ត៌មានទូទៅនៃរមណីយដ្ឋាន។ ចំណែកឯសេវាកម្មផ្ទះស្នាក់ក៏ល្បីមិនចាញ់សេវាកម្មមគ្គុទេសក៍ប៉ុន្មានដែរ នេះដោយសារតែទេសចរជាពិសេសទេសចរអន្តរជាតិនៅពេលដែលមកដល់តែងតែស្វែងរកផ្ទះស្នាក់ ដើម្បីស្នាក់នៅបណ្តុះអាសន្នមួយយប់ឬពីរយប់។ ម្យ៉ាងទៀតកត្តាដែលទាក់ទាញទេសចរឱ្យប្រើប្រាស់សេវាកម្មទាំងពីរនេះច្រើនជាងគេនោះគឺព្រោះតែវាមានតម្លៃសមរម្យមិនថ្លៃហើយក៏មិនថោកពេកដែរ ពោលគឺសេវាកម្មមគ្គុទេសក៍មានតម្លៃត្រឹមតែ១៥-២០ដុល្លារក្នុងមួយថ្ងៃនិងសេវាកម្មផ្ទះស្នាក់មានតម្លៃត្រឹមតែ៥-៧ដុល្លារប៉ុណ្ណោះក្នុងមួយយប់។

សម្រាប់សេវាកម្មដែលពុំសូវទទួលបានការចាប់អារម្មណ៍ពីសំណាក់ទេសចរ សហគមន៍បានអនុវត្តវិធានការមួយចំនួនដូចជា ការសិក្សាបន្ថែមលើចំណុចខ្វះខាតថាហេតុអ្វីបានជាទេសចរមិនសូវប្រើប្រាស់សេវាកម្មទាំងនោះ ហើយធ្វើការកែលំអ និងស្តាបនាបន្ថែមលើចំណុចទាំងអស់នោះ។ បន្ទាប់មកទៀត សហគមន៍

បានពឹងពាក់ឱ្យទេសចរចាស់ៗ ដែលគាត់ធ្លាប់មកកម្សាន្ត និងប្រើប្រាស់សេវាកម្មឱ្យជួយផ្សព្វផ្សាយ ព្រមទាំងចែករំលែកបទពិសោធន៍ល្អៗទៅកាន់បុគ្គលផ្សេងៗទៀតដូចជា បងប្អូន ញាតិមិត្ត ឬអ្នកធ្វើការជាមួយជាដើម ដើម្បីអូសទាញឱ្យពួកគាត់ចាប់អារម្មណ៍ និងមកកម្សាន្តនៅរមណីយដ្ឋាននេះដែរ។ លើសពីនេះទៀត សហគមន៍បានចាប់ដៃគូជាមួយក្រុមហ៊ុនទេសចរណ៍ មួយចំនួនធំ ជាពិសេសក្រុមហ៊ុនហនុមាន ដើម្បីឱ្យពួកគាត់ជួយក្នុងការផ្សព្វផ្សាយ និងរៀបចំកញ្ចប់សេវាកម្មនាំទេសចរ មកកាន់រមណីយដ្ឋានសំបូរព្រៃគុកឱ្យកាន់តែច្រើន។ មួយវិញទៀត សហគមន៍ក៏បានទាក់ទងជាមួយនឹងស្ថាប័នរដ្ឋដែលជាដៃគូដើម្បីឱ្យស្ថាប័នទាំងនោះជួយក្នុងការអភិវឌ្ឍ និងលើកតម្កើងសេវាកម្មទាំងអស់នោះឱ្យទទួលបានជោគជ័យដូចសេវាកម្មដទៃទៀតដែរ។

## ២.៥. បញ្ហាប្រឈម

ទន្ទឹមនិងភាពរីកចម្រើនដែលរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកទទួលបាន រមណីយដ្ឋាននេះក៏នៅជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជាៈ

- **ហេដ្ឋារចនាសម្ព័ន្ធ៖** តាមជាក់ស្តែងផ្លូវចូលទៅកាន់រមណីយដ្ឋានជាផ្លូវក្រាលដីក្រហម ដែលធ្វើឱ្យទេសចរ ដែលបានធ្វើដំណើរកម្សាន្តទៅកាន់រមណីយដ្ឋានពុំមានភាពងាយស្រួលក្នុងការធ្វើដំណើរ រីឯចំណតរថយន្តវិញ គេបានសង្កេតឃើញថាពុំទាន់មានការរៀបចំឱ្យមានរបៀបរៀបរយសម្រាប់ចំណតយានជំនិះនៅឡើយទេ។
- **សេវាសាធារណៈ៖** យោងតាមការសម្ភាសរបស់ប្រជាពលរដ្ឋនៅទីនោះបានឱ្យដឹងថាប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធអគ្គិសនីនៅមានភាពខ្វះខាតនៅឡើយ។ ទោះបីជាប្រជាជនអាចប្រើប្រាស់នូវសេវាទាំងនោះបានក៏ដោយ ក៏ប៉ុន្តែការផ្គត់ផ្គង់នៅមានកម្រិតដែលជាបញ្ហាប្រឈមដែលត្រូវដោះស្រាយ។
- **បញ្ហាបរិស្ថាន៖** បរិស្ថានគឺជាកត្តាមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍អោយមានភាពរីកចម្រើន។ ជាក់ស្តែងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកជារមណីយដ្ឋានដែលមានធនធានធម្មជាតិដ៏ស្រស់បំព្រង និងគួរឱ្យគយគន់។ ប៉ុន្តែវាក៏មាននូវបញ្ហាដែលធ្វើឱ្យបរិស្ថាននៅជុំវិញប្រាសាទបាត់បង់នូវសោភណ្ឌភាពផងដែរ បញ្ហានោះគឺបញ្ហាសំរាម។ ទោះបីជាមាននូវធុងសំរាមក៏ដោយតែយ៉ាងណាក៏នូវតែមានសំរាមមួយចំនួននៅក្នុងបរិវេណប្រាសាទដែរដែលធ្វើឱ្យប៉ះពាល់ដល់ទិដ្ឋភាពនិងភាពទាក់ទាញទាំងមូលរបស់រមណីយដ្ឋាន។
- **បញ្ហាធនធានមនុស្ស៖** វិស័យទេសចរណ៍អាចអភិវឌ្ឍទៅមុខបានលុះត្រាតែមានរទាំងកម្លាំងពលកម្មជំនាញព្រមទាំងចំណេះដឹង។ ទាំងអស់នេះហើយគឺជាកត្តាដ៏សំខាន់ដែលធ្វើឱ្យ សេវាកម្មក្នុងវិស័យទេសចរណ៍អាចបង្កើន និងពង្រឹងនូវគុណភាពដែលជាតម្រូវការយ៉ាងចាំបាច់សម្រាប់ទេសចរគ្រប់រូប។

ហេតុដូចនេះហើយបញ្ហាធនធានមនុស្សជាបញ្ហាដែលគួរអោយយកចិត្តទុកដាក់យ៉ាងខ្លាំង ប្រសិនបើគ្មានការបណ្តុះបណ្តាលពាក់ព័ន្ធទៅនឹងសេវាកម្មមគ្គុទេសក៍ និងសេវាកម្មផ្សេងៗទៀតនោះក៏មិនអាចបំពេញនូវសេចក្តីត្រូវការរបស់ទេសចរបានដែរ ហើយវាក៏បង្កើតជាបញ្ហាប្រឈមដែលធ្វើឱ្យមានការរាំងឃាត់ស្ទះដល់ការរីកចម្រើន ជាពិសេសខាតបង់នូវប្រាក់ចំណូលរបស់ជាតិ និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ។

# ជំពូកទី ៣

# លទ្ធផលនៃការស្រាវជ្រាវស្តីពីការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

ក្រុមនិស្សិតយើងខ្ញុំបានចុះទៅសម្ភាសដោយផ្ទាល់ជាមួយនឹងប្រជាជាពលរដ្ឋក្នុងតំបន់ និងអាជីវករចំនួន១០ នាក់ ទេសចរ២៥នាក់ និងអាជ្ញាធរពាក់ព័ន្ធមួយចំនួន៣នាក់ ដើម្បីស្វែងរកព័ត៌មានដែលច្បាស់លាស់ និងគួរជាទីទុកចិត្តសម្រាប់យកមកចងក្រងធ្វើជាសារណាមួយនេះ។ កម្រងសំណួរត្រូវបានបែងចែកជា៣ ដោយកម្រងសំណួរទី១មានចំនួន៥សំណួរ ដែលទាក់ទិននឹងព័ត៌មានផ្ទាល់ខ្លួន និងទស្សនៈទានរបស់ប្រជាពលរដ្ឋក្នុងតំបន់ទាក់ទងនឹងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។ កម្រងសំណួរទី២មានចំនួន១៥សំណួរ ដែលសំណួរទាំងនេះទាក់ទិនទៅនឹងព័ត៌មានផ្ទាល់ខ្លួនរបស់ទេសចរ។ ចំណែកឯកម្រងសំណួរទី៣វិញមានចំនួន១៤សំណួរ ដែលសំណួរទាំងអស់គឺសម្រាប់សាកសួរទៅកាន់អាជ្ញាធរពាក់ព័ន្ធនៅក្នុងខេត្តកំពង់ធំ និងក្នុងបូរអំពីយុទ្ធសាស្ត្រនៃការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

## ៣.១. លទ្ធផលនៃការសម្ភាសន៍អំពីប្រជាសាស្ត្រ

### ៣.១.១. ការសម្ភាសន៍ទៅលើភេទ

តាមក្រាហ្វិកខាងក្រោមនេះ ក្នុងចំណោមប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន១០នាក់ ដែលបានចូលរួមក្នុងកិច្ចសម្ភាសដោយផ្ទាល់ យើងសង្កេតឃើញថាប្រជាពលរដ្ឋចំនួន៤នាក់ ដែលស្មើនឹង៤០% ជាស្ត្រី ចំណែកឯ៦នាក់ទៀត ដែលស្មើនឹង៦០% ជាបុរស។

**ក្រាហ្វិច ៣.១. អត្រានៃភេទ**




### ៣.១.២. ការសម្ភាសន៍លើអាយុ

យោងតាមការសម្ភាសជាមួយនឹងប្រជាពលរដ្ឋក្នុងសហគមន៍បានឱ្យដឹងថា ប្រជាពលរដ្ឋអាយុ១៨-២៥ឆ្នាំដែលបានចូលរួមឆ្លើយសំណួរមានចំនួន៣នាក់ដែលស្មើនឹង៣០% ប្រជាពលដែលមានអាយុ២៦-៤០ឆ្នាំមានចំនួន២នាក់ដែលស្មើនឹង២០% អ្នកមានអាយុ៤១-៥០ឆ្នាំមានចំនួន២នាក់ដែលស្មើនឹង២០% អ្នកមានអាយុ៥១-៦០ឆ្នាំ មានចំនួន២នាក់ និងអ្នកដែលមានអាយុ៦១ឆ្នាំឡើង មានចំនួន១នាក់ដែលស្មើនឹង ១០%។

**ក្រាហ្វិច ៣.២. អត្រាអាយុ**




### ៣.១.៣. ការសម្ភាសន៍លើមុខរបរ

តាមរយៈការសម្ភាសទៅកាន់ប្រជាពលរដ្ឋក្នុងសហគមន៍បានបង្ហាញឱ្យឃើញថាប្រជាពលរដ្ឋដែលជាកសិករប្រកបរបរធ្វើស្រែចំការដើម្បីជួយទ្រទ្រង់ជីវភាពប្រចាំថ្ងៃមានចំនួន៧នាក់ ដែលស្មើនឹង៧០% និងប្រជាពលរដ្ឋដែលជាអាជីវករមានចំនួន៣នាក់ ដែលស្មើនឹង៣០%។

**ក្រាហ្វិច ៣.៣. អត្រានៃមុខរបរ**



### ៣.១.៤. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាបរិយាកាស

តាមការសម្ភាសទៅកាន់ប្រជាពលរដ្ឋទាក់ទងទៅនឹងបរិយាកាសក្នុងសហគមន៍បានឱ្យដឹងថា ក្នុងនោះមានប្រជាពលរដ្ឋចំនួន៣នាក់ ដែលស្មើនឹង៣០% បានយល់ឃើញថាសហគមន៍មានបរិយាកាសល្អណាស់សម្រាប់ការរស់នៅក៏ដូចជាប្រកបមុខរបរផ្សេងៗជាដើម ចំណែកប្រជាពលរដ្ឋចំនួន៧នាក់ទៀត ដែលស្មើនឹង៧០% បានបញ្ចេញមតិថាបរិយាកាសមានភាពល្អបង្គួរសម្រាប់ការរស់នៅរបស់ពួកគាត់។

**ក្រាហ្វិច ៣.៤. ការយល់ឃើញលើបញ្ហាបរិយាកាស**




### ៣.១.៥. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាអនាម័យ

យោងតាមការផ្តល់នូវចម្លើយពីសំណាក់ប្រជាពលរដ្ឋក្នុងសហគមន៍បានឱ្យដឹងថាប្រជាពលរដ្ឋចំនួន៦នាក់ ដែលស្មើនឹង៦០% បានបង្ហាញការយល់ឃើញថាសហគមន៍បានរក្សានូវអនាម័យល្អណាស់ដែលធ្វើឱ្យការរស់នៅរបស់គាត់មានភាពស្រស់ស្រាយនិងមានផាសុកភាព ហើយប្រជាពលរដ្ឋចំនួន៤នាក់ទៀត ដែលស្មើនឹង៤០% បានយល់ឃើញថាអនាម័យនៅក្នុងសហគមន៍មានលក្ខណៈល្អបង្គួរសម្រាប់ការរស់នៅ។

**ក្រាហ្វិច ៣.៥. ការយល់ឃើញលើបញ្ហាអនាម័យ**



### ៣.១.៦. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

លទ្ធផលនៃការសម្ភាសបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋចំនួន៧នាក់ ដែលស្មើនឹង៧០% យល់ឃើញថាផ្លូវថ្នល់មានសភាពល្អបង្គួរ ដែលទេសចរអាចធ្វើដំណើរមកលេងកម្សាន្តនៅរមណីយដ្ឋានប្រកបដោយមានភាពងាយស្រួល រីឯប្រជាពលរដ្ឋចំនួន៣នាក់ទៀត ដែលស្មើនឹង៣០% បានបង្ហាញថាផ្លូវថ្នល់នាពេលបច្ចុប្បន្ននេះមានសភាពមិនសូវល្អនៅឡើយទេ ហើយវាទាមទារឱ្យនូវការអភិវឌ្ឍបន្ថែមទៀត ដើម្បីឱ្យមានភាពងាយស្រួលជាងនេះទៅទៀត។

**ក្រាហ្វិច ៣.៦. ការយល់ឃើញលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន**




### ៣.១.៧. ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាព

សន្តិសុខ និងសុវត្ថិភាពគឺជាកត្តាដ៏សំខាន់មួយដែលធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍មានភាពរីកចម្រើនក៏ដូចជាពោរពេញទៅដោយភាពរីករាយ។ តាមការសម្ភាស ប្រជាពលរដ្ឋចំនួន២នាក់ ដែលស្មើនឹង២០% បានបង្ហាញថាសន្តិសុខនិងសុវត្ថិភាពក្នុងសហគមន៍មានលក្ខណៈល្អណាស់ និងប្រជាពលរដ្ឋចំនួន៨នាក់ទៀត ដែលស្មើនឹង៨០% យល់ឃើញថាសន្តិសុខនិងសុវត្ថិភាពមានសភាពល្អបង្គួរដែលធ្វើឱ្យគាត់មានភាពទុកចិត្តក្នុងការរស់នៅ។

**ក្រាហ្វិច ៣.៧. ការយល់ឃើញលើបញ្ហាសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាព**




### ៣.១.៨. ការសម្ភាសន៍លើស្ថានភាពប្រជាពលរដ្ឋ

យោងតាមការផ្តល់នូវចម្លើយនៃការសម្ភាសពីសំណាក់ប្រជាពលរដ្ឋបានឱ្យដឹងថា ប្រជាពលរដ្ឋទាំង ១០នាក់ ដែលស្មើនឹង១០០% បានឆ្លើយថាជីវភាពរបស់គាត់មានការប្រែប្រួលគួរជាទីកត់សំគាល់ ដោយសារតែមានទេសចរមកកម្សាន្តច្រើនជាងមុន ដែលធ្វើឱ្យផលិតផល និងអាជីវកម្មរបស់ពួកគាត់មានការរីកចម្រើន ព្រមទាំងទទួលបាននូវ ចំណូលសមរម្យសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃផងដែរ។

**ក្រាហ្វិច ៣.៨. ការយល់ឃើញលើស្ថានភាពប្រជាពលរដ្ឋ**




## ៣.២. លទ្ធផលនៃការសម្ភាសន៍ជាមួយទេសចរ

### ៣.២.១. ការសម្ភាសន៍ទៅលើភេទ

យោងទៅតាមលទ្ធផលជាក់ស្តែងដែលទទួលបានពីទេសចរដែលមកទស្សនាកម្សាន្តនៅក្នុងរមណីយដ្ឋានប្រាសាទបានឱ្យដឹងថា ក្នុងចំណោមទេសចរចំនួន២៥នាក់ មានទេសចរ១៥នាក់ ដែលស្មើនឹង៦០% ជាមនុស្សប្រុស និងមានទេសចរត្រឹមតែ១០នាក់ប៉ុណ្ណោះ ដែលស្មើនឹង៤០% ជាមនុស្សស្រី។

**ក្រាហ្វិច ៣.៩. អត្រានៃភេទរបស់ទេសចរ**




### ៣.២.២. ការសម្ភាសន៍លើអាយុ

ចំពោះការចូលរួមផ្តល់នូវចម្លើយ ទេសចរដែលមកកម្សាន្តលេងនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកមានអាយុផ្សេងៗគ្នា ដែលក្នុងនោះរួមមានអាយុចាប់ពី១៨-២៥ឆ្នាំមានចំនួន៧នាក់ ដែលត្រូវនឹង២៨% ចំណែកអាយុចាប់ពី២៦-៤០ឆ្នាំមានរហូតដល់ទៅ៩នាក់ ដែលស្មើនឹង៣៦% ចំពោះអាយុចាប់ពី៤១-៥០ឆ្នាំ មានចំនួន៥នាក់ ដែលស្មើនឹង២០% រីឯអាយុចាប់ពី៥១-៦០ឆ្នាំមាន៣នាក់ ស្មើនឹង១២% សម្រាប់អាយុចាប់ពី៦១ឆ្នាំឡើងទៅមានត្រឹមតែ១ នាក់ប៉ុណ្ណោះ ដែលស្មើនឹង៤%។

**ក្រាហ្វិច ៣.១០. អត្រាអាយុរបស់ទេសចរ**




### ៣.២.៣. ការសម្ភាសន៍នៅលើចំនួនដងដែលធ្លាប់មកកម្សាន្តនៅរមណីយដ្ឋាន

តាមលទ្ធផលនៃការស្ទង់មតិបានឱ្យឃើញថា ទេសចរដែលធ្លាប់មកទស្សនាកម្សាន្តនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកបានចំនួនមួយដងមានចំនួន៨នាក់ ដែលត្រូវនឹង៣២% ទេសចរដែលមកទស្សនាបានចំនួនពីរដងមានចំនួន៩នាក់ ដែលស្មើនឹង៣៦% ទេសចរដែលមកកម្សាន្តបានបីដងមានចំនួន៤នាក់ ដែលស្មើនឹង១៦% ហើយសម្រាប់ទេសចរដែលមកលេងកម្សាន្តលើសពីបីដងមានចំនួន៤នាក់។ ទេសចរម្នាក់ដែលមកទស្សនារមណីយដ្ឋាននេះបានលើកឡើងថា ទោះបីជាការមកទស្សនាកម្សាន្តនៅរមណីយដ្ឋានលើកនេះជាលើកទីពីររបស់គាត់ក៏ពិតមែន ប៉ុន្តែរូបគាត់នៅតែចង់មកទស្សនាម្តងហើយម្តងទៀត ដោយសារតែទិដ្ឋភាពដ៏អស្ចារ្យរបស់ប្រាង្គប្រាសាទ និងសម្រស់ធម្មជាតិដ៏ស្រស់បំព្រងរបស់រមណីយដ្ឋាន។

**ក្រាហ្វិច ៣.១១. អត្រាចំនួនដងដែលទេសចរធ្លាប់មកកម្សាន្ត**



### ៣.២.៤. ការសម្ភាសន៍នៃការស្គាល់រមណីយដ្ឋានរបស់ទេសចរ

សហគមន៍បានធ្វើការយ៉ាងសកម្មក្នុងការចូលរួមផ្សព្វផ្សាយរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដើម្បីឱ្យទេសចរកាន់តែច្រើនបានស្គាល់ និងមកលេងរមណីយដ្ឋាននេះ។ យោងទៅតាមលទ្ធផលជាក់ស្តែងបានឱ្យឃើញថា ទេសចរដែលស្គាល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកតាមរយៈប្រព័ន្ធផ្សព្វផ្សាយមានចំនួន៦នាក់ត្រូវនឹង២៤% ទេសចរស្គាល់តាមរយៈមិត្តភក្តិ ឬបងប្អូនមានចំនួន៩នាក់ ដែលត្រូវនឹង៣៦% អ្នកដែលស្គាល់តាមរយៈក្រុមហ៊ុនទេសចរណ៍មានចំនួន៥នាក់ ដែលត្រូវនឹង២០% និងផ្សេងៗដូចជាការស្គាល់តាមមគ្គុទេសក៍ទេសចរណ៍ ទស្សនាវដ្ដី កាសែត អូតែល ឬក្រុមហ៊ុនដឹកជញ្ជូនមានចំនួន៥នាក់ស្មើនឹង២០%។ តាមការសម្ភាសជាមួយបងស្រីម្នាក់បានឱ្យដឹងថា គាត់បានស្គាល់រមណីយដ្ឋាននេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ហើយគាត់ក៏ចែករំលែកការ និងផ្សព្វផ្សាយនេះទៅកាន់មិត្តភក្តិ ព្រមទាំងបងប្អូនឱ្យមកកម្សាន្តផងដែរ។

**ក្រាហ្វិច ៣.១២. ការស្គាល់រមណីយដ្ឋានរបស់ទេសចរ**




### ៣.២.៥. ការសម្ភាសន៍លើគោលបំណងដែលមកទស្សនា

យោងតាមរយៈការផ្ដល់ចម្លើយរបស់ទេសចរបានឱ្យដឹងថា អ្នកដែលបានមកដើម្បីទស្សនាកម្សាន្តនៅរមណីយដ្ឋានមានចំនួន២១នាក់ដែលត្រូវនឹង៨៤% ចំណែកឯអ្នកដែលមកដើម្បីធ្វើការសិក្សាស្រាវជ្រាវមានចំនួន៣នាក់ដែលស្មើនឹង១២%និងអ្នកដែលមកដើម្បីបំពេញកិច្ចការមានត្រឹម១នាក់ប៉ុណ្ណោះ ដែលស្មើនឹង៤%។

**ក្រាហ្វិច ៣.១៣. គោលបំណងដែលទេសចរមកទស្សនា**




### ៣.២.៦. ការសម្ភាសន៍លើការយល់ឃើញលើចំនួនធុងសម្រាម

យោងតាមការសម្ភាសដោយផ្ទាល់ជាមួយនឹងទេសចរបានឱ្យដឹងថា ទេសចរដែលគិតថាចំនួនធុងសម្រាមដែលមាននៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកគ្រប់គ្រាន់មានចំនួន២២នាក់ ដែលស្មើនឹង៨៨% រីឯអ្នកដែលយល់ថាចំនួនធុងសម្រាមមានមិនគ្រប់គ្រាន់នោះមានត្រឹមតែ៣នាក់តែប៉ុណ្ណោះដែលស្មើនឹង១២%។ អ្នកមីងម្នាក់ដែលបានអញ្ជើញមកពីភ្នំពេញបានលើកឡើងថា ធុងសម្រាមមានច្រើនក៏ពិតមែនប៉ុន្តែវាមានតែនៅក្នុងបរិវេណប្រាសាទតែប៉ុណ្ណោះ បើទេសចរធ្វើដំណើរផុតពីម្តុំនោះ គេនឹងពុំឃើញមានធុងសម្រាមសម្រាប់ទេសចរចោលកាកសំណល់ច្រើនដូចមុនទៀតឡើយ។

**ក្រាហ្វិច ៣.១៤. ការយល់ឃើញរបស់ទេសចរនៅលើចំនួនធុងសម្រាម**



### ៣.២.៧. ការសម្ភាសន៍លើការយល់ឃើញលើចំនួនបន្ទប់អនាម័យ

តាមការស្ទង់មតិសរុបបានសរឱ្យឃើញថាមានទេសចរ៨នាក់ ស្មើនឹង៣២% បានជ្រើសយកចម្លើយដែលថាចំនួនបង្គន់អនាម័យគឺគ្រប់គ្រាន់ ចំណែកឯទេសចរចំនួន១៨នាក់ ដែលស្មើនឹង៦៨% បានឆ្លើយថាបង្គន់អនាម័យមានចំនួនមិនគ្រប់គ្រាន់សម្រាប់បម្រើតម្រូវការរបស់ពួកគាត់ពេលមកដល់ទេ។

**ក្រាហ្វិច ៣.១៥. ការយល់ឃើញរបស់ទេសចរនៅលើចំនួនបន្ទប់អនាម័យ**




### ៣.២.៨.ការសម្ភាសន៍ពីការយល់ឃើញលើបញ្ហាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

តាមរយៈលទ្ធផលនៃការសម្ភាសបែបខ្លីៗជាមួយនឹងទេសចរបានឱ្យដឹងថា ទេសចរចំនួន១១នាក់ដែលស្មើនឹង៤៤% យល់ឃើញថាបញ្ហាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកមានកម្រិតមធ្យម ពោលគឺមិនល្អពេក ហើយក៏មិនអាក្រក់ហួសហេតុពេកដែរ។ ឯទេសចរចំនួន១៤នាក់ផ្សេងទៀត ដែលស្មើនឹង៥៦% បានបង្ហាញថាពួកគាត់មានការពេញចិត្តនឹងបញ្ហាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នាពេលបច្ចុប្បន្ននៅក្នុងបរិវេណប្រាសាទ។

**ក្រាហ្វិច ៣.១៦. ការយល់ឃើញរបស់ទេសចរលើបញ្ហាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់**




### ៣.២.៩. ការសម្ភាសន៍លើការយល់ឃើញលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធ

តាមទិន្នន័យដែលទទួលបានពីការសម្ភាសជាមួយនឹងទេសចរទាក់ទងនឹងកម្រិតនៃការពេញចិត្តលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធបានឱ្យឃើញថា ទេសចរ៧នាក់ស្មើនឹង២៨% មានការពេញចិត្តមធ្យម ឯទេសចរ១៦នាក់ ដែលស្មើនឹង៦៤% បានបង្ហាញការពេញចិត្តមកលើហេដ្ឋារចនាសម្ព័ន្ធរបស់រមណីយដ្ឋានពេលដែលគាត់បានមកទស្សនា ចំណែកឯទេសចរ១នាក់ ដែលស្មើនឹង៤% បានសម្តែងការពេញចិត្តយ៉ាងខ្លាំងលើស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ។ ទន្ទឹមនឹងនោះដែរក៏មានទេសចរម្នាក់ដែលបានសម្តែងការមិនពេញចិត្តចំពោះបញ្ហាហេដ្ឋារចនាសម្ព័ន្ធផងដែរ។

**ក្រាហ្វិច ៣.១៧. ការយល់ឃើញរបស់ទេសចរលើបញ្ហាហេដ្ឋារចនាសម្ព័ន្ធ**



### ៣.២.១០. ការសម្ភាសន៍លើការយល់ឃើញលើបញ្ហាបរិស្ថាន

ទេសចរ២នាក់ ស្មើនឹង៨% បានសម្តែងក្តីមិនពេញចិត្តចំពោះបញ្ហាបរិស្ថាននៅក្នុងរមណីដ្ឋាន។ ក្រៅពីនេះមានទេសចរ៧នាក់ ស្មើនឹង២៨% បានពោលថាស្ថានភាពបរិស្ថានមានកម្រិតមធ្យម ទេសចរ១១នាក់ ដែលត្រូវនឹង៤៤% បានឆ្លើយថាគាត់មានការពេញចិត្តនឹងបរិស្ថានក្នុងតំបន់នោះ រីឯទេសចរ៥នាក់ទៀត ស្មើនឹង ២០% មានការពេញចិត្តយ៉ាងខ្លាំង។

**ក្រាហ្វិច ៣.១៨. ការយល់ឃើញរបស់ទេសចរលើបញ្ហាបរិស្ថាន**




## ៣.៣. សំណូមពររបស់ទេសចរ

តាមលទ្ធផលនៃការសម្ភាសបានបង្ហាញថា ទេសចរ៣នាក់ដែលត្រូវនឹង១២% បានយល់ឃើញថារមណីយដ្ឋានគួរអភិវឌ្ឍបន្ថែមលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ទេសចរ១១នាក់ស្មើនឹង៤៤%ជ្រើសរើសផ្នែកសេវាសាធារណៈ ៣នាក់ជ្រើសរើសផ្នែកបរិស្ថាន ៣នាក់ជ្រើសរើសផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់ និង៥នាក់ដែលស្មើនឹង២០% បានជ្រើសរើសចម្លើយស្នើសុំឱ្យរមណីយដ្ឋានអភិវឌ្ឍគ្រប់ផ្នែកទាំងអស់ខាងលើ។ បញ្ហាទាំងប៉ុន្មាននេះសុទ្ធសឹងតែជាបញ្ហាសំខាន់ៗដែលរាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវរកវិធានការក្នុងការដោះស្រាយ ដើម្បីធានាសុវត្ថិភាពនិងបំពេញតម្រូវការទេសចរ។

**ក្រាហ្វិច ៣.១៩. ការយល់ឃើញរបស់ទេសចរលើផ្នែកដែលគួរអភិវឌ្ឍ**




### ៣.៣.១. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យទេសចរណ៍ ដោយវាអាចបង្កើនកម្រិតនៃការពេញចិត្ត និងឆ្លើយតបនូវសេចក្ដីចង់បានរបស់ទេសចរនៅពេលមកដល់តំបន់គោលដៅ។ បើយើងក្រឡេកមកមើលករណីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកវិញ យើងឃើញថាផ្នែកហេដ្ឋារចនាសម្ព័ន្ធនៅទីនោះនៅមានកម្រិតនៅឡើយ ពោលគឺផ្លូវនៅតំបន់ខ្លះមានភាពងាយស្រួលក្នុងការធ្វើដំណើរឆ្លងកាត់ រីឯផ្លូវនៅតំបន់ខ្លះទៀតមានលក្ខណៈរអិលដែលអាចនឹងបង្កការលំបាកដល់ទេសចរក្នុងការប្រាស្រ័យឆ្លងកាត់។

ជាក់ស្ដែង យោង តាមសម្ដីរបស់អ៊ំប្រុសម្នាក់ដែលបានអញ្ជើញមកតាំងពីខេត្តសៀមរាបបានប្រាប់មកកាន់ក្រុមនិស្សិតយើងថាគាត់មិនសូវពេញចិត្តនឹងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសគឺបញ្ហាផ្លូវជិះចូលរមណីយដ្ឋាននាពេលសព្វថ្ងៃនេះ ដោយសារតែបន្ទាប់ពីប្រហែល១គីឡូម៉ែត្រពីច្រកចូលដែលជាផ្លូវកៅស៊ូ អ្នកធ្វើដំណើរត្រូវឆ្លងកាត់ផ្លូវដីក្រហមប្រមាណ១គីឡូម៉ែត្រកន្លះទៀតទើបមកដល់តំបន់ប្រាសាទសំបូរព្រៃគុក។ ផ្លូវដីក្រហមនេះមានសភាពរកាក់រកុបឡើងចុះៗ ដែលធ្វើឱ្យអ្នកធ្វើដំណើរ ជាពិសេសអ្នកធ្វើដំណើរតាមទោចក្រយានយន្តមានភាពពិបាកក្នុងការជិះចូលទៅ។ គាត់បានបន្ថែមពីលើថាបើនៅរដូវវស្សាវិញ ផ្លូវត្រូវបានរងការខូចខាតជាខ្លាំងដោយសារតែមានភក់ដក់ពាសពេញផ្លូវ ដែលធ្វើឱ្យរថយន្តនិងរថយន្តមានភាពពិបាកក្នុងការជៀសពីគ្នា ចំណែកឯអ្នកជិះម៉ូតូវិញ ពួកគេតែងតែដួលជារឿយៗធ្វើឱ្យប្រឡាក់សំលៀកបំពាក់ព្រោះតែផ្លូវរអិលពេក។ បើក្នុងរដូវប្រាំងវិញនៅពេលដែលមានយានយន្តណាមួយជិះលឿនវានឹងធ្វើឱ្យផ្លូវមានសភាពហ៊ុយខ្លាំង ដែលធ្វើឱ្យអ្នកធ្វើដំណើរដទៃទៀតពិបាកក្នុងការមើលផ្លូវ ក៏ដូចជាមើលការធ្វើចរាចរណ៍របស់យានយន្តដទៃទៀត។ កត្តានេះអាចនឹងបង្កគ្រោះថ្នាក់ដល់អ្នកធ្វើដំណើរ ប្រសិនបើអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធមិនរួសរាន់រកដំណោះស្រាយទេ។

មិនត្រឹមតែទេសចរប៉ុណ្ណោះទេដែលសម្ដែងក្ដីមិនពេញចិត្តនឹងផ្នែកហេដ្ឋារចនាសម្ព័ន្ធ សូម្បីតែប្រជាពលរដ្ឋក្នុងតំបន់នោះផ្ទាល់ក៏បានបញ្ចេញមតិសំណូមពរឱ្យមានការអភិវឌ្ឍផ្នែកនេះដែរ។ ដូចដែលបានរៀបរាប់នៅ

ក្នុងចំណុច ៣.១.៦. ប្រជាជនជាច្រើនរូបទាំងស្រី ទាំងប្រុសមានគំនិត និងសំណូមពរដូចៗគ្នា គឺឱ្យលោកជំទាវរដ្ឋមន្ត្រី និងអាជ្ញាធរស្ថាប័នពាក់ព័ន្ធមេត្តាជួយជួសជុលកែលម្អ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវចូលមកក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដើម្បីសម្រួលដល់ការធ្វើដំណើរទេសចរឱ្យមានភាពងាយស្រួលផង ព្រោះនៅពេលដែលមានទេសចរមកកម្សាន្តច្រើន នោះពួកគាត់ដែលជាអាជីវករនឹងទទួលបានប្រាក់ចំណូលពីទេសចរណ៍កាន់តែប្រសើរជាងមុន ហើយពួកគាត់នឹងអាចផ្គត់ផ្គង់គ្រួសារព្រមទាំងបញ្ជូនកូនៗឱ្យចូលសាលារៀន ដើម្បីទទួលបានចំណេះដឹងទុកប្រើប្រាស់នៅក្នុងពេលអនាគត។

ដូចនេះហើយ មន្ទីរទេសចរណ៍ខេត្តកំពង់ធំ អភិបាលស្រុកប្រាសាទសំបូរ អាជ្ញាធរសំបូរព្រៃគុក អាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធទាំងឡាយគួរតែពួតដៃសហការគ្នាក្នុងការចូលរួមបន្តការចាក់បេតុងលុបផ្លូវដីក្រហមដែលខូចខាតសឹករិចរឹល ដើម្បីកាត់បន្ថយនិងលុបបំបាត់ការរអិលដួលម៉ូតូដែលអាចនឹងបង្កគ្រោះថ្នាក់ដល់អ្នកធ្វើដំណើរ។ បន្ទាប់ពីស្ថាបនាផ្លូវរួច អាជ្ញាធរពាក់ព័ន្ធក៏ត្រូវតែគិតគូរលើការអភិវឌ្ឍបន្ថែម ដោយលោកអាចតម្លើងបង្គោលភ្លើងនៅតាមសងខាងផ្លូវរាល់៥០-១០០ម៉ែត្រមួយ ដើម្បីសម្របសម្រួលដល់ការធ្វើដំណើររបស់ទេសចរនិងប្រជាជននៅពេលមេឃចុះងងឹត។ អាជ្ញាធរគួរតែបំពាក់នូវអំពូលតូចៗនៅជុំវិញផ្លាកសញ្ញាប្រាប់ទិសដើម្បីឱ្យអ្នកធ្វើដំណើរដឹងពីទិសដៅថាផ្លូវណាទៅណា ជៀសវាងការវង្វេងក្នុងព្រៃជ្រៅពិបាករកផ្លូវចេញវិញ។ ផងនោះដែរអាជ្ញាធរសំបូរព្រៃគុកគួរគិតគូរលើការសាងសង់ផ្លូវវាងមួយឱ្យឆ្ងាយពីតំបន់ប្រាសាទ សម្រាប់ឱ្យរថយន្តធន់ធំដឹកផ្លែឈើឬសម្ភារៈផ្សេងៗ ដើម្បីបញ្ឈប់រថយន្តទាំងនោះក្នុងការបរកាត់ពាក់កណ្តាលរមណីយដ្ឋាន ដែលអាចធ្វើឱ្យរញ្ជួយប្រាសាទនិងផ្តល់ផលប៉ះពាល់អវិជ្ជមានដល់សំណង់បុរាណនានានៅទីនោះ។

**៣.៣.២. ផ្នែកសេវាសាធារណៈ**

សេវាសាធារណៈជាសេវាកម្មមួយប្រភេទសម្រាប់បម្រើជូនទេសចរពេលមកដល់។ វាគឺជាផ្នែកមួយដ៏សំខាន់ក្នុងការទាក់ទាញទេសចរឱ្យមកកម្សាន្តក្នុងរមណីយដ្ឋានគោលដៅណាមួយ ព្រោះពេលដែលរមណីយដ្ឋានមួយមានសេវាសាធារណៈកាន់តែល្អនោះទេសចរកាន់តែចង់ចូលមក។ បើយើងងាកមកមើលខាងផ្នែកសេវាសាធារណៈនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកវិញ យើងអាចនិយាយបានថាសេវានៅទីនោះនៅមានភាពខ្វះខាតជាច្រើនដែលកំពុងរងចាំការកែលំអពីសំណាក់មន្ត្រីពាក់ព័ន្ធ។

យោងតាមក្រាហ្វិច ៣.១៩. ភាគរយទេសចរដែលយល់ឃើញថាផ្នែកសេវាសាធារណៈជាផ្នែកដែលគួរកែលំអមានរហូតដល់ទៅ៤៤% លើសពីផ្នែកផ្សេងៗទៀត។ នៅពេលចុះសម្ភាសផ្ទាល់ ក្រុមនិស្សិតយើងបានកំណត់សម្គាល់ឃើញថាបញ្ហាធំដែលទេសចរភាគច្រើនជួបប្រទះនោះគឺកង្វះបង្គន់សាធារណៈ ដែលមានគុណភាព និងអនាម័យត្រឹមត្រូវសម្រាប់ទេសចរប្រើប្រាស់ពេលត្រូវការ។ យោងតាមប្រសាសន៍របស់អ្នកមីងម្នាក់

ដែលបានធ្វើដំណើរមកកម្សាន្តតាំងពីភ្នំពេញបានឱ្យដឹងថា នៅពេលដែលគាត់មកដល់គាត់រកបន្ទប់ទឹកមិនឃើញទាល់តែសោះ ដូច្នេះគាត់ចង់ស្នើសុំឱ្យមន្ទីរទេសចរណ៍ ឬអាជ្ញាធរប្រចាំតំបន់ឱ្យកសាងបន្ទប់ទឹកផង បើសិនជាអាចគួរសាងសង់បន្ទប់ទឹកសាធារណៈនៅជិតប្រាសាទនីមួយៗ ដើម្បីសម្រួលសម្រួលដល់ទេសចរដូចជារូបគាត់ជាដើម។

យោងតាមការចុះទៅអង្កេតដោយផ្ទាល់ ក្រុមយើងខ្ញុំឃើញថា នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកមានបង្គន់សាធារណៈសម្រាប់ទេសចរ ប៉ុន្តែដោយសារតែវាស្ថិតនៅជ្រៅពេកទើបធ្វើឱ្យមនុស្សមួយចំនួនធំភណ្ឌច្រឡំថារមណីយដ្ឋាននេះមិនមានបង្គន់សាធារណៈទៅវិញ។ ទោះជាយ៉ាងណាមិញ នៅពេលដែលពួកយើងប្រើប្រាស់បន្ទប់ទឹកនោះ យើងអាចនិយាយបានថាកម្រិតអនាម័យវានៅមានភាពខ្វះខាតនៅឡើយ ដោយសារតែកង្វះអ្នកគ្រប់គ្រង និងសម្អាតឱ្យបានដឹតដល់។ ជាងនេះទៅទៀត ចំនួនបង្គន់អនាម័យមានតែ២ទេ ដែលចំនួននេះអាចបំពេញតម្រូវការបានត្រឹមតែទេសចរមួយភាគរយតូចប៉ុណ្ណោះ។ ថ្វីត្បិតតែបញ្ហាបង្គន់អនាម័យមិនត្រូវបានចាត់ទុកជាបញ្ហាធំក៏ដោយ ក៏ប៉ុន្តែជាក់ស្តែងវាបានតួយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយតំបន់ទេសចរណ៍ និងលើកមុខមាត់ប្រទេស។ ប្រទេសមួយចំនួនដូចជា ប្រទេសសិង្ហបុរី អាល្លឺម៉ង់ ជប៉ុន និងកាណាដាសុទ្ធសឹងតែជាប្រទេសដែលជាប់ឈ្មោះថាជាប្រទេសដែលមានបង្គន់អនាម័យស្អាតបំផុតនៅលើពិភពលោក។ ឧទាហរណ៍ ស្ទើរតែគ្រប់បន្ទប់ទឹកសាធារណៈទាំងអស់នៅក្នុងប្រទេសជប៉ុនត្រូវបានថែទាំយ៉ាងល្អ និងមានសណ្តាប់ធ្នាប់ ដើម្បីធានានូវផាសុកភាពជូនអ្នកធ្វើដំណើរមកកាន់ប្រទេសជប៉ុន ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះគឺបន្ទប់ទឹកទាំងនោះត្រូវបានបំពាក់ដោយបច្ចេកវិទ្យាទំនើបៗនិងបានបើកជូនឱ្យប្រើប្រាស់ដោយឥតគិតថ្លៃឡើយ។

**ក្រាហ្វិច ៣.២០. ការយល់ឃើញរបស់ទេសចរលើកន្លែងចតយានជំនិះ**



ក្រៅពីកង្វះបន្ទប់ទឹកសាធារណៈ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកក៏ជួបប្រទះនូវបញ្ហាមួយទៀតផង ដែរ គឺកង្វះកន្លែងចតយានជំនិះរបស់ទេសចរ។ យោងតាមក្រាហ្វិច ៣.២០. ទេសចរចំនួន២២នាក់ ដែលស្មើ នឹង៨៨% បានឆ្លើយថាចំណតយានជំនិះមិនមានគ្រប់គ្រាន់ទេ រីឯទេសចរ៣នាក់ទៀត ដែលត្រូវនឹង១២% បាន ពោលថាចំណត យានជំនិះមានគ្រប់គ្រាន់ហើយ។ បើយោងតាមសម្ដីរបស់បងប្រុសម្នាក់ដែលបានអញ្ជើញមក កម្សាន្តដោយម៉ូតូបានឱ្យដឹងថា នៅពេលគាត់មកដល់គាត់មិនបានឃើញកន្លែងផ្ញើម៉ូតូទេ ដូចនេះហើយ គាត់មិនដឹងត្រូវទុកនៅឯណាទេ មានតែចតនៅជាយបរិវេណប្រាសាទ។ បងប្រុសបានបន្តថា គាត់បារម្ភ ពីសុវត្ថិភាពយានជំនិះរបស់គាត់ណាស់នៅពេលដែលគាត់ទុកវាចោលរបៀបនេះ ដូច្នេះហើយអារម្មណ៍របស់ គាត់មិនមូលទេ ពោលគឺគាត់ទស្សនាប្រាង្គប្រាសាទនិងចម្លាក់បុរាណៗបណ្ដើរភ័យពីម៉ូតូគាត់បណ្ដើរ។ ហេតុ នេះហើយ បងប្រុសបានសំណូមពរទៅកាន់អាជ្ញាធរសំបូរព្រៃគុក គណៈកម្មការប្រតិបត្តិ និងអង្គការក្រៅ រដ្ឋាភិ បាលឱ្យជួយរៀបចំកសាងកន្លែងចតយានជំនិះបន្ថែមឱ្យកាន់តែច្រើន ដើម្បីផ្ដល់សុវត្ថិភាពជូនទេសចរពេលមក ដល់។

ជារួម មន្ទីរទេសចរណ៍ខេត្តកំពង់ធំ អភិបាលស្រុកប្រាសាទសំបូរ អាជ្ញាធរសំបូរព្រៃគុក គណៈកម្មការ ប្រតិបត្តិ ព្រមទាំងមន្ត្រីពាក់ព័ន្ធនានាគួរតែយកគម្រូតាមបរទេសក្នុងការបង្កើនចំនួនបង្គន់សាធារណៈ កន្លែងចត យានជំនិះ និងសេវាសាធារណៈផ្សេងៗទៀត ដើម្បីបង្កើនភាពងាយស្រួលដល់ទេសចរទាំងជាតិ និងអន្តរជាតិ ដែលបានមកកម្សាន្តក្នុងរមណីយដ្ឋាននេះផ្ទាល់។ នៅពេលដែលអភិវឌ្ឍចំណុចទាំងនេះរួចរាល់ រាជរដ្ឋាភិបាល គួរមានវិធានការច្បាស់លាស់ក្នុងការគ្រប់គ្រងគ្រឿងបរិក្ខារសាធារណៈទាំងនោះឱ្យគង់វង្ស ជៀសវាងការខូចខាត នានា។

### ៣.៣.៣. ផ្នែកបរិស្ថានអនាម័យ

ផ្នែកបរិស្ថានអនាម័យបានដើរតួយ៉ាងសំខាន់ក្នុងការទាក់ទាញទេសចរទាំងភ្ញៀវជាតិ និងអន្តរជាតិឱ្យ មកកម្សាន្តនៅរមណីយដ្ឋានណាមួយ ដូចនេះប្រទេសនីមួយៗគួរមានវិធានការក្នុងការគ្រប់គ្រងបរិស្ថានឱ្យបាន ខ្ជាប់ខ្ជួនមិនគួរធ្វេសប្រហែសឡើយ។ យោងតាមរយៈការចុះអង្កេតដោយក្រុមនិស្សិតយើងផ្ទាល់បានឱ្យឃើញថា ស្ថានភាពបរិស្ថានអនាម័យនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកស្ថិតនៅក្នុងកម្រិតបង្គួរ ដែលនៅមានចន្លោះ ប្រហោងបន្តិចបន្តួចដែលគួរតែពង្រឹងនិងកែលំអបន្ថែម។ ក្រឡេកមកមើលបញ្ហាសម្រាម បើទោះបីជាធុង សម្រាមមានច្រើនមែន ប៉ុន្តែវាមានតាមតំបន់តែប៉ុណ្ណោះ ដែលនេះជាហេតុធ្វើឱ្យបរិស្ថានអនាម័យមានភាពមិន មានសណ្ដាប់ធ្នាប់ត្រឹមត្រូវ។ លើសពីនេះទៀត ការធ្វើដំណើរមិនឈប់មិនឈរចូលក្នុងតំបន់រមណីយដ្ឋានក៏បង្ក

គុណវិបត្តិដែរ ដោយសារតែយានយន្តទាំងនោះបានបញ្ចេញកាបូនឌីអុកស៊ីតដែលជាឧស្ម័នមានជាតិពុល ដែលបណ្តាលឱ្យមានប៉ះពាល់ដល់ទេសចរ និងប្រជាពលរដ្ឋក្នុងសហគមន៍។

យោងតាមសម្តីរបស់បងស្រីដែលបានមកពីខេត្តព្រះសីហនុបានប្រាប់ក្រុមនិស្សិតយើងថាគាត់មិនសូវមានការពេញចិត្តនឹងស្ថានភាពបរិស្ថានទេ ព្រោះតែគាត់បានប្រទះឃើញសម្រាមជាច្រើននៅពេលដែលគាត់ធ្វើដំណើរចូលមកក្នុងរមណីយដ្ឋាននេះ។ មិនត្រឹមតែបងស្រីទេ សូម្បីតែទេសចរដទៃទៀតក៏បានលើកឡើងស្រដៀងៗគាត់ដែរ ដែលអ្នកទាំងនោះបាននិយាយថាធុងសម្រាមនៅក្នុងបរិវេណប្រាសាទមានច្រើនណាស់ ប៉ុន្តែនៅពេលចេញផុតពីនោះ ពួកគាត់មិនឃើញមានធុងសម្រាមដូចមុនទេ។ កត្តានេះបានធ្វើឱ្យទេសចរចាប់ផ្តើមបោះកាកសំណល់ពាសវាលពាសកាលជាលទ្ធផលវាបានបំផ្លាញដល់បរិស្ថានអនាម័យក្នុងតំបន់ទេសចរណ៍ប្រាសាទសំបូរព្រៃគុកនេះ។ ដោយហេតុនេះហើយទើប ទេសចរមួយចំនួនយល់ឃើញថាផ្នែកបរិស្ថានអនាម័យជាផ្នែកមួយដែលគួរកែលំអ ហើយពួកគាត់ក៏បានអំពាវនាវស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធគិតគូរលើបញ្ហាបរិស្ថានមួយទៀតដោយបង្កើនចំនួនធុងសម្រាម ដើម្បីបង្កភាពងាយស្រួលមកដល់ទេសចរ និងជួយរក្សាបរិស្ថានឱ្យប្រសើរជាងមុន។

ក្រៅពីទេសចរ ប្រជាពលរដ្ឋក្នុងសហគមន៍ក៏បានសម្តែងក្តីបារម្ភចំពោះបញ្ហាបរិស្ថាននៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដែរ។ អ្នកមីងម្នាក់ដែលជាអាជីវករលក់ភេសជ្ជៈបានប្រាប់មកពួកយើងថាចាប់តាំងពីប្រាសាទសំបូរព្រៃគុកត្រូវបានចុះបញ្ជីចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកដោយអង្គការយូណេស្កូមក គាត់សង្កេតឃើញចំនួនទេសចរទាំងជាតិ និងអន្តរជាតិមានការកើនឡើងច្រើនជាងមុន ដោយសារតែពួកគាត់ចង់ស្គាល់ពីប្រាសាទនេះ។ អ្នកមីងបានបន្តថាការកើនឡើងនេះបានផ្តល់ប្រយោជន៍យ៉ាងច្រើនអណេកដល់ជីវភាពគ្រួសារគាត់ ប៉ុន្តែអ្វីដែលគាត់បារម្ភនោះគឺការសឹករិចរឹលនៃសិលាចារឹកដែលត្រូវបានឆ្លាក់នៅលើស៊ុមទ្វា ឬឆ្លាក់រាក់ៗលើប្រាង្គប្រាសាទនានា ដែលយូរៗទៅអាចនឹងធ្វើឱ្យមានភាពរលុប និងបាត់បង់សោភណ្ឌភាពប្រាសាទដោយសាររតែទេសចរ រាប់ពាន់នាក់បានប៉ះវាកំឡុងពេលដើរទស្សនា។

ចំណែកឯបញ្ហារបំពុលខ្យល់ក៏ជាផ្នែកដ៏សំខាន់ដែលរាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធគួរយកចិត្តទុកដាក់ផងដែរ។ តាមការអង្កេតឃើញជាក់ស្តែងរបស់ក្រុមនិស្សិតយើងពេលទៅដល់បានឱ្យដឹងថា ដោយសារតែមួយភាគធំនៃផ្លូវចូលនៅជាផ្លូវដីក្រហមនៅឡើយ ដូច្នេះហើយវាមានភាពហ៊ុយយ៉ាងសម្បារនៅពេលដែលមានរថយន្ត ឬម៉ូតូជិះកាត់ក្នុងល្បឿនលឿន។ បញ្ហានេះមិនត្រឹមតែធ្វើឱ្យខូចខាតសម្រស់ និងភាពទេសទាញនៃតំបន់ទេសចរណ៍ទេ ប៉ុន្តែដីហ៊ុយ បូកផ្សំជាមួយនឹងឧស្ម័នមានជាតិពុលចេញពីយានជំនិះក៏អាចនឹងបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពប្រជាពលរដ្ឋដែលមានផ្ទះនៅជាប់ផ្លូវផងដែរ ដោយក្នុងរយៈវែងពួកគាត់អាចនឹងប្រឈម

មុខនឹងជម្ងឺខាងផ្លូវដង្ហើម សួត ថ្លើម និងសរីរាង្គដទៃផ្សេងៗទៀត។ ជាងនេះទៀត ដីហុយ និងឧស្ម័នពុលក៏អាច ប៉ះពាល់ដល់គុណភាពម្ហូបអាហារដែលបើកលក់ជូនទេសចរនៅទីនោះដែរ ប្រសិនបើអាជីវករមិនបានគ្រប ឬ ការពារឱ្យត្រឹមត្រូវទេ។ ជាលទ្ធផល ការបរិភោគអាហារដែល មានមេរោគអាចបណ្ដាលឱ្យអ្នកបរិភោគចាប់ផ្ដើម មានអាការៈជាច្រើនរួមមានមិនស្រួលខ្លួន ក្អួត ឬរាគជាដើម ហើយបើធ្ងន់ធ្ងរគឺត្រូវបញ្ជូនទៅមន្ទីរពេទ្យឯណោះ។

បែបនេះហើយមន្ទីរទេសចរណ៍ ក្រសួងបរិស្ថាន អភិបាលស្រុក អាជ្ញាធរ និងក្រុមព្រឹក្សាភិបាល ទាំងអស់គួរក្រឡេកមកយកចិត្តទុកដាក់លើបញ្ហាបរិស្ថានអនាម័យនៅក្នុងរមណីយដ្ឋានសំបូរព្រៃគុក ដោយជំហានដំបូងលោកអាចបង្កើនចំនួនធុងសម្រាមបន្ថែមដើម្បីឱ្យទេសចរងាយស្រួលក្នុងការទុកដាក់កាកសំណល់។ ការបំពាក់ធុងសម្រាមនេះមិនមែនធ្វើតែត្រឹមបរិវេណប្រាសាទទេ តែត្រូវដាក់នៅកន្លែងផ្សេងៗ បើអាចចន្លោះ៥០-១០០ម៉ែត្រមួយចាប់ពីច្រកចូលរហូតដល់ក្នុងរមណីយដ្ឋានតែម្ដង។ ការកាត់បន្ថយការចោលកាកសំណល់គ្មានសណ្ដាប់ធ្នាប់នេះអាចផ្ដល់ផលប្រយោជន៍យ៉ាងធំដល់ការការពារបរិស្ថានធម្មជាតិ ព្រោះកាកសំណល់មួយចំនួនដូចជាកញ្ចប់អាហារដែលបរិភោគរួច ដបប្លាស្ទិក កំប៉ុងភេសជ្ជៈ និងថង់គ្រឿងទេសនានាមានផ្ទុកសារធាតុពុល ឬសារធាតុគីមី និងត្រូវការពេលវេលាយូរក្នុងការរំលាយ ហើយបើសិនជាវាបក់តាមខ្យល់ចូលទៅក្នុងទឹក នោះវានឹងអាចបំពុលទឹក និងសត្វក្នុងទឹកផងដែរ។ ឯកាកសំណល់ ដូចជាកន្ទុយបារីវិញ បើបោះចោលមិនត្រឹមត្រូវស្របពេលដែលវាមិនទាន់រលត់ទាំងស្រុងអាចបង្កជាភ្លើង និងបណ្ដាលឱ្យមានភ្លើងឆេះព្រៃក៏ថាបាន។ នៅពេលធុងសម្រាមត្រូវបានដាក់ជូនទេសចរហើយ នាយកដ្ឋានទេសចរណ៍វប្បធម៌និងបរិស្ថាន រួមជាមួយនឹងអាជ្ញាធរពាក់ព័ន្ធគួរតែចេញវិធានការនៅក្នុងការពង្រឹងបរិស្ថានតាមរយៈការផ្សព្វផ្សាយចំណេះដឹងទាក់ទងទៅនឹងគុណវិបត្តិនៃការបំផ្លាញបរិស្ថាន និងលើកទឹកចិត្តអាជីវករទាំងអស់ឱ្យចូលរួមថែរក្សា និងចេះស្រលាញ់បរិស្ថានដែលនៅជុំវិញខ្លួន ដើម្បីជៀសវាងការស្ដាយក្រោយនៅពេលបាត់បង់។ អ្វីដែលអាជីវករអាចធ្វើគឺត្រូវទុកដាក់កាកសំណល់ខ្លួនឱ្យមានសណ្ដាប់ធ្នាប់ និងត្រូវមានធុងសម្រាមគ្រប់គ្រាន់នៅក្នុងហាងរបស់ខ្លួនសម្រាប់ភ្ញៀវ។ សម្រាប់ទេសចរ និងប្រជាពលរដ្ឋក្នុងសហគមន៍វិញក៏ដូចគ្នា គឺអាជ្ញាធរពាក់ព័ន្ធអាចបង្កើតជាកម្មវិធីអប់រំតាមផ្ទះ ឬសហការជាមួយនឹងមគ្គុទេសក៍ទេសចរណ៍ដើម្បីលើកស្ទួយចំណេះដឹងទាក់ទងនឹងការការពារបរិស្ថាន។ បើសិនជាវិធានការទន់មិនទទួលបានលទ្ធផលដូចការរំពឹងទុក រាជរដ្ឋាភិបាលអាចណែនាំយន្តការណ៍ថ្មី គឺការផាកពិន័យលើបុគ្គលណាដែលចោលសម្រាមផ្ដេសផ្ដាសក្រៅធុងសម្រាម ដើម្បីគម្រាមដល់បុគ្គលដទៃកុំឱ្យយកគម្រូតាម។ រាជរដ្ឋាភិបាលអាចយកគម្រូតាមប្រទេសមួយចំនួនដូចជា អាល្លឺម៉ង់ អូទ្រីស កូរ៉េខាងត្បូង និងស្វីស ដែលប្រទេសទាំងនេះសុទ្ធសឹងតែជាប្រទេសឆ្នើមក្នុងការគ្រប់គ្រង និងកែច្នៃកាកសំណល់របស់ខ្លួន។ ជាឧទាហរណ៍ នៅអាល្លឺម៉ង់រាជរដ្ឋាភិបាលបានដាក់ធុងសម្រាមគ្រប់កន្លែង ជាពិសេសនៅតំបន់មានមនុស្សច្រើន

ដូចជា ទីប្រជុំជន ផ្សារទំនើប និងតំបន់ទេសចរណ៍។ ទន្ទឹមនឹងនោះ ធុងសម្រាមក៏ត្រូវបានបែងចែកជាប្រាំមួយពណ៌ផ្សេងៗគ្នា ដែលពណ៌នីមួយៗប្រាប់អ្នកប្រើប្រាស់នូវប្រភេទកាកសំណល់ដែលពួកគេអាចដាក់ចូលក្នុងធុងនោះ។ ការធ្វើបែបនេះមិនត្រឹមតែអាចជួយសម្រួលពេលវេលាប្រជាពលរដ្ឋ និងជួយថែរក្សាបរិស្ថានប៉ុណ្ណោះទេ តែសម្រាមទាំងនោះក៏អាចយកទៅកែច្នៃផលិតជាសម្ភារៈប្រើប្រាស់ម្តងទៀតផងដែរ។

រីឯបញ្ហាការសឹករិចរឹលនៃសំណង់ប្រាសាទវិញ អាជ្ញាធរសំបូរព្រៃគុក និងគណៈកម្មការប្រតិបត្តិគួរធ្វើផ្លាក ដើម្បីរារាំងទេសចរទាំងជាតិ និងអន្តរជាតិមិនឱ្យប៉ះពាល់ ឬយកវត្ថុមុតស្រួចទៅកកិតជាមួយនឹងសិលាចារឹកណាមួយឡើយ ព្រោះទង្វើនេះអាចបំផ្លាញកេរ្តិ៍ដំណែលដែលបានបន្សល់មកតាំងពីយូរលង់ណាស់មកហើយ។ ជាមួយគ្នានោះដែរ ការថតដោយកាមេរ៉ា ឬទូរស័ព្ទក៏គួរតែមានកម្រិតផងដែរ ព្រោះពន្លឺដែលចេញពីឧបករណ៍ទាំងអស់នោះក៏អាចបន្សល់នូវផលប៉ះពាល់ក្នុងរយៈពេលវែងដែរ ដោយវាអាចធ្វើឱ្យសឹកបន្តិចម្តងៗ។ ចំណែកបញ្ហាធូលី និងឧស្ម័នពុលចេញពីយានជំនិះ រាជរដ្ឋាភិបាលអាចកែលម្អផ្លូវ និងបន្តការចាក់បេតុង ដើម្បីកាត់បន្ថយការហ៊ុយពាសពេញផ្លូវ និងចូលច្រមុះប្រជាពលរដ្ឋនិងទេសចរដែលធ្វើដំណើរកាត់នោះ ដែលអាចនាំឱ្យមានផលប៉ះពាល់ដល់សុខភាព។ ជាងនេះទៀត មន្ត្រីពាក់ព័ន្ធគួរកាត់បន្ថយឡានធន់ធំៗក្នុងការធ្វើដំណើរកាត់រមណីយដ្ឋាននេះ ព្រោះរថយន្តទាំងនោះភាគច្រើនមានសភាពចាស់ និងបញ្ចេញផ្សែងពុលច្រើនហួសពីយានយន្ត និងទោចក្រយានយន្តប្រភេទផ្សេងៗ។

ដូចនេះ វិធានការដែលបានរៀបរាប់ខាងលើសុទ្ធតែជាវិធានការដែលរាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធគួរតែអនុវត្ត ដើម្បីពង្រឹងសោភណ្ឌភាពរបស់រមណីយដ្ឋាន និងទាក់ទាញទេសចរឱ្យមកកម្សាន្តកាន់តែច្រើនជាមុន ព្រោះកត្តាបរិស្ថាន ព្រមទាំងអនាម័យគឺជាចំណុចដំបូងដែលទេសចរគិតគូរមុនពេលដែលពួកគេសម្រេចចិត្តទៅកម្សាន្តនៅតំបន់ ទេសចរណ៍ណាមួយ។

### ៣.៣.៤. ផ្នែកសន្តិសុខ និងសុវត្ថិភាព

បញ្ហាសន្តិសុខ និងសុវត្ថិភាពជាចំណុចមួយដ៏សំខាន់ក្នុងការអូសទាញទេសចរឱ្យមកកម្សាន្តនៅទីកន្លែងណាមួយ។ ដូចដែលបានឃើញជាក់ស្តែង តំបន់ទេសចរណ៍ដែលស្ថិតនៅក្នុងប្រទេសកំពុងមានសង្គ្រាម ឬភាពចលាចលតែងតែទទួលបានទេសចរចូលទៅទស្សនាតិចជាងប្រទេសដែលមានសន្តិសុខ និងសុវត្ថិភាព នេះមកពីទេសចរទៅកម្សាន្តព្រោះចង់បានភាពសប្បាយរីករាយត្រលប់មកវិញ មិនមែនគ្រោះថ្នាក់ដែលអាចនឹងបន្សល់ស្លាកស្នាមដល់រាងកាយ និងផ្លូវចិត្តនោះទេ។ កត្តាមួយនេះបានសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថាផ្នែកសន្តិសុខនិងសុវត្ថិភាពពិតជាមានសារសំខាន់ណាស់ ដោយសារតែវាអាចកំណត់ភាពជោគជ័យ ឬបរាជ័យនៃគោលដៅទេសចរណ៍បាន។

ចំពោះករណីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកវិញ យោងតាមការសម្ភាសជាមួយប្រជាជនពលរដ្ឋក្នុងតំបន់បានឱ្យដឹងថា បញ្ហាអសន្តិសុខមួយចំនួនដូចជាអំពើចោរកម្ម ឆក់ ប្លន់ ឬការចាក់សម្លាប់គ្នាផ្សេងៗកម្រនឹងកើតមាននៅក្នុងបរិវេណរមណីយដ្ឋានណាស់ ដោយសារតែបុគ្គលម្នាក់ៗមានការងារសុចរិតត្រឹមត្រូវរៀងៗខ្លួន។ ប៉ុន្តែទន្ទឹមនឹងនោះកងកម្លាំងដែលមានភារកិច្ចក្នុងការគ្រប់គ្រងប្រាសាទ និងថែរក្សាសុវត្ថិភាពជូនទេសចរ និងប្រជាពលរដ្ឋក្នុងតំបន់នៅមានភាពខ្វះខាតនៅឡើយ ព្រោះតែក្នុងរមណីយដ្ឋានទាំងមូលមានឆ្មាំការពារត្រឹមតែប៉ុន្មាននាក់ប៉ុណ្ណោះ ខណៈដែលប្រាសាទមានរហូតដល់រាប់រយ។

ដូចនេះ រាជរដ្ឋាភិបាល មន្ទីរទេសចរណ៍ខេត្ត និងអាជ្ញាធរពាក់ព័ន្ធគ្រប់កម្រិតថ្នាក់គួរតែផ្តួចផ្តើមគំនិតបង្កើតយន្តការណ៍ក្នុងការប្រមូលសមាជិកក្នុងសហគមន៍ឱ្យហ្វឹកហ្វាត់ ដើម្បីចូលខ្លួនមកបម្រើការជូនទេសចរទាំងជាតិ និងអន្តរជាតិ ព្រមទាំងប្រជាជនទាំងអស់ក្នុងភូមិសំបូរ។ វត្តមានរបស់កងកម្លាំងទាំងនោះមានសារសំខាន់យ៉ាងខ្លាំងក្នុងការឃ្លាំមើលសកម្មភាពរបស់ទេសចរ ដោយពួកគាត់អាចប្រាប់ដាស់តឿនប្រសិនបើទេសចរធ្វើរឿងមិនគម្បីក្នុងប្រាសាទដូចជា ចតយានជំនិះក្នុងបរិវេណប្រាសាទ ចោលសម្រាម បរិភោគក្នុងទីធ្លាប្រាសាទ សរសេរលើប្រាង្គសិលាចារឹក ឬឡើងលើប្រាសាទជាដើមដែលទង្វើទាំងនេះសុទ្ធតែជាទង្វើងមិនសមគួរឡើយ។ លើសពីនេះទៀត អាជ្ញាធរគួរតែបិទផ្លាកសញ្ញានៅកន្លែងទាំងឡាយណាដែលអាចនឹងបង្កគ្រោះថ្នាក់ ព្រោះការធ្វើបែបនេះនឹងអាចក្រើនរំលឹកឱ្យទេសចរទាំងអស់បន្ថែមការប្រុងប្រយ័ត្នរាល់ពេលដើរកម្សាន្ត។ រាជរដ្ឋាភិបាលអាចយកគម្រូតាមប្រទេសអង់គ្លេស ដែលនៅទីនោះនៅគ្រប់តំបន់ទេសចរណ៍ទាំងអស់សុទ្ធតែមានផ្លាកឱ្យដំណឹងមកកាន់ទេសចរដូចជា ផ្លាកប្រាប់ឱ្យប្រយ័ត្នការរអិលដួល ការពារសត្វកាចសាហាវ ប្រាំងថ្មចោទ ឬប្រយ័ត្នទឹកជ្រៅជាដើម។ ផងនោះដែរ ដើម្បីឱ្យផ្លាកសញ្ញានោះមានប្រសិទ្ធភាព អាជ្ញាធរដែលទទួលបន្ទុករៀបចំក៏ត្រូវយល់ដឹងពីកន្លែងដែលត្រូវដាក់តាំងផ្លាកនោះដែរ ពោលគឺផ្លាកសញ្ញាសុវត្ថិភាពត្រូវតែតាំងនៅកម្ពស់ខ្ពស់ល្មមផុតពីក្បាលអ្នកធ្វើដំណើរ ហើយនិមិត្តសញ្ញា អក្សរ និងពណ៌ត្រូវមានសភាពច្បាស់ល្អ ដើម្បីឱ្យទេសចរមានភាពងាយស្រួលក្នុងការមើលឃើញ និងដឹងពីសភាពការណ៍មុន។ ជាងនេះទៀត អាជ្ញាធរប្រចាំតំបន់គួរតែបង្កើតស្តង់ពេទ្យតូចមួយដែលមានបុគ្គលិកជំនាញ៣-៤នាក់ និងឡានសាម៉ុយមួយសម្រាប់សង្គ្រោះដល់ទេសចរក្នុងករណីដែលពួកគាត់រងគ្រោះថ្នាក់ដោយយថាហេតុណាមួយ។ ទន្ទឹមនឹងនោះ អាជ្ញាធរក៏គួរតែមានរថយន្តពន្លត់អគ្គិភ័យនៅប្រចាំការនៅទីនោះដែរ ដើម្បីការពារនៅពេលដែលមានភ្លើងផ្សេងឆេះឡើង។ ជាក់ស្តែង ការឆាប់ឆេះនេះពិតជាកម្រនឹងកើតឡើងណាស់ ប៉ុន្តែដូចអ្វីដែលសុភាសិតខ្មែរបានលើកឡើង "ការពារប្រសើរជាងព្យាបាល"។

## ៣.៤. យន្តការគ្រប់គ្រងនៃខេត្តកំពង់ធំ

### ៣.៤.១. មន្ទីរទេសចរណ៍ខេត្តកំពង់ធំ

នៅក្នុងការគ្រប់គ្រងខេត្តទាំងមូល មន្ទីរទេសចរណ៍ខេត្តកំពង់ធំមួយត្រូវបានបង្កើតឡើង ដោយអនុលោមតាមប្រកាសលេខ ១២៣ ចុះថ្ងៃអង្គារ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ កក្កដា ឆ្នាំ២០១៩។ ផ្អែកតាមប្រកាសនេះគឺមន្ទីរទេសចរណ៍ខេត្តកំពង់ធំមានទម្រង់ដូចខាងក្រោមៈ




យោងតាមប្រការ៣ នៃការប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្តបានឱ្យដឹងថា មន្ទីរទេសចរណ៍រាជធានីខេត្តជាសេនាធិការឱ្យក្រសួងទេសចរណ៍ទទួលបន្ទុកអនុវត្ត គ្រប់គ្រង តាមដាន ត្រួតពិនិត្យ វាយតម្លៃ រៀបចំផែនការអភិវឌ្ឍន៍ ពង្រឹងគុណភាពផលិតផល អាជីវកម្ម និងសេវាកម្មទេសចរណ៍ សំដៅធានាដល់ការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ។

យោងតាមប្រការទី៤ មន្ទីរទេសចរណ៍ខេត្តកំពង់ធំមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍវិស័យទេសចរណ៍នៅថ្នាក់ក្រោមជាតិ
- រៀបចំគម្រោងអភិវឌ្ឍន៍ទេសចរណ៍ តាមតំបន់អាទិភាពទេសចរណ៍នៅក្នុងខេត្ត ដោយសហការជាមួយមន្ទីរ អង្គការ និងផ្នែកពាក់ព័ន្ធដទៃទៀតដើម្បីដាក់ជូនរដ្ឋបាលខេត្ត និងក្រសួងទេសចរណ៍ពិនិត្យ និងសម្រេច
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងផែនការបណ្ដុំបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងរដ្ឋ និងឯកជន ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច
- គ្រប់គ្រង ត្រួតពិនិត្យព័ត៌មានទេសចរណ៍ និងជំរុញចលនាទេសចរណ៍ក្នុងស្រុកនៅក្នុងខេត្ត
- គ្រប់គ្រងរមណីយដ្ឋានទេសចរណ៍ អាជីវកម្មទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតដែលបម្រើអោយវិស័យទេសចរណ៍
- គ្រប់គ្រង និងថែរក្សាតំបន់ទេសចរណ៍ មណ្ឌលទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ កសិទេសចរណ៍ និងអេកូទេសចរណ៍ក្នុងខេត្ត
- គ្រប់គ្រង និងរៀបចំក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ មុខដំណែង គ្រឿងឥស្សរិយយស និងប្រព័ន្ធលាភការផ្សេង ទៀតរបស់មន្ត្រីរាជការក្រោមឱវាទ
- គ្រប់គ្រងស្ថានភាពចំណូលចំណាយហិរញ្ញវត្ថុនៅក្នុងមន្ទីរ ស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ
- អនុវត្តគោលនយោបាយ គោលការណ៍ ប្រកាស សារាចរ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតរបស់ក្រសួងទេសចរណ៍ ដើម្បីរក្សានិរន្តភាពវិស័យទេសចរណ៍ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីលើកកម្ពស់ និងជំរុញចលនាប្រឡងប្រណាំង" ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិយទេសចរណ៍ និងស្តង់ដាទេសចរណ៍
- ចូលរួម និងជំរុញការអនុវត្តយន្តការ និងនីតិវិធីនៅថ្នាក់ក្រោមជាតិដើម្បីពិនិត្យ និងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្ម និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងទំនៀមទម្លាប់ប្រពៃណីដែលជាមូលដ្ឋានបម្រើវិស័យទេសចរណ៍ក្នុងខេត្ត

- ទាក់ទងជាមួយវិនិយោគិន និងដៃគូអភិវឌ្ឍន៍នានាក្នុងគោលបំណងទាក់ទងការវិនិយោគ និងការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងខេត្ត

- សិក្សាស្រាវជ្រាវទីផ្សារទេសចរណ៍ និងផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ដែលមាននៅក្នុងមូលដ្ឋាន

- លើកសំណើ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងក្នុងការកែលម្អ និងអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្ត ដោយមានការគាំទ្រពីរដ្ឋបាលខេត្ត និងអាជ្ញាធរមូលដ្ឋាន

- ធ្វើកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេរភាគី ពហុភាគី អាស៊ាន តំបន់ និងអនរជាតិ

- សហការរៀបចំកិច្ចប្រជុំ ព្រឹត្តិការណ៍ និងសន្និសីទទេសចរណ៍ថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ

- សហការជាមួយក្រសួងស្ថាប័នរដ្ឋបាលខេត្ត មន្ទីរ និងអង្គការពាក់ព័ន្ធនានាក្នុងការអនុវត្តវិធានការចំពោះប្រតិបត្តិករទេសចរណ៍ដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ទេសចរណ៍ និងបទប្បញ្ញត្តិជាធរមាន

- សហការគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្ម ផលិតកម្ម សេវាកម្ម និងប្រតិបត្តិករទេសចរណ៍ធានាបាននូវប្រសិទ្ធភាព គុណភាព និរន្តភាព របៀបរៀបរយ អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ

- សហការពង្រឹងនិងចាត់វិធានការចាំបាច់ទាក់ទងនឹងការរក្សាសន្តិសុខនិងសុវត្ថិភាពទេសចរកិច្ចការសង្គ្រោះបឋម និងបន្ទាន់នៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍នានា

- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការគ្រប់គ្រង និងរៀបចំចងក្រងទិន្នន័យស្ថិតិទេសចរណ៍

- សហការជាមួយរដ្ឋបាលខេត្ត មន្ទីរ អង្គភាព និងស្ថាប័នពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការផលិត ការនាំចូល ការចែកចាយ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន និងការជួញដូរស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍ ព្រមជាមួយនឹងការបញ្ជ្រាបការយល់ដឹងពីជំងឺអេដស៍ និងបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍

- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំ

- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីក្រសួងទេសចរណ៍។

មន្ទីរទេសចរណ៍ខេត្តកំពង់ធំ មានការិយាល័យចំណុះចំនួន០៦( ប្រាំមួយ) ដូចតទៅៈ

១. ការិយាល័យរដ្ឋបាល បុគ្គលិក ហរិញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ

២. ការិយាល័យផែនការ វិនិយោគ និងអភីវឌ្ឍន៍ផលិតផលទេសចរណ៍

៣. ការិយាល័យគ្រប់គ្រង់ឧស្សាហកម្មទេសចរណ៍

៤. ការិយាល័យអប់រំបណ្តុះបណ្តាល

៥. ការិយាល័យព័ត៌មានទេសចរណ៍ និងផ្សព្វផ្សាយទេសចរណ៍

៦. ការិយាល័យទីក្រុងស្អាត[45]។

ចំពោះតួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗអាចរកបាននៅក្នុងឧបសម្ព័ន្ធ។

**៣.៤.២. សហគមន៍សំបូរព្រៃគុក**

យោងទៅតាមសម្តីរបស់លោកប្រធានសហគមន៍សំបូរព្រៃគុកបានឱ្យដឹងថា នៅក្នុងសហគមន៍មានផែនការ៥ឆ្នាំ ដែលផែនការនេះសំដៅទៅលើលក្ខន្តិកៈនៅក្នុងការជ្រើសរើសប្រធានគណៈកម្មការប្រតិបត្តិនូវរៀងរាល់៥ឆ្នាំម្តងតាមរយៈការបោះឆ្នោត ដើម្បីបន្តការគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ឱ្យកាន់តែមានវិវឌ្ឍភាព។ លក្ខន្តិកៈទាំងនោះត្រូវបានកែប្រែមួយចំនួន ជាពិសេសនៅកន្លែងដែលមិនសមស្របនឹង។ ជាឧទាហរណ៍កាលមុនសហគមន៍មានតួនាទីជាច្រើន រួមទាំងការអភិរក្សតំបន់សំបូរព្រៃគុកដូចជា ការដាំដុះបន្ថែម ការត្រួសព្រៃ សម្អាតតំបន់ ព្រមទាំងបង្កើតសេវាកម្មជូនទេសចរណ៍។ ប៉ុន្តែបន្ទាប់ពីអាជ្ញាធរជាតិសំបូរព្រៃគុក ដែលត្រូវបានបញ្ជូនមកពីថ្នាក់ក្រសួងចូលមក សហគមន៍ក៏បានផ្លាស់ប្តូរនូវផែនការរបស់ខ្លួនមកត្រឹមគ្រប់គ្រង និងអភិវឌ្ឍវិញ ដើម្បីកុំឱ្យធ្វើការជាន់គ្នា។ យ៉ាងណាមិញ សហគមន៍នៅតែបន្តធ្វើជាដៃគូសហការនៅក្នុងការចូលរួមអភិរក្សតំបន់ គ្រាន់តែសហគមន៍មិនរ៉ាប់រងក្នុងការអភិរក្សតំបនើទាំងស្រុងដូចមុន។

ជំហានដំបូងនៅក្នុងការបោះឆ្នោតជ្រើសរើសគណៈកម្មការប្រតិបត្តិគឺគេត្រូវតែងតាំងមនុស្ស២រូប ទាំងស្រីនិងប្រុសនៅតាមភូមិនីមួយៗ ប្រសិនបើការតែងតាំងនេះអាចទទួលយកបាន អ្នកភូមិទាំងអស់នឹងការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនក្នុងភូមិ។

គណៈកម្មការប្រតិបត្តិមានសមាជិកចំនួន១០រូប ដែលក្នុងនោះមានស្ត្រីយ៉ាងតិច៣រូប មកពីភូមិដូចខាងក្រោម៖

- អ្នកតំណាង ភូមិពោធិទ្រេត១រូប ភូមិកំពង់ឈើទាល២រូប ភូមិសំរឹទ្ធ១រូប ភូមិសំបូរ២រូប ភូមិអូរគ្រូកែ២រូប ភូមិជាយសំពៅ១រូប និងភូមិអាត់ស៊ូ១រូប។

លើសពីនេះ គណៈកម្មការប្រតិបត្តិមានទីប្រឹក្សាមកពី៖

- សមាជិកក្រុមប្រឹក្សាស្រុក២រូប
- សមាជិកក្រុមប្រឹក្សាឃុំ៣រូប
- អភិរក្សចំនួន១រូប
- ទេសចរណ៍ចំនួន១រូប។

តួនាទីរបស់គណៈកម្មការប្រតិបត្តិមានដូចខាងក្រោម៖

[45] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, ២០១៩

- អភិវឌ្ឍវិស័យទេសចរណ៍វប្បធម៌ និងធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍។ ពន្យល់អ្នកភូមិអំពីទស្សនៈនៃការបង្កើតទេសចរណ៍វប្បធម៌ និងធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍ជំរុញលើកទឹកចិត្តដល់ការចូលរួមរបស់អ្នកភូមិក្នុងតំបន់។
- ផ្តល់ព័ត៌មានពីអ្វីដែលគណៈកម្មការប្រតិបត្តិបានប្រជុំពិភាក្សា និងពាំនាំការផ្តល់យោបល់អ្នកភូមិទៅដល់គណៈកម្មការវិញ។
- រៀបចំគ្រប់គ្រង និងអនុវត្តទេសចរណ៍វប្បធម៌ធម្មជាតិ និងការអភិរក្សប្រាសាទទាំងឡាយដែលគ្រប់គ្រងដោយសហគមន៍
- ចរចារនឹងអ្នកដែលពាក់ព័ន្ធសំខាន់ៗសម្រាប់ទេសចរណ៍វប្បធម៌ធម្មជាតិ និងការអភិរក្សប្រាសាទដែលគ្រប់គ្រងដោយសហគមន៍ដូចជា រដ្ឋអំណាច ម្ចាស់ដីកម្មសិទ្ធ និងអង្គការក្រៅរដ្ឋាភិបាលជាដើម[46]។

សម្រាប់តួនាទី និងភារកិច្ចរបស់ទីប្រឹក្សារបស់គណៈកម្មការប្រតិបត្តិអាចរកបាននៅក្នុងឧបសម្ព័ន្ធ។

[46] លក្ខន្តិកៈគណៈកម្មការប្រតិបត្តិសហគមន៍អភិរក្សនិងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំ, ទំព័រ ៣-៤

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ និងវិភាគលើទិន្នន័យដែលទទួលបានពីប្រភពសំខាន់ៗមួយចំនួន រួមផ្សំនឹងការចុះទៅសម្ភាសដោយផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋក្នុងសហគមន៍ និងទេសចរបានឱ្យដឹងបង្ហាញឱ្យឃើញរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកត្រូវបានអភិវឌ្ឍ និងកែប្រែឱ្យក្លាយជាគោលដៅទេសចរណ៍មួយដ៏មានប្រជាប្រិយនៅក្នុងព្រះរាជាណាចក្រកម្ពុជាបន្ទាប់ពីរមណីយដ្ឋាននេះត្រូវដាក់បញ្ចូលទៅក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក។ ដូចដែលបានឃើញជាក់ស្ដែង ទេសចរទាំងជាតិនិងអន្តរជាតិមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែភាពអស្ចារ្យនៃប្រាង្គប្រាសាទ និងទេសភាពដ៏ស្រស់បំព្រងនៅទីនោះ។

ទោះបីជារមណីយដ្ឋានប្រាសាទសំបូរព្រៃគុកមានភាពទាក់ទាញយ៉ាងណាក៏ដោយ យោងទៅតាមការសិក្សា និងអង្កេតយ៉ាងល្អិតល្អន់មក យើងឃើញថារមណីយដ្ឋាននេះនៅមានចន្លោះខ្វះខាតមួយចំនួនដែលទាមទារឱ្យស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធចូលរួមនៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍដើម្បីពង្រឹងសោភណ្ឌភាព និងសក្ដានុពលទេសចរណ៍នៃតំបន់នេះ។ ចំណុចខ្វះខាតទាំងនោះរួមមាន ផ្នែកហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈរួមមានបង្គន់អនាម័យ និងចំណត យានយន្ត ការគ្រប់គ្រងបញ្ហាបរិស្ថានអនាម័យ និងកង្វះកងកម្លាំងក្នុងការថែរក្សាសន្តិសុខ និងសុវត្ថិភាពក្នុងតំបន់។ នេះសុទ្ធសឹងតែជាបញ្ហាដែលត្រូវការឱ្យរាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធស្វែងរកវិធីសាស្ត្រថ្មីៗមកអនុវត្តក្នុងគោលបំណងកែលំអចំណុចខ្វះខាត ដើម្បីទាញមកវិញនូវលទ្ធផលល្អដែលអាចផ្ដល់ផលប្រយោជន៍ដល់គ្រប់ភាគីពាក់ព័ន្ធនិងថែរក្សារមណីយដ្ឋានប្រាសាទសំបូរព្រៃគុកក្នុងពេលដំណាលគ្នា។

សរុបមក បន្ទាប់ពីបានរៀបរាប់ និងសិក្សាយ៉ាងលម្អិតក្នុងជំពូកទី៣មក ក្រុមនិស្សិតយើងយល់ថារមណីយដ្ឋានប្រាសាទសំបូរព្រៃគុកនៅមានផ្នែកមួយចំនួនដែលត្រូវការអភិវឌ្ឍបន្ថែម ដើម្បីកែប្រែកន្លែងនិងកែច្នៃទេសចរណ៍មួយនេះឱ្យដើរលើមាគ៌ាជោគជ័យ និងក្លាយជារមណីយដ្ឋានឆ្នើមមួយដែលទេសចរចង់មកកម្សាន្តក្រោយពេលដែលលើឈ្មោះ "រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក" ហើយ។

## ២. ការផ្ដល់អនុសាសន៍

ដើម្បីគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកឱ្យក្លាយទៅជាគោលដៅទេសចរណ៍ដ៏មានសក្ដានុពល និងដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតដែលកើតមាន យើងខ្ញុំសូមចូលរួមក្នុងការបញ្ចេញមតិយោបល់មួយចំនួនដូចខាងក្រោមៈ

- **បង្កើនកិច្ចសហប្រតិបត្តិការ៖** អាជ្ញាធរប្រចាំស្រុកសំបូរគួរតែសហការជាមួយនឹងស្ថាប័នពាក់ព័ន្ធដូចជា មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ និងមន្ត្រីដទៃទៀតក្នុងគោលបំណងពិភាក្សា លើការកែលំអផ្លូវ ជាពិសេសផ្លូវចូលរមណីយដ្ឋាន ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ទេសចរ និងជួសជុលប្រាង្គប្រាសាទទាំងឡាយណាដែលមានសភាពបាក់បែក ដើម្បីរក្សាសុវត្ថិភាពទេសចរពេលកំពុងចូលទស្សនា។
- **បង្កើនសេវាទេសចរណ៍៖** អាជ្ញាធរពាក់ព័ន្ធគួរសាងសង់សម្បទារទេសចរណ៍បន្ថែមដូចជា បង្គន់អនាម័យ ចំណតយានយន្ត ព្រមទាំងជំរុញពលរដ្ឋសហគមន៍ឱ្យសង់ផ្ទះស្នាក់តាមបែបសហគមន៍ដែលមានស្តង់ដា និងអនាម័យត្រឹមត្រូវគុណសម្រាប់បម្រើទេសចរពេលមកដល់។
- **ការអប់រំ និងបណ្តុះបណ្តាល៖** អាជ្ញាធរពាក់ព័ន្ធគួរបង្កើតកម្មវិធីបណ្តុះបណ្តាលជូនប្រជាជនក្នុងតំបន់ទាក់ទង នឹងការថែរក្សាបរិស្ថាន ការបម្រើសេវាជូនភ្ញៀវប្រកបដោយជាសុកភាព ការបង្ហាត់បង្រៀនភាសាក្នុងការទំនាក់ទំនងនិងការផ្តល់បដិសណ្ឋារកិច្ចជូនភ្ញៀវ ព្រមទាំងបង្រៀននូវជំនាញនានាដូចជា ជំនាញធ្វើម្ហូបអាហារ គ្រឿងទេស ឬភេសជ្ជៈ ដើម្បីទទួលបានផលប្រយោជន៍ពីទេសចរណ៍។

# ឯកសារយោង

✦ **ឯកសារជាភាសាខ្មែរ**


១. សួនវ៉ានី, ២០០៦, ទ្រឹស្តីនិងទស្សនៈមូលដ្ឋាន, ភ្នំពេញ

២. សួនវ៉ានី និង សហការី, ២០១២, និរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍, ភ្នំពេញ

២. ជួន ណាត, ២០០៩, វចនានុក្រមខ្មែរ, ភ្នំពេញ

៣. ហុង វណ្ណៈ, ឈុន ពហុ, និង សហការី, ២០១៣, លំនាំដើមទេសចរណ៍

៤. ហុង វណ្ណៈ, ជា ស៊ីថា និងសាំង ចន្ទូ, ២០១៤, សេចក្តីផ្តើមទេសចរណ៍, ភ្នំពេញ

៥. ព្រះរាជាណាចក្រកម្ពុជា, ២០០៩, ច្បាប់ស្តីពីទេសចរណ៍, ភ្នំពេញ

៦. ក្រសួងទេសចរណ៍, ២០១៧, ផែនការអភិវឌ្ឍន៍ទេសចរណ៍របស់ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ២០១៧-២០២៥, ភ្នំពេញ

៧. មន្ទីរទេសចរណ៍ខេត្តកំពង់ធំ, ២០២២, របាយការណ៍បូកសរុបលទ្ធផលការងារទេសចរណ៍ប្រចាំឆ្នាំ ២០២១, កំពង់ធំ

៨. គណៈកម្មការប្រតិបត្តិសហគមន៍ប្រាសាទសំបូរព្រៃគុក, ២០០៤, លក្ខន្តិកៈគណៈកម្មការប្រតិបត្តិសហគមន៍អភិរក្សនិងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំ, កំពង់ធំ

៩. រដ្ឋបាលខេត្តកំពង់ធំ, ២០២១, ស្ថានភាពទូទៅ និងសក្តានុពលរបស់ខេត្តកំពង់ធំ, កំពង់ធំ

១០. ខេមបូឌៀអ៊ីនធឺប្រ៊ីណឺ, ២០២១, អ្វីជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង, ភ្នំពេញ

១១. ប៊ិន ប៊ុណ្ណា, ២០១៦, មុនឡើងភ្នំសន្ទុកត្រូវដឹងរឿងរ៉ាវ៧ចំណុចនេះ, ភ្នំពេញ, https://news.sabay.com.kh/article/894714 (ចូលទស្សនាថ្ងៃទី៤ កក្កដា ២០២២)

១២. សូត សុខប្រាថ្នា, ២០១៦, ពលរដ្ឋថាសត្វស្លាបនៅតំបន់បឹងទន្លេឆ្មាខេត្តកំពង់ធំថយចុះដោយសារភ្លើងឆេះព្រៃលិចទឹក, ភ្នំពេញ, អាចរកបាននៅ https://www.rfa.org/khmer/news/environment/birds-at-tonle-chhmar-lake-05042016045217.html (ចូលទស្សនាថ្ងៃទី៤ កក្កដា ២០២២)

១៣. ម៉ង់ វ៉ាលី, ២០២២, ប្រាសាទភូមិប្រាសាទ, ភ្នំពេញ, អាចរកបាននៅ https://ams.com.kh/khmercivilization/detail/19134 (ចូលទស្សនាថ្ងៃទី៤ កក្កដា ២០២២)

១៤. ប្រាជ្ញ សុវណ្ណារ៉ា, ២០២០, បឹងសំរឹទ្ធិជារមណីយដ្ឋានកែច្នៃដ៏ស្រស់ស្អាតមួយនៅក្នុងខេត្តកំពង់ធំ, កំពង់ធំ, អាចរកបាននៅ https://khmerpostasia.com/archives/57520 (ចូលទស្សនាថ្ងៃទី៥ កក្កដា ២០២២)

១៥. ខេមរា, ២០១៤, រមណីយដ្ឋានធម្មជាតិកែច្នៃដ៏ស្ទឹងព្រៃប្រស់, កំពង់ធំ, អាចរកបាននៅ https://www.khemaradaily.com/p/26895 (ចូលទស្សនាថ្ងៃទី៥ កក្កដា ២០២២)
១៦. គេហទំព័រ Visit Cambodia, ២០២២, វិមានវេស៊ីដង់បារាំងចាស់ និង សត្វប្រចៀវ, កំពង់ធំ, អាចរកបាននៅ https://www.visitcambodia.travel/kh/item/view/54c494f4a4t27424y2p2u2z2 (ចូលទស្សនាថ្ងៃទី៥ កក្កដា ២០២២)
១៧. គេហទំព័រ Visit Cambodia, ២០២២, សហគមន៍អភិរក្ស និងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុគ, កំពង់ធំ, អាចរកបាននៅ https://visitcambodia.travel/kh/item/view/5454848494s21444y2x23333 (ចូលទស្សនាថ្ងៃទី៦ កក្កដា ២០២២)
១៨. ហេង វុធ្ធី, ២០២០, ទេសភាពតំបន់ប្រាសាទសំបូរព្រៃគុកលេចឆោមស្រស់ខ្ចី សម្លេងសោភ័ណភាពទាក់ចិត្តទេសចរ, កំពង់ធំ, អាចរកបាននៅ https://huunghivietnamcampuchia.thoidai.com.vn/detail-article-1711.html (ចូលទស្សនាថ្ងៃទី៦ កក្កដា ២០២២)
១៩. ថា ចាន់ធី, ២០២២, ប្រវត្តិប្រាសាទសំបូរព្រៃគុក, ភ្នំពេញ, អាចរកបាននៅ https://www.vayofm.com/news/detail/117318-461.html (ចូលទស្សនាថ្ងៃទី៧ កក្កដា ២០២២)

### ✦ឯកសារជាភាសាបរទេស

១. https://www.unwto.org/glossary-tourism-terms (ចូលទស្សនាថ្ងៃទី០៨ មិថុនា ២០២២)
២.https://dos.myflorida.com/cultural/info-and-opportunities/resources-by-topic/cultural-tourism-toolkit/what-is-cultural-tourism-basic-information/ (ចូលទស្សនាថ្ងៃទី០៨ មិថុនា ២០២២)
៣. https://tourismteacher.com/why-tourism-development-planning-is-important/ (ចូលទស្សនាថ្ងៃទី២២ ឧសភា ២០២២)
៤https://www.tutorialspoint.com/tourism_management/tourism_management_introduction.htm (ចូលទស្សនាថ្ងៃទី២២ ឧសភា ២០២២)
៥. https://ticketsntour.com/pros-cons-tourism/ (ចូលទស្សនាថ្ងៃទី២២ ឧសភា ២០២២)
៦. https://wttc.org/Research/Economic-Impact (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០២២)
៧. https://dictionary.cambridge.org (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០២២)
៨. https://encartadictionaryonlinefid.wordpress.com (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០២២)

៩. https://www.biodiversity.ru/coastlearn/tourism-eng/why_economicbenefits.html (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០២២)

១០.https://tourismteacher.com/social-impacts-of-tourism/#1-positive-social-impacts-of-tourism (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០២២)

១១. https://greentumble.com/positive-impacts-of-tourism-on-environment/ (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០២២)

១២. https://localizejs.com/articles/cultural-differences-9-surprising-customs-from-around-the-world/ (ចូលទស្សនាថ្ងៃទី២៤ ឧសភា ២០២២)

១៣.https://www.forbes.com/sites/forbesbusinessdevelopmentcouncil/2022/04/04/how-one-of-the-worlds-largest-industries-could-emerge-stronger-from-this-pandemic/?sh=53384d1b34f2 (ចូលទស្សនាថ្ងៃទី២៤ ឧសភា ២០២២)

១៤.https://tourismteacher.com/social-impacts-of-tourism/#8-negative-social-impacts-of-tourism (ចូលទស្សនាថ្ងៃទី២៤ ឧសភា ២០២២)

១៥.https://www.timetravelturtle.com/best-places-to-visit-lumbini-nepal/ (ចូលទស្សនាថ្ងៃទី២៦ ឧសភា ២០២២)

១៦.https://www.khmertimeskh.com/501021335/kampong-thom-farmers-cultivation-of-rice-surpasses-target/ (ចូលទស្សនាថ្ងៃទី២៩ មិថុនា ២០២២)

១៧.https://www.tourismcambodia.com/travelguides/provinces/kampong-thom/what-to-see/179_prasat-kuhak-nokor.htm (ចូលទស្សនាថ្ងៃទី២៩ មិថុនា ២០២២)

១៨.https://www.smartsinntravel.com/attraction-detail.html?name=prasat-kok-rokar-sart-sinn-travel (ចូលទស្សនាថ្ងៃទី២៩ មិថុនា ២០២២)

១៩. https://www.smartsinntravel.com/attraction-detail.html?name=prasat-kok-rokar-sart-sinn-travel (ចូលទស្សនាថ្ងៃទី៣០ មិថុនា ២០២២)

២០. https://www.tourismcambodia.com/attractions/kampong-thom.htm (ចូលទស្សនាថ្ងៃទី៣០ មិថុនា ២០២២)

២១. https://www.lonelyplanet.com/cambodia/kompong-thom-province/attractions/santuk-silk-farm/a/poi-sig/1381364/1336590 (ចូលទស្សនាថ្ងៃទី១ កក្កដា ២០២២)

២២. https://www.phnompenhpost.com/national/kampong-thoms-sambor-prei-kuk-gets-unesco-listing (ចូលទស្សនាថ្ងៃទី២ កក្កដា ២០២២)

២៣. United Nations Educational, Scientific and Cultural Organization, Petra World Heritage Site: INTEGRATED MANAGEMENT PLAN 2019 (Jordan៖ Jordan, 2019), 79-81, https://en.unesco.org/sites/default/files/petra_integrated_management_plan_1.pdf (ចូលទស្សនាថ្ងៃទី២៦ ឧសភា ២០២២)

២៤. Ugur Sunlu, Environmental impacts of tourism (Turkey៖ Turkey, 2003), 263-270, https://om.ciheam.org/om/pdf/a57/04001977.pdf (ចូលទស្សនាថ្ងៃទី២៦ ឧសភា ២០២២)

២៥. Su, M. Ming, Preservation and Development at the Great Wall World Heritage Sites, China (Canada៖ Waterloo, 2009), 115-122, https://uwspace.uwaterloo.ca/bitstream/handle/10012/4989/Su_MingMing.pdf?sequence=1 (ចូលទស្សនាថ្ងៃទី២៦ ឧសភា ២០២២)

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
លេខ..៤៧០.....ស.ភ.ន.វ.ស

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

**ជម្រាបជូន**
**លោកប្រធានមន្ទីរទេសចរណ៍ ខេត្តកំពង់ធំ**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន០២រូប ចុះស្រាវជ្រាវឯកសារ។

**យោង៖** សំណើរបស់សាមីនិស្សិតចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូន លោកប្រធានមន្ទីរ ជ្រាបថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួន០២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី «ការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ៖ ករណីសិក្សាប្រាសាទសម្បូរព្រៃគុហ៍» នៅមន្ទីរទេសចរណ៍ ខេត្តកំពង់ធំ ចាប់ពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកប្រធានមន្ទីរ ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម លោកប្រធានមន្ទីរ ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

**ជ. សាកលវិទ្យាធិការ**
**សាកលវិទ្យាធិការរង**

**យិត-សុវុច**

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ

យើងខ្ញុំឈ្មោះ **ឈុំ សុវណ្ណរ័ត្ន** និង **សេង លីដា** ជានិស្សិតថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច ឆ្នាំទី៤ ជំនាន់ទី៨ ក្រុមT4A01 ឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពជូន**

**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

កម្មវត្ថុ៖ សំណើសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ

តាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថាបន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេរសារណា និង ការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី **"ការគ្រប់គ្រង និង អភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ៖ករណីសិក្សាប្រាសាទសម្បូរព្រៃគុហ៍"** ដោយត្រូវចុះស្រាវជ្រាវឯកសារនៅមន្ទីរទេសចរណ៍ខេត្តកំពង់ធំ ចាប់ពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម** មេត្តាអនុញ្ញាតឲ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

ហត្ថលេខា

ឈុំ សុវណ្ណរ័ត្ន　　សេង លីដា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## បញ្ជីរាយនាម

**និស្សិតថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច**
**ឆ្នាំទី៤ ជំនាន់ទី៨ ក្រុម T4A1 ឆ្នាំសិក្សា ២០២១ - ២០២២**
**ដែលត្រូវចុះស្រាវជ្រាវឯកសារនៅ មន្ទីរទេសចរណ៍ ខេត្តកំពង់ធំ**

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ឈុំ សុវណ្ណារ័ត្ន | ស្រី | ២០-វិច្ឆិកា-២០០០ | ០៦១ ៩១ ៣១ ៥១ | |
| ២ | សេង លីដា | ស្រី | ៣១-តុលា-២០០០ | ០៩៦ ៧៤៦ ៧៤៥៤ | |

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

**ប្រធានការិយាល័យស្រាវជ្រាវ**

ញឹក-វុឌ្ឍី

# ឧបសម្ព័ន្ធទី ១

## កម្រងសំណួរស្រាវជ្រាវសម្រាប់ទេសចរ និងប្រជាជនក្នុងតំបន់

## ស្ដីពីៈ "ការគ្រប់គ្រងតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រករណីសិក្សាៈ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក"

ជាបឋម យើងខ្ញុំសូមគោរពជំរាបសួរ លោក លោកស្រី អ្នកនាង កញ្ញាជាទីគោរព យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញា បត្រ ផ្នែកគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច ឆ្នាំទី៤ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ នៅក្នុងឆ្នាំបញ្ចប់ការសិក្សានេះ យើងខ្ញុំត្រូវធ្វើការសិក្សាស្រាវជ្រាវប្រមូលឯកសារ ដើម្បីការពារនិក្ខេបបទរបស់យើង។ ហេតុនេះហើយ យើងខ្ញុំសុំការអនុញ្ញាតពីលោក លោកស្រី អ្នកនាង កញ្ញាដែលជាភ្ញៀវទេសចរ និងប្រជាជនក្នុងតំបន់ទាំងអស់ ជួយផ្តល់នូវចម្លើយខ្លះៗសំរាប់ទុកជាទិន្នន័យ។ ចម្លើយរបស់លោកអ្នកនឹងយកមកប្រើប្រាស់ក្នុងគោលបំណងសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ ហើយពួកយើងសន្យាថានឹងមិនប្រើប្រាស់ទិន្នន័យទាំងនោះក្នុងន័យអវិជ្ជមានណាមួយឡើយ។

សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐ ជាចម្លើយរបស់លោកអ្នក។

I. ការសម្ភាសជាមួយប្រជាពលរដ្ឋ

+ ពត៌មានទូទៅ

១. ភេទ

- ស្រី ☐
- ប្រុស ☐

២. អាយុ

- ១៨ - ២៥ ឆ្នាំ ☐
- ២៦ - ៤០ ឆ្នាំ ☐
- ៤១ - ៥០ ឆ្នាំ ☐
- ៥១ - ៦០ ឆ្នាំ ☐
- ៦១ ឆ្នាំឡើង ☐

៣. មុខរបរ

- សិស្ស/និស្សិត ☐
- មន្ត្រីរាជការ ☐

- បុគ្គលិកឯកជន ☐
- កសិករ ☐
- អាជីវករ ☐
- ផ្សេងៗ ☐

៤. តើបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងរមណីយដ្ឋានសំបូរព្រៃគុកមានលក្ខណៈបែបណាដែរ?

- បរិយាកាស ☐ ល្អណាស់ ☐ ល្អបង្គួរ ☐ មិនសូវល្អ ☐ មិនល្អ ☐
- អនាម័យ ☐ ល្អណាស់ ☐ ល្អបង្គួរ ☐ មិនសូវល្អ ☐ មិនល្អ ☐
- ផ្លូវថ្នល់ ☐ ល្អណាស់ ☐ ល្អបង្គួរ ☐ មិនសូវល្អ ☐ មិនល្អ ☐
- សន្តិសុខ និងសុវត្ថិភាព ☐ ល្អណាស់ ☐ ល្អបង្គួរ ☐ មិនសូវល្អ ☐ មិនល្អ ☐

៥. តើស្ថានភាពជីវភាពរបស់លោកពូ អ្នកមីង មុនពេល និងពេលអភិវឌ្ឍហើយមានការផ្លាស់ប្ដូរដែរឬទេ?

- ផ្លាស់ប្ដូរ ☐
- មិនផ្លាស់ប្ដូរ ☐

II. ការសម្ភាសជាមួយទេសចរ

១. ភេទ

- ស្រី ☐
- ប្រុស ☐

២. អាយុ

- ១៨ - ២៥ ឆ្នាំ ☐
- ២៦ - ៤០ ឆ្នាំ ☐
- ៤១ - ៥០ ឆ្នាំ ☐
- ៥១ - ៦០ ឆ្នាំ ☐
- ៦១ ឆ្នាំឡើង ☐

៣. តើអ្នកធ្លាប់មកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុកប៉ុន្មានដង?

- ១ ដង ☐
- ២ ដង ☐
- ៣ ដង ☐

- លើសពី ៣ ដង ☐

៤. តើអ្នកស្គាល់រមណីយដ្ឋាននេះដោយរបៀបណា?

- ប្រព័ន្ធផ្សព្វផ្សាយ ☐
- មិត្តភក្តិ/បងប្អូន ☐
- ក្រុមហ៊ុនទេសចរណ៍ ☐
- ផ្សេងៗ ☐

៥. តើអ្នកអញ្ជើញមកក្នុងគោលបំណងអ្វី?

- ទស្សនាកម្សាន្ត ☐
- សិក្សាស្រាវជ្រាវ ☐
- ការងារ ☐
- ផ្សេងៗ ☐

៦. តើអ្នកយល់យ៉ាងណាចំពោះស្ថានភាពអនាម័យនៅក្នុងរមណីយដ្ឋាន?

- មិនពេញចិត្តយ៉ាងខ្លាំង ☐
- មិនពេញចិត្ត ☐
- មធ្យម ☐
- ពេញចិត្ត ☐
- ពេញចិត្តយ៉ាងខ្លាំង ☐

៧. តើរមណីយដ្ឋាននេះមានកន្លែងចតយានជំនិះត្រឹមត្រូវដែរ ឬ ទេ?

- បាទ/ចាស៎ មាន ☐
- បាទ/ចាស៎ មិនមានទេ ☐

៨. តើរមណីយដ្ឋាននេះមានធុងសម្រាមគ្រប់គ្រាន់ដែរ ឬ ទេ?

- បាទ/ចាស៎ គ្រប់ ☐
- បាទ/ចាស៎ មិនគ្រប់គ្រាន់ទេ ☐

៩. តើរមណីយដ្ឋាននេះមានបង្គន់អនាម័យជូនភ្ញៀវគ្រប់គ្រាន់ដែរ ឬ ទេ?

- បាទ/ចាស៎ គ្រប់ ☐
- បាទ/ចាស៎ មិនគ្រប់គ្រាន់ទេ ☐

១០. តើអ្នកយល់ឃើញយ៉ាងណាចំពោះបញ្ហាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់?

- មិនពេញចិត្តយ៉ាងខ្លាំង ☐
- មិនពេញចិត្ត ☐
- មធ្យម ☐
- ពេញចិត្ត ☐
- ពេញចិត្តយ៉ាងខ្លាំង ☐

១១. តើអ្នកចូលចិត្តមកកម្សាន្តនៅទីនេះក្នុងឱកាសអ្វី?

- ចុងសប្តាហ៍ ☐
- ពិធីបុណ្យនានា ☐
- ផ្សេងៗ ☐

១២. តើអ្នកយល់ឃើញយ៉ាងណាចំពោះហេដ្ឋារចនាសម្ព័ន្ធ?

- មិនពេញចិត្តយ៉ាងខ្លាំង ☐
- មិនពេញចិត្ត ☐
- មធ្យម ☐
- ពេញចិត្ត ☐
- ពេញចិត្តយ៉ាងខ្លាំង ☐

១៣. តើអ្នកយល់ឃើញយ៉ាងណាចំពោះបរិស្ថាន?

- មិនពេញចិត្តយ៉ាងខ្លាំង ☐
- មិនពេញចិត្ត ☐
- មធ្យម ☐
- ពេញចិត្ត ☐
- ពេញចិត្តយ៉ាងខ្លាំង ☐

១៤. តើអ្នកយល់ថា គួរអភិវឌ្ឍន៍អ្វីខ្លះក្នុងរមណីយដ្ឋាន?

- ហេដ្ឋារចនាសម្ព័ន្ធ ☐
- សេវាសាធារណៈ ☐
- បរិស្ថានអនាម័យ ☐

- សន្តិសុខ សណ្តាប់ធ្នាប់ ☐

- ទាំងអស់ខាងលើ ☐

១៥. បើមានឱកាស តើអ្នកចង់មកកម្សាន្តនៅរមណីយដ្ឋាននេះទៀតដែរឬទេ?

- ចង់ ☐

-មិនចង់ ☐

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកពូ អ្នកមីង បងប្អូនក្នុងសហគមន៍ ព្រមទាំងភ្ញៀវទេសចរ ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ ដើម្បីផ្តល់ជាព័ត៌មានបន្ថែមឱ្យពួកខ្ញុំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច។ ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរឱ្យលោកពូ អ្នកមីង និងបងប្អូនទាំងអស់ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# កម្រងសំណួរស្រាវជ្រាវ

## ស្តីពីៈ "ការគ្រប់គ្រងតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រករណីសិក្សាៈ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក"

### I. សំណួរទាក់ទងនឹងសេវាកម្ម

១. តើសហគមន៍មានសេវាកម្មអ្វីខ្លះដើម្បីបម្រើភ្ញៀវពេលមកដល់?

២. ក្នុងចំណោមសេវាកម្មទាំងអស់ តើសេវាកម្មមួយណាដែលមានភាពលេចធ្លោជាងគេ?

៣. តើសហគមន៍មានយន្តការយ៉ាងណាដើម្បីលើកស្ទួយសេវាកម្មដែលមិនសូវទទួលបានការចាប់អារម្មណ៍?

### II. សំណួរទាក់ទងនឹងការគ្រប់គ្រង

១. តើសហគមន៍បានគ្រប់គ្រងទៅលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់ ក៏ដូចជាផ្នែកផ្សេងៗ ទៀតដោយរបៀបណា?

២. តើសហគមន៍មានយុទ្ធសាស្ត្របែបណាក្នុងការគ្រង់គ្រងតំបន់ទេសចរណ៍នេះដើម្បីឱ្យមាននិរន្តភាព?

៣. ក្នុងពេលអនុវត្តផែនការ តើសហគមន៍បានជួបឧបសគ្គ និងបញ្ហាអ្វីខ្លះក្នុងការគ្រង់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ នេះ?

### III. សំណួរទាក់ទងនឹងការផ្សព្វផ្សាយ

១. តើភ្ញៀវដែលមកកម្សាន្តនៅតំបន់នេះស្គាល់សហគមន៍ដោយរបៀបណា?

២. តើសហគមន៍បានធ្វើការផ្សព្វផ្សាយពីតំបន់នេះដែរ ឬទេ? បើដែរ តើតាមរយៈណាខ្លះ?

### IV. សំណួរទាក់ទងនឹងការបណ្តុះបណ្តាល និងអប់រំ

១. តើសហគមន៍ធ្លាប់មានកម្មវិធីបណ្តុះបណ្តាល និងអប់រំជូនប្រជាជនក្នុងតំបន់ដែរ ឬទេ?

២. តើកម្មវិធីទាំងនោះផ្តោតទៅលើចំណុចណាខ្លះ?

៣. តើសហគមន៍ធ្លាប់បានចែករំលែកចំណេះដឹងដល់ភ្ញៀវទេសចរដែលបានមកដល់ដែរ ឬទេ?

### V. សំណួរទាក់ទងនឹងអ្នកពាក់ព័ន្ធនៅក្នុងសហគមន៍

១. តើសហគមន៍នេះស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នណាខ្លះ?

២. តើស្ថាប័ននីមួយៗបានជួយជ្រោមជ្រែងក្នុងការគ្រង់គ្រង និងអភិវឌ្ឍសហគមន៍ដល់កម្រិតណា?

៣. តើសហគមន៍មានការប្រែប្រួលយ៉ាងដូចម្តេចខ្លះ បន្ទាប់ពីបានសហការជាមួយស្ថាប័នទាំងនោះមក?

សូមអរគុណសម្រាប់ការចូលរួមផ្តល់ចម្លើយ!

# ឧបសម្ព័ន្ធទី ២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១២៧ ប្រក

## ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត

### រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ ២៥៥១ មស.នក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ ៩២៧៤ សហវ.អថ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត
- រៀបចំឱ្យមានធនធានមនុស្សក្នុងរចនាសម្ព័ន្ធរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យទេសចរណ៍នៅថ្នាក់ក្រោមជាតិ។

## ជំពូកទី២
## តួនាទី និងភារកិច្ច

**ប្រការ៣ .-**

**មន្ទីរទេសចរណ៍រាជធានីខេត្ត** ជាសេនាធិការឱ្យក្រសួងទេសចរណ៍ទទួលបន្ទុកអនុវត្ត គ្រប់គ្រង តាមដាន ត្រួតពិនិត្យ វាយតម្លៃ រៀបចំផែនការអភិវឌ្ឍន៍ ពង្រឹងគុណភាពផលិតផល អាជីវកម្ម និងសេវាកម្មទេសចរណ៍ សំដៅធានាដល់ការគ្រប់គ្រងនិងការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ។

**ប្រការ៤ .-**

**មន្ទីរទេសចរណ៍រាជធានីខេត្ត** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍវិស័យទេសចរណ៍នៅថ្នាក់ក្រោមជាតិ
- រៀបចំគម្រោងអភិវឌ្ឍន៍ទេសចរណ៍ តាមតំបន់អាទិភាពទេសចរណ៍នៅក្នុងរាជធានីខេត្ត ដោយសហការជាមួយមន្ទីរអង្គភាពនិងផ្នែកពាក់ព័ន្ធដទៃទៀត ដើម្បីដាក់ជូនរដ្ឋបាលរាជធានីខេត្ត និងក្រសួងទេសចរណ៍ពិនិត្យនិងសម្រេច
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ទាំងរដ្ឋនិងឯកជន ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេច
- គ្រប់គ្រង ត្រួតពិនិត្យព័ត៌មានទេសចរណ៍ និងជំរុញចលនាទេសចរណ៍ក្នុងស្រុកនៅក្នុងរាជធានីខេត្ត
- គ្រប់គ្រងរមណីយដ្ឋានទេសចរណ៍ អាជីវកម្មទេសចរណ៍ និងសេវាកម្មផ្សេងៗទៀត ដែលបម្រើឱ្យវិស័យទេសចរណ៍
- គ្រប់គ្រងនិងថែរក្សាតំបន់ទេសចរណ៍ មណ្ឌលទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ កសិទេសចរណ៍ និងអេកូទេសចរណ៍ក្នុងរាជធានីខេត្ត
- គ្រប់គ្រងនិងរៀបចំក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ មុខតំណែង គ្រឿងឥស្សរិយយស និងប្រព័ន្ធលាភការផ្សេងៗទៀតរបស់មន្ត្រីរាជការក្រោមឱវាទ
- គ្រប់គ្រងស្ថានភាពចំណូលចំណាយហិរញ្ញវត្ថុនៅក្នុងមន្ទីរ ស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តគោលនយោបាយ គោលការណ៍ ប្រកាស សារាចរ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតរបស់ក្រសួងទេសចរណ៍ ដើម្បីរក្សានិរន្តរភាពវិស័យទេសចរណ៍និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីលើកកម្ពស់ និងជំរុញចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងស្តង់ដារទេសចរណ៍
- ចូលរួមនិងជំរុញការអនុវត្តយន្តការនិងនីតិវិធីនៅថ្នាក់ក្រោមជាតិដើម្បីពិនិត្យ និងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្ម និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រួមចំណែកការពារនិងថែរក្សាធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងទំនៀមទម្លាប់ប្រពៃណី ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត

- ទាក់ទងជាមួយវិនិយោគិននិងដៃគូអភិវឌ្ឍន៍នានា ក្នុងគោលបំណងទាក់ទាញការវិនិយោគ និងការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត
- សិក្សាស្រាវជ្រាវទីផ្សារទេសចរណ៍និងផ្សព្វផ្សាយពីសក្ដានុពលទេសចរណ៍ដែលមាននៅក្នុងមូលដ្ឋាន
- លើកសំណើនិងផ្ដល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងក្នុងការកែលម្អនិងអភិវឌ្ឍវិស័យទេសចរណ៍ក្នុងរាជធានីខេត្ត ដោយមានការគាំទ្រពីរដ្ឋបាលរាជធានីខេត្ត និងអាជ្ញាធរមូលដ្ឋាន
- សម្រាប់មន្ទីរទេសចរណ៍ដែលមានឆ្នេរសមុទ្រនិងកោះ ត្រូវចូលរួមគ្រប់សកម្មភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រ និងកោះស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍និងរដ្ឋបាលខេត្ត
- ធ្វើកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី អាស៊ាន តំបន់ និងអន្តរជាតិ
- សហការរៀបចំកិច្ចប្រជុំ ព្រឹត្តិការណ៍ និងសន្និសីទទេសចរណ៍ថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ
- សហការរួមចំណែកការពារបរិស្ថាននិងលើកកម្ពស់ "កម្ពុជាស្អាត កម្ពុជាបៃតង" នៅក្នុងរាជធានីខេត្ត
- សហការជាមួយក្រសួង ស្ថាប័នរដ្ឋបាលរាជធានីខេត្ត មន្ទីរនិងអង្គភាពពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការចំពោះប្រតិបត្តិករទេសចរណ៍ដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ស្ដីពីទេសចរណ៍ និងបទប្បញ្ញត្តិជាធរមាន
- សហការគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្ម ផលិតកម្ម សេវាកម្ម និងប្រតិបត្តិករទេសចរណ៍ ធានាបាននូវប្រសិទ្ធភាព គុណភាព និរន្តរភាព របៀបរៀបរយ អនាម័យ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- សហការពង្រឹង និងចាត់វិធានការចាំបាច់ទាក់ទងនឹងការរក្សាសន្តិសុខ និងសុវត្ថិភាពទេសចរ កិច្ចការសង្គ្រោះបឋមនិងបន្ទាន់ នៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍នានា
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការគ្រប់គ្រងនិងរៀបចំចងក្រងទិន្នន័យស្ថិតិទេសចរណ៍
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការផលិត ការនាំចូល ការចែកចាយ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន និងការជួញដូរស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍ ព្រមជាមួយនឹងការបញ្ជ្រាបការយល់ដឹងពីជំងឺអេដស៍ និងបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីក្រសួងទេសចរណ៍។

មន្ទីរទេសចរណ៍រាជធានីខេត្ត ដឹកនាំដោយប្រធាន០១(មួយ)រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**ប្រការ៥ ..**

មន្ទីរទេសចរណ៍រាជធានីខេត្ត មានការិយាល័យចំណុះដូចខាងក្រោម៖

ក.មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបាត់ដំបង មានការិយាល័យចំណុះចំនួន ០៧(ប្រាំពីរ) ដូចតទៅ៖

១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ

២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍

៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
៧-ការិយាល័យទីក្រុងស្អាត។

ខ.មន្ទីរទេសចរណ៍ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ មានការិយាល័យចំណុះចំនួន០៦(ប្រាំមួយ) ដូចតទៅ៖
១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យទីក្រុងស្អាត។

គ.មន្ទីរទេសចរណ៍ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង មានការិយាល័យចំណុះចំនួន០៧(ប្រាំពីរ)ដូចតទៅ៖
១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យគ្រប់គ្រងឆ្នេរ
៧-ការិយាល័យទីក្រុងស្អាត។

ឃ.មន្ទីរទេសចរណ៍ខេត្តព្រះសីហនុមានការិយាល័យចំណុះចំនួន ០៩(ប្រាំបួន) ដូចតទៅ៖
១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
៧-ការិយាល័យគ្រប់គ្រងឆ្នេរ
៨-ការិយាល័យទេសចរណ៍កោះរ៉ុង
៩-ការិយាល័យទីក្រុងស្អាត។

**ប្រការ៦ .–**

នៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ ដែលមានសក្តានុពលទេសចរណ៍ ត្រូវមានការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ មួយដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង ក្រោមការគ្រប់គ្រងរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត។

**ប្រការ៧ .–**

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន០១(មួយ)រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ៨ .–**

ការិយាល័យនីមួយៗមានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ** មានតួនាទី និងភារកិច្ច៖

- គ្រប់គ្រងលិខិតស្នាមដែលបញ្ជូនចេញនិងទទួលលិខិតពីបណ្តាមន្ទីរអង្គភាពនិងក្រសួងស្ថាប័នដទៃទៀត
- ចរាចរលិខិតឯកសារចូល និងចេញទៅកាន់គោលដៅទាំងក្នុងនិងក្រោមមន្ទីរ
- លើកវិធានការ ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ និងសោភ័ណភាពរបស់មន្ទីរ
- រៀបចំតុបតែង និងលម្អមន្ទីរ នៅរៀងរាល់ពិធីបុណ្យជាតិ អន្តរជាតិ និងចូលរួមក្នុងការងារសង្គមនានា
- គ្រប់គ្រងស្ថិតិ ក្របខណ្ឌ និងតារាងព័ត៌មានការងារមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត និងរៀបចំផែនការធនធានមនុស្សរបស់មន្ទីរ
- រៀបចំសំណើសុំលើការជ្រើសរើស ការតាំងស៊ប់ក្នុងក្របខណ្ឌ ការរៀបចំបៀវត្សរ៍ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្លាស់ប្តូរ ការផ្ទេរក្របខណ្ឌ ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស ការដាក់វិន័យ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះឬបញ្ឈប់ពីការងារ ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរ៍ ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម និងការដាក់ឱ្យចូលនិវត្តន៍ ឬបាត់បង់សម្បទាវិជ្ជាជីវៈនៃមន្ត្រីរាជការ
- រៀបចំសលាកបត្រវិញ្ញាបនបត្ររដ្ឋបាល លិខិតបញ្ជាបេសកកម្ម លិខិតឧទ្ទេសនាម សេចក្តីជូនដំណឹង លិខិតបទដ្ឋាន របាយការណ៍ និងកំណត់ហេតុនានា
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងចំណូលចំណាយរបស់មន្ទីរ ស្របតាមគោលការណ៍កំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់គ្រងចលនទ្រព្យនិងអចលនទ្រព្យ សន្និធិ សម្ភារៈ ប្រេងឥន្ធនៈ និងធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងការប្រើប្រាស់ ការរៀបចំជួសជុលសម្ភារៈ បរិក្ខាររបស់មន្ទីរ
- រៀបចំនិងបើកប្រាក់បៀវត្ស របបសង្គមកិច្ច និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ជូនមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- សហការផ្សព្វផ្សាយ ណែនាំ និងជំរុញឱ្យគ្រប់អាជីវកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសេវាផ្សេងៗទៀតបម្រើឱ្យវិស័យទេសចរណ៍ ដើម្បីបង្កើនការការពារសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីចាត់វិធានការចាំបាច់ទាក់ទងនឹងការរក្សាសន្តិសុខ និងសុវត្ថិភាពជូនទេសចរ កិច្ចការសង្គ្រោះបឋមនិងបន្ទាន់ ព្រមទាំងកិច្ចការសុវត្ថិភាពទេសចរផ្សេងៗទៀត ពិសេសនៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍នានា
- សហការជាមួយក្រសួង ស្ថាប័ន អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង មន្ទីរនិងអង្គភាពនានា ដើម្បីដោះស្រាយវិវាទនិងបំពេញភារកិច្ចអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង

- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំ និងលើកទិសដៅការងារបន្តរបស់មន្ទីរទេសចរណ៍។

**២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត រួមមានៈ ផែនការវិនិយោគ អភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ ទេសចរណ៍សហគមន៍ កសិទេសចរណ៍ និងទេសចរណ៍ធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធនានា
- រៀបចំបង្កើតសហគមន៍ទេសចរណ៍នៅតាមតំបន់ដែលមានសក្តានុពលខ្ពស់ និងជំរុញឱ្យមានការថែរក្សាទីតាំងវប្បធម៌ប្រវត្តិសាស្ត្រ បេតិកភណ្ឌ ទីសក្ការៈបូជា ដើម្បីទាក់ទាញភ្ញៀវទេសចរ ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធនានា
- សិក្សានិងរៀបចំបញ្ជីសក្តានុពលវិនិយោគទេសចរណ៍ និងធ្វើបច្ចុប្បន្នកម្មលើទិន្នន័យនិងស្ថិតិនៃគម្រោងវិនិយោគក្នុងវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត
- ចូលរួមអនុវត្តបទដ្ឋានគតិយុត្ត ស្តង់ដារអប្បបរមា និងការអនុវត្តនានា ដើម្បីតាមដាន ត្រួតពិនិត្យ កែលម្អ និងរក្សាគុណភាពរមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ និងធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀតនៅថ្នាក់ក្រោមជាតិ
- ជំរុញសកម្មភាពភូមិមួយផលិតផលមួយរបស់សហគមន៍ទេសចរណ៍នៅក្នុងមូលដ្ឋាន
- ជំរុញលើកទឹកចិត្តឱ្យមានការផលិត និងប្រើប្រាស់ផលិតផលក្នុងស្រុកសម្រាប់បម្រើឱ្យទេសចរណ៍
- ធ្វើកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី អាស៊ាន និងអន្តរជាតិ
- សហការរៀបចំកិច្ចប្រជុំ ព្រឹត្តិការណ៍ និងសន្និសីទទេសចរណ៍ថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ
- សហការសិក្សាស្រាវជ្រាវប្រវត្តិរមណីយដ្ឋាន ប្រវត្តិវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ដើម្បីចងក្រងជាឯកសារ និងរៀបចំធ្វើជាព្រឹត្តិការណ៍ទេសចរណ៍នៅតាមរាជធានីខេត្ត និងគោលដៅទេសចរណ៍
- សហការចូលរួមជំរុញនិងអនុវត្តចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ក្នុងការពិនិត្យលើផ្នែកសំណង់ស្ថាបត្យកម្មទេសចរណ៍ ឱ្យស្របទៅតាមរចនាបថខ្មែរ ទាំងការតុបតែងលម្អ ការប្រគុំតន្ត្រីបុរាណ សម្លៀកបំពាក់តាមបែបបុរាណខ្មែរ និងការប្រើប្រាស់ផលិតផលក្នុងស្រុក នៅតាមមូលដ្ឋានអាជីវកម្មនិងសេវាកម្មទេសចរណ៍ ដោយរក្សាបាននូវអត្តសញ្ញាណជាតិ
- សហការត្រួតពិនិត្យការលក់ដូរវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវទេសចរ
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្តាលមកពីគម្រោងវិនិយោគក្នុងវិស័យទេសចរណ៍និងការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍នៅក្នុងមូលដ្ឋាន។

**៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- គ្រប់គ្រង និងត្រួតពិនិត្យលើរាល់អាជីវកម្មនិងសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ ទេសចរណ៍-ម៉ាយ MICE (ម៉ាយៈ ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) សេវាកម្មម៉ាស្សានិងស្ប៉ា ទីភ្នាក់ងារដឹកជញ្ជូនទេសចរ សេវាកម្សាន្តនិងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្ម និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ផ្សព្វផ្សាយនិងជំរុញអនុវត្តច្បាប់ស្តីពីទេសចរណ៍ឱ្យបានទូលំទូលាយក្នុងផ្នែកសាធារណៈ និងឯកជន
- ចូលរួមនិងជំរុញការអនុវត្តយន្តការនិងនីតិវិធីនៅថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យនិងវាយតម្លៃលើ

សំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្ដល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ ទេសចរណ៍-ម៉ាយ MICE (ម៉ាយ៖ ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) សេវាកម្មម៉ាស្សានិងស្ប៉ា ភ្នាក់ងារ ដឹកជញ្ជូនទេសចរ សេវាកម្សាន្ត និងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្មនិងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន

- លើកសំណើ ដើម្បីពិនិត្យវាយតម្លៃចំណាត់ថ្នាក់ ការលើកសរសើរ ផ្ដល់រង្វាន់ និងបណ្ណសរសើរដល់មូលដ្ឋានសេវាកម្ម អាជីវកម្ម និងប្រតិបត្តិករទេសចរណ៍គ្រប់ប្រភេទនៅក្នុងរាជធានីខេត្ត
- សហការចូលរួមជំរុញ និងអនុវត្តចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- សហការពង្រឹងនិងជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុក សំដៅបង្កើនតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា
- សហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ស្តង់ដារអប្បបរមា និងការអនុវត្តនានា ដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងធានារក្សា គុណភាពអាជីវកម្ម និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ សេវាកម្មម៉ាស្សានិងស្ប៉ា ភ្នាក់ងារ ដឹកជញ្ជូនទេសចរ សេវាកម្សាន្តនិងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្មនិងសេវាកម្មទេសចរណ៍ផ្សេងៗទៀត
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្ដាលមកពីការធ្វើអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ ទេសចរណ៍-ម៉ាយ MICE (ម៉ាយ៖ ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) សេវាកម្មម៉ាស្សា និងស្ប៉ា ភ្នាក់ងារ ដឹកជញ្ជូនទេសចរ សេវាកម្សាន្ត និងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្មនិងសេវាកម្មទេសចរណ៍ ផ្សេងៗទៀត
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនិងផ្នែកពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់បទល្មើសនិងការជួញដូរគ្រឿងញៀន ការជួញដូរស្ត្រីនិងកុមារក្នុងវិស័យទេសចរណ៍ លើកស្ទួយកិត្តិយស សេចក្ដីថ្លៃថ្នូរ តម្លៃស្ត្រី និងកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមពាក្យស្លោក **ចូលរួមការពារគតសម្បត្តិជាតិយើង**
- សហការផ្សព្វផ្សាយ ណែនាំ និងជំរុញឱ្យគ្រប់អាជីវកម្មទេសចរណ៍ និងសេវាផ្សេងៗទៀតបម្រើឱ្យវិស័យទេសចរណ៍ ដើម្បីបង្កើនការការពារសន្តិសុខនិងសុវត្ថិភាពទេសចរ។

**៤-ការិយាល័យអប់រំបណ្ដុះបណ្ដាល** មានតួនាទី និងភារកិច្ច៖

- រៀបចំផែនការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ ទាំងផ្នែករដ្ឋ ឯកជន និងសាធារណៈ ស្របតាមគោលការណ៍ និងការណែនាំរបស់ក្រសួង
- រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តនិងឯកសារពាក់ព័ន្ធការងារវិស័យទេសចរណ៍ សម្រាប់បើកវគ្គបណ្ដុះបណ្ដាល
- បើកវគ្គបណ្ដុះបណ្ដាលលើគ្រប់ជំនាញនិងគ្រប់ទម្រង់ សេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការបញ្ជ្រាបយេនឌ័រក្នុងវិស័យទេសចរណ៍ សិទ្ធិកុមារ ច្បាប់ជាតិ អន្តរជាតិ អនុសញ្ញាជាតិ ដែលពាក់ព័ន្ធ ដើម្បីទប់ស្កាត់គ្រោះថ្នាក់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មកុមារក្នុងវិស័យទេសចរណ៍ ដល់ប្រតិបត្តិករទេសចរណ៍ដែលកំពុងធ្វើអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងរាជធានីខេត្ត
- ទំនាក់ទំនងជាមួយផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាលឱ្យចូលរួមឧបត្ថម្ភគាំទ្រដល់ការបណ្ដុះបណ្ដាលធនធានមនុស្សក្នុងវិស័យទេសចរណ៍
- សហការសិក្សាអំពីតម្រូវការ ការជ្រើសរើស និងការបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍នៅតាមរាជធានីខេត្ត និងតំបន់ ដែលត្រូវបានកំណត់ដោយក្រសួងទេសចរណ៍

- សហការជាមួយមន្ទីរនិងអង្គភាពពាក់ព័ន្ធ ដើម្បីតម្រង់ទិសការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ តាមវិទ្យាល័យ សាលាចំណេះទូទៅនិងបច្ចេកទេស និងគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលផ្សេងៗទៀត
- សហការត្រួតពិនិត្យ វាយតម្លៃ និងតាមដានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ សំដៅធានាឱ្យមានការបណ្តុះបណ្តាលប្រកបដោយគុណភាព និងស្របតាមស្តង់ដារនិងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍កម្រិតជាតិ អន្តរជាតិ អាស៊ាន តំបន់ និងពិភពលោក។

**៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំ គ្រប់គ្រង ប្រមូល និងចងក្រងស្ថិតិទេសចរណ៍នៅក្នុងរាជធានីខេត្ត
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អាជ្ញាធរពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងផ្នែកឯកជនលើការងារស្ថិតិទេសចរណ៍
- សិក្សាស្រាវជ្រាវ វិភាគនិន្នាការ និងព្យាករណ៍ទេសចរណ៍នៅក្នុងរាជធានីខេត្ត
- សិក្សាស្រាវជ្រាវនិងវិភាគអំពីផលប៉ះពាល់នៃការអភិវឌ្ឍវិស័យទេសចរណ៍ ផលប៉ះពាល់វិជ្ជមានអវិជ្ជមាន ស្ថានភាពទេសចរណ៍ តម្រូវការហេដ្ឋារចនាសម្ព័ន្ធ សម្បទានិងសេវាកម្មទេសចរណ៍ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់តំបន់ទេសចរណ៍ដែលមានសក្តានុពល ដើម្បីអភិវឌ្ឍឱ្យក្លាយទៅជាគោលដៅទេសចរណ៍
- គ្រប់គ្រងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ប្រមូលទិន្នន័យ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងផ្តល់ព័ត៌មានពិតជូនភ្ញៀវទេសចរ
- បង្កើតសៀវភៅផ្ចត់របស់មន្ទីរទេសចរណ៍ បង្ហាញពីផែនទីនិងផ្សព្វផ្សាយផលិតផលទេសចរណ៍ទាំងក្នុងទាំងក្រៅប្រទេស
- សហការបង្កើត គ្រប់គ្រង និងអភិវឌ្ឍគេហទំព័រ ប្រព័ន្ធទំនាក់ទំនងសង្គមនានា ដើម្បីផ្សព្វផ្សាយសក្តានុពលទេសចរណ៍ដែលមាននៅក្នុងរាជធានីខេត្ត
- សហការរៀបចំបង្កើតពិព័រណ៍ទេសចរណ៍និងព្រឹត្តិការណ៍ទេសចរណ៍នានានៅតាមតំបន់និងគោលដៅទេសចរណ៍ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

**៦-ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- ចូលរួមអនុវត្តយន្តការនិងនីតិវិធី ដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ចុះអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍
- ជំរុញផ្សព្វផ្សាយនិងណែនាំមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ក្រមប្រតិបត្តិនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងបទប្បញ្ញត្តិជាធរមាន
- សិក្សាតម្រូវការមគ្គុទេសក៍ឱ្យស្របតាមកំណើននៃភ្ញៀវទេសចរ ក្នុងការបើកវគ្គបណ្តុះបណ្តាលភាសាជំនាញបន្ថែមផ្សេងៗ ឱ្យបានសមស្របនិងទាន់ពេលទៅតាមតម្រូវការទីផ្សារទេសចរណ៍
- លើកសំណើជូនក្រសួងទេសចរណ៍ ចំពោះបាតុភាពដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់សង្គម សម្បត្តិវប្បធម៌និងធនធានធម្មជាតិ ដែលបង្កឡើងដោយមគ្គុទ្ទេសក៍ទេសចរណ៍
- សហការគ្រប់គ្រងនិងត្រួតពិនិត្យរាល់អាជីវកម្ម និងសេវាកម្មទាក់ទងនឹងមគ្គុទ្ទេសក៍ទេសចរណ៍នៅក្នុងរាជធានីខេត្ត ឱ្យអនុវត្តទៅតាមគោលការណ៍របស់ថ្នាក់ជាតិ
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត អាជ្ញាធរមូលដ្ឋាន និងផ្នែកពាក់ព័ន្ធ ដើម្បីពង្រឹងគុណភាពសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងមគ្គុទ្ទេសក៍ទេសចរណ៍

- សហការរៀបចំកម្មវិធីផ្សេងៗក្នុងការប្រឡងជ្រើសរើសមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកនិយាយភាសាបរទេសផ្សេងៗធ្វើម។

**៧-ការិយាល័យគ្រប់គ្រងឆ្នេរ** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការនិងសកម្មភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រនិងកោះ ស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍និងរដ្ឋបាលខេត្ត
- រៀបចំផែនការនិងចំណាត់ការចាំបាច់នានាក្នុងការគ្រប់គ្រង បង្ការ ការជួយសង្គ្រោះ និងការធានាសុវត្ថិភាពដល់ទេសចរតាមឆ្នេរសមុទ្រនិងកោះ
- គ្រប់គ្រងទិន្នន័យនិងស្ថិតិភ្ញៀវទេសចរមកកម្សាន្តនៅរមណីយដ្ឋានឆ្នេរសមុទ្រនិងកោះ
- ត្រួតពិនិត្យនិងជួយសង្គ្រោះភ្ញៀវទេសចរមានបញ្ហាពេលហែលទឹកកម្សាន្ត
- ពង្រឹងគុណភាពផលិតផលទេសចរណ៍ សេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅតាមរមណីយដ្ឋានឆ្នេរសមុទ្រនិងកោះ
- ផ្សព្វផ្សាយ អប់រំ និងណែនាំដល់អាជីវករតាមឆ្នេរសមុទ្រនិងកោះ អំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានា សំដៅដល់ការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការចូលរួមទទួលខុសត្រូវខ្ពស់
- ចូលរួមផ្សព្វផ្សាយ អប់រំនិងណែនាំដល់អាជីវករតាមឆ្នេរសមុទ្រនិងកោះ អំពីគុណភាពចំណីអាហារ ការថែរក្សាអនាម័យ និងបរិស្ថាននៅតាមឆ្នេរសមុទ្រនិងកោះ
- សម្របសម្រួលជម្លោះផ្សេងៗរវាងប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ និងរាយការណ៍មកមន្ទីរទេសចរណ៍ ដើម្បីមានវិធានការបន្ត
- លើកសំណើនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំមន្ទីរនិងក្រសួងទេសចរណ៍ក្នុងការកែលម្អ និងអភិវឌ្ឍស្តង់ដាររមណីយដ្ឋានឆ្នេរសមុទ្រ
- សហការជាមួយអង្គភាពពាក់ព័ន្ធនិងផ្នែកឯកជន ដើម្បីរៀបចំសកម្មភាពកម្សាន្តកីឡាទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍នានានៅរមណីយដ្ឋានឆ្នេរសមុទ្រ។

**៨-ការិយាល័យទេសចរណ៍កោះរ៉ុង** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការនិងសកម្មភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង ឱ្យស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍និងរដ្ឋបាលខេត្តព្រះសីហនុ
- គ្រប់គ្រងទិន្នន័យនិងស្ថិតិភ្ញៀវទេសចរមកកម្សាន្តនៅតំបន់កោះរ៉ុង
- ត្រួតពិនិត្យនិងជួយសង្គ្រោះភ្ញៀវទេសចរមានបញ្ហាពេលហែលទឹកកម្សាន្ត
- រៀបចំផែនការនិងចំណាត់ការចាំបាច់នានាក្នុងការគ្រប់គ្រង បង្ការ ការជួយសង្គ្រោះ និងការធានាសុវត្ថិភាពដល់ទេសចរតាមឆ្នេរសមុទ្រនៅតំបន់កោះរ៉ុង
- ផ្សព្វផ្សាយ អប់រំ និងណែនាំដល់អាជីវករនៅតំបន់កោះរ៉ុង អំពីលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំនានា សំដៅដល់ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនិងការចូលរួមទទួលខុសត្រូវខ្ពស់
- ចូលរួមផ្សព្វផ្សាយ អប់រំនិងណែនាំដល់អាជីវករ អំពីគុណភាពចំណីអាហារ ការថែរក្សាអនាម័យ និងបរិស្ថាននៅតាមឆ្នេរសមុទ្រនិងកោះនៃតំបន់កោះរ៉ុង
- ពង្រឹងគុណភាពផលិតផលទេសចរណ៍ សេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅតាមរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង

- សម្របសម្រួលជម្លោះផ្សេងៗរវាងប្រតិបត្តិករទេសចរណ៍និងភ្ញៀវទេសចរ និងរាយការណ៍មកមន្ទីរទេសចរណ៍ ដើម្បីមានវិធានការបន្ត
- លើកសំណើ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំមន្ទីរនិងក្រសួងទេសចរណ៍ក្នុងការកែលម្អនិងអភិវឌ្ឍស្តង់ដាររមណីយដ្ឋានឆ្នេរសមុទ្រ
- សហការជាមួយអង្គភាពពាក់ព័ន្ធនិងផ្នែកឯកជន ដើម្បីរៀបចំសកម្មភាពកម្សាន្តកីឡាទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍នានានៅរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីការងារនិងថែរក្សាធនធានធម្មជាតិលើកោះនិងបាតសមុទ្រ។

**៩-ការិយាល័យទីក្រុងស្អាត** មានតួនាទី និងភារកិច្ចៈ

- ជំរុញលើកកម្ពស់សោភណភាពទីប្រជុំជននិងគោលដៅទេសចរណ៍ក្នុងក្រុងខណ្ឌបេក្ខភាពនៃរាជធានីខេត្ត
- រៀបចំ ជំរុញ ពិនិត្យ និងវាយតម្លៃទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាតនៅក្នុងមូលដ្ឋាន
- ចូលរួមអង្កេតនិងវាយតម្លៃការអនុវត្តផែនការនិងគម្រោងអភិវឌ្ឍន៍ការងារប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាតនៅក្នុងមូលដ្ឋាន
- ចូលរួមផ្សព្វផ្សាយ អប់រំការយល់ដឹងអំពីគុណប្រយោជន៍នៃវិស័យទេសចរណ៍ក្នុងបរិបទសេដ្ឋកិច្ចសង្គម វប្បធម៌ និងបរិស្ថាន និងទស្សនទាន "ស្អាត និងបៃតង" ដល់ប្រតិបត្តិករ អាជីវករ កម្មករ និងប្រជាពលរដ្ឋ ព្រមទាំងគោលដៅទេសចរណ៍ សាលារៀន រោងចក្រ ផ្សារ និងទីប្រជុំជននានា
- ចូលរួមរៀបចំ ចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីសក្តានុពលទេសចរណ៍ក្នុងតំបន់តាមរយៈគេហទំព័រសារអេឡិចត្រូនិចនិងបណ្តាញផ្សព្វផ្សាយសង្គម
- ចូលរួមរៀបចំនិងផ្សព្វផ្សាយព័ត៌មានអប់រំការយល់ដឹងជាសាធារណៈទាក់ទងនឹងកិច្ចអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពនិងទទួលខុសត្រូវ
- សហការសិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគទិន្នន័យនិងឯកសារ ដែលពាក់ព័ន្ធនឹងការងារវាយតម្លៃទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- សហការជំរុញការចូលរួមពីសាធារណជននិងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- សហការផ្សព្វផ្សាយអំពីការប្រឡងប្រណាំងកម្ពុជាស្អាត សាលាស្អាត និងផ្សារស្អាត និងការប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍និងស្ថាប័នពាក់ព័ន្ធ
- សហការផ្សព្វផ្សាយអំពីការប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អដល់ក្រុង ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត បេក្ខភាពច្រកទ្វារអន្តរជាតិ និងប្រតិបត្តិករទេសចរណ៍។

**១០-ការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ** មានតួនាទី និងភារកិច្ចៈ

- ជាសេនាធិការឱ្យមន្ទីរទេសចរណ៍រាជធានីខេត្ត ក្នុងការអនុវត្តការងារទេសចរណ៍នៅក្នុងមូលដ្ឋាន
- ធានាអនុវត្តគោលនយោបាយ គោលការណ៍ សេចក្តីណែនាំ និងរាល់លិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងទេសចរណ៍ និងផែនការទិសដៅភារកិច្ចរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត
- គ្រប់គ្រងនិងត្រួតពិនិត្យរាល់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ក្នុងមូលដ្ឋាន ដែលក្រសួងទេសចរណ៍ បានធ្វើប្រតិភូកម្មអំណាច
- ផ្តល់ព័ត៌មានអំពីការវិវឌ្ឍនិងដំណើរការប្រែប្រួលអាជីវកម្មនិងសេវាកម្មទេសចរណ៍នានា
- សម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌនិងអាជ្ញាធរមូលដ្ឋាន ដើម្បីជំរុញការអនុវត្តចលនាប្រឡងប្រណាំង **ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**

- ជំរុញការផ្សព្វផ្សាយ និងការអនុវត្តច្បាប់ស្តីពីទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍ឱ្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្នុងក្រុង ស្រុក ខណ្ឌឱ្យបានត្រឹមត្រូវ និងរំឭក ដល់ម្ចាស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ឱ្យសុំបន្តអាជ្ញាប័ណ្ណមុនពេលផុតសុពលភាព
- ស្រាវជ្រាវ ប្រមូលផ្តុំ និងផ្តល់ព័ត៌មានអំពីការអភិវឌ្ឍវិស័យទេសចរណ៍ និងដំណើការប្រែប្រួលអាជីវកម្មសេវាកម្មទេសចរណ៍នៅក្នុងមូលដ្ឋាន
- លើកគំនិតផ្តួចផ្តើមស្នើដល់មន្ទីរទេសចរណ៍រាជធានីខេត្ត ដើម្បីបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍រយៈពេលខ្លីនិងមធ្យម ដល់និយោជក និយោជិត និងប្រតិបត្តិករទេសចរណ៍នានា ដែលធ្វើសកម្មភាពអាជីវកម្មនិងសេវាកម្មទេសចរណ៍
- លើកសំណើនិងផ្តល់យោបល់ដល់មន្ទីរទេសចរណ៍រាជធានីខេត្ត ក្នុងការកែលម្អនិងអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងមូលដ្ឋាន ដោយមានការគាំទ្រពីអាជ្ញាធរក្រុង ស្រុក ខណ្ឌ
- លើកសំណើនិងផ្តល់យោបល់ជូនមន្ទីរទេសចរណ៍រាជធានីខេត្ត ក្នុងការផ្តល់រង្វាន់និងបណ្ណសរសើរដល់ប្រតិបត្តិករទេសចរណ៍គំរូ
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅមូលដ្ឋាន ដើម្បីគ្រប់គ្រងស្ថិតិទេសចរណ៍ មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍គ្រប់ប្រភេទនៅក្នុងក្រុង ស្រុក ខណ្ឌ និងចុះត្រួតពិនិត្យសកម្មភាពនានា ការរៀបចំរបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងរក្សាសុវត្ថិភាពនៅក្នុងសេវាកម្មទេសចរណ៍នៅក្នុងក្រុង ស្រុក ខណ្ឌ។

**ប្រការ៩ .-**

ការិយាល័យនីមួយៗ ចំណុះឱ្យមន្ទីរទេសចរណ៍រាជធានីខេត្ត មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាពការងារនិងគម្រោងចំណាយប្រចាំឆ្នាំជូនប្រធានមន្ទីរទេសចរណ៍
- ធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំជូនប្រធានមន្ទីរទេសចរណ៍
- ទទួលអនុវត្តតួនាទីភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីប្រធានមន្ទីរទេសចរណ៍។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**ប្រការ១០ .-**

ការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតកន្លងមក ត្រូវអនុវត្តតាមតួនាទី និងភារកិច្ច ដូចមានកំណត់នៅក្នុងប្រកាសនេះ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ១១ .-**

ប្រកាសនេះ និរាករប្រកាសដូចខាងក្រោមៈ

- ប្រកាសលេខ០៦៧ ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីរទេសចរណ៍ខេត្ត-ក្រុង
- ប្រកាសលេខ១៨៧ ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យគ្រប់គ្រងឆ្នេរចំណុះឱ្យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
- ប្រកាសលេខ០៦៨ ប្រក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យទេសចរណ៍កោះរ៉ុងចំណុះឱ្យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានីខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ ១២៣ ប្រក ចុះថ្ងៃ អង្គារ ១២កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត

## អង្គការលេខនៃមន្ទីរទេសចរណ៍ខេត្តកំពង់ធំ



# ឧបសម្ព័ន្ធទី ៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

មន្ទីរទេសចរណ៍ខេត្តកំពង់ធំ

លេខ ០៤៤ របក.មទច

# របាយការណ៍

# បូកសរុបលទ្ធផលការងារទេសចរណ៍

# ប្រចាំឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**
**មន្ទីរទេសចរណ៍ខេត្តកំពង់ធំ**
**លេខ** ០៤៤ ទសក.កពធ

**CAMBODIA**
*Kingdom of Wonder*
*feel the warmth*

**ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ**

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**តាមរយៈ ៖ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ**

**កម្មវត្ថុ** ៖ របាយការណ៍បូកសរុបសកម្មភាពការងារទេសចរណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តរបស់មន្ទីរទេសចរណ៍ខេត្តកំពង់ធំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាប អំពីសកម្មភាពការងារទេសចរណ៍ប្រចាំឆ្នាំ២០២១ របស់មន្ទីរទេសចរណ៍ខេត្តកំពង់ធំមានដូចខាងក្រោម៖

## ១.ស្ថិតិភ្ញៀវទេសចរមកទស្សនា និងស្នាក់នៅ

ភ្ញៀវទេសចរជាតិ និងបរទេស ដែលបានមកទស្សនា និងស្នាក់នៅ ក្នុងខេត្តកំពង់ធំប្រចាំឆ្នាំ ២០២១ មានដូចខាងក្រោម៖

- ស្ថិតិភ្ញៀវទេសចរមកទស្សនាសរុបមានចំនួន ៦៤,៧១០នាក់ ប្រៀបធៀបចំនួនភ្ញៀវទេសចរប្រចាំឆ្នាំ២០២០កន្លងមក មានចំនួនសរុប ១៤៨,០៦៥នាក់ ថយចុះចំនួន ៥៦.៣០% រួមមាន៖

ក. ភ្ញៀវទេសចរជាតិ មានចំនួនសរុប ៦៤,២៧៦នាក់ ប្រៀបធៀបចំនួនភ្ញៀវទេសចរជាតិប្រចាំឆ្នាំ២០២០កន្លងមក មានចំនួនសរុប ១៤០,៣៤១នាក់ ថយចុះចំនួន ៥៤.២០%។

ខ. ភ្ញៀវទេសចរបរទេស មានចំនួនសរុប ៤៣៤នាក់ ប្រៀបធៀបចំនួនភ្ញៀវទេសចរបរទេសប្រចាំឆ្នាំ២០២០កន្លងមក មានចំនួនសរុប ៧,៧២៤នាក់ ថយចុះចំនួន ៩៤.៣៨%។

- ស្ថិតិភ្ញៀវទេសចរមកស្នាក់នៅសរុបមានចំនួន ៦៧,០២៦នាក់ ប្រៀបធៀបចំនួនភ្ញៀវទេសចរប្រចាំឆ្នាំ២០២០កន្លងមក មានចំនួនសរុប ១២៧,៩០១នាក់ ថយចុះចំនួន ៤៧.៦០% រួមមាន៖

ក. ភ្ញៀវទេសចរជាតិ មានចំនួនសរុប ៦៦,៣៤១នាក់ ប្រៀបធៀបចំនួនភ្ញៀវទេសចរជាតិប្រចាំឆ្នាំ២០២០កន្លងមក មានចំនួនសរុប ១២៣,៩៥២នាក់ ថយចុះចំនួន ៤៦.៤៨%។

ខ. ភ្ញៀវទេសចរបរទេស មានចំនួនសរុប ៦៨៥នាក់ ប្រៀបធៀបចំនួនភ្ញៀវទេសចរបរទេសប្រចាំឆ្នាំ២០២០កន្លងមក មានចំនួនសរុប ៣,៩៤៩នាក់ ថយចុះចំនួន ៨២.៦៥%។

## ២.ការគ្រប់គ្រងខ្សែចង្វាក់ផលិតកម្មទេសចរណ៍

- អាជ្ញាបណ្ណទេសចរណ៍ដែលបានចុះពិនិត្យ និងបញ្ជូនឯកសារស្នើសុំការសម្រេចជូនប្រតិបត្តិករទេសចរណ៍នៅក្នុងឆ្នាំ២០២១ មានសរុបចំនួន ១៩១ទីតាំង ដូចខាងក្រោម៖

ក. រមណីយដ្ឋាន ចំនួន០២ទីតាំង (អាជ្ញាបណ្ណចេញដោយក្រសួងទេសចរណ៍ចំនួន០២ទីតាំង)បន្តចំនួន០២ទីតាំង និងមានបុគ្គលិកចំនួន៣៧នាក់ ស្រី១៤នាក់។

ខ.សណ្ឋាគារ ចំនួន០៨ទីតាំង មានចំណុះ៣០៩បន្ទប់ (អាជ្ញាបណ្ណចេញដោយក្រសួងទេសចរណ៍ចំនួន០៦ទីតាំង អង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំចំនួន០២ទីតាំង)បន្តចំនួន០៨ទីតាំង និងមានបុគ្គលិកចំនួន៦៤នាក់ ស្រី៤២នាក់។

គ.ផ្ទះភ្ញៀវ ចំនួន៥៣ទីតាំង មានចំណុះ៨៥៦បន្ទប់ (អាជ្ញាបណ្ណចេញដោយក្រសួងទេសចរណ៍ចំនួន០៨ទីតាំង អង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំចំនួន៣២ទីតាំង ការិយាល័យច្រកចេញចូលតែមួយក្រុងស្ទឹងសែនចំនួន០៨ទីតាំង ការិយាល័យច្រកចេញចូលតែមួយស្រុកស្ទោងចំនួន០៣ទីតាំង ការិយាល័យច្រកចេញចូលតែមួយស្រុកសន្ទុកចំនួន០២ទីតាំង) ថ្មីចំនួន០៥ទីតាំង បន្តចំនួន៤៧ទីតាំង និងមានបុគ្គលិកចំនួន១៤៥នាក់ ស្រី១០៥នាក់។

ឃ.ភោជនីយដ្ឋាន-អាហារដ្ឋាន ចំនួន៥២ទីតាំង មានចំណុះ៣,០៤៩កៅអី (អាជ្ញាបណ្ណផ្តល់ដោយក្រសួងទេសចរណ៍ចំនួន០២ទីតាំង អង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំចំនួន១៦ទីតាំង ការិយាល័យច្រកចេញចូលតែមួយក្រុងស្ទឹងសែនចំនួន២៣ទីតាំង ការិយាល័យច្រកចេញចូលតែមួយស្រុកសន្ទុកចំនួន១០ទីតាំង និងការិយាល័យច្រកចេញចូលតែមួយស្រុកស្ទោងចំនួន០១ទីតាំង) ថ្មីចំនួន០៨ទីតាំង បន្តចំនួន៤៤ទីតាំង និងមានបុគ្គលិកសរុបចំនួន៣១៣នាក់ ស្រី២២១នាក់។

ង. ម៉ាស្សាសុខភាព ចំនួន០៥ទីតាំង មានចំណុះ២៨គ្រែ (អាជ្ញាបណ្ណចេញដោយអង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំចំនួន០១ទីតាំង ការិយាល័យច្រកចេញចូលតែមួយក្រុងស្ទឹងសែនចំនួន០៤ទីតាំង) បន្តចំនួន០៥ទីតាំង និងមានបុគ្គលិក១២នាក់ ស្រី១២នាក់។

ច.ខារ៉ាអូខេ ចំនួន១៣ទីតាំង មានចំណុះ៨៤បន្ទប់ (អាជ្ញាបណ្ណចេញដោយអង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំចំនួន០៥ទីតាំង ការិយាល័យច្រកចេញចូលតែមួយក្រុងស្ទឹងសែនចំនួន០៧ទីតាំង ការិយាល័យច្រកចេញចូលតែមួយស្រុកសន្ទុកចំនួន០១ទីតាំង) ថ្មីចំនួន០១ទីតាំង បន្តចំនួន១២ទីតាំង និងមានបុគ្គលិកមានបុគ្គលិក៧៨នាក់ ស្រី៦១នាក់។

ឆ.ហាងលក់គុយទាវកាហ្វេ ចំនួន២៤ទីតាំង មានចំណុះ៨៦៨កៅអី (អាជ្ញាបណ្ណចេញដោយការិយាល័យច្រកចេញចូលតែមួយក្រុងស្ទឹងសែនចំនួន២២ទីតាំង ការិយាល័យច្រកចេញចូលតែមួយស្រុកស្ទោងចំនួន០២ទីតាំង ថ្មីចំនួន០៥ទីតាំង បន្តចំនួន១៩ទីតាំង និងមានបុគ្គលិកសរុបចំនួន៥៨នាក់ ស្រី៥០នាក់។

ជ.ផ្ទះជួលបន្ទប់ស្នាក់នៅ ចំនួន២៧ទីតាំង មានចំណុះ២០៩បន្ទប់ (អាជ្ញាបណ្ណចេញដោយការិយាល័យច្រកចេញចូលតែមួយក្រុងស្ទឹងសែនចំនួន២៤ទីតាំង ការិយាល័យច្រកចេញចូលតែមួយស្រុកសន្ទុកចំនួន០៣ទីតាំង) ថ្មីចំនួន០៣ទីតាំង បន្តចំនួន២៤ទីតាំង។

ឈ.កីឡាស្នូកឃ័រ ចំនួន០៧ទីតាំង មានចំណុះ៣២តុ (អាជ្ញាបណ្ណចេញដោយអង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំចំនួន០៣ទីតាំង ការិយាល័យច្រកចេញចូលតែមួយក្រុងស្ទឹងសែន

ចំនួន០៤ទីតាំង) ថ្មីចំនួន០១ទីតាំង បន្តចំនួន០៦ទីតាំង និងមានបុគ្គលិកចំនួន១១នាក់ ស្រី០៨នាក់។

- បានផ្សព្វផ្សាយ និងណែនាំដល់អ្នកគ្រប់គ្រងអាជីវកម្ម ដើម្បីសហការជាមួយសមត្ថកិច្ចក្នុងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ការជួញដូរស្ត្រី និងកុមារ ក្នុងមូលដ្ឋានអាជីវកម្មបានចំនួន៥០ទីតាំង (សណ្ឋាគារ ចំនួន០៨ទីតាំង ផ្ទះសំណាក់ ចំនួន៤០ទីតាំង ស្នូកឃ័រចំនួន០៣ទីតាំង ខារ៉ាអូខេចំនួន០៥ទីតាំង)។
- បានចូលវគ្គបណ្តុះបណ្តាលស្តីពី វិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មម៉ាស្សា នាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងកញ្ចប់ទស្សនកិច្ចទេសចរក្នុងស្រុកចាក់វ៉ាក់សាំង នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំលើកទី១នៃក្រុមការងារអន្តរស្ថាប័នរៀបចំ យុទ្ធនាការអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍ នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) តាមគន្លងប្រក្រតីភាពថ្មី សម្រាប់អាជីវកម្មខារ៉ាអូខេ រង្គសាលឌីស្កូតែក និងអាជីវកម្មសេវាម៉ាស្សា ដើម្បីត្រៀមបើកដំណើរការឡើងវិញ ជូនម្ចាស់អាជីវកម្មទេសចរណ៍ក្នុងខេត្តកំពង់ធំ ចំនួន៣៨ទីតាំង (ខារ៉ាអូខេ ចំនួន២៨ទីតាំង ម៉ាស្សាសុខភាពចំនួន១០ទីតាំង) នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសាលប្រជុំមន្ទីរទេសចរណ៍ខេត្តកំពង់ធំ។
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការរៀបចំគោលដៅខេត្តសៀមរាបៈ ជាគោលដៅទទួលទេសចរណ៍វ៉ាក់សាំង នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មខារ៉ាអូខេ រង្គសាល-ឌីស្កូតែក និងអាជីវកម្មសេវាម៉ាស្សា ដើម្បីត្រៀមបើកដំណើរការឡើងវិញ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលពិធីប្រកាសផ្សព្វផ្សាយវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មបៀរហ្គាឌិន នាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធអនឡាញចុះបញ្ជីកញ្ចប់ទស្សនកិច្ចចាក់វ៉ាក់សាំង នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- ក្រុមការងារមន្ទីរបានចុះផ្សព្វផ្សាយប្រកាស សេចក្តីសម្រេច និងសារាចរណែនាំ ស្តីពីការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ និង

រមណីយដ្ឋានទេសចរណ៍ជូនម្ចាស់អាជីវកម្មទេសចរណ៍ក្នុងស្រុកសន្ទុក ស្រុកកំពង់ស្វាយ ស្រុកស្ទោង ស្រុកតាំងគោក ស្រុកប្រាសាទសំបូរ និងស្រុកសណ្ដាន់ បានចំនួន៤៦ទីតាំង (រមណីយដ្ឋានចំនួន០៣ទីតាំង ផ្ទះភ្ញៀវចំនួន០៩ទីតាំង ភោជនីយដ្ឋាន អាហារដ្ឋាន ចំនួន ៣២ទីតាំង និងសហគមន៍ទេសចរណ៍ចំនួន០២ទីតាំង)។

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីនីតិវិធីប្រតិបត្តិស្ដង់ដារអប្បរមា (SOP) តាមគន្លងប្រក្រតីថ្មីសម្រាប់ផ្សារសាធារណៈ និងផ្សារទំនើប នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំផ្ទៀងផ្ទាត់លទ្ធផលរបាយការណ៍ការធ្វើបច្ចុប្បន្នភាព នៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្ដង់ដារអប្បរមា(SOP) សម្រាប់ជំហានទី១ របស់រដ្ឋបាលរាជធានី ខេត្ត នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំឆ្លងសេចក្ដីព្រាង ស្ដីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្ដង់ដារអប្បរមា(SOP) តាមគន្លងប្រក្រតីថ្មី សម្រាប់អាជីវកម្មបៀរហ្គាឌិន អាជីវកម្មកីឡាវាយកូនគោល អាជីវកម្មម៉ាស្សា និងសេវាកម្មទេសចរណ៍ម៉ាយ(MICE) នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយប្រកាស សេចក្ដីសម្រេច និងសារាចរណែនាំ ស្ដីពីការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្ដង់ដារអប្បបរមាសម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ជូនម្ចាស់អាជីវកកម្មទេសចរណ៍ក្នុងក្រុងស្ទឹងសែន ចំនួន៧០ទីតាំង (សណ្ឋាគារ ចំនួន១០ទីតាំង ផ្ទះភ្ញៀវ ចំនួន២៥ទីតាំង ភោជនីយដ្ឋាន អាហារដ្ឋាន ចំនួន៣៥ទីតាំង) ចាប់ពីថ្ងៃទី១០-១៤ ខែកញ្ញា ឆ្នាំ២០២១ នៅសាលប្រជុំមន្ទីរទេសចរណ៍ខេត្តកំពង់ធំ។
- បានចូលរួមកិច្ចប្រជុំ ស្ដីពីការពង្រឹងគុណភាព និងទិន្នន័យទេសចរណ៍ នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការបញ្ចូលទិន្នន័យបុគ្គលិកដែលបម្រើការងារក្នុងវិស័យទេសចរណ៍ដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងប្រព័ន្ធ Telegram Bot នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីបទដ្ឋានគតិយុត្តដាក់ឱ្យអនុវត្តបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្ដង់ដារអប្បបរមាសម្រាប់សេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំលើកទី១ នៃក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្ដារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ Zoom Meeting។

- ចុះផ្សព្វផ្សាយសេចក្ដីសម្រេចលេខ ១២០/២១ សសរ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តកំពង់ធំ ស្ដីពីការដាក់ចេញវិធានការរដ្ឋបាល ដោយផ្អាកបណ្ដោះអាសន្ន សកម្មភាពការងារមុខរបរ និងអាជីវកម្ម ដែលមានហានិភ័យខ្ពស់នៃការឆ្លងជំងឺកូវីដ១៩ និងការប្រមូលផ្ដុំ ឬជួបជុំមនុស្សជាលក្ខណៈឯកជនរយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ដល់ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ នៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ហាងលក់គុយទាវ កាហ្វេ និងនៅតាមរមណីយដ្ឋានទេសចរណ៍ក្នុងខេត្តកំពង់ធំ។
- បានផ្សព្វផ្សាយសេចក្ដីសម្រេចលេខ១១៥/២១ សសរ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តកំពង់ធំ ស្ដីពីការបន្តអនុវត្តវិធានការរដ្ឋបាល ចាប់ពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ នៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ហាងលក់គុយទាវកាហ្វេក្នុងខេត្តកំពង់ធំ។
- បានផ្សព្វផ្សាយសេចក្ដីសម្រេចលេខ ៤៤៨០/២១ សសរ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តកំពង់ធំ ស្ដីពីការអនុវត្តវិធានការរដ្ឋបាល ចាប់ពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ នៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ហាងលក់គុយទាវកាហ្វេក្នុងខេត្តកំពង់ធំ។
- បានចូលរួមកិច្ចប្រជុំផ្ទៀងផ្ទាត់របាយការណ៍ ស្ដីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍អមជាមួយនឹងការផ្ទៀងផ្ទាត់របាយការណ៍បច្ចុប្បន្នភាពស្ថិតិបិទនិងផ្អាកអាជីវកម្មទេសចរណ៍របស់មន្ទីរទេសចរណ៍រាជធានី ខេត្ត នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញកម្មវិធី Zoom Meeting។
- ចុះផ្សព្វផ្សាយសេចក្ដីសម្រេចលេខ ០៩០/២១ សសរ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តកំពង់ធំ ពីការបន្តផ្អាកជាបណ្ដោះអាសន្នការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ ការជួបជុំគ្នាពិសារគ្រឿងស្រវឹង និងការទទួលភ្ញៀវចូលទទួលទានអាហារ ឬភេសជ្ជៈតាមអាហារដ្ឋាន ចាប់ពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ នៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ហាងលក់គុយទាវកាហ្វេ និងនៅតាមរមណីយដ្ឋានទេសចរណ៍ក្នុងខេត្តកំពង់ធំ។
- បានចុះពង្រឹងការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល វិធានសុវត្ថិភាពទេសចរណ៍ សម្រាប់សេវាកម្មស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ និងការរៀបចំគ្រប់គ្រងចរន្តភ្ញៀវទេសចរនៅតាមរមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ និងគោលដៅទេសចរណ៍ ជូនប្រតិបត្តិករទេសចរណ៍តាមសេវាស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន និងអាហារដ្ឋាន រមណីយដ្ឋានទេសចរណ៍ និងគោលដៅទេសចរណ៍ក្នុងខេត្តកំពង់ធំ សរុបចំនួន៧៩ទីតាំង (សណ្ឋាគារ ចំនួន០១ទីតាំង ផ្ទះភ្ញៀវចំនួន ២២ទីតាំង ភោជនីយដ្ឋាន-អាហារដ្ឋាន ចំនួន៥៤ទីតាំង និងរមណីយដ្ឋានចំនួន០២ទីតាំង) ចាប់ពីថ្ងៃទី០៤ ខែឧសភា ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១។

- បានចុះផ្សព្វផ្សាយសេចក្តីណែនាំលេខ ០៤២/២១ សណន របស់រដ្ឋបាលខេត្តកំពង់ធំ ស្តីពីវិធានការរដ្ឋបាលបណ្តោះអាសន្នរយៈពេល០៩ថ្ងៃ ចាប់ពីថ្ងៃទី១០ ដល់១៨ ខែមេសា ឆ្នាំ ២០២១ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរក្នុងភូមិសាស្ត្រខេត្តកំពង់ធំ និងសេចក្តីជូនដំណឹងលេខ ១៨៤ សជណ.អអទ របស់ក្រសួងទេសចរណ៍ ស្តីពីការបិទរមណីយដ្ឋានទូទាំងប្រទេសជាបណ្តោះអាសន្នរយៈពេល១៤ថ្ងៃ នៅតាមបណ្តាមូលដ្ឋានអាជីវកម្មទេសចរណ៍ និងរមណីយដ្ឋាននានាក្នុងខេត្តកំពង់ធំ។
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ ១៨៨ សជណ.អទ របស់ក្រសួងទេសចរណ៍ស្តីពីការបន្តបិទរមណីយដ្ឋានទេសចរណ៍ជាបណ្តោះអាសន្នរយៈពេល០៨ថ្ងៃបន្តទៀត រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមរមណីយដ្ឋានទេសចរណ៍ និងគោលដៅទេសចរណ៍ក្នុងខេត្តកំពង់ធំ។
- បានចុះធ្វើបច្ចុប្បន្នភាពអាជីវកម្មទេសចរណ៍តាមបណ្តាក្រុង ស្រុក ក្នុងខេត្តកំពង់ធំ ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១។
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការបន្តបិទអាជីវកម្មខារ៉ាអូខេ បៀហ្គាឌិន និងម៉ាស្សាសុខភាព ស្ប៉ា ដល់ប្រតិបត្តិករក្នុងខេត្តកំពង់ធំ ចាប់ពីថ្ងៃទី២២-២៤ ខែកុម្ភៈ២០២១។
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាង ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មម៉ាស្សា សុខភាព ខារ៉ាអូខេ ក្លឹបកម្សាន្ត(រង្គសាល ឌីស្កូតែក) និងបៀរហ្គាឌិន នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានសហការជាមួយក្រុមការងារក្រសួងទេសចរណ៍ ក្នុងការចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងក្រុងស្ទឹងសែនស្តីពី "បរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍" នាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។
- បានចូលរួមវគ្គបណ្តុះបណ្តាលជនបង្គោលតាមរាជធានី ខេត្ត ស្តីពីការបង្កើតQR Code សម្រាប់ចុះវត្តមានទេសចរក្នុងដំណាក់កាលជំងឺកូវីដ១៩ នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយនីតិវិធីនៃចលនាប្រឡងប្រណាំង "ទីក្រុងស្អាតៈ ទីក្រុងដែលអនុវត្តវិធានសុវត្ថិភាពល្អ" នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានចូលរួមប្រជុំបូកសរុបរបាយការណ៍ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងរបាយការណ៍អាជីវកម្មបានបិទ ផ្អាក ក្នុងដំណាក់កាលវិបត្តិជំងឺឆ្លងកូវីដ-១៩ ក្នុងឆ្នាំ២០២០ នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីគ្រូបង្គោលជំនាញសហគ្រិនភាពក្នុងវិស័យទេសចរណ៍ ចាប់ពីថ្ងៃទី២៥-២៧ ខែមករា ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានចូលរួមប្រជុំបូកសរុបរបាយការណ៍ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងរបាយការណ៍អាជីវកម្មបានបិទ ផ្អាក ក្នុងដំណាក់កាលវិបត្តិជំងឺឆ្លងកូវីដ-១៩ ក្នុងឆ្នាំ២០២០ នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។

## ៣.ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍

ក. សកម្មភាពផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍តាមអាជីវកម្មទេសចរណ៍ប្រចាំឆ្នាំ២០២១ ដូចខាងក្រោម៖

- ក្រុមការងារមន្ទីរបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មខារ៉ាអូខេ វង្គសាល-ឌីស្កូតែក និងម៉ាស្សា បានចំនួន៣៨ទីតាំង។
- ក្រុមការងារមន្ទីរបានចុះផ្សព្វផ្សាយផ្ទាល់តាមមូលដ្ឋានអាជីវកម្ម ស្តីពីការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មទេសចរណ៍បានចំនួន៤៦ទីតាំង។
- មន្ទីរបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយប្រកាស សេចក្តីសម្រេច និងសារាចរណែនាំ ស្តីពីការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ជូនម្ចាស់អាជីវកកម្មទេសចរណ៍ក្នុងក្រុងស្ទឹងសែន ចំនួន៧០ទីតាំង (សណ្ឋាគារ ចំនួន១០ទីតាំង ផ្ទះភ្ញៀវ ចំនួន២៥ទីតាំង ភោជនីយដ្ឋាន អាហារដ្ឋាន ចំនួន៣៥ទីតាំង) ចាប់ពីថ្ងៃទី១០-១៤ ខែកញ្ញា ឆ្នាំ២០២១ នៅសាលប្រជុំមន្ទីរទេសចរណ៍ខេត្តកំពង់ធំ។
- ក្រុមការងារមន្ទីរ បានចុះត្រួតពិនិត្យវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មទេសចរណ៍ចំនួន៤៩ទីតាំង។

### ខ.លទ្ធផលការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍

ចាប់តាំងពីប្រកាសដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ មន្ទីរបានចុះផ្សព្វផ្សាយនិងត្រួតពិនិត្យវាយតម្លៃ និងផ្តល់ឡាបិលដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ ដូចខាងក្រោម៖

- ក្នុងឆ្នាំ២០២០ មន្ទីរបានផ្តល់ឡាបិលវិធានសុវត្ថិភាពទេសចរណ៍ សរុបចំនួន៥៦ទីតាំង ក្នុងនោះមានសេវាកម្មស្នាក់នៅទេសចរណ៍ចំនួន២៦ទីតាំង (សណ្ឋាគារ ចំនួន០៧ទីតាំង ផ្ទះភ្ញៀវ ចំនួន១៩ទីតាំង) ភោជនីយដ្ឋាន-អាហារដ្ឋាន ចំនួន២៩ទីតាំង និងរមណីយដ្ឋានទេសចរណ៍ ចំនួន០១ទីតាំង។
- ក្នុងឆ្នាំ២០២១ មន្ទីរបានបន្តផ្សព្វផ្សាយលើការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍បានសរុបចំនួន១៥៤កន្លែង (រមណីយដ្ឋាន ចំនួន០៣ទីតាំង សណ្ឋាគារ ចំនួន១០ទីតាំង ផ្ទះភ្ញៀវ ចំនួន៣៤ទីតាំង ភោជនីយដ្ឋាន-អាហារដ្ឋានចំនួន៦៧ទីតាំង សហគមន៍ទេសចរណ៍ចំនួន០២ទីតាំង ខារ៉ាអូខេចំនួន២៨ទីតាំង ម៉ាស្សាចំនួន១០ទីតាំង) និងត្រួតពិនិត្យលើការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ សរុបចំនួន៤៩ទីតាំង (សណ្ឋាគារ ចំនួន០៧ទីតាំង ផ្ទះភ្ញៀវ ចំនួន២៧ទីតាំង ភោជនីយដ្ឋាន-អាហារដ្ឋាន ចំនួន១២ទីតាំង ខារ៉ាអូខេចំនួន០៣ទីតាំង) និងបានផ្តល់ឡាបិលវិធានសុវត្ថិភាពទេសចរណ៍ជូនប្រតិបត្តិករទេសចរណ៍ចំនួន០៤អាជីវកម្ម (សណ្ឋាគារ ចំនួន០២ទីតាំង ផ្ទះភ្ញៀវ ចំនួន០២ទីតាំង)។
- តាមរយៈការចុះផ្សព្វផ្សាយនិងវាយតម្លៃសង្កេតឃើញថា អាជីវកម្មទេសចរណ៍ភាគច្រើនបានព្យាយាមអនុវត្តន៍តាមវិធានសុវត្ថិភាពទេសចរណ៍ក្នុងការបង្ការជំងឺកូវីដ-១៩ ដោយមានបិទសារណែនាំស្របតាមវិធានសុខាភិបាល មានដាក់អាល់កុល ឬជែលសម្រាប់លាងសម្អាតដៃ

មានបិទ QR Code Stop covid-19 មានការវាស់កម្តៅមុនចូលក្នុងបរិវេណអាជីវកម្ម ព្រមទាំងណែនាំដល់បុគ្គលិកបម្រើសេវាកម្មពាក់ម៉ាស់ការពារការចម្លង។ ដោយឡែកសម្រាប់អាជីវកម្មជាលក្ខណៈគ្រួសារតូចៗមួយចំនួននៅពុំទាន់អនុវត្តន៍ បានគ្រប់លក្ខណៈវិនិច្ឆ័យតាមវិធានសុវត្ថិភាពទេសចរណ៍នៅឡើយ។

**៤.ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍**

- បានចុះអប់រំណែនាំ និងបណ្តុះបណ្តាលផ្ទាល់ដល់ទីតាំងសេវាកម្មទេសចរណ៍ផ្នែកបដិសណ្ឋារកិច្ច សុវត្ថិភាពចំណីអាហារ និងយេនឌ័រក្នុងវិស័យទេសចរណ៍ ជូនម្ចាស់ និងបុគ្គលិកបម្រើការងារនៅក្នុងភោជនីយដ្ឋាន អាហារដ្ឋានចំនួន២២ទីតាំង ដែលមានអ្នកចូលរួមចំនួន១៧៤នាក់ ស្រី ១១៤នាក់។
- បានចូលរួមកិច្ចប្រជុំពិភាក្សាណែនាំជាមួយអាជ្ញាធរពាក់ព័ន្ធតាមបណ្តាភូមិ ឃុំ គោលដៅនៃគម្រោងបញ្ជ្រាបយេនឌ័រ ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE) របស់ក្រសួងកិច្ចការនារី រួមមានភូមិព្រៃគុយ(ក) ឃុំព្រៃគុយ ស្រុកកំពង់ស្វាយ និងភូមិឈើទាល ភូមិអូរគ្រូកែ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាថ្ងៃទី១-៤ ខែវិច្ឆិកា ឆ្នាំ២០២១។
- បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារនារី និងយេនឌ័រក្នុងត្រីមាសទី៣ នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង នីតិវិធីប្រតិបត្តិស្តង់ដារអប្បរមាសម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃក្នុងគន្លងប្រក្រតីថ្មី នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ www.tptd.org។
- បានចូលរួមកិច្ចប្រជុំក្រុមការងារបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ នៅមន្ទីរកិច្ចការនារីខេត្តកំពង់ធំ។
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី១លើសេចក្តីព្រាង ស្តីពីស្តង់ដាសមត្ថភាពសម្រាប់អ្នកបម្រើសេវាកម្មក្នុងកម្មវិធីអាពាហ៍ពិពាហ៍ និងពិធីជប់លៀងផ្សេងៗ នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ www.tptd.org។
- បានចូលរួមកិច្ចប្រជុំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការជំរុញការចូលរួមរបស់ស្ត្រីក្នុងផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ នាថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ www.tptd.org។
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីសារាចរ ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍តាមប្រព័ន្ធអនឡាញ www.tptd.org នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ www.tptd.org

- បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារនារី និងយេនឌ័រប្រចាំឆមាសទី១ ឆ្នាំ២០២១ របស់ក្រសួងទេសចរណ៍ នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញកម្មវិធីZoom Meeting។
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រប្រើប្រាស់ប្រព័ន្ធចុះទិន្នន័យអ្នកជំនាញទេសចរណ៍ដែលទទួលបានការបណ្តុះបណ្តាល និងទិន្នន័យកម្លាំងពលកម្មដែលកំពុងបម្រើការងារក្នុងឧស្សាហកម្មទេសចរណ៍ទៅក្នុងប្រព័ន្ធអនឡាញ www.tptd.org នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០២១ តាមរយៈប្រព័ន្ធអនឡាញ www.tptd.org។
- បានចូលរួមកិច្ចប្រជុំ ស្តីពីសេចក្តីព្រាងផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ក្នុងដំណាក់កាល និងក្រោយវិបត្តិកូវីដ១៩ ឆ្នាំ២០២១-២០២៥ នាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានចូលរួមសិក្ខាសាលា ស្តីពីការបង្កើតតារាងម៉ាទ្រិករៀបចំគម្រោង(PDM)និងផែនការប្រតិបត្តិ និងកិច្ចប្រជុំក្រុមការងារបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីលើកទី៤ ចាប់ពីថ្ងៃទី០២-០៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅមន្ទីរកិច្ចការនារីខេត្តកំពង់ធំ។
- បានសហការជាមួយនាយកដ្ឋានអប់រំបណ្តុះបណ្តាលនៃក្រសួងទេសចរណ៍ និងមន្ទីរកិច្ចការនារីខេត្តកំពង់ធំ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍសមត្ថភាពឆ្លើយតបនឹងជំងឺកូវីដ-១៩ សម្រាប់ស្ត្រីក្នុងវិស័យទេសចរណ៍ ជូនសហគមន៍ទេសចរណ៍សំបូរព្រៃគុក នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ នៅមជ្ឈមណ្ឌលលក់ផលិតផលសហគមន៍សំបូរព្រៃគុក។
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលបឋមនៃការអង្កេត ស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យទេសចរណ៍ខេត្តសៀមរាប និងកំពង់ធំ នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានផ្សព្វផ្សាយដល់បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍អំពីការជ្រើសរើសយុវជន និងសិស្សានុសិស្សចូលរៀនដោយឥតគិតថ្លៃនៅសាលាទេសចរណ៍និងបដិសណ្ឋារកិច្ចវីត សម្រាប់ឆ្នាំ២០២០-២០២១ នាថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១។

**៥.ការអភិវឌ្ឍផលិតផលទេសចរណ៍**

រមណីយដ្ឋានទេសចរណ៍ដែលមានសក្តានុពលក្នុងខេត្តរួមមានៈ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ប្រាសាទគុកនគរ រមណីយដ្ឋានភ្នំសន្ទុក រមណីយដ្ឋានស្ទឹងជីនិត ស្ទឹងព្រៃប្រស់ បឹងសំរីទ្ធិ ទំនប់៦មករា ផ្ទះតាព្រំ រមណីយដ្ឋានកែងគោល មជ្ឈមណ្ឌលសាសនា វប្បធម៌ ទេសចរណ៍ សំពៅត្រៃលោកត្រៃលក្ខណ៍ និងវត្តឥន្ទ្រីយ៍សំវរៈ (ហៅវត្តកំពង់ធំ) ដែលមានទេសចរចូលចិត្តទៅទស្សនាកំសាន្តជាច្រើនក្នុងខេត្ត។

- បានចុះពង្រឹងការងាររៀបចំសេវាកម្មផ្ទះស្នាក់ និងការរៀបចំកន្លែងទស្សនានៅក្នុងសហគមន៍ទេសចរណ៍ និងរមណីយដ្ឋាន នៅស្រុកកំពង់ស្វាយ ស្រុកប្រាសាទសំបូរ ស្រុកសន្ទុក និងស្រុកសណ្តាន់ បានចំនួន០៥ទីតាំង (សហគមន៍ទេសចរណ៍ចំនួន០៤ទីតាំង និងរមណីយដ្ឋានចំនួន ០១ទីតាំង)។
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី វេទិកាទេសចរណ៍អាស៊ានឆ្នាំ២០២២ នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ តាម រយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំបច្ចេកទេសគម្រោងអភិវឌ្ឍន៍សហគមន៍នេសាទផាត់សណ្តាយ និងដំណើរទស្សនកិច្ចទៅកាន់ខេត្តកែប និងកំពត ចាប់ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០២១។

- បានចូលរួមប្រជុំឆ្លងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២១-២០២៣)របស់គណកម្មាធិការសម្របសម្រួលបច្ចេកទេស និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២២-២០២៤) របស់រដ្ឋបាលខេត្តកំពង់ធំ នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសាលាខេត្តកំពង់ធំ។
- បានចូលរួមកិច្ចប្រជុំឆ្លុះបញ្ចាំងលទ្ធផលការចុះប្រមូលព័ត៌មាន និងផ្សព្វផ្សាយផលិតផលសហគមន៍ ដើម្បីត្រៀមរៀបចំពិព័រណ៍សហគមន៍ឆ្នាំ២០២២ ក្នុងខេត្តកំពង់ធំ នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីលទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ នាថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសណ្ឋាគារកំពង់ធំរ៉ូយ៉ាល់។
- បានចូលរួមវេទិកាកសិករថ្នាក់តំបន់ជុំវិញបឹងទន្លេសាប ស្តីពីការលើកកម្ពស់ទីផ្សារ និងការកែច្នៃកសិផលរបស់កសិករខ្នាតតូច និងមធ្យម នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមក្នុងពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការដាក់ឱ្យអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំបូកសរុបការងារទេសចរណ៍ក្នុងស្រុក០៩ខែ ដើមឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមប្រជុំ ស្តីពីសមាសភាគគម្រោងរបស់អង្គការវីអេសអូកម្ពុជា នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយនាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍នៃក្រសួងទេសចរណ៍ ស្តីពីឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តកំពង់ធំ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត ស្តីពីការសិក្សាវាយតម្លៃស្ថានភាពការងារគ្រប់គ្រង និងសេដ្ឋកិច្ចសង្គមនៃតំបន់ស្ទឹងសែន និងតំបន់ស្នូលបឹងទន្លេឆ្មា ចាប់ពីថ្ងៃទី១២-១៣ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ Zoom Meeting។
- បានចូលរួមកិច្ចប្រជុំជាមួយក្រុមបេសកជនរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ស្តីពីការគាំទ្របច្ចេកទេសដោយក្រុមប្រឹក្សា ADB លើការកសាងផែនការប្រើប្រាស់ដីចំនួន ០៤កន្លែង និងប្លង់គោលប្រើប្រាស់ដីធ្លីចំនួន ០២កន្លែងក្នុងក្រុងស្ទឹងសែន នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញកម្មវិធី Zoom Meeting។
- បានចូលរួមកិច្ចប្រជុំពិភាក្សាស្វែងយល់អំពី ផែនការអភិវឌ្ឍន៍ខេត្ត និងផែនការគ្រប់គ្រងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ នៅសាលប្រជុំសាលាខេត្តកំពង់ធំ។
- បានចូលរួមកិច្ចប្រជុំស្តីពី "ការគ្រប់គ្រងរមណីយដ្ឋាន និងសហគមន៍ទេសចរណ៍" តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយដោយប្រើប្រាស់កម្មវិធី Zoom Meeting នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១។

- បានចូលរួមពិគ្រោះយោបល់ស្តីពី"គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃស្តង់ដាសហគមន៍ទេសចរណ៍និងផ្ទះស្នាក់សហគមន៍ទេសចរណ៍"តាមរយៈប្រព័ន្ធវីដេអូ ដោយប្រើប្រាស់កម្មវិធី Zoom Meeting នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១។
- បានចូលរួមកិច្ចប្រជុំក្រុមបច្ចេកទេស "គម្រោងអភិរក្សធនធានជលផល និងបង្កើនជីវភាពផាត់សណ្តាយ" នាថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ នៅសាលាខេត្តកំពង់ធំ។
- បានប្រជុំពិភាក្សាជាមួយក្រុមនិស្សិតសាកលវិទ្យាល័យន័រតុន ដើម្បីចែករំលែកអំពីការងារ និងផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តកំពង់ធំ នាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ នៅមន្ទីរទេសចរណ៍ខេត្តកំពង់ធំ។
- បានចុះធ្វើបច្ចុប្បន្នភាពទិន្នន័យរមណីយដ្ឋាន តំបន់សក្តានុពលទេសចរណ៍ សិប្បកម្ម និងសហគមន៍នានា នៅក្នុងស្រុកសន្ទុក ស្រុកបារាយណ៍ ស្រុកតាំងគោក ស្រុកកំពង់ស្វាយ និងស្រុកស្ទោង ចាប់ពីថ្ងៃទី០៨-០៩ ខែកុម្ភៈ ឆ្នាំ២០២១។
- បានចូលរួមសិក្ខាសាលាសមារណកម្ម កម្មវិធីវិនិយោគថ្នាក់ស្រុក ឃុំ នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅរដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ។
- បានចូលរួមសិក្ខាសាលាសមារណកម្ម កម្មវិធីវិនិយោគថ្នាក់ស្រុក ឃុំ នាថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ នៅរដ្ឋបាលស្រុកបារាយណ៍ និងរដ្ឋបាលស្រុកតាំងគោក ខេត្តកំពង់ធំ។
- បានចូលរួមវេទិកាជាតិអេកូទេសចរណ៍លើកទី២ នាថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០២១ នៅខេត្តសៀមរាប។
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការកំណត់បែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងតំបន់រ៉ាមសារបឹងទន្លេឆ្មារនាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ នៅមន្ទីរបរិស្ថានខេត្តកំពង់ធំ។
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការកំណត់បែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងតំបន់រ៉ាមសារស្ទឹងសែននាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១នៅមន្ទីរបរិស្ថានខេត្តកំពង់ធំ។
- បានរៀបចំកិច្ចប្រជុំជាមួយក្រុមការងារអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) អំពីវឌ្ឍនភាពការងារសហគមន៍ និងការបង្កើនកិច្ចសហការក្នុងការជំរុញអោយដំណើរវិស័យអេកូទេសចរណ៍ធម្មជាតិ សហគមន៍គោលដៅប្រកបដោយនិរន្តភាព នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ នៅមន្ទីរទេសចរណ៍ខេត្តកំពង់ធំ។
- បានចុះពង្រឹងសមត្ថភាព និងការបញ្ជ្រាបចំណេះដឹងបន្ថែមលើការរៀបចំផ្ទះស្នាក់សហគមន៍នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ នៅសហគមន៍វស្សីភូមិពីរគីរីបឹងក្រញ៉ាកស្ថិតក្នុងស្រុកសណ្តាន់ខេត្តកំពង់ធំ។
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំទំព័រហ្វេសប៊ុក ការរៀបចំមាតិកា និងជំនាញក្នុងការថតរូប វីដេអូ ដែលរៀបចំដោយគម្រោង USAID ព្រៃឡង់បៃតង ចាប់ពីថ្ងៃទី១៩-២១ ខែមករា ឆ្នាំ២០២១ នៅខេត្តកំពង់ធំ។
- បានចូលរួមកិច្ចប្រជុំ ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (២០២១-២០២៣) នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ នៅសាលាខេត្តកំពង់ធំ។
- បានរៀបចំកិច្ចប្រជុំជាមួយក្រុមការងារនាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ អំពីវឌ្ឍនភាពនៃការរៀបចំឯកសារផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តកំពង់ធំនាថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ នៅមន្ទីរទេសចរណ៍ខេត្តកំពង់ធំ។

**៦.ការគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍**

- បានប្រចាំការផ្តល់ព័ត៌មានជូនភ្ញៀវទេសចរ នៅការិយាល័យព័ត៌មានទេសចរណ៍ប្រាសាទសំបូរព្រៃគុក។
- បានប្រមូលស្ថិតិភ្ញៀវទេសចរនៅតាមរមណីយដ្ឋានទេសចរណ៍ សណ្ឋាគារ និងសេវាកម្មស្នាក់នៅក្នុងខេត្តកំពង់ធំ សម្រាប់រៀបចំរបាយការណ៍ស្ថិតិភ្ញៀវទេសចរក្នុងឆ្នាំ២០២១។
- បានចុះណែនាំ ស្តីពីការរៀបចំគ្រប់គ្រងភ្ញៀវទេសចរ និងការពង្រឹងផលិតផលទេសចរក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ជូនប្រតិបត្តិករទេសចរណ៍ តាមមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅ ភោជនីយដ្ឋាន អាហារដ្ឋាន និងរមណីយដ្ឋាននៅក្នុងខេត្តកំពង់ធំ។
- បានសម្របសម្រួលជូនក្រុមការងារបណ្តាញផ្សព្វផ្សាយសង្គមក្រសួងទេសចរណ៍ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងការងារគ្រប់គ្រងបណ្តាញសង្គមក្នុងវិស័យទេសចរណ៍នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសាលប្រជុំមន្ទីរទេសចរណ៍ខេត្តកំពង់ធំ។
- បានផ្សព្វផ្សាយសារាចរណែនាំ ស្តីពីការរៀបចំគ្រប់គ្រងភ្ញៀវទេសចរនិងការពង្រឹងផលិតផលទេសចរក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិ ជូនប្រតិបត្តិករទេសចរណ៍ តាមមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅ ភោជនីយដ្ឋាន អាហារដ្ឋាន និងរមណីយដ្ឋាននៅក្នុងខេត្តកំពង់ធំ។
- បានចុះផ្សព្វផ្សាយ និងពង្រឹងការរៀបចំមូលដ្ឋានអាជីវកម្មស្របតាមសារាចរណែនាំលេខ ០០៣ សរណន ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ស្តីពីការរៀបចំគ្រប់គ្រងចរន្តភ្ញៀវទេសចរតាមមូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងគោលដៅទេសចរណ៍ទូទាំងប្រទេស នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅតាមបណ្តារមណីយដ្ឋានទេសចរណ៍ និងមូលដ្ឋានអាជីវកម្មទេសចរណ៍ក្នុងខេត្តកំពង់ធំ។
- បានផ្សព្វផ្សាយណែនាំ និងត្រួតពិនិត្យលើការងាររៀបចំពង្រឹងគុណភាពផលិតផលទេសចរណ៍ក្នុងឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីចិន-វៀតណាម ចាប់ពីថ្ងៃទី១២-១៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅតាមបណ្តា រមណីយដ្ឋានទេសចរណ៍ និងមូលដ្ឋានអាជីវកម្មទេសចរណ៍។
- បានរៀបចំ និងជួសជុលស្លាកសញ្ញាបង្ហាញពីសក្តានុពលទេសចរណ៍ខេត្តកំពង់ធំ បានចំនួន ០៥ទីតាំង។
- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពមន្ត្រីជំនាញប្រមូលទិន្នន័យស្ថិតិទេសចរណ៍ក្នុងបរិការណ៍ជំងឺកូវីដ១៩ ចាប់ពីថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០២១ នៅខេត្តកំពង់ចាម។
- បានសម្របសម្រួលជូនក្រុមការងារទូរទស្សន៍អាស៊ីអាគ្នេយ៍ ចុះថតទិដ្ឋភាពរមណីយដ្ឋានស្ទឹងជីនិត និងទិដ្ឋភាពទំនប់បង្អៀរ ៦មករា ដើម្បីផលិតកម្មវិធីកម្សាន្តទេសចរណ៍។

**៧.ទិសដៅការងារសម្រាប់អនុវត្តបន្ត**

- អញ្ជើញម្ចាស់អាជីវកម្មទេសចរណ៍ឱ្យមកដាក់ពាក្យស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍ពីអង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំនិងក្រសួងទេសចរណ៍។
- ចុះត្រួតពិនិត្យទីតាំងស្នើសុំប្រកបអាជីវកម្មតាមប្រភេទសេវាកម្មទេសចរណ៍ និងរៀបចំឯកសារពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍បញ្ជូនទៅក្រសួងទេសចរណ៍ ដើម្បីស្នើសុំការសម្រេចជូនប្រតិបត្តិករទេសចរណ៍។

- ចុះត្រួតពិនិត្យទីតាំងស្នើសុំប្រកបអាជីវកម្មតាមប្រភេទសេវាកម្មទេសចរណ៍ និងរៀបចំឯកសារផ្តល់អាជ្ញាបណ្ណទេសចរណ៍បញ្ជូនទៅអង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំ ដើម្បីស្នើសុំការសម្រេចជូនប្រតិបត្តិករទេសចរណ៍។
- បន្តការចុះផ្សព្វផ្សាយ ត្រួតពិនិត្យ និងវាយតម្លៃផ្តល់ឡាបិល ស្តីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ជូនអាជីវកម្មទេសចរណ៍។
- ផ្សព្វផ្សាយនិងណែនាំដល់មូលដ្ឋានអាជីវកម្មដែលងាយរងគ្រោះដោយសារគ្រឿងញៀន ការជួញដូរស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍ ឱ្យចូលរួមសហការជាមួយសមត្ថកិច្ចដើម្បីបង្ការនិងទប់ស្កាត់បានទាន់ពេលវេលា។
- បន្តការតាមដានការបិទអាជីវកម្មទេសចរណ៍ជាបណ្តោះអាសន្ន ដែលរងផលប៉ះពាល់នៃការរាតត្បាតដោយជំងឺកូវីដ-១៩ នៅក្នុងកំពង់ធំ។
- ចុះពង្រឹងលើការងារផ្តល់អាជ្ញាបណ្ណទេសចរណ៍ របស់មន្ត្រីជួរក្រោយទទួលបន្ទុកនៅតាមការិយាល័យច្រកចេញចូលតែមួយស្រុក ក្នុងខេត្តកំពង់ធំ។
- ចុះអប់រំណែនាំ និងបណ្តុះបណ្តាលផ្ទាល់ដល់ទីតាំងសេវាកម្មទេសចរណ៍ផ្នែកបដិសណ្ឋារកិច្ចសុវត្ថិភាពចំណីអាហារ និងការបញ្ជ្រាបយេនឌ័រក្នុងវិស័យទេសចរណ៍ និងការចុះឈ្មោះសិក្ខាកាមនូវជំនាញវិជ្ជាជីវៈទេសចរណ៍តាមរយៈប្រព័ន្ធអនឡាញ។
- បន្តរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍទេសចរណ៍របស់ខេត្តកំពង់ធំ ឆ្នាំ២០២១-២០២៥ និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធស្របតាមគោលការណ៍ណែនាំរបស់ក្រសួងទេសចរណ៍។
- បន្តកិច្ចសហការជាមួយអង្គការដៃគូ ដើម្បីរៀបចំផែនការសកម្មភាពការងារសម្រាប់គាំទ្រដល់សហគមន៍ទេសចរណ៍ក្នុងខេត្តកំពង់ធំ។
- បន្តការគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ និងផ្តល់ព័ត៌មានជូនភ្ញៀវទេសចរជាប្រចាំថ្ងៃនៅការិយាល័យព័ត៌មានទេសចរណ៍ប្រាសាទសំបូរព្រៃគុក។
- ប្រមូល និងចងក្រងទិន្នន័យស្ថិតិភ្ញៀវជាតិ បរទេស នៅតាមរមណីយដ្ឋានទេសចរណ៍ សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ប្រចាំខែ។
- ចុះផ្សព្វផ្សាយសារចរណែនាំ ស្តីពីការរៀបចំគ្រប់គ្រងភ្ញៀវទេសចរនិងការពង្រឹងផលិតផលទេសចរក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ នៅតាមបណ្តារមណីយដ្ឋានទេសចរណ៍ និងមូលដ្ឋានអាជីវកម្មទេសចរណ៍ក្នុងខេត្តកំពង់ធំ។
- បន្តការផ្សព្វផ្សាយ “កម្ពុជាៈព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ” និងចលនា “ប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ”។
- បន្តការផ្សព្វផ្សាយ “កម្ពុជាៈព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ” និងចលនា “ប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ”។
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារទេសចរណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ២០២២។
- ត្រួតពិនិត្យវត្តមានរបស់មន្ត្រីរាជការមន្ត្រីជាប់កិច្ចសន្យា និងរៀបចំរបាយការណ៍វត្តមានប្រចាំសប្តាហ៍ ប្រចាំខែជូនក្រសួងទេសចរណ៍។
- រៀបចំឯកសារបើកប្រាក់បៀវត្សជូនមន្ត្រីរាជការប្រចាំខែ និងបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលាកំណត់ ស្របតាមលិខិតបទដ្ឋានគតិយុត្ត។

- រៀបចំរបាយការណ៍ចំណូលចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ២០២២ ជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ធំ។
- រៀបចំឯកសារដំណើរការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់មន្ទីរ និងរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ២០២២។

**៨.បញ្ហាប្រឈម និងសំណូមពរ**

ក. បញ្ហាប្រឈម

- អំឡុងពេលចុះផ្សព្វផ្សាយត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ឃើញថានៅមានអាជីវកម្មទេសចរណ៍តូចៗជាលក្ខណៈគ្រួសារ មានការលំបាកក្នុងការជំរុញឱ្យពួកគាត់អនុវត្តន៍តាមលក្ខខណ្ឌតម្រូវឱ្យអនុវត្ត។
- បច្ចុប្បន្ននេះចំនួនមន្ត្រីរាជការបំពេញការងារនៅក្នុងរចនាសម្ព័ន្ធមន្ទីរ មានចំនួនតិចនៅឡើយ ដែលពុំស្របតាមទំហំការងារប្រចាំថ្ងៃ និងរចនាសម្ព័ន្ធរបស់មន្ទីរ។

ខ. សំណូមពរ

- ស្នើសុំមន្ត្រីក្របខណ្ឌថ្មីបន្ថែម ដើម្បីបំពេញការងារប្រចាំថ្ងៃស្របតាមទំហំការងារ និងរចនាសម្ព័ន្ធមន្ទីរ ដោយពេលបច្ចុប្បន្ននេះមន្ទីរមានចំនួន០៦ការិយាល័យ និងមានមន្ត្រីរាជការសរុបមានចំនួន១៣រូប ដឹកនាំដោយប្រធានមន្ទីរចំនួន០១រូប អនុប្រធានមន្ទីរចំនួន០១រូប ប្រធានការិយាល័យចំនួន០៤រូប អនុប្រធានការិយាល័យចំនួន០៦រូប (ស្រី០៤រូប) និងមន្ត្រីចំនួន០១រូប។

សេចក្តីដូចបានគោរពជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបអំពីសកម្មភាពការងារ និងទិសដៅអនុវត្តបន្តរបស់មន្ទីរ និងសូមមេត្តាផ្តល់នូវអនុសាសន៍ណែនាំបន្ថែមទៀតដើម្បីឱ្យមន្ទីរអាចអនុវត្តនូវសកម្មភាពការងារឱ្យមានប្រសិទ្ធភាពនិងទទួលបានលទ្ធផលល្អប្រសើរ។

សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងទេសចរណ៍** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃចន្ទ ៨រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
កំពង់ធំ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

**ប្រធានមន្ទីរ**

**សេង អាន**

លេខ.............................

បានឃើញ

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
កំពង់ធំ ថ្ងៃទី ខែ ឆ្នាំ២០២១

**អភិបាល**

## ឧបសម្ព័ន្ធទី ៤



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លក្ខន្តិកៈ

គណៈកម្មការប្រតិបត្តិ

សហគមន៍អភិរក្ស និងអភិវឌ្ឍន៍

ប្រាសាទសំបូរព្រៃគុក

ខេត្តកំពង់ធំ

ខែធ្នូ ឆ្នាំ២០០៤

## លក្ខន្តិកៈ
## របស់គណៈកម្មការប្រត្តិបត្តិសហគមន៍ អភិរក្ស និងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុក

មាតិកា

ទំព័រ


១. គោលបំណងនៃការបង្កើតគណៈកម្មការប្រត្តិបត្តិសហគមន៍ ........................ ២
២. ផលប្រយោជន៍នៃការអភិរក្ស និងអភិវឌ្ឍន៍ទេសចរណ៍ដែលគ្រប់គ្រងដោយសហគមន៍ ........................ ២
៣. ការបោះឆ្នោតជ្រើសរើសគណៈកម្មការប្រត្តិបត្តិ ........................ ២
៤. តួនាទីគណៈកម្មការប្រត្តិបត្តិ ........................ ៣
៥. របនាសម្ព័ន្ធគណៈកម្មការប្រត្តិបត្តិ ........................ ៣
៦. អាណត្តិរបស់គណៈកម្មការប្រត្តិបត្តិ ........................ ៤
៧. ការប្រជុំរបស់គណៈកម្មការប្រត្តិបត្តិ ........................ ៥
៨. ការដកហូតពីសមាជិកគណៈកម្មការប្រត្តិបត្តិ ........................ ៩
៩. អំពីរបាយការណ៍ ........................ ៩
១០. ការដោះស្រាយជម្លោះ ........................ ១០
១១. ការកែប្រែអាណត្តិ ........................ ១០

# លក្ខន្តិកៈ

## របស់គណៈកម្មការប្រតិបត្តិសហគមន៍ អភិរក្ស និងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុក

**១ គោលបំណងនៃការបង្កើតគណៈកម្មការប្រតិបត្តិ**

ក- ដើម្បីធ្វើផែនការគ្រប់គ្រង និងរៀបចំវិស័យទេសចរណ៍វប្បធម៌ធម្មជាតិប្រាសាទសំបូរព្រៃគុក ដែលមានទីតាំងក្នុងស្រុកប្រាសាទ សំបូរ ខេត្តកំពង់ធំ។

ខ- ដើម្បីទំនាក់ទំនងជាមួយអង្គការ ក្រៅរដ្ឋាភិបាល រដ្ឋាភិបាល និងភ្នាក់ងារដទៃទៀតដែលពាក់ព័ន្ធទៅនឹងទេសចរណ៍វប្បធម៌ ធម្មជាតិ ក្នុងគោលបំណងសម្របសម្រួលក្នុងការអនុវត្តគម្រោងទេសចរណ៍វប្បធម៌ធម្មជាតិ។

គ- ដើម្បីឱ្យប្រជាជននៅក្នុងតំបន់មានកម្រិតជីវភាពកាន់តែប្រសើរតាមរយៈការអភិវឌ្ឍវិស័យទេសចរណ៍នេះ។

**២ ផលប្រយោជន៍នៃទេសចរណ៍វប្បធម៌ធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍**

ក- ផ្តល់ផលប្រយោជន៍ផ្ទាល់ដល់អ្នកភូមិដែលរស់នៅជុំវិញ។

ខ- ផ្តល់ផលប្រយោជន៍ជាប្រយោជន៍ដល់អ្នកទេសចរណ៍ និងប្រជាជនដែលមកធ្វើទស្សនកិច្ច ដោយឱ្យគេបានយល់ដឹងពីតម្លៃសម្បត្តិបេតិកភណ្ឌវប្បធម៌ និងធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍។

**៣ ការបោះឆ្នោតជ្រើសរើសគណៈកម្មការប្រតិបត្តិ**

**៣.១- ការបោះឆ្នោតជ្រើសរើសតំណាងថ្នាក់ (ភូមិទាំងប្រាំពីរ)**

ក- ជំហានដំបូងជ្រើសរើស តែងតាំងមនុស្ស២រូបពីភូមិនីមួយៗ (ប្រុស និងស្រី)។

ខ- ប្រសិនបើការតែងតាំងនេះអាចទទួលយកបាន អ្នកភូមិទាំងអស់នឹងបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនតាមភូមិ។

**៣.២- ការបោះឆ្នោតជ្រើសរើសតំណាងស្ត្រី**

ក- ជំហានដំបូងភូមិនីមួយៗ តែងតាំង និងបោះឆ្នោតតំណាងស្ត្រីម្នាក់។

ខ- ក្រៅពីអ្នកតំណាងប្រាំពីរនាក់ អនុគណៈកម្មការជ្រើសរើសតំណាងបីនាក់ទៀត។

**៣.៣- សិទ្ធិនៃការបោះឆ្នោត**

ដើម្បីជ្រើសរើសសមាជិកគណៈកម្មការប្រតិបត្តិភូមិម្នាក់ៗត្រូវមានលក្ខណៈដូចខាងក្រោម :

- អ្នកភូមិដែលបានចុះឈ្មោះនៅក្រុមប្រឹក្សា ឃុំ សង្កាត់។
- មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។

- ការបោះឆ្នោតត្រូវតែធ្វើឡើងដោយការបោះឆ្នោតជាសម្ងាត់។

### ៣.៤- សិទ្ធិនៃការឈរឈ្មោះ

- បេក្ខជនត្រូវមានកាយសម្បទាល្អ។
- មានអាយុចាប់ពី២៥ឆ្នាំឡើងទៅ។
- មានសីលធម៌។
- មានកម្រិតវប្បធម៌ អាចសរសេរ និងអានបាន។
- មានការទទួលខុសត្រូវចំពោះការងារ។

## ៤ តួនាទីរបស់គណៈកម្មការប្រតិបត្តិ

តួនាទីរបស់គណៈកម្មការប្រតិបត្តិមានដូចខាងក្រោម :

- អភិវឌ្ឍវិស័យទេសចរណ៍វប្បធម៌ និងធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍។ ពន្យល់អ្នកភូមិអំពីទស្សនៈនៃការបង្កើតទេសចរណ៍វប្បធម៌ និងធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍ជំរុញលើកទឹកចិត្តដល់ការចូលរួមរបស់អ្នកភូមិនៅក្នុងតំបន់។

- ផ្តល់ពត៌មានអំពីអ្វីដែលគណៈកម្មការប្រតិបត្តិបានប្រជុំពិភាក្សា និងពាំនាំការផ្តល់យោបល់អ្នកភូមិទៅដល់គណៈកម្មការវិញ។

- អភិរក្សសម្បត្តិវប្បធម៌បេតិកភណ្ឌជាតិ និងធម្មជាតិសម្រាប់ប្រជាជនខ្មែរជំនាន់នេះ និងជំនាន់ក្រោយដោយសារសម្បត្តិដែលដូនតាបន្សល់ទុកមកទាំងនេះផ្តល់ប្រយោជន៍ដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ធ្វើឱ្យជីវភាពប្រជាជនដែលរស់នៅ ជុំវិញតំបន់នេះកាន់តែប្រសើរឡើង។

- រៀបចំគ្រប់គ្រង និងអនុវត្តទេសចរណ៍វប្បធម៌ធម្មជាតិ និងការអភិរក្សប្រាសាទដែលគ្រប់គ្រង ដោយសហគម៌ន៍។

- ចរចានឹងអ្នកដែលពាក់ព័ន្ធសំខាន់ៗសម្រាប់ទេសចរណ៍វប្បធម៌ធម្មជាតិ និងការអភិរក្សប្រាសាទដែលគ្រប់គ្រងដោយសហគមន៍ដូចជា : រដ្ឋអំណាច ម្ចាស់ជីកម្មសិទ្ធិ និងអង្គការក្រៅរដ្ឋាភិបាលជាដើម។

## ៥ រចនាសម្ព័ន្ធគណៈកម្មការប្រតិបត្តិ

### ៥.១- រចនាសម្ព័ន្ធ

គណៈកម្មការប្រតិបត្តិមានសមាជិកចំនួន១០រូប ដែលក្នុងនោះមានស្ត្រីពីររូបយ៉ាងតិច មកពីភូមិដូចខាងក្រោម:

- អ្នកតំណាង ភូមិពោធិទ្រេត១រូប ភូមិកំពង់ឈើទាល២រូប ភូមិសិរីខ្ទួ១រូប ភូមិសំបូរ២រូប ភូមិអូរគ្រួកែ២រូប ភូមិជាយសំពៅ១រូប និងភូមិអាត់ស្វ៊១រូប។

៥.២- លើសពីនេះគណៈកម្មការប្រតិបត្តិមានទីប្រឹក្សាមកពីៈ

- សមាជិកក្រុមប្រឹក្សាស្រុក២រូប
- សមាជិកក្រុមប្រឹក្សាឃុំ៣រូប
- អភិរក្សចំនួន១រូប
- ទេសចរណ៍ចំនួន១រូប។

**៥.២.១- តួនាទីរបស់ទីប្រឹក្សា ឃុំ ស្រុក**

- ជួយសម្របសម្រួល និងដោះស្រាយទំនាស់។
- ផ្តល់ជាយោបល់ដល់គណៈកម្មការប្រតិបត្តិ ដើម្បីអភិវឌ្ឍគម្រោង។
- ចូលរួមរៀងរាល់ការប្រជុំរបស់គណៈកម្មការប្រតិបត្តិ។
- ផ្តល់ព័ត៌មានអំពីលទ្ធផលប្រជុំទៅឱ្យក្រុមប្រឹក្សា ឃុំ ស្រុក ជារៀងរាល់ខែ។
- រាយការណ៍អំពីសកម្មភាពផ្សេងៗទៅឱ្យវិទ្យាស្ថាន និង NGO នានា។

**៥.២.២- តួនាទីរបស់តំណាងមកពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ**

- ជួយសម្របសម្រួលផ្នែកអភិរក្សជាខ្វះទៅក្នុងតំបន់ប្រាសាទ។ ចូលរួមចំណែកការងារជួសជុល និងអភិរក្ស និងធ្វើកំណាយត្រូវសហការណ៍ជាមួយអ្នកជំនាញមកពីវិទ្យាស្ថាន និងមន្ទីរជំនាញពាក់ព័ន្ធ ទាំងក្នុង និងក្រៅស្រុក។
- ដាក់ផែនការណ៍ដល់ផ្នែកអភិរក្ស និងសំអាតព្រៃរបោះ និងកែលម្អផ្លូវ។
- ចូលរួមជាយោបល់ដល់គណៈកម្មការប្រតិបត្តិ ដើម្បីអភិរក្សគម្រោង។
- ចូលរួមរាល់ការប្រជុំរបស់គណៈកម្មការប្រតិបត្តិ។
- អប់រំ និងណែនាំ ផ្សព្វផ្សាយពីវប្បធម៌ ប្រវត្តិសាស្ត្រ ប្រពៃណី ដល់សហគមន៍ និងប្រជាជនទាំងអស់។
- រាយការណ៍រាល់សកម្មភាពពាក់ព័ន្ធនឹងការអភិរក្ស និងអភិវឌ្ឍន៍នៅក្នុងតំបន់ ដល់ខេត្តកំពង់ធំ និងមន្ទីរជំនាញពាក់ព័ន្ធ។

**៥.២.៣- តួនាទីរបស់តំណាងមកពីមន្ទីរទេសចរណ៍**

- ជួយសម្របសម្រួលផ្នែកទេសចរណ៍។
- ផ្តល់ជាយោបល់ដល់គណៈកម្មការប្រតិបត្តិ ដើម្បីអភិវឌ្ឍទេសចរណ៍ដល់គណៈកម្មការប្រតិបត្តិ។
- ចូលរួមរាល់ការប្រជុំរបស់គណៈកម្មការប្រតិបត្តិ។
- រាយការណ៍រាល់សកម្មភាពពាក់ព័ន្ធដល់ខេត្តកំពង់ធំ និងមន្ទីរទេសចរណ៍។

៥.៣- វិទ្យាស្ថាន និងអង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ មានតួនាទីដើម្បីសម្របសម្រួល និងផ្តល់ជំនួយនានាទៅ

លើការធ្វើគម្រោងការបង្កើត និងការគ្រប់គ្រងទេសចរណ៍វប្បធម៌ធម្មជាតិនៅតំបន់សំបូរព្រៃគុក។




**៥.៨- តួនាទី និងការទទួលខុសត្រូវរបស់សមាជិកអនុគណៈកម្មការ**

**៥.៨.១- តួនាទីរបស់ប្រធានគណៈកម្មការប្រតិបត្តិ**

- សម្របសម្រួលគ្រប់សកម្មភាពទាក់ទងនឹងគម្រោងទេសចរណ៍វប្បធម៌ធម្មជាតិ និងការអភិរក្សប្រាសាទដែលគ្រប់គ្រងដោយសហគមន៍។
- ដោះស្រាយនូវរាល់បញ្ហាដែលជួបប្រទះ។
- អប់រំ និងផ្តល់ការណែនាំសមាជិកគណៈកម្មការប្រតិបត្តិ។
- ត្រួតពិនិត្យនូវរាល់ប្រាក់ចំណូល និងចំណាយ។
- ធ្វើផែនការ និងអនុវត្តនូវរាល់សកម្មភាពរបស់គម្រោងអភិរក្សប្រាសាទ និងធម្មជាតិ។
- ថែរក្សា និងគ្រប់គ្រងរាល់ឯកសាររបស់គម្រោងទេសចរណ៍វប្បធម៌ធម្មជាតិ។
- ធ្វើការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងគម្រោង។
- តាមដាន និងវាយតម្លៃ។
- ពេលដែលអវត្តមាន ត្រូវផ្ទេរការងារទៅឱ្យអនុប្រធាន ឬសមាជិកខ្លួន។
- ធ្វើរបាយការណ៍ពីសកម្មភាពការងារជូនស្ថាប័នពាក់ព័ន្ធរៀងរាល់ខែ។

**៥.៨.២- តួនាទីរបស់អនុប្រធានគណៈកម្មការប្រតិបត្តិ**

- ជំនួសការឱ្យប្រធាន និងជំនួយការប្រធាន ក្នុងពេលប្រធានអវត្តមាន។
- អនុវត្តផ្ទាល់នូវរាល់ការងារដែលប្រធានដាក់ជូន។
- ទំនាក់ទំនងល្អជាមួយប្រធាន និងសមាជិក។

- អប់រំនិងផ្តល់ការណែនាំដល់សមាជិកគណៈកម្មការប្រតិបត្តិ។
- រាយការណ៍នូវសកម្មភាពការងារទៅឱ្យប្រធានគណៈកម្មការប្រតិបត្តិ។
- ផ្តល់នូវពត៌មានស្តីពីសកម្មភាពទេសចរណ៍វប្បធម៌ និងធម្មជាតិ និងការងារអភិរក្សទៅឱ្យប្រជាជន។

**៥.៤.៣- តួនាទីរបស់គណនេយ្យ**

- គ្រប់គ្រងគម្រោងថវិកា។
- ធ្វើបញ្ជីចំណូល និងចំណាយ។
- ថែរក្សានូវរាល់ឯកសារដែលទាក់ទងនឹងការចំណូលនិងចំណាយ។
- ធ្វើរបាយការណ៍ជារៀងរាល់ខែទៅឱ្យប្រធានគណៈកម្មការប្រតិបត្តិ។
- មានទំនាក់ទំនងល្អជាមួយសមាជិក។
- ត្រូវដឹងពីចំនួនភ្ញៀវទេសចរណ៍ដែលមកទស្សនា។

**៥.៤.៤- តួនាទីរបស់អ្នកគ្រប់គ្រងចំណត**

- ទទួលខុសត្រូវលើសំបុត្រយានយន្ត និងបញ្ជីគណនេយ្យ។
- ធ្វើរបាយការណ៍នៃប្រាក់ចំណូលទៅឱ្យគណនេយ្យ។
- កត់ត្រាទុកនូវចំនួនយានយន្ត។
- រៀបចំកន្លែងចំណតកង់ រទេះគោ និងយានយន្តគ្រប់ប្រភេទប្រកបដោយសុវត្ថិភាព និងមានសណ្តាប់ធ្នាប់។
- ធ្វើរបាយការណ៍អំពីសកម្មភាពការងារទៅឱ្យប្រធានគណៈកម្មការប្រតិបត្តិ។

**៥.៤.៥- តួនាទីអ្នកគ្រប់គ្រងសេវាកម្ម កង់ រទេះគោ (ផ្នែកដឹកជញ្ជូន)**

- រៀបចំកង់ រទេះគោសម្រាប់ភ្ញៀវ។
- គ្រប់គ្រងរទេះ និងត្រួតពិនិត្យលើសុវត្ថិភាព។
- ស្មោះត្រង់ និងច្បាស់លាស់នៅក្នុងការគ្រប់គ្រង និងបែងចែកថវិកា។
- ធ្វើរបាយការណ៍ទៅឱ្យប្រធានរៀងរាល់ខែ។

**៥.៤.៦- តួនាទីអ្នកគ្រប់គ្រងសេវាកម្មនាំភ្ញៀវ (មគ្គុទ្ទេសក៍)**

- រៀបចំអ្នកនាំភ្ញៀវសម្រាប់ភ្ញៀវទេសចរ។
- ចាត់ចែងនូវសមាជិករបស់ខ្លួនសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ។
- មានទំនាក់ទំនងល្អជាមួយសមាជិកគណៈកម្មការប្រតិបត្តិ ក៏ដូចជាសមាជិកទូទៅ។
- កត់ត្រានូវគំនិតល្អៗរបស់អ្នកទេសចរ ដើម្បីអភិវឌ្ឍគម្រោង។

- សរសេររបាយការណ៍ទៅឱ្យប្រធានគណៈកម្មការប្រតិបត្តិជារៀងរាល់ខែ។

- ការជ្រើសរើសមគ្គុទ្ទេសក៍ត្រូវជាសិស្សដែលបានជាប់ឌីប្លូម ឬបាក់ឌុប ចេះភាសាបរទេស និងជាកូនចៅអ្នកភូមិក្នុងសហគមន៍។

- ចូលរួមក្នុងការបណ្តុះបណ្តាលអ្នកនាំភ្ញៀវ។

- អប់រំពីប្រវត្តិសាស្ត្ររបស់ប្រាសាទ បរិស្ថាន និងសម្របសម្រួលដល់ទេសចរណ៍ដែលមកទស្សនកិច្ច។

- កត់ត្រាទុកចំនួនអ្នកដែលបាននាំភ្ញៀវ។

**៥.៨.៧- តួនាទីអ្នកគ្រប់គ្រងផ្នែកឆ្មាំ និងអនាម័យ**

- រៀបចំឈ្មោះអ្នកចុះប្រចាំការ កំណត់ពេលវេលា និងវេនសម្រាប់ប្រចាំការ។

- ធ្វើរបាយការណ៍រាល់សកម្មភាពការងារទៅឱ្យគណៈកម្មការប្រតិបត្តិជារៀងរាល់ខែ។

- ត្រូវមានទំនាក់ទំនងល្អជាមួយអភិរក្ស និងជួសជុលប្រាសាទ។

- ពន្យល់ពីភារកិច្ចរបស់ឆ្មាំនៅពេលបំពេញការងារចំពោះភ្ញៀវទេសចរ :

  - ត្រូវហាមយានជំនិះគ្រប់ប្រភេទចូលក្នុងបរិវេណប្រាសាទ។
  - ហាមចោលសំរាម។
  - ហាមបរិភោគក្នុងបរិវេណប្រាសាទ។
  - ហាមសរសេរលើប្រាសាទ។
  - ហាមឡើងលើប្រាសាទ។

- ឆ្មាំទាំងអស់ត្រូវមានភារកិច្ចសំអាតទាំងក្នុង និងក្រៅបរិវេណប្រាសាទ។

- ក្នុងពេលប្រចាំការ ប្រសិនជួបនឹងបញ្ហាបទល្មើសណាមួយ ត្រូវរាយការណ៍ជាបន្ទាន់ដល់ប្រធានគណៈកម្មការប្រតិបត្តិ។

- ត្រូវប្រកាន់ខ្ជាប់នូវឆន្ទៈជាអ្នកថែរក្សាសម្បត្តិវប្បធម៌ប្រាសាទ និងធម្មជាតិដែលមានជុំវិញ។

- ត្រូវពន្យល់ដល់ប្រជាជនឱ្យដឹងនូវបទបញ្ជាផ្ទៃក្នុងរបស់ទេសចរណ៍ធម្មជាតិ វប្បធម៌ និងការអភិរក្សប្រាសាទ។

- ណែនាំភ្ញៀវ និងអ្នកលក់ដូរ អំពីផលប៉ះពាល់នៃសំរាម។

- ការត្រួតពិនិត្យលើបញ្ហាសំរាម គឺត្រូវអនុវត្តនៅក្នុងបរិវេណប្រាសាទ ចំពោះអ្នកនាំភ្ញៀវត្រូវពិនិត្យលើបញ្ហាសំរាមដែរ ដែលមាននៅតាមដងផ្លូវ។

**៥.៨.៨- តួនាទីរបស់អ្នកគ្រប់គ្រងសេវាកម្មលក់ដូរ**

- រៀបចំសេវាកម្មលក់ដូរមានភេសជ្ជៈ និងវត្ថុអនុស្សាវរីយ៍។

- គ្រប់គ្រង និងថែរក្សាតូបសម្រាប់លក់ដូរ។
- ធ្វើបញ្ជីសារពើភណ្ឌនូវសម្ភារៈដែលទទួល និងសម្ភារៈដែលបានលក់ហើយ។
- គ្រប់គ្រង និងថែរក្សាឯកសារបញ្ជីសម្ភារៈ។
- ត្រួតពិនិត្យនូវរាល់សកម្មភាពលក់ដូរ និងធ្វើការបែងចែកវេន។
- សរសេររបាយការណ៍ជូនទៅប្រធានគណៈកម្មការប្រតិបត្តិជារៀងរាល់ខែ។
- អប់រំ និងណែនាំដល់ភ្ញៀវ និងអ្នកលក់ដូរពីបញ្ហាសំរាម។
- រាល់តូបលក់ឥវ៉ាន់ អាហារដែលនៅក្រៅកម្មវិធីរបស់សហគមន៍ចាំបាច់ត្រូវបដិភាគទានដល់សហគមន៍ចំនួន ១០០រៀលក្នុងមួយថ្ងៃ។

**៥.៤.៥- តួនាទីរបស់អ្នកគ្រប់គ្រងផ្នែកអភិរក្សសំអាតព្រៃរបោះ និងកែលម្អផ្លូវ**

- រៀបចំផែនការនៃការអភិរក្សដោយខ្លួនឯងឬដោយយោបល់ពីក្រុមអ្នកជំនាញមកពីវិទ្យាស្ថាន។
- ទទួលផែនការ និងអនុវត្តការងារសំអាតព្រៃរបោះនៅក្នុងបរិវេណប្រាសាទ និងនៅតាមដងផ្លូវ និងការរៀបចំកែលម្អផ្លូវ។
- ធ្វើរបាយការណ៍ពីសមាជិកចូលរួមក្នុងសកម្មភាពក្នុង១លើក១និងរាយការណ៍ដល់ប្រធានគណៈកម្មការប្រតិបត្តិជារៀងរាល់ខែ។
- រាយការណ៍ពីទីតាំងប្រាសាទថ្មីៗដែលពុំទាន់ចុះបញ្ជីសារពើភណ្ឌ។
- មានភារកិច្ច អភិរក្សប្រាសាទដែលមាននៅបរិវេណចម្ការស្រែ
- សម្របសម្រួល និងធ្វើទំនាក់ទំនងល្អរវាងសមាជិក និងក្រុមអ្នកអភិរក្សជួសជុលប្រាសាទ ដោយត្រូវរៀនសូត្រពីបច្ចេកទេសនៃអ្នកអភិរក្ស។
- ត្រូវរាយការណ៍ពីស្ថានភាពគ្រោះថ្នាក់របស់ប្រាសាទដល់ក្រុមអ្នកជំនាញការអភិរក្ស និងជួសជុលប្រាសាទ។
- ត្រូវពន្យល់ដល់ប្រជាជនឱ្យយល់ពីតម្លៃ និងសារសំខាន់នៃការថែរក្សាប្រាសាទ និងប្រវត្តិសាស្ត្រ។

**៦- អាណត្តិរបស់គណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិមានអាណត្តិរយៈពេល២ឆ្នាំ។ ពេលអនុគណៈកម្មការនេះចប់អាណត្តិ សមាជិកភាពគណៈកម្មការប្រតិបត្តិទាំងអស់ និងធ្វើការជ្រើសរើសឡើងវិញតាមរយៈការបោះឆ្នោត។ សមាជិកដដែលនោះអាចឈរឈ្មោះឱ្យគេបោះឆ្នោតជាគណៈកម្មការប្រតិបត្តិសារជាថ្មីបាន។

**៧- ការប្រជុំរបស់គណៈកម្មការប្រតិបត្តិ**

## ឧបសម្ព័ន្ធទី ៥ ៖ រូបភាពនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក




រូបទី១៖ ច្រកចូលរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក



រូបទី២៖ ស្រះទឹកក្នុងរមណីយដ្ឋាន




រូបទី៣៖ ផ្ទាំងពត៌មាន




រូបទី៤៖ ក្រមប្រតិបត្តិសម្រាប់អ្នកទស្សនា



រូបទី៥៖ បញ្ជរលក់សំបុត្រ




រូបទី៦៖ ផែនទីប្រាសាទសំបូរព្រៃគុក




រូបទី៧៖ គម្រោងជួសជុលក្រុមប្រាសាទតោ




រូបទី៨៖ ក្រុមប្រាសាទតោ



រូបទី៩៖ ប្រាសាទតោ




រូបទី១០៖ ក្រុមប្រាសាទយាយព័ន្ធ



រូបទី១១៖ ប្រាសាទយាយព័ន្ធ